# មហាសន្និបាត

ចែកជូន៖ ទូទៅ
ថ្ងៃទី១០ តុលា ២០១២

ជាភាសាអង់គ្លេស

ក្រុមប្រឹក្សាសិទ្ធិមនុស្ស

សម័យប្រជុំលើកទីម្ភៃមួយ

របៀបវារៈចំណុចទី ១០

ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព

## របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្ស នៅកម្ពុជា លោក សុរិយា ស៊ូប៊ែឌី

ឧបសម្ព័ន្ធ

## ការវិភាគផ្អែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានគោលដៅដទៃទៀត នៅព្រះរាជាណាចក្រកម្ពុជា

*សេចក្តីសង្ខេប*

របាយការណ៍នេះ ត្រូវបានបញ្ជូនស្របតាមសេចក្តីសម្រេចចិត្តលេខ១៨/២៥ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ គឺជាការវាយតំលៃអំពីផលប៉ះពាល់សិទ្ធិមនុស្សដោយសម្បទានដីសេដ្ឋកិច្ច (ELCs) និងសម្បទានដទៃទៀត និងគម្រោងអភិវឌ្ឍន៍ធំៗនៅកម្ពុជា (ជាទូទៅ គឺនិយាយសំដៅលើ "សម្បទានដី" នៅក្នុងរបាយការណ៍នេះទាំងមូល លុះត្រាមានការបញ្ជាក់ដោយឡែក)។ របាយការណ៍នេះ មិនត្រឹមតែជាការវិភាគទៅលើសម្បទានទាក់ទងនឹងវិស័យកសិ-ឧស្សាហកម្ម (មានជាអាទិ៍ ចំការកៅស៊ូ ចំការអំពៅ ចំការម៉ៃសាក់ និង ចំការដំឡូងមី) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការវិភាគទៅលើសម្បទានរ៉ែ ប្រេងកាត និងឧស្ម័ន ព្រៃឈើ និងសម្បទានសម្រាប់គោលដៅទេសចរណ៍ ការអភិវឌ្ឍន៍អចលនទ្រព្យ និងគម្រោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំមួយចំនួន មានដូចជា ទំនប់វារីអគ្គីសនីជាដើម។

អំឡុងបេសកកម្មរបស់ខ្ញុំកាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រី បានប្រកាសពីកិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាល ទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច រួមមានទាំងការគ្រប់គ្រងលើការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការត្រួតពិនិត្យឡើងវិញ លើការអនុវត្តទាក់ទងនឹងកិច្ចសន្យា និងកាតព្វកិច្ច តាមច្បាប់របស់សម្បទានិកនៃសម្បទានដីដែលមានស្រាប់។ ជាបន្តបន្ទាប់ លោកនាយករដ្ឋមន្ត្រី បានប្រកាសអំពីកិច្ចផ្តួចផ្តើមធ្វើប័ណ្ណកម្មសិទ្ធិដី សម្រាប់ប្រជាពលរដ្ឋរស់នៅជិតតំបន់សម្បទាន។ របាយការណ៍នេះ ក៏ពិចារណាផងដែរពីការវិវឌ្ឍន៍ថ្មីៗទាំងអស់នេះ និងស្វះស្វែងដើម្បីបង្កើតឲ្យមានទិដ្ឋភាពវិជ្ជមានមួយចេញពីកិច្ចផ្តួចផ្តើមទាំងនេះ។

របាយការណ៍នេះ ធ្វើការវិភាគរាល់ព័ត៌មានដែលខ្ញុំបានទទួលតាំងពីដើមដំបូងនៃអាណត្តិរបស់ខ្ញុំ ក្នុងឆ្នាំ២០០៩ រហូតមកទល់ចុងខែកក្កដា ឆ្នាំ២០១២ រាប់ទាំងក្របខ័ណ្ឌច្បាប់ជាតិគ្រប់គ្រងលើសិទ្ធិដីធ្លី (ច្បាប់ និងគោលនយោបាយផ្សេងៗពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ) ការវិវឌ្ឍន៍ជាអន្តរជាតិ ទាក់ទងនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជាលើវិស័យដីធ្លី និងផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃផ្សេងទៀតទៅលើការទទួលបានសិទ្ធិមនុស្ស។ ករណីមួយចំនួនដែលបានជ្រើសសម្រាំងនៅក្នុងរបាយការណ៍នេះ ឆ្លុះបញ្ចាំងពីការបង្ហាញទាំងនេះ។ របាយការណ៍នេះ ផ្អែកលើទិន្នន័យ និងព័ត៌មានផ្លូវការរបស់រដ្ឋាភិបាល ញត្តិជាបុគ្គល និងសក្ខីកម្ម ដែលបានដាក់តាមរយៈបុគ្គល សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ របាយការណ៍នេះ ក៏បានមកពីការសិក្សាស្រាវជ្រាវដែល បានធ្វើឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)នៅកម្ពុជា ដែលបាននិងកំពុងបន្តតាមឃ្លាំមើល និងធ្វើការតស៊ូមតិលើបញ្ហានេះ។ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យOHCHR នៅកម្ពុជា ចំពោះការជួយឧបត្ថម្ភគាំទ្រដ៏មានតំលៃក្នុងបញ្ហានេះ។ ទន្ទឹមនឹងគ្រប់សកម្មភាពការងារទាំងអស់របស់ខ្ញុំ មានការសហការពីរដ្ឋាភិបាលក្តី ក៏ជាការគួរកត់សំគាល់ផងដែរថា ឯកសារផ្លូវការដែលត្រូវការចាំបាច់សម្រាប់ធ្វើការវិភាគឲ្យបានពេញលេញទាំងស្រុង មិនមានគ្រប់គ្រាន់ទេ ហើយព័ត៌មានទៀតសោត ក៏នៅមានភាពចន្លោះប្រហោងដែរ។

ចាប់តាំងពីពេលចាប់ផ្តើម គួរកត់សំគាល់ថា កាលៈទេសៈប្រវត្តិសាស្ត្រ រាប់ទាំងគោលនយោបាយនៃរបបខ្មែរក្រហម ការបំផ្លិចបំផ្លាញ និងការជន្លៀសប្រជាជនចេញគ្រប់ទីកន្លែងនៅទូទាំងប្រទេស ដែលបានបន្សល់ទុកដោយសង្គ្រាមស៊ីវិលរយៈពេលដ៏យូរនៅកម្ពុជា បាននាំឲ្យមានការផ្ទុះឡើងនូវទំនាស់ដីធ្លី ដែលរដ្ឋាភិបាលបាននិងកំពុងតែគ្រប់គ្រងដោះស្រាយ។ ម្យ៉ាងវិញទៀត គួរកត់សំគាល់ដែរថា កម្ពុជា គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ អាចមានបំណងប្រាថ្នាផ្តល់អាទិភាពលើការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ខ្លួន ដើម្បីធ្វើការអភិវឌ្ឍន៍ និងធ្វើឲ្យសម្បូររុងរឿងថែមទៀត។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំយល់ឃើញថាសម្បទានដី គួរតែត្រូវបានផ្តល់ និងគ្រប់គ្រងក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយមួយរឹងមាំ រាប់ទាំងការពិចារណាត្រឹមត្រូវចំពោះ និងការពិគ្រោះយោបល់ជាមួយអ្នកទាំងឡាយដែលនឹងរងផលប៉ះពាល់ និងគិតគូពីការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចិរភាព។

ភាគច្រើននៃបញ្ហាប្រឈមដែលខ្ញុំសំគាល់ឃើញដែលមាននៅក្នុងរបាយការណ៍នេះ (ដូចដែលបានវិភាគក្នុងផ្នែកទី V ដល់ផ្នែកទី VIII) កើតចេញពីការខកខានក្នុងការអនុវត្តក្របខ័ណ្ឌគតិយុត្តក្នុងស្រុក នោះគឺច្បាប់ គោលនយោបាយ និង បទដ្ឋានគតិយុត្ត ដែលរដ្ឋាភិបាលខ្លួនឯងផ្ទាល់បានបង្កើតឡើង (ដូចបានពន្យល់ក្នុងផ្នែកទី III)។ ការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតនោះ កម្ពុជារងគ្រោះដោយការខ្វះតម្លាភាព និងការគោរពខ្ជាប់ខ្ជួនចំពោះច្បាប់ដែលមានស្រាប់។ ភាគច្រើនលើសលុបនៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវបានរៀបចំតាក់តែងបានល្អនៅលើក្រដាស ប៉ុន្តែបញ្ហាគឺនៅត្រង់ការអនុវត្តច្បាប់ជាក់ស្តែង។

ម្យ៉ាងវិញទៀត បញ្ហារីករាយដាលមួយទៀត ដែលខ្ញុំបានជួបប្រទះនោះ គឺលទ្ធភាពមិនស្មើគ្នាក្នុងទទួលបានព័ត៌មាន ដែលជាចំណែកធ្វើឲ្យមនុស្សចំនួនភាគតិចតែប៉ុណ្ណោះ ដែលទទួលអត្ថប្រយោជន៍ពីសម្បទាននេះ ក៏ដូចជាការ

វិកសាយនៃជម្លោះទាក់ទងនឹងដីធ្លីដែលអាចនាំឲ្យមានអស្ថិរភាព។ រដ្ឋាភិបាល គួរមានភាពម៉ឺងម៉ាត់ និងមានតម្លាភាពក្នុងការផ្តល់ និងការតាមឃ្លាំមើលសម្បទានដី (សូមមើលផ្នែកទី II និងទី VI) ជាពិសេសនៅពេលធ្វើការចរចារគ្នា ឈានទៅការចុះកិច្ចព្រមព្រៀងសម្បទានជាមួយក្រុមហ៊ុនជាតិ និងក្រុមហ៊ុនបរទេស ជៀសវាងទំនាស់ផលប្រយោជន៍ ហើយត្រូវដាក់ឲ្យក្រុមហ៊ុនសម្បទានទាំងអស់ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យសកម្មភាព និងដោះស្រាយទំនាស់ដីធ្លីរបស់ខ្លួន។ ការគ្មានតម្លាភាពក្នុងបញ្ហាទាំងនេះ បានបង្កើតឲ្យមានការមន្ទិលសង្ស័យពីអំពើពុករលួយ នៅតាមស្ថាប័នរដ្ឋ គ្រប់ជាន់ថ្នាក់ ហើយបានធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាជាច្រើន មានការអាក់អន់ស្រពន់ចិត្ត។ ទោះជាដំណើរទស្សនៈកិច្ចមកកាន់ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០០៩ រហូតមក ខ្ញុំបានទទួលកិច្ចសហការក្នុងកម្រិតមួយល្អ ពីសំណាក់រដ្ឋាភិបាល ក្នុងវិស័យជាច្រើននៃអាណត្តិរបស់ខ្ញុំក្តី ខ្ញុំនៅមានការពិបាកក្នុងការទទួលបានព័ត៌មានចាំបាច់ផ្លូវការ និងការទំនាក់ទំនងជាមួយក្រុមហ៊ុននានា ដែលកាន់កាប់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត។ កង្វះការទទួលបានព័ត៌មានសំខាន់ៗ នេះ បានធ្វើឲ្យមានការពិបាកជាខ្លាំងក្នុងការសរសេររបាយការណ៍ទូលំទូលាយមួយអំពីបញ្ហាទាំងនេះ។

ទន្ទឹមពេលដែលទីផ្សារកម្ពុជាកំពុងងើបឡើង ហានិភ័យ ក៏កំពុងកើតមានដល់កិត្តិសព្ទលើឆាកអន្តរជាតិសម្រាប់ការវិនិយោគ ដែលមិនមានភាពប្រាកដប្រជាក្នុងវិស័យដីធ្លី និងវិស័យផ្សេងទៀតជាទូទៅ។ បរិយាកាសបច្ចុប្បន្ននៃការអភិវឌ្ឍន៍ បានបង្ហាញឲ្យឃើញពីតម្លាភាពភាព នៅមានកម្រិតទាប និងលទ្ធភាពមិនស្មើគ្នា ក្នុងទទួលបានព័ត៌មាន ការពិគ្រោះយោបល់ និងការរួមបញ្ចូលអ្នកពាក់ព័ន្ធមិនបានគ្រប់គ្រាន់ ហើយបើតាមការយល់ឃើញខ្ញុំ គឺមិនមានចិរភាពនោះទេ ហើយវាទំនងជានឹងបង្កឧបសគ្គថែមទៀតដល់កំណើនសេដ្ឋកិច្ចជាតិ។ ជាការពិតណាស់ ករណីសម្បទានដីខ្លះ ទំនងជាមានផលប៉ះពាល់វិជ្ជមានសម្រាប់ប្រជាជនកម្ពុជា ក្នុងលក្ខខណ្ឌនៃការបង្កើតការងារ ការបង្កើនសេដ្ឋកិច្ចមូលដ្ឋាន ការបង្កើតចំណូលដល់សេវាហិរញ្ញវត្ថុសាធារណៈ និង ការរួមចំណែកទូទៅដល់ការអភិវឌ្ឍន៍ជាតិ។ ទោះជាយ៉ាងណាក៏ដោយ ការខូចខាតទៅលើមនុស្សដោយសារសម្បទាន ភាគច្រើនមានកម្រិតខ្ពស់ ហើយសិទ្ធិមនុស្ស គួរតែជាបេះដូងនៃអភិក្រមឈានទៅការផ្តល់ និងការគ្រប់គ្រងដីសម្បទាន ដើម្បីឲ្យសម្បទានទាំងនោះ ផ្តល់ផលវិជ្ជមាន។ មានការចងក្រងឯកសារយ៉ាងម៉ត់ចត់អំពីការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងវិវាទដ៏រីករាលដាលពាក់ព័ន្ធនឹងសម្បទានដី ដែលត្រូវការឲ្យមានការឆ្លើយតបដោយការដោះស្រាយកែតម្រូវឡើងវិញ។ ការចោទប្រកាន់សកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្ស គឺជាកង្វល់ដ៏ធំមួយ ដោយសារសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការប្រជុំ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់សង្គមមួយដែលមានដំណើរការលិទ្ធិប្រជាធិបតេយ្យបានល្អ។

ម្យ៉ាងវិញទៀត នៅទូទាំងការវិភាគរបស់ខ្ញុំទាំងមូល ខ្ញុំបានខិតខំស្វែងយល់ឲ្យបានពេញលេញអំពីសម្បទានដីជាច្រើនដែលរដ្ឋាភិបាលបានផ្តល់។ ជាទូទៅ មិនមានភាពច្បាស់លាស់ទេ អំពីវិសាលភាពនៃផលប្រយោជន៍ពិតប្រាកដដែលប្រជាជនកម្ពុជាទទួលបានពីសម្បទានដីទាំងនេះ ហើយខ្ញុំមានកង្វល់ថា ទោះបីជាមានការសន្យារបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្តីក៏មានសម្បទានិកជាច្រើនប្រតិបត្តិការដោយភាពលាក់កំបាំង។ អត្ថប្រយោជន៍ពីសម្បទានដី ប្រសិនជាមានមែន គួរតែបង្ហាញឲ្យឃើញអំពីបរិមាណរបស់វា និងធ្វើឲ្យគេបានមើលឃើញច្បាស់ផង ហើយប្រសិនជាវាគ្មានភស្តុតាងអំពីអត្ថប្រយោជន៍ទេនោះ គោលនយោបាយ និងការអនុវត្តជុំវិញការផ្តល់សម្បទានដីនោះ គួរតែធ្វើការកែសម្រួលឡើងវិញ។ ផលប៉ះពាល់នៃសម្បទានដី គួរតែបានធ្វើការវិភាគអំពីផលវិបាករយៈពេលខ្លី និងរយៈពេលវែងរបស់វា ហើយជាការពិតណាស់គឺ អត្ថប្រយោជន៍គួរតែមានពិតប្រាកដ និងមានច្រើនជាងភាពបាត់បង់សម្រាប់មនុស្សភាគច្រើន ដើម្បីអាចចាត់ទុកថាមានសារៈប្រយោជន៍ទៅបាន។ ខ្ញុំយល់ឃើញថា ការអភិវឌ្ឍន៍ដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា អាចនឹងមានផលប៉ះពាល់វិជ្ជមានទៅលើជីវិតរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់រូប ប្រសិនជាត្រូវបានធ្វើដោយសមធម៌ និងប្រកបដោយនិរន្តរភាព និងស្ថិតក្នុងក្របខណ្ឌនៃកាតព្វកិច្ចសិទ្ធិមនុស្ស របស់រដ្ឋាភិបាល ហើយស្ថិតក្នុងស្មារតីស្ថាបនា ដែលខ្ញុំបង្ហាញរបាយការណ៍នេះ។

# មាតិកា


| | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|
| I. សេចក្តីផ្តើម និង វិសាលភាព............................................................ | ១-៥ | ៩ |
| II. ការតាមឃ្លាំមើលសម្បទានដីនៅក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយ.... | ៦-១៣ | ១០ |
| III. ក្របខ័ណ្ឌជាតិ – ច្បាប់ និងនីតិវិធីផ្សេងៗ .......................................... | ១៤-៦៥ | ១៣ |
| ក. ការគ្រប់គ្រងដីធ្លីៈ ការធ្វើចំណាត់ថ្នាក់ដីធ្លី និងការធ្វើអនុបយោគដីសាធារណៈ របស់រដ្ឋ.................................................................................................. | ១៥-១៩ | ១៣ |
| ខ. ច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងលើសម្បទានដី.................................... | ២០-២៥ | ១៥ |
| គ. បច្ចុប្បន្នភាពនៃនីតិវិធីផ្តល់សម្បទានដី – តួនាទីរបស់តួអង្គរដ្ឋ..................... | ២៦-៣៤ | ១៧ |
| ឃ. អន្តរកម្មជាមួយច្បាប់ និងបទប្បញ្ញត្តិដទៃទៀតដែលគ្រប់គ្រប់លើសម្បទានដី... | ៣៥-៤៨ | ២២ |
| ង. កម្មសិទ្ធិដីធ្លី និងសិទ្ធិភោគៈ.................................................................. | ៤៩-៥១ | ២៩ |
| ច. សិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច...................................................... | ៥២-៥៤ | ៣១ |
| ឆ. ការពិនិត្យមើលត្រួសៗលើយន្តការដោះស្រាយទំនាស់ដីធ្លីដែលមានស្រាប់...... | ៥៥-៥៩ | ៣២ |
| ជ. ការប្រែប្រួលថ្មីៗ នៃច្បាប់ និងគោលនយោបាយ........................................ | ៦០-៦៣ | ៣៤ |
| ឈ. សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិដែលកំពុងរង់ចាំការអនុម័ត....................... | ៦៤-៦៥ | ៣៥ |
| IV. ក្របខ័ណ្ឌច្បាប់អន្តរជាតិ................................................................. | ៦៦-៨០ | ៣៦ |
| ក. ការវិវឌ្ឍន៍នៅក្នុងប្រព័ន្ធច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹង កាតព្វកិច្ចសិទ្ធិមនុស្ស របស់កម្ពុជា......................................................... | ៦៦-៧២ | ៣៦ |
| ខ. ការវិវឌ្ឍន៍ជាអន្តរជាតិទាក់ទងនឹងការទទួលខុសត្រូវខាងសិទ្ធិមនុស្សរបស់ សហគ្រាសពាណិជ្ជកម្ម......................................................................... | ៧៣-៧៦ | ៣៩ |
| គ. បទដ្ឋានអន្តរជាតិ សម្រាប់ការបង្ការ និងការដោះស្រាយផលប៉ះពាល់ | | |

| | | | |
|---|---|---|---|
| | សិទ្ធិមនុស្ស........................................................................................ | ៧៧-៨០ | ៤១ |
| V. | ទិដ្ឋភាពទូទៅនៃសម្បទានដីសេដ្ឋកិច្ច (ELC) និងសម្បទានដទៃទៀត នៅកម្ពុជា........................................................................................ | ៨១-៩៥ | ៤៣ |
| | ក. ចំនួនផ្លូវការនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ដែលបានផ្ដល់ (ទិដ្ឋភាពទូទៅ)................................................................ | ៨១-៨៦ | ៤៣ |
| | ខ. លទ្ធភាពទទួលបានព័ត៌មាន និងឯកសារ................................................. | ៨៧-៩២ | ៤៦ |
| | គ. ចំនួនសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀតដែលបានផ្ដល់ នៅក្នុងតំបន់ការពារ និងនៅលើដីរបស់ជនជាតិដើមភាគតិច......................... | ៩៣-៩៥ | ៥០ |
| VI. | ច្បាប់ និងការអនុវត្តជាក់ស្ដែងៈ សម្បទានដី និងការអនុវត្តតាម លក្ខខណ្ឌតម្រូវនៃច្បាប់ និងនីតិវិធី.................................................... | ៩៦-១២៦ | ៥១ |
| | ក. ទំហំផ្ទៃដីសម្បទាន និងកម្មសិទ្ធិ............................................................ | ៩៧-១០០ | ៥២ |
| | ខ. ការពិនិត្យមើលឡើងវិញ ការតាមដានត្រួតពិនិត្យ និង ការលុបចោល សម្បទានដី.......................................................................................... | ១០១-១០៥ | ៥៤ |
| | គ. ការអនុវត្តន៍ស្របតាមក្របខ័ណ្ឌនៃការអភិរក្សចំពោះតំបន់ការពារ និងព្រៃឈើ.......................................................................................... | ១០៦-១១៣ | ៥៦ |
| | ឃ. ការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម............................................................................................ | ១១៤-១១៧ | ៥៨ |
| | ង. ការអនុវត្តតាមក្របខ័ណ្ឌការពារតាមផ្លូវច្បាប់សម្រាប់ដីធ្លីរបស់ ជនជាតិដើមភាគតិច.......................................................................... | ១១៨-១២៦ | ៥៩ |
| VII. | ផលប្រយោជន៍ និងផលប៉ះពាល់អវិជ្ជមាននៃសម្បទានដីនានា................ | ១២៧-១៧៦ | ៦២ |
| | ក. ផលប៉ះពាល់ទូទៅលើសិទ្ធិមនុស្ស........................................................... | ១២៩ | ៦៣ |
| | ខ. បញ្ហាអស្ថិរភាព និងការគ្រប់គ្រងទន់ខ្សោយ............................................... | ១៣០-១៣៧ | ៦៤ |
| | គ. ការបណ្ដេញចេញដោយបំពាន និងការផ្លាស់ប្ដូរទីលំនៅថ្មី............................ | ១៣៨-១៤៥ | ៦៦ |

| | | |
|---|---|---|
| ឃ. ការបំផ្លាញបរិស្ថាន និងផលប៉ះពាល់លើលើជីវភាពរស់នៅ.......................... | ១៤៦-១៥៣ | ៧១ |
| ង. បញ្ហាជុំវិញលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់...................................... | ១៥៤-១៥៧ | ៧៣ |
| ច. កង្វល់ទាក់ទងនឹងសន្តិសុខៈ ការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ និងបុគ្គលិកសន្តិសុខឯកជន...................................................................... | ១៥៨-១៦១ | ៧៤ |
| ឆ. ផលប៉ះពាល់លើជនជាតិដើមភាគតិច...................................................... | ១៦២-១៦៤ | ៧៥ |
| ជ. ផលប៉ះពាល់លើតំបន់ដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ និង ខាងការគោរពបូជា................................................................................... | ១៦៥-១៦៧ | ៧៦ |
| ឈ. ផលប៉ះពាល់លើស្ត្រី និងក្មេងស្រី............................................................ | ១៦៨-១៧៣ | ៧៧ |
| ញ. ផលប៉ះពាល់លើកុមារ.......................................................................... | ១៧៤-១៧៦ | ៨០ |
| VIII. លទ្ធភាពទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព.................. | ១៧៧-១៩៥ | ៨១ |
| ក. ភាពមាន និងលទ្ធភាពប្រើប្រាស់នៃយន្តការក្រៅប្រព័ន្ធតុលាការ ដែលមានស្រាប់.......................................................................................... | ១៧៧-១៨០ | ៨១ |
| ខ. ការប្រើប្រាស់ប្រព័ន្ធតុលាការ និងការចោទប្រកាន់បទព្រហ្មទណ្ឌចំពោះ បុគ្គលដែលប្ដឹងតវ៉ាទាមទារដីរបស់ខ្លួន និងសកម្មជនខាងដីធ្លី........................ | ១៨១-១៨៤ | ៨២ |
| គ. បរិយាកាសសម្រាប់សង្គមស៊ីវិល និងសកម្មភាពរបស់សហគមន៍................... | ១៨៥-១៨៧ | ៨៤ |
| ឃ. យន្តការដោះស្រាយវិវាទកម្រិតប្រតិបត្តិការ............................................. | ១៨៨-១៩០ | ៨៥ |
| ង. ភាពមាន និងលទ្ធភាពទៅប្រើប្រាស់ យន្តការដោះស្រាយ វិវាទកម្រិតអន្តរជាតិ............................................................................. | ១៩១-១៩៥ | ៨៦ |
| IX. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍....................................................... | ១៩៦-២៤២ | ៨៩ |
| ក. ការទទួលបានព័ត៌មាន និងតម្លាភាព...................................................... | ២០១-២០៥ | ៩១ |
| ខ. ការផ្ដល់សម្បទានដី - ការពិគ្រោះយោបល់ និងការត្រួតពិនិត្យ..................... | ២០៦-២១១ | ៩២ |
| គ. ការផ្ដល់សម្បទានដី - ការការពារបរិស្ថាន និងសង្គម.................................. | ២១២-២១៦ | ៩៣ |
| ឃ. សកម្មភាពនៃសម្បទានដី...................................................................... | ២១៧-២២៤ | ៩៣ |

| | | | |
|---|---|---|---|
| ង. | ការឃ្លាំមើល ការស្រាវជ្រាវ និងការវិភាគ | ២២៥-២៣១ | ៩៥ |
| ច. | ការដោះស្រាយទំនាស់ | ២៣២-២៣៥ | ៩៥ |
| ឆ. | ការពិនិត្យឡើងវិញដោយស្ថាប័នសិទ្ធិមនុស្សនានា និងយន្តការបណ្តឹងអន្តរជាតិផ្សេងៗ | ២៣៦-២៣៩ | ៩៦ |
| ជ. | ការតស៊ូមតិលើសិទ្ធិដីធ្លី និងការអប់រំ | ២៤០-២៤២ | ៩៧ |

## ឧបសម្ព័ន្ធ៖

| | | |
|---|---|---|
| I. | សម្បទានដីដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិដែលបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យ (ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣) | ៩៨ |
| II. | សម្បទានដីដែលត្រូវបានផ្តល់នៅក្នុងតំបន់ ដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ និង/ឬ ប្រើប្រាស់ជាប្រពៃណី | ១៤១ |
| III. | ក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប (Union Development Group Co., Ltd) ឧទ្យានជាតិបុទុមសាគរ ខេត្ត កោះកុង | ១៧០ |
| IV. | ក្រុមហ៊ុន ជីងហ្សុងរី ខេមបូឌា ខូអិលលធីឌី (Jing Zhong Ri) សម្បទានដីសេដ្ឋកិច្ចនៅលើដីជនជាតិដើមភាគតិចទំពួន ក្នុងស្រុកលំផាត់ ខេត្តរតនៈគិរី | ១៧៨ |
| V. | ផែនទីនៃដីសម្បទានដែលមានទីតាំងជាប់ៗគ្នា ឬ ក្បែរៗគ្នា | ១៨២ |

# I. សេចក្ដីផ្ដើម និង វិសាលភាព

១. របាយការណ៍នេះ ត្រូវបានបញ្ជូនស្របតាមសេចក្ដីសំរេចចិត្តលេខ១៨/២៥ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ គឺជាការវាយតំលៃអំពីផលប៉ះពាល់សិទ្ធិមនុស្ស ដោយសម្បទានដីសេដ្ឋកិច្ច (ELCs) និងសម្បទានដីដទៃទៀត និងគម្រោងអភិវឌ្ឍន៍ធំៗនៅកម្ពុជា (ជាទូទៅគឺ និយាយសំដៅលើ "សម្បទានដី" នៅក្នុងរបាយការណ៍នេះទាំងមូល លុះត្រាមានការបញ្ជាក់ដោយឡែក)។ របាយការណ៍នេះ មិនត្រឹមតែជាការវិភាគទៅលើសម្បទានទាក់ទងនឹងវិស័យកសិ-ឧស្សាហកម្ម (មានជាអាទិ៍ ចំការកៅស៊ូ ចំការអំពៅ ចំការម៉ៃសាក់ និង ចំការដំឡូងមី) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការវិភាគទៅលើ សម្បទានរ៉ែ ប្រេងកាត និងឧស្ម័ន ព្រៃឈើ និងសម្បទានសម្រាប់គោលដៅទេសចរណ៍ ការអភិវឌ្ឍន៍ អចលនទ្រព្យ និងគម្រោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំមួយចំនួន មានដូចជា ទំនប់វារីអគ្គីសនី ជាដើម។

២. ចាប់តាំងពីពេលខ្ញុំចូលកាន់មុខតំណែងជាអ្នករាយការណ៍ពិសេសក្នុងឆ្នាំ២០០៩ មក ខ្ញុំបានទទួលព័ត៌មានជាហូរហែរអំពីបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងសម្បទានដី រាប់ទាំងការបណ្ដេញចេញដោយបំពាន ការតាំងទីលំនៅថ្មី និងការផ្លាស់ប្ដូរទីលំនៅគ្មានផែនការច្បាស់លាស់ ការបំផ្លាញបរិស្ថាន និងការធ្វើអាជីវកម្មធនធានធម្មជាតិ ដែលគ្មាននិរន្តរភាព និងការគំរាមកំហែងដល់ការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច ប្រពៃណី និងវប្បធម៌ ក្នុងចំណោមបញ្ហាជាច្រើនទៀត។ ចំនួនករណីបណ្ដឹងមានការកើនឡើងដែលខ្ញុំបានដឹងផងដែរ ដែលក្នុងនោះ មានបុគ្គល និងសហគមន៍ជាច្រើនកំពុងតែធ្វើការទាមទារសិទ្ធិលើដីធ្លីរបស់ខ្លួន សកម្មជនដីធ្លី និងអ្នកការពារ សិទ្ធិមនុស្សដទៃទៀត ត្រូវបានគេយាយីរំខាន គម្រាមកំហែង ឬ ដាក់ទោសព្រហ្មទណ្ឌដោយសារតែពួកគេធ្វើការ តវ៉ាចំពោះការផ្ដល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត។ ខ្ញុំបានតាមឃ្លាំមើលបញ្ហាទាំងនេះពេញអាណត្តិការងាររបស់ខ្ញុំ និងបានមានឱកាសជួបដោយផ្ទាល់ជាមួយប្រជាពលរដ្ឋទាំងឡាយដែលរងការប៉ះពាល់ ឬ អ្នកបានដឹងឮអំពី សម្បទានដីទាំងនេះ នៅអំឡុងពេលបំពេញបេសកកម្មចំនួនប្រាំពីរលើករបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា។ ខ្ញុំបានលើកឡើងអំពីបញ្ហាទាំងនេះនៅគ្រប់របាយការណ៍របស់ខ្ញុំ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅក្នុងលិខិតរបស់ខ្ញុំផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជា និងក្នុងកិច្ចសន្ទនារបស់ខ្ញុំជាមួយតំណាងនានារបស់រដ្ឋាភិបាល នៅអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា។

៣. ដោយសារភាពធ្ងន់ធ្ងរ និងភាពស្រួចស្រាវនៃបញ្ហាប្រឈមនេះ និងការងារដ៏ច្រើនដែលបុព្វធិការីរបស់ខ្ញុំបានធ្វើលើបញ្ហាសម្បទានដីសេដ្ឋកិច្ច ខ្ញុំបានផ្ដោតនៅក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា ក្នុង ខែឧសភា ឆ្នាំ ២០១២ លើសម្បទានដី និងបង្ហាញរបាយការណ៍នេះជូនក្រុមប្រឹក្សាសិទ្ធិមនុស្សជាឧបសម្ព័ន្ធនៃរបាយការណ៍គោលរបស់ខ្ញុំសម្រាប់ឆ្នាំ២០១១-២០១២ ដែលបានផ្ដោតលើកំណែទម្រង់ប្រព័ន្ធបោះឆ្នោត។ គោលបំណងគឺ ដើម្បីពិនិត្យមើលស្ថានការណ៍វិវត្តន៍ថ្មីៗអំពីបញ្ហាប្រឈមខាងសិទ្ធិមនុស្សដែលកើតចេញពីសម្បទានដី នៅចំពោះមុខសន្ទុះនៃការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនសម្បទានដី ដែលបានផ្ដល់ឲ្យក្រុមហ៊ុនជាតិ និងក្រុមហ៊ុនបរទេស និងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងររបស់សម្បទានដីទាំងនេះដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។ ដូច្នេះ របាយការណ៍នេះ ដកស្រង់ផងដែរ ពីរបាយការណ៍ចំនួនពីរស្ដីពីសម្បទានដី ដែលបុព្វធិការីរបស់ខ្ញុំពីររូប គឺតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (SRSG) ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានធ្វើនាពេលកន្លងមកនៅក្នុងឆ្នាំ ២០០៤ និងឆ្នាំ២០០៧។ ទោះជាយ៉ាងណាក៏ដោយ ដោយសាររបាយការណ៍កន្លងមក បានផ្ដោតជាចម្បងលើសម្បទានដីសម្រាប់គោលដៅកសិកម្ម ដូច្នេះរបាយការណ៍នេះរបស់ខ្ញុំ គ្របដណ្ដប់លើបញ្ហាសិទ្ធិមនុស្សទូទៅទាក់ទងនឹងសម្បទានដីសម្រាប់គោលដៅកសិកម្ម ក៏ដូចជាប្រភេទដទៃទៀតនៃសម្បទាន ហើយក្នុងនោះមានបញ្ហាខ្លះគឺជាបញ្ហា

ថ្មី។ ខ្ញុំសូមហៅរបាយការណ៍នីមួយៗ នៃរបាយការណ៍ទាំងពីរកន្លងមកនេះ ថាជា "របាយការណ៍តំណាងពិសេសឆ្នាំ ២០០៤" និង "របាយការណ៍តំណាងពិសេស ឆ្នាំ២០០៧" នៅក្នុងរបាយការណ៍នេះទាំងមូល។ របាយការណ៍នេះ មានបញ្ចូល ការវិភាគអំពីផលប៉ះពាល់ទូទៅលើសិទ្ធិមនុស្ស ដោយសារតែការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ទាំងនៅតំបន់ទីប្រជុំជន និង នៅតំបន់ជនបទ។ ទោះជាយ៉ាងណាក៏ដោយ ពីព្រោះតែកង្វល់ អំពីការបំផ្លាញធនធានធម្មជាតិនៅកម្ពុជា នៅតែមានជាបន្ត ខ្ញុំបានសម្រេចផ្តោតការយកចិត្តទុកដាក់ជាពិសេស លើសម្បទានដីនៅក្នុងតំបន់ការពារធម្មជាតិ នៅក្នុងរបាយការណ៍នេះ (សូមមើលឧបសម្ព័ន្ធទី I ស្តីពីបញ្ជីសម្បទានដី ដែលបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិ)។

៤. ក្នុងដំណើរបេសកម្មនៅក្នុងខែឧសភា ឆ្នាំ២០១២ ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់ខេត្តរតនគីរី ស្ទឹងត្រែង និង ខេត្តក្រចេះ ក៏ដូចជានៅរាជធានីភ្នំពេញ។ នៅក្នុងខេត្តនីមួយៗ ខ្ញុំបានជួបជាមួយសហគមន៍មួយចំនួនដែលរងផលប៉ះពាល់ពីសម្បទានដី ក៏ដូចជាជួបជាមួយអាជ្ញាធរខេត្ត។ ខ្ញុំបានព្យាយាមទាក់ទងជាមួយក្រុមហ៊ុនផ្សេងៗ ដែលត្រូវបានរដ្ឋាភិបាលផ្តល់សម្បទានពាក់ព័ន្ធឲ្យ ហើយខ្ញុំនឹងខិតខំប្រឹងប្រែងតទៅទៀត ដើម្បីប្រាស្រ័យទាក់ទងជាមួយក្រុមហ៊ុនទាំងនេះ ដែលពួកគេគឺជាតួអង្គសំខាន់ក្នុងការប្រតិបត្តិការសម្បទានដី និងជាតួអង្គសំខាន់ដែលទទួលផលប្រយោជន៍ពីសម្បទានដីទាំងនោះ។ ខ្ញុំក៏បានជួបផងដែរជាមួយតំណាងសង្គមស៊ីវិលជាច្រើន ជួបជាមួយក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំណាងទូត និងអ្នកផ្តល់ជំនួយ និងក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ខ្ញុំមានការសោកស្តាយ ដែលខ្ញុំមិនបានជួបជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ជាពិសេស ពីព្រោះតែក្រសួងនេះ គឺជាអង្គភាពមួយរបស់រដ្ឋាភិបាល ដែលពាក់ព័ន្ធខ្លាំងជាងគេក្នុងវិស័យសម្បទានដីនេះ។ ព័ត៌មានបន្ថែមមួយចំនួន ត្រូវបានផ្តល់ឲ្យដោយក្រសួង បរិស្ថាន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៥. អំឡុងបេសកកម្មថ្មីៗបំផុតរបស់ខ្ញុំ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រី បានប្រកាសពីកិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច រួមមានទាំងការគ្រប់គ្រងលើការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការត្រួតពិនិត្យឡើងវិញលើការអនុវត្តទាក់ទងនឹងកិច្ចសន្យា និងកាតព្វកិច្ចតាមច្បាប់របស់សម្បទានិកនៃសម្បទានដីដែលមានស្រាប់។ ជាបន្តបន្ទាប់ លោកនាយករដ្ឋមន្ត្រី បានប្រកាសអំពីកិច្ចផ្តួចផ្តើមធ្វើប័ណ្ណកម្មសិទ្ធិដីសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដីសម្បទាន។ របាយការណ៍នេះក៏ធ្វើការពិចារណាផងដែរពីការវិវឌ្ឍន៍ថ្មីៗ ទាំងអស់នេះ និងស្វះស្វែងដើម្បីបង្កើតឲ្យមានទិដ្ឋភាពវិជ្ជមានមួយចេញពីកិច្ចផ្តួចផ្តើមទាំងនេះ។ របាយការណ៍នេះ ធ្វើការវិភាគលើរាល់ព័ត៌មានដែលខ្ញុំបានទទួលតាំងពីដើមដំបូងនៃអាណត្តិរបស់ខ្ញុំ ក្នុងឆ្នាំ២០០៩ រហូតមកទល់ចុងខែកក្កដា ឆ្នាំ២០១២ រាប់ទាំងក្របខ័ណ្ឌច្បាប់ជាតិគ្រប់គ្រងលើសិទ្ធិដីធ្លី (ច្បាប់ និងគោលនយោបាយផ្សេងៗពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ) ការវិវឌ្ឍន៍ជាអន្តរជាតិទាក់ទងនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជាលើវិស័យដីធ្លី និងផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃផ្សេងទៀតទៅលើការទទួលបានសិទ្ធិមនុស្ស។ ករណីមួយចំនួនដែលបានជ្រើសសម្រាំង នៅក្នុងរបាយការណ៍នេះឆ្លុះបញ្ចាំងពីការបង្ហាញជូនទាំងនេះ។ របាយការណ៍នេះផ្អែកលើទិន្នន័យ និងព័ត៌មានផ្លូវការរបស់រដ្ឋាភិបាល ញត្តិជាបុគ្គល និងសក្ខីកម្មដែលបានដាក់តាមរយៈបុគ្គល សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិផងដែរ។ របាយការណ៍នេះ ក៏បានមកពីការសិក្សាស្រាវជ្រាវដែលបានធ្វើឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅកម្ពុជា ដែលបាននិងកំពុងបន្តតាមឃ្លាំមើល និងធ្វើការតស៊ូមតិលើបញ្ហានេះ។ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យ OHCHR នៅកម្ពុជា ចំពោះការជួយឧបត្ថម្ភគាំទ្រដ៏ មានតំលៃនេះ។ ទន្ទឹមនឹងគ្រប់សកម្មភាពការងារទាំងអស់របស់ខ្ញុំមានការសហការពីរដ្ឋាភិបាលក្តី ក៏ជាការគួរកត់សំគាល់ផងដែរថា ឯកសារផ្លូវការដែលត្រូវការចាំបាច់សម្រាប់ការវិភាគឲ្យបានពេញលេញទាំងស្រុង មិនមានគ្រប់គ្រាន់ទេ ហើយព័ត៌មានទៀតសោតក៏នៅមានភាពចន្លោះប្រហោងដែរ។

## II. ការតាមឃ្លាំមើលសម្បទានដី នៅក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយ

៦. សម្បទានដី គឺជាកិច្ចសន្យាមួយធ្វើឡើងរវាងរដ្ឋាភិបាល និងតួអង្គមួយទៀត ដែលផ្តល់ឲ្យតួអង្គនោះនូវសិទ្ធិជាក់លាក់ក្នុងការគ្រប់គ្រងផ្ទៃដីមួយកន្លែង ដែលមានកំណត់រយៈពេល ស្ថិតក្នុងកម្មវត្ថុនៃកិច្ចព្រមព្រៀង ដែលកំណត់ពីសកម្មភាពដែលត្រូវធ្វើនៅលើផ្ទៃដីនោះ។ ឧទាហរណ៍ សម្បទានិកមួយរូប អាចនឹងត្រូវបានផ្តល់សិទ្ធិពិសេសក្នុងការគ្រប់គ្រង ការដាំដុះ និងប្រមូលផលលើផ្ទៃដីនោះ។ ទោះបីជាសម្បទានដី ជារឿយៗ ត្រូវបានផ្តល់សម្រាប់រយៈពេលមួយវែង ហើយសម្បទានិកអាចត្រូវបានផ្តល់សិទ្ធិពិសេសក្នុងការប្រើប្រាស់ផ្ទៃដីនោះក្តី ក៏សម្បទានិក មិនត្រូវបានផ្តល់ឲ្យនូវសិទ្ធិកម្មសិទ្ធិទាំងស្រុងដែរ ហើយដីនោះទៀតសោធ ក៏នៅតែជាដីរបស់រដ្ឋដដែល។ កង្វល់អំពីផលប៉ះពាល់នៃសម្បទានដី ចាប់ផ្តើមកើតមានឡើងតាំងពីទសវត្សរ៍ ឆ្នាំ១៩៩០ នៅពេលដែលអង្គការសិទ្ធិមនុស្សនានាបានចាប់ផ្តើមទទួលពាក្យបណ្តឹងអំពីការរំលោភសិទ្ធិមនុស្ស នៅតំបន់ដីសម្បទាន។ ផលប៉ះពាល់ទៅលើសិទ្ធិមនុស្ស ដោយសារសម្បទានដីសម្រាប់គោលដៅកសិ-ឧស្សាហកម្ម គឺជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវ ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងជាកម្មវត្ថុនៃរបាយការណ៍ផ្សេងៗទៀតរបស់បុព្វាធិការីរបស់ខ្ញុំមួយចំនួន ដែលជាតំណាងពិសេសរបស់អគ្គលេខាធិការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា[១] និងដូចបានកត់សំគាល់ របាយការណ៍នេះ មានគោលបំណងយកការវិភាគចេញពីរបាយការណ៍មុនៗរបស់បុព្វាធិការីរបស់ខ្ញុំមកពិចារណាផងដែរ ។

៧. តំណាងពិសេស ដំបូងគេបំផុត គឺលោក មៃឃឹល ឃីប៊ី បានទៅទស្សនាដីសម្បទានមួយកន្លែងក្នុងខែ មករា ឆ្នាំ១៩៩៦ ក្នុងខេត្តរតនគីរី និងបានសំដែងកង្វល់អំពីផលប៉ះពាល់នៃសម្បទានដីកសិកម្មទៅលើ សិទ្ធិមនុស្ស និងការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ នៅក្នុងរបាយការណ៍បន្តបន្ទាប់របស់លោកដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស (ជាឈ្មោះដែលគេហៅនាពេលនោះ) លោកបានផ្តល់អនុសាសន៍ថា "បណ្តឹងរបស់អ្នកភូមិអំពីការមិនបានពិគ្រោះយោបល់ ការប្រើឆ្នាំប្រដាប់អាវុធ ការឲ្យចុះហត្ថលេខាលើកិច្ចសន្យាដែលមិនមានការពន្យល់ប្រាប់ ការបាញ់សម្លាប់គោក្របី ដែលដើរចូលក្នុងតំបន់ដីសម្បទាន និងការភ័យខ្លាចមានគ្រោះថ្នាក់ ដល់អាយុជីវិតរបស់អ្នកភូមិ និង សុវត្ថិភាពនៃទីកន្លែងកប់សាកសពជាប្រពៃណី វាលស្មៅសម្រាប់សត្វពាហណៈ និងដីកសិកម្ម គួរតែត្រូវបានដោះស្រាយ ដោយមិនត្រូវអូសបន្លាយពេលវេលា និងប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ហើយនិងអនុលោមតាមច្បាប់។"[២]

៨. បុព្វាធិការីរបស់លោក មៃឃឹល ឃីប៊ី គឺលោក ថូម៉ាស់ ហាំម៉ាបឺក បានបន្តពិនិត្យមើលលើផលប៉ះពាល់សិទ្ធិជនជាតិដើមភាគតិច ដោយសារសម្បទានដីកសិកម្ម និងសម្បទានព្រៃឈើ ហើយលោកបានស្នើយ៉ាងទទូចដល់រដ្ឋាភិបាលដែលសំណើមួយក្នុងចំណោមសំណើដទៃទៀត គឺសូមឲ្យទទួលស្គាល់ជាផ្លូវការនូវសិទ្ធិរបស់ពួកគេ ក្នុងការប្រើប្រាស់ដីព្រៃឈើ និងធនធានធម្មជាតិដទៃទៀត និងអត្តសញ្ញាណវប្បធម៌ និងរបៀបរបបរស់នៅផ្សេងពីគេ និងដែលមានតែមួយរបស់ពួកគេ ក៏ដូចជាតួនាទីរបស់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រង និងការអភិរក្សព្រៃឈើ និងជីវចម្រុះ។ លោកបានផ្តល់អនុសាសន៍ថា "ភូមិ ដីធ្លី និងព្រៃឈើដែលជនជាតិដើមភាគតិច ដែលបាននិងកំពុងប្រើប្រាស់ ត្រូវមានការកំណត់ឲ្យបានច្បាស់លាស់ ហើយត្រូវរក្សាវាទុក ដោយមិនគួរផ្តល់សម្បទានលក្ខណៈពាណិជ្ជកម្មណាមួយ ទាំងនៅពេលបច្ចុប្បន្ន ទាំងទៅថ្ងៃអនាគត ឬ ការប្រើប្រាស់ណាមួយដែលមានចរិតលក្ខណៈស្រដៀងគ្នានេះ។ គម្រោងព្រៃឈើសហគមន៍មូលដ្ឋាន គួរតែត្រូវបានទទួលស្គាល់ និងគាំទ្រ។ គម្រោងសាធារណៈ និងគម្រោងឯកជននានា អាចនឹងធ្វើ

---

[១] សម្រាប់ទិដ្ឋភាពទូទៅនៃសម្បទានដី សូមមើលរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៤ ទំព័រ ១០-១៤ ។

[២] ឯកសារអង្គការសហប្រជាជាតិ លេខ E/CN.4/1996/93 ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ កថាខ័ណ្ឌទី ៨៤ ។

ទៅបាន បន្ទាប់ពីមានការពិគ្រោះយោបល់ត្រឹមត្រូវជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងបន្ទាប់ពីបានសិក្សាវាយតំលៃអំពីផលប៉ះពាល់សង្គម បរិស្ថាន និងវប្បធម៌រួចហើយ។[៣] កាលនោះ ក្របខ័ណ្ឌច្បាប់សម្រាប់ការផ្តល់ និងការអភិវឌ្ឍន៍សម្បទានដីកសិកម្មនៅមានកម្រិតបំផុត និងមានតិចតួចនៅឡើយ ក្នុងទម្រង់ជាបទបញ្ញាសម្រាប់ប្រភេទសម្បទានដីទាំងនេះ។[៤] ករណីនេះមានការផ្លាស់ប្តូរ ក្នុងឆ្នាំ ២០០១ នៅពេលដែលច្បាប់ភូមិបាលថ្មី កំណត់អំពីលក្ខខ័ណ្ឌជាមូលដ្ឋាន សម្រាប់ការផ្តល់នូវអ្វីដែលបច្ចុប្បន្ននេះហៅថាសម្បទានដីសេដ្ឋកិច្ច (ឬ ELCs) ជាការធ្វើសម្បទានសម្រាប់គោលដៅកសិ-ឧស្សាហកម្ម។[៥] បទប្បញ្ញត្តិអំពីសម្បទានដីក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ ដែលក្រោយមក ត្រូវបានចែងលំអិតដោយអនុក្រឹត្យមួយដែលនិយាយតែអំពីសម្បទានដីសេដ្ឋកិច្ច ។[៦]

៩. គិតត្រឹមទសវត្សរ៍ ឆ្នាំ២០០០ បុព្វាធិការីរបស់លោក ថូម៉ាស់ ហាំម៉ាប៊ឹក គឺលោក ភីថឺរ លយប្រែកត៏ បានសិក្សាស៊ីជម្រៅអំពីផលប៉ះពាល់នៃប្រព័ន្ធសម្បទានដីសេដ្ឋកិច្ច ដោយផ្អែកលើទស្សនៈទានខាងសិទ្ធិមនុស្ស ដែលជាប្រធានបទនៃរបាយការណ៍ ឆ្នាំ២០០៤។ របាយការណ៍នោះ បានបរិយាយលំអិតអំពី ការអនុវត្តបច្ចុប្បន្ន និងជាប្រវត្តិសាស្ត្រនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច រាប់ទាំងការបង្កើតឡើងតាំងពីដំបូងនៃប្រព័ន្ធសម្បទាន និងបានផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្ស និងការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ គោលបំណងនៃរបាយការណ៍នោះ គឺជួយសាធារណជនទូទៅឲ្យបានយល់ដឹងអំពីបញ្ហាផ្សេងៗ និងដើម្បីជួយឲ្យមានការកែប្រែដល់ គោលនយោបាយ និង ការអនុវត្ត ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រកម្ពុជា និងមនុស្សជំនាន់ក្រោយ។ លោក ភីថឺរ លយប្រែកត៏ បានសំដែងការភ្ញាក់ផ្អើលជាខ្លាំងពេលបានឃើញស្ថានភាពបែបនេះ និងបានធ្វើការវាយតម្លៃថា "គោលនយោបាយនេះខុស... ការផ្តល់សិទ្ធិឲ្យទៅក្រុមហ៊ុននូវសិទ្ធិលើដីធ្លី ដែលមានលក្ខណៈស្រដៀងគ្នាបំផុតទៅនឹងសិទ្ធិកម្មសិទ្ធិ និងមិនគិតគូទាល់តែសោះ ឬ គិតគូតិចតួចដល់សុខមាលភាពរបស់ប្រជាពលរដ្ឋ ហើយក្រុមហ៊ុនទាំងនោះរួមចំណែកតិចតួចបំផុតដល់ចំណូលថវិកាជាតិ... គោលនយោបាយទាំងនេះ មិនត្រឹមតែមិនជួយកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបណ្តោយឲ្យមានការបន្តប្លន់យកធនធានធម្មជាតិរបស់ខ្លួនទៀតផង។"[៧] លោកបានអំពាវនាវសូមឲ្យលាតត្រដាងទាំងស្រុង នូវព័ត៌មានទាំងឡាយ ដែលទាក់ទងនឹងសម្បទានដីទាំងអស់នៅកម្ពុជា រាប់ទាំងសម្បទានដីសេដ្ឋកិច្ចផងដែរ។

១០. ក្រោយមកទៀត ដោយសារតែផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងការរំលោភសិទ្ធិមនុស្ស ជាយថាហេតុបានបន្តប៉ះពាល់ដល់សហគមន៍ជាច្រើនទៀត ទើបបុព្វាធិការីរបស់លោក លោក ភីថឺរ លយប្រែកត៏ គឺលោក យ៉ាស ហ្គាយ បានបន្តធ្វើការពិនិត្យបញ្ហានេះតទៅទៀត ដោយផ្តោតជាសំខាន់លើការរំលោភសិទ្ធិមនុស្ស ដែលក្រុមហ៊ុនទទួលបានសម្បទានដី ជាអ្នកប្រព្រឹត្តទៅលើសហគមន៍ជនបទ ជាពិសេស ជនជាតិដើមភាគតិច។ លទ្ធផលនៃការងារនេះ គឺរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ ដែលបានធ្វើបច្ចុប្បន្នភាពលើការវិវត្តន៍សំខាន់ៗចាប់តាំងពីរបាយការណ៍តំណាងពិសេសឆ្នាំ២០០៤ មក រាប់ទាំងក្របខ័ណ្ឌច្បាប់ និងបទបញ្ញាក្រោមច្បាប់ដែលបានពិនិត្យឡើងវិញ សម្រាប់ការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងការអនុវត្តក្របខ័ណ្ឌនេះ។ ក្នុងសេចក្តីផ្តើមនៃរបាយការណ៍នោះ

[៣] ឯកសារអង្គការសហប្រជាជាតិ លេខ E/CN.4/1998/95 ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ១៩៩៨ កថាខ័ណ្ឌទី ១៥៣ ។

[៤] សូមមើលរបាយការណ៍របស់តំណាងពិសេស ឆ្នាំ២០០៤ កថាខ័ណ្ឌទី ១២-១៤ ។

[៥] ច្បាប់ភូមិបាល ឆ្នាំ២០០១ ជំពូកទី ៥ ។

[៦] អនុក្រឹត្យ លេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច ។

[៧] បុព្វកថា នៃរបាយការណ៍របស់តំណាងពិសេស ឆ្នាំ២០០៤ ។

លោកតំណាងពិសេស យ៉ាស ហ្គាយ បានកត់សំគាល់ថា ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច បានបន្តឆ្លុះបញ្ចាំងពីលំនាំបញ្ហាទាំងឡាយ ដែលបានចងក្រងក្នុងរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៤ ហើយដែលរហូតដល់ពេលនោះ សម្បទានដី បានធ្វើឲ្យមានការខូចខាតយ៉ាងដំណំដល់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ សហគមន៍នានា ទាញយកអត្ថប្រយោជន៍បានតិចតួចបំផុតពីសម្បទានដី ហើយមិនមានការដោះស្រាយប្រកបដោយប្រសិទ្ធភាពឡើយ នៅពេលដែលសិទ្ធិរបស់ពួកគេ ត្រូវបានរំលោភបំពាននោះ។ លោកតំណាងពិសេស យ៉ាស ហ្គាយ ក៏បានគូសបញ្ជាក់ផងដែរអំពីអនុសាសន៍នៃរបាយការណ៍របស់តំណាងពិសេស ឆ្នាំ២០០៤ រាប់ទាំងអនុសាសន៍មួយ ដែលលើកឡើងថា ប្រព័ន្ធសម្បទានដីសេដ្ឋកិច្ចទាំងមូល គួរតែត្រូវបានធ្វើការពិនិត្យពិចារណាឡើងវិញ ហើយ គំរូជាជម្រើសផ្សេងសម្រាប់ការអភិវឌ្ឍន៍ខាងកសិកម្ម គួរតែបានយកមកអនុវត្ត សម្រាប់ជាអត្ថប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជានៅតំបន់ជនបទ។

១១. ទោះបីជាមានការអំពាវនាវដូច្នេះក្តី និងការអំពាវនាវជាច្រើនដទៃទៀតក្តី ឲ្យធ្វើការពិនិត្យមើលឡើងវិញ និងធ្វើកំណែទម្រង់ក៏ដោយ ក៏រដ្ឋាភិបាលបានបន្តផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតក្នុងអត្រាមួយដ៏គួរឲ្យភ្ញាក់ផ្អើល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សម្បទានដីដែលបានផ្តល់ឲ្យក្រុមហ៊ុនឯកជន មានការកើនឡើងទាំងចំពោះ ក្រុមហ៊ុនជាតិ និងក្រុមហ៊ុនបរទេស សម្រាប់គោលដៅអភិវឌ្ឍន៍ទ្រង់ទ្រាយធំៗលើវិស័យកសិកម្ម ការរុករករ៉ែ ហេដ្ឋារចនាសម្ព័ន្ធ ទេសចរណ៍ធម្មជាតិ និងតំបន់សេដ្ឋកិច្ចពិសេស។[៨] ការផ្តល់សម្បទានដីទាំងនេះ ភាគច្រើនបានធ្វើនៅលើដី ដែលសហគមន៍ជនជាតិដើមភាគតិចបាននិងកំពុងតែរស់នៅ រាប់ទាំងតំបន់ការពារ និងតំបន់ព្រៃឈើផងដែរ។ ទោះបីជាផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ២០០៩-២០០១៣ រួមបញ្ចូលសេចក្តីយោងលើបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងសម្បទានដី រាប់ទាំងតម្រូវការក្នុងការប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាពថែមទៀតក៏ដោយ ក៏ខ្ញុំមានកង្វល់ជាពិសេសថា ខ្ញុំមិនទទួលបានរបាយការណ៍វាយតម្លៃគ្រប់ជ្រុងជ្រោយណាមួយអំពីផលប៉ះពាល់នៃសម្បទានដីទៅលើប្រជាជន និងធនធានធម្មជាតិកម្ពុជា ដែលត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលឡើយ។ ម្យ៉ាងវិញទៀតចំណូលដែលបានមកពីសម្បទានដីទាំងនេះ មិនត្រូវបានលាតត្រដាងឲ្យដឹងជាសាធារណៈ តាមវិធីមួយដែលអាចអនុញ្ញាតឲ្យមានការវិភាគគ្រប់ជ្រុងជ្រោយបាន ដូច្នេះហើយវាស្ទើរតែមិនអាចស្វែងរកព័ត៌មានបែបនេះបានតែម្តង។[៩]

១២. ដើម្បីបំពេញចន្លោះប្រហោងនៃការខ្វះទិន្នន័យលំអិត និង ការវិភាគផ្លូវការទាំងស្រុងរបស់រដ្ឋាភិបាល ទើបអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួន បានបង្កើនការផ្តោតការងារវាលរបស់ខ្លួនជាបន្ថែមទៀតលើការតាមឃ្លាំមើលសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ក្រោមការជួយឧបត្ថម្ភគាំទ្រធនធានពីអ្នកផ្តល់ជំនួយអន្តរជាតិ។ ជាពិសេស អង្គការសិទ្ធិមនុស្សកម្ពុជាចំនួនពីរដែលនាំមុខគេគឺ អង្គការលីកាដូ និងអង្គការអាដហុក ដែលបាន និងកំពុងធ្វើការប្រមូលទិន្នន័យ ខណៈពេលដែលពួកគេបានតាមឃ្លាំមើលជម្លោះដីធ្លី ក្នុងអំឡុងពេលពីរទសវត្សរ៍កន្លងមកនេះ។ អង្គការទាំងនេះ បានរាយការណ៍ថា មានផ្ទៃដីទំហំជាងពីរលានហិកតា នាបច្ចុប្បន្ននេះ ដែលត្រូវបានជួលក្នុងរូបភាពជាការផ្តល់សម្បទានឲ្យទៅក្រុមហ៊ុនឯកជនច្រើនជាង ២០០ ក្រុមហ៊ុន និងមានផ្ទៃដីទំហំក្រោមពីរលានហិកតាបន្តិច ដែល

[៨] អង្គការលីកាដូ និងកាសែត Cambodia Daily (ការវិភាគរួមគ្នា), "ការកាត់ផ្ទៃដីជាចំនែកៗនៅកម្ពុជា៖ ការផ្តល់សម្បទានដីនៅពេលតែមួយ (ច្បាប់លេខ ៧៣០) ចុះថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០១២", អាចរកមើលបាននៅគេហទំព័រ៖ http://licadho-cambodia.org/land2012

[៩] ក្នុងអំឡុងពេលសរសេររបាយកាណ៍នេះ មិនមានឯកសារយោងសំខាន់ណាមួយ ត្រូវបានរកឃើញនៅលើគេហទំព័ររបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទេ។ ចំណូលខ្លះអាចមានបង្ហាញនៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល (TOFE) នៅក្រោមក្របខណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការចេញផ្សាយព័ត៌មាននេះ គឺជាផ្នែកមួយនៃផែនការការងារ ដែលរៀបចំដោយក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពី ការកៀងគរ និងការគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែ និងមានរៀបចំជារបាយការណ៍ទៀងទាត់មួយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សូមមើលគេហទំព័រ៖ http://www.mef.gov.kh/tofe.html

ត្រូវបានផ្តល់ឲ្យក្រុមហ៊ុនរុករករ៉ែ ដើម្បីរុករករ៉ែមាស រ៉ែដែក រ៉ែស្ពាន់ និងរ៉ែមានតំលៃដទៃទៀត ។[១០]

១៣. កង្វះការវាយតំលៃជាសាធារណៈដោយរដ្ឋាភិបាលអំពីផលប៉ះពាល់នៃប្រព័ន្ធសម្បទានទៅលើសិទ្ធិមនុស្ស និងការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន បរិស្ថាន និងការខូតខាតផ្សេងៗទៀតទៅលើមនុស្ស និងសេដ្ឋកិច្ចនៃប្រព័ន្ធសម្បទាន គួបផ្សំជាមួយការខ្វះតម្លាភាពជាទូទៅជុំវិញសកម្មភាពសម្បទាន គឺជាប្រភពនាំឲ្យមានការមិនពេញចិត្ត និងការតវ៉ា។ ផលវិបាកនេះ កើតចេញពីកង្វះការជឿទុកចិត្តពីសំណាក់សហគមន៍ទៅលើអាជ្ញាធរដែលទទួលខុសត្រូវក្នុងការផ្តល់សម្បទានដី ទៅលើអាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ ដែលទទួលបន្ទុកក្នុងការសម្រួលដល់ការអនុវត្តន៍នៃសម្បទានដី និងទៅលើក្រុមហ៊ុនសាជីវកម្មដែលប្រតិបត្តិការសម្បទានដី ដែលជារឿយៗ ត្រូវបានគេមើលឃើញថា ធ្វើសកម្មភាពដើម្បីគិតតែពីកេងយកផលចំណេញ និង ដោយផាត់ចេញនូវសហគមន៍ដែលរងការប៉ះពាល់។

## III. ក្របខ័ណ្ឌជាតិ – ច្បាប់ និងនីតិវិធីផ្សេងៗ

១៤. មានការបង្កើតគោលនយោបាយ និងច្បាប់ជាច្រើន ចាប់តាំងពីរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ មកដែលជាការកសាងបន្ថែមលើក្របខ័ណ្ឌច្បាប់ជាតិរឹងមាំ ដែលមានស្រាប់សម្រាប់ការគ្រប់គ្រងដីធ្លី។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបអំពីបញ្ញត្តិច្បាប់សំខាន់ៗទាក់ទងនឹងការផ្តល់សម្បទានដី ក៏ដូចជាស្ថានការណ៍វិវត្តន៍ថ្មីៗ។

### ក. ការគ្រប់គ្រងដីធ្លី៖ ការធ្វើចំណាត់ថ្នាក់ដីធ្លី និងការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ

១៥. ក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ ដីរដ្ឋចែកចេញជាពីរប្រភេទ គឺ ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ការដាក់ឲ្យឃើញពីភាពខុសគ្នានេះ មានសារៈសំខាន់ណាស់ ដោយសារថា ការធ្វើចំណាត់ថ្នាក់ដីរដ្ឋនេះមានជាប់ទាក់ទងទៅនឹងរបៀបប្រើប្រាស់ដី និងអំពីការអភិវឌ្ឍន៍បែបណាខ្លះ ដែលអាចអនុម័តយល់ព្រមឲ្យធ្វើបាននៅលើតំបន់ជាក់លាក់នីមួយៗនេះ។ បើតាមច្បាប់ភូមិបាល មាត្រា១៥ និងអនុក្រឹត្យឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងដីរដ្ឋ ដីសាធារណៈរបស់រដ្ឋ គឺជាដីដែលប្រើប្រាស់សម្រាប់ផលប្រយោជន៍ទូទៅ និងរាប់បញ្ចូលទាំងធនធានធម្មជាតិផងដែរ ដូចជា ព្រៃឈើ ទន្លេ បឹងធម្មជាតិ ដែនបម្រុងធម្មជាតិការពារដោយច្បាប់ បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។ ដីសាធារណៈរបស់រដ្ឋ មិនអាចលក់ដូរ ឬផ្ទេរសិទ្ធិបានឡើយ និងមិនអាចស្ថិតក្រោមកម្មវត្ថុនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬ សម្បទានដីសង្គមកិច្ចឡើយ (ដែលមានពិភាក្សាច្រើនថែមទៀតនៅផ្នែកខាងក្រោម)។[១១] ច្បាប់នេះចែងមិនសូវច្បាស់អំពីថា តើសម្បទានប្រភេទផ្សេងពីនេះអាចផ្តល់បានឬទេ នៅលើដីសាធារណៈរបស់រដ្ឋ ហើយដែលវាជាធម្មតា គម្រោងរុករករ៉ែ និងគម្រោងវារីអគ្គីសនី ទំនងជាស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ ដូចជា ភ្នំ និងទន្លេ ជាដើម។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះចែងច្បាស់ថា កិច្ចសន្យាជួលដីសាធារណៈរបស់រដ្ឋ មិនអាចមានរយៈពេលលើសពី ១៥ (ដប់ប្រាំ) ឆ្នាំឡើយ ហើយរាល់សកម្មភាពនៅលើដីនោះទៀតសោធ មិនត្រូវមានការប៉ះពាល់ ឬ ធ្វើឲ្យផ្លាស់ប្តូរដល់មុខងារ

[១០] សូមមើលរបាយការណ៍របស់សមាគមអាដហុកស្តីពី សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ឆ្នាំ២០១១ ដែលកត់សំគាល់ថា នៅឆ្នាំ២០១១ រាជរដ្ឋាភិបាល បានផ្តល់សម្បទានដីសេដ្ឋកិច្ចប្រមាណជា ២.២៧៦.៣៤៩ហិកតា ទៅឲ្យក្រុមហ៊ុនចំនួន ២២៥។ តែនៅក្នុងឆ្នាំ២០០១ រាជរដ្ឋាភិបាល បានផ្តល់ផ្ទៃដីចំនួន ៧៥១.៨៨២ហិកតា ទៅឲ្យក្រុមហ៊ុនឯកជនសម្រាប់សម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនរុករករ៉ែបានទទួលសម្បទានដីទំហំ ១,៩ លានហិកតា។ យោងតាមផែនទីរបស់អង្គការលីកាដូ មានផ្ទៃដីចំនួន ៣.៩៣៦.៤៨១ហិកតា ត្រូវបានផ្តល់ជាសម្បទានរ៉ែ និងសម្បទានដីសេដ្ឋកិច្ច ដែលគ្របដណ្តប់លើផ្ទៃដី ២២ភាគរយនៃផ្ទៃដីសរុប។ សម្បទានដីសម្រាប់ដំណាំកសិ-ឧស្សាហកម្មសរុបទាំងអស់មាន ២.០៣៦.១៧០ ហិកតា ។

[១១] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា១៥ ។

ដើមរបស់វាឡើយ ឬ ទុកដីនោះចោលក្នុងស្ថានភាពមួយ ដែលមិនបម្រើប្រយោជន៍សាធារណៈឡើយ។[១២] ទោះជាយ៉ាងណាក៏ដោយ ដីឯកជនរបស់រដ្ឋ អាចជាកម្មវត្ថុនៃការលក់ ការដូរ ឬ ការផ្ទេរសិទ្ធិបាន។[១៣]

១៦. ដីសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាដីឯកជនរបស់រដ្ឋ ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងទៀត រាប់ទាំងគោលដៅសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ហើយក៏អាចជាកម្មវត្ថុនៃការជួលរយៈពេលវែងផងដែរ។ ដីសាធារណៈរបស់រដ្ឋ អាចក្លាយទៅជាដីឯកជនរបស់រដ្ឋបាន តែតាមរយៈការធ្វើអនុបយោគផ្លូវការស្របតាម "ច្បាប់ស្តីពីការធ្វើអនុបយោគទ្រព្យសម្បត្តិរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ"។[១៤] ទោះបីជាច្បាប់ភូមិបាល ហាក់តម្រូវឲ្យមានការអនុម័តច្បាប់មួយ ដើម្បីគ្រប់គ្រងលើការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋក្តី ក៏បច្ចុប្បន្ននេះ ការធ្វើអនុបយោគ កំពុងត្រូវបានអនុវត្តតាមនីតិវិធីដែលបានកំណត់ក្នុងព្រះរាជក្រឹត្យ និងអនុក្រឹត្យដែលលិខិតបទដ្ឋានទាំងពីរនេះបានចេញនៅក្នុងឆ្នាំ២០០៦។[១៥]

១៧. នៅក្នុងឆ្នាំ២០០៥ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវបានអនុម័ត ដែលវាកំណត់ក្របខ័ណ្ឌសម្រាប់ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ និងបញ្ចូលបទប្បញ្ញត្តិមួយចំនួន សម្រាប់ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ។[១៦] អនុក្រឹត្យ ក៏បានកំណត់អំពីនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាដីសាធារណៈរបស់រដ្ឋ ឬ ដីឯកជនរបស់រដ្ឋនូវដីរដ្ឋដែលបានចុះបញ្ជីរួចហើយ។ ដំណើរការនេះតម្រូវថា រាល់សំណើសុំធ្វើចំណាត់ថ្នាក់ដីរដ្ឋ ត្រូវតែបានពិនិត្យពិចារណាដោយស្ថាប័នរដ្ឋទាំងឡាយដែលពាក់ព័ន្ធ និងត្រូវធ្វើការបិទផ្សាយជាសាធារណៈ ដើម្បីប្រមូលមតិយោបល់ពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងសង្គមស៊ីវិល។ រាល់ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ត្រូវធ្វើឡើងតាមរយៈអនុក្រឹត្យជាក់លាក់មួយ។[១៧]

១៨. មិនដល់មួយឆ្នាំក្រោយមក នៅក្នុងខែសីហា ឆ្នាំ២០០៦ ព្រះរាជក្រឹត្យមួយត្រូវបានចេញដោយព្រះមហាក្សត្រ[១៨] ដែលព្រះរាជក្រឹត្យនេះ បញ្ជាក់អំពីគោលបំណងច្បាស់លាស់គឺ "កំណត់គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ"។[១៩] ព្រះរាជក្រឹត្យនេះចែងថាដីសាធារណៈរបស់រដ្ឋ អាចធ្វើអនុបយោគបាន លុះត្រាតែបំពេញលក្ខខ័ណ្ឌតម្រូវមួយចំនួន ជាពិសេស គឺដីនោះលែងបម្រើប្រយោជន៍

[១២] អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ មាត្រា ១៨ និង មាត្រា ១៦។

[១៣] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ១៧។

[១៤] ដូចគ្នាខាងលើ មាត្រា ១៦។

[១៥] អនុក្រឹត្យ ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ ជាទូទៅ អនុក្រឹត្យ ពន្យល់អធិប្បាយ ឬ សម្រាប់អនុវត្តដំណើរការផ្លូវច្បាប់មួយដែលមានចែងនៅក្នុងច្បាប់ស្រាប់។ អនុក្រឹត្យ ត្រូវតែស្របទៅតាមរដ្ឋធម្មនុញ្ញ និងអនុលោមតាមច្បាប់ ដែលអនុក្រឹត្យនេះបានយោង ។

[១៦] អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។

[១៧] ដូចគ្នាខាងលើ ជំពូកទី ៥។

[១៨] ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។

[១៩] ដូចគ្នាខាងលើ មាត្រា ១។

សាធារណៈទៀត បានបាត់បង់មុខងារដើមរបស់វា ឬ ដីនោះ មិនត្រូវបានសាធារណៈជនប្រើប្រាស់ដោយផ្ទាល់តទៅទៀត។[២០] បន្ទាប់ពីបានចេញព្រះរាជក្រឹត្យនេះរួចមក មានអនុក្រឹត្យដាច់ដោយឡែកមួយ ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីដែលចែងថា ការធ្វើអនុបយោគណាមួយលើដីសាធារណៈរបស់រដ្ឋ ត្រូវតែអនុវត្តស្របតាមព្រះរាជក្រឹត្យនេះប៉ុន្តែមិនមានចែងលំអិតអំពីនីតិវិធីឡើយ។[២១] វាមិនច្បាស់ទេថាមកដល់ត្រង់ចំណុចនេះ តើព្រះរាជក្រឹត្យ និងអនុក្រឹត្យឆ្នាំ ២០០៦នេះ មានឧត្តមានុភាពលើបទប្បញ្ញត្តិស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ដែលមានចែងក្នុងអនុក្រឹត្យពីពេលមុន គឺអនុក្រឹត្យឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ឬយ៉ាងណា ប៉ុន្តែគួរកត់សំគាល់ថា ច្បាប់ក្រោយនេះ ចែងមិនសូវ លំអិតទេ និងមិនមានបទប្បញ្ញត្តិដែលនិយាយពីការបិទផ្សាយ ឬ ការប្រមូលមតិយោបល់ឡើយ។

១៩. នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានឧទាហរណ៍ជាច្រើននៃដីសាធារណៈរបស់រដ្ឋ ត្រូវបានបង្វែរឲ្យទៅជាដីឯកជនរបស់រដ្ឋ ហើយបន្ទាប់មក ត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឯកជននានាសម្រាប់គោលដៅអភិវឌ្ឍន៍ ដែលបញ្ហានេះមានវិភាគបន្ថែមទៀតនៅផ្នែកទី VI ខាងក្រោម។

## ខ. ច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងលើសម្បទានដី

២០. ច្បាប់ភូមិបាលឆ្នាំ២០០១ អនុញ្ញាតនូវការផ្តល់សម្បទានដីសម្រាប់គោលដៅសេដ្ឋកិច្ច ឬគោលដៅសង្គមកិច្ច។ ច្បាប់ភូមិបាល ក៏ចែងអំពី "សម្បទានប្រភេទផ្សេងទៀត" ដែលអាចអនុញ្ញាតឲ្យផ្តល់សម្រាប់ការប្រើប្រាស់ដី ឬ ការធ្វើអាជីវកម្ម។ នេះរាប់ទាំងវិស័យរ៉ែ[២២] ការនេសាទ[២៣] ការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម[២៤] និង សម្បទានកំពង់ផែ ប៉ុន្តែសម្បទានប្រភេទទាំងនេះ មិនស្ថិតក្នុងវិសាលភាពនៃច្បាប់ភូមិបាលឡើយ។[២៥]

២១. សម្បទានដី មិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានទេ ផ្ទុយទៅវិញ សម្បទានដីត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច មុនការកាន់កាប់ដីនោះ ហើយសម្បទានដីត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលក្រសួងនេះជាអ្នកផ្តល់ "វិញ្ញាបនបត្រសម្គាល់សិទ្ធិជួល

---

[២០] ដូចគ្នាខាងលើ មាត្រា ៣ ។

[២១] អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ មាត្រា ៤០ និង មាត្រា ៤១ ។

[២២] គ្របដណ្តប់ដោយច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០០១ ។

[២៣] គ្របដណ្តប់ដោយច្បាប់ស្តីពី ជលផល ឆ្នាំ២០០៦។

[២៤] ច្បាប់ស្តីពីសម្បទាន ឆ្នាំ២០០៧ គ្រប់គ្រង កិច្ចសន្យាសម្បទាន ទាក់ទងនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យដូចតទៅ៖ (ក)-ការផលិត ការបញ្ជូន និងការចែកចាយ ថាមពលអគ្គិសនី (ខ)-ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធ ដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក (គ)-ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (ឃ)-ហេដ្ឋារចនាសម្ព័ន្ធបំរើឲ្យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន (ង)-ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្ភារៈបម្រើឲ្យគំរោងផ្នែកទេសចរណ៍ មានជាអាទិ៍ រមណីយដ្ឋានទេសចរណ៍ សារមន្ទីរ (ច)-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឲ្យវិស័យឧស្ម័ន និងប្រេង មានជាអាទិ៍ បំពង់បង្ហូរប្រេង និងឧស្ម័ន (ឆ)-ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបូមស្តារ (ជ)-ប្រព្រឹត្តិកម្ម និងគ្រប់គ្រងសំណល់ (ឈ)-ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ និងវិស័យកីឡា (ញ)-ហេដ្ឋារចនាសម្ព័ន្ធ បម្រើឲ្យតំបន់សេដ្ឋកិច្ចពិសេស និងលំនៅដ្ឋានសង្គម (ដ)-ហេដ្ឋារចនាសម្ព័ន្ធបំរើឲ្យប្រព័ន្ធធារាសាស្ត្រ និងការងារកសិកម្ម (ឋ)-វិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយ អនុញ្ញាតិឲ្យមានការផ្តល់នូវសម្បទាន ។

[២៥] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៥០ ។

រយៈពេលវែង" ឬ "វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច" ។[២៦] ដូចបានបរិយាយខាងលើ សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច អាចផ្តល់បានតែនៅលើដីឯកជនរបស់រដ្ឋតែប៉ុណ្ណោះ។[២៧]

២២. សម្បទានដីសង្គមកិច្ច អាចត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋឲ្យដល់គ្រួសារក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន ឬ ធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងផ្តល់ដីលំនៅដ្ឋានដល់យោធិនរំសាយ និង គ្រួសារយុទ្ធជនពលីពិការ។ សម្បទាននេះ ត្រូវបានបញ្ញត្តិដោយអនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច។[២៨] អនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានផ្តល់ឲ្យសម្បទានិក ធ្វើការឈូសឆាយដី ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្ម កសិកម្ម និងកសិ-ឧស្សាហកម្ម។ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានអនុម័តក្នុងខែធ្នូ ឆ្នាំ២០០៥ បញ្ញត្តិអំពីនីតិវិធីផ្តល់សម្បទាន និងផ្តល់មកនូវការវិវឌ្ឍវិកចម្រើនដ៏សំខាន់មួយ ក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ និងបទបញ្ញាសម្រាប់ការផ្តល់ និងការគ្រប់គ្រងសម្បទានប្រភេទនេះ រាប់ទាំងលក្ខខណ្ឌតម្រូវឲ្យធ្វើការពិគ្រោះយោបល់ជាសាធារណៈ និងធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (លក្ខណៈវិនិច្ឆ័យធំៗពីរ ក្នុងចំណោមលក្ខខ័ណវិនិច្ឆ័យធំៗចំនួនប្រាំ មានសរសេរនៅ ក្នុងផ្នែកទី III (គ) ចំណុច ១.៣។[២៩]

២៣. សម្បទានដីសម្រាប់គោលដៅសេដ្ឋកិច្ច រាប់ទាំងចំការឈើដាំ (មានដូចជា កៅស៊ូ ដូងប្រេង ម៉ៃសាក់ ប្រេងខ្យល់ និងដូង) និងកសិ-ឧស្សាហកម្ម" (ផលិតកម្មម្ហូបអាហារទ្រង់ទ្រាយធំ ដូចជា ដំឡូងមី ស្រូវ ពោត និងសណ្តែកសៀង ជាដើម)។[៣០] ក្រោមច្បាប់ភូមិបាល សម្បទានដីសេដ្ឋកិច្ច ផ្តល់សិទ្ធិផ្តាច់មុខឲ្យវិនិយោគិនក្នុងការគ្រប់គ្រង និងប្រមូលផលលើដីនោះ ប៉ុន្តែវាបង្កើតបានត្រឹមតែសិទ្ធិប្រើប្រាស់ដីនោះ ក្នុងអំឡុងពេលមួយដែលបានកំណត់ច្បាស់លាស់ក្នុងកិច្ចសន្យាសម្បទានប៉ុណ្ណោះ។[៣១] ការផ្តល់សម្បទានដីសម្រាប់គោលដៅសេដ្ឋកិច្ច គឺសម្រាប់ជាថ្នូរនឹងការបានមកវិញនូវការវិនិយោគជាក់លាក់ ពន្ធអាករ និងថ្លៃឈ្នួលដី។

២៤. ច្បាប់បានកំណត់ថា សម្បទានដីសេដ្ឋកិច្ច អាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០ (មួយម៉ឺនហិកតា) ហើយការផ្តល់សម្បទានដីច្រើនកន្លែងឲ្យទៅបុគ្គលតែម្នាក់ ឬ ឲ្យនីតិបុគ្គលច្រើន តែគ្រប់គ្រងដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលដដែលៗ ត្រូវបានហាមឃាត់។ (នេះទំនងជាក្នុងគោលបំណងជៀសវាងការប្រើប្រាស់ផ្តាច់មុខតែម្នាក់ឯងនូវធនធានធម្មជាតិ)។ សម្បទានដីសេដ្ឋកិច្ច មានរយៈពេលកំណត់ ៩៩ ឆ្នាំ (កៅសិបប្រាំបួន) ឆ្នាំ យ៉ាងច្រើន។[៣២] កន្លងមករដ្ឋាភិបាលថ្នាក់ខេត្ត-ក្រុង មានសិទ្ធិអំណាចផ្តល់សម្បទានដីទំហំ ១.០០០ (មួយពាន់ហិកតា) ឬ តិចជាងនេះ (នេះបើយោងតាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥)។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ២០០៨ សិទ្ធិអំណាចនេះ

---

[២៦] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៥៣ និង អនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ច មាត្រា ៦។

[២៧] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៥៨។

[២៨] អនុក្រឹត្យ លេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច មាត្រា ២ និង មាត្រា ៣។

[២៩] អនុក្រឹត្យ លេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច មាត្រា ៤ (៣) និង មាត្រា៥ (៥)។

[៣០] សម្បទានដីសេដ្ឋកិច្ចមួយចំនួន បានរាប់បញ្ចូលទាំងសម្ភារៈឧបករណ៍សម្រាប់ការចិញ្ចឹមសត្វ សូមមើលឧទាហរណ៍៖ ក្រុមហ៊ុនវិនិយោគអាគ្រូស្តារ (Agro Star Investment) នៅខេត្តកំពង់ចាម (http://www.elc.maff.gov.kh/en/profile/10-kcm/23-kcm-agrostar.html)

[៣១] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៥២។

[៣២] ដូចគ្នាខាងលើ មាត្រា ៥៩ និង មាត្រា ៦១។

ត្រូវបានដកហូតវិញ ដោយរដ្ឋាភិបាលថ្នាក់កណ្តាល។ បច្ចុប្បន្ន មានតែស្ថានប័នជាតិតែប៉ុណ្ណោះ ដែលមានអំណាចផ្តល់សម្បទានដីសេដ្ឋកិច្ច ទោះជាសម្បទានមានទំហំប៉ុណ្ណាក៏ដោយ។[៣៣] រដ្ឋាភិបាលអាចលុបចោលសម្បទានដីបាន ប្រសិនជាសម្បទានិកមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាសម្បទាន។[៣៤] ម្យ៉ាងវិញទៀត សម្បទានក៏ស្ថិតក្រោមកម្មវត្ថុនៃបញ្ញត្តិរបស់ក្រមរដ្ឋប្បវេណីដែរទាក់ទងនឹងការជួលជាអចិន្ត្រៃយ៍ និងការជួលរយៈពេលវែង។[៣៥]

២៥. អនុក្រឹត្យមួយ ដែលបានចេញក្នុងឆ្នាំ២០០៧ កំណត់អំពីគោលការណ៍ និងលក្ខខណ្ឌតម្រូវក្នុងការផ្តល់សិទ្ធិដល់អ្នកវិនិយោគក្នុងការដាក់បញ្ចាំសម្រាប់ធានា និងការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ច ។[៣៦] អនុក្រឹត្យនេះ ផ្តល់សិទ្ធិឲ្យសម្បទានិក អាចផ្ទេរសម្បទានដីសេដ្ឋកិច្ច ឬ ប្រើប្រាស់វាសម្រាប់ការដាក់បញ្ចាំ[៣៧] ប៉ុន្តែសម្បទានិកមិនអាចផ្ទេរសិទ្ធិ ឬ ដាក់បញ្ចាំ សម្បទានដីសេដ្ឋកិច្ចនោះបានឡើយ ប្រសិនជាដីនោះមិនត្រូវបានអភិវឌ្ឍន៍ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាសម្បទានដើម។[៣៨] បទបញ្ញត្តិនេះ ទំនងជាមានគោលដៅបង្ការឈ្មួញដី ពីការប្រមូលទិញដីទុកលក់យកចំណេញតាមរយៈប្រព័ន្ធសម្បទានដី។ អនុក្រឹត្យនេះចែងថា មានតែអចលនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ ទើបអាចជាកម្មវត្ថុនៃការធ្វើសម្បទានបាន ហើយលុះត្រាតែសម្បទាននេះ ត្រូវបានអនុម័តយល់ព្រមដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ឬ អភិបាលខេត្ត-ក្រុងពាក់ព័ន្ធដែលគ្រប់គ្រងដីនោះ។[៣៩] អនុក្រឹត្យនេះ បានបញ្ជាក់ឡើងវិញផងដែរថា សម្បទានិក មិនអាចក្លាយជាកម្មសិទ្ធិករលើដីនោះបានឡើយ។[៤០]

## គ. បច្ចុប្បន្នភាពនៃនីតិវិធីផ្តល់សម្បទានដី – តួនាទីរបស់តួអង្គរដ្ឋ

### ១.១ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

២៦. ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (ក្រសួងកសិកម្ម) គឺជាស្ថាប័នតែមួយគត់ ដែលមានអំណាចផ្តល់សម្បទានដីសេដ្ឋកិច្ច។ បើយោងតាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច នីតិវិធីសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តួចផ្តើមឡើងតាមរយៈសំណើមានការអំពាវនាវ ដែលអាជ្ញាធររដ្ឋាភិបាលមានសមត្ថកិច្ច ជាអ្នកលើកគម្រោង ដើម្បីអំពាវនាវឲ្យអ្នកវិនិយោគដាក់សំណើ ឬ សំណើមិនមានការអំពាវនាវ ដែលអ្នកវិនិយោគជាអ្នកលើកគម្រោង ។ ទោះជាយ៉ាងណាក៏ដោយ ក៏វិធីសាស្ត្រអាទិភាព សម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺវិធីសាស្ត្រអំពាវនាវ

[៣៣] អនុក្រឹត្យ លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។

[៣៤] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៥៥។

[៣៥] ក្រមរដ្ឋប្បវេណី មាត្រា ៣០៧។

[៣៦] អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ច។

[៣៧] ដូចគ្នាខាងលើ មាត្រា ១។

[៣៨] ដូចគ្នាខាងលើ មាត្រា ៣។

[៣៩] ដូចគ្នាខាងលើ មាត្រា ៥។

[៤០] ដូចគ្នាខាងលើ មាត្រា ៤។

ឲ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង ហើយសំណើមិនមានការអំពាវនាវ អាចត្រូវបានពិចារណាតែក្នុងករណីពិសេស ដែលអ្នកវិនិយោគសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស តាមរយៈការនាំមកនូវបច្ចេកវិទ្យាថ្មី ការរួមចំណែកជាពិសេសទៅសម្បទានដីសង្គមកិច្ច ឬ ផ្តល់លទ្ធភាពក្នុងការរកទីផ្សារកែច្នៃ ឬទី ផ្សារនាំចេញ។[៤១] សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឲ្យតែចំពោះដីដែលបានបំពេញគ្រប់លក្ខណវិនិច្ឆ័យខាងក្រោមនេះ៖[៤២] ដីដែលត្រូវបានចុះបញ្ជី និងបានធ្វើចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ, ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ, និងដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន, ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មី ស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន ដោយអាជ្ញាធរធានាថា មិនមានការបង្ខំឲ្យធ្វើការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និង ត្រូវត្រូវធានាចំពោះការគោរពសិទ្ធិមានមានច្រកចេញចូលទៅកាន់ដីឯកជន, និងដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬ សំណើសម្បទានដីសេដ្ឋកិច្ច ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន។

២៧. អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ក៏បានបង្កើតឡើងផងដែរនូវលេខាធិការដ្ឋានបច្ចេកទេស ដែលតាំងនៅក្រសួងកសិកម្មដែលមានអាណត្តិគាំទ្រដល់អាជ្ញាធរក្នុងការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ រាប់ទាំងលើការអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យាសម្បទាន, ប្រាក់ចំណូល និងថ្លៃប្រើប្រាស់ដី តាមកិច្ចសន្យាសម្បទាន, ការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ចនៅឃុំ/សង្កាត់ ដែលដីសម្បទាននោះស្ថិតនៅ, ស្នើឲ្យមានការធ្វើនិយ័តកម្មដីនោះ[៤៣] និងស្នើឲ្យសម្បទានិក ស្ម័គ្រចិត្តកាត់ផ្ទៃដីដែលមានទំហំលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ។ លេខាធិការដ្ឋានបច្ចេកទេស ក៏ត្រូវតម្រូវឲ្យបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច។[៤៤]

## ១.២ ក្រសួងបរិស្ថាន

២៨. ក្រសួងបរិស្ថាន (MoE) ទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយបរិស្ថាន និងអនុវត្តផែនការសកម្មភាពស្តីពីបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធដទៃទៀត។ ក្រសួងនេះ ដើរតួនាទីសំខាន់ផងដែរក្នុងការអង្កេតពិនិត្យ និងផ្តល់យោបល់ជូនរដ្ឋាភិបាលអំពីផលប៉ះពាល់ដែលអាចមានរបស់គម្រោងវិនិយោគ។ ក្រសួងនេះ ក៏ទទួល

[៤១] អនុក្រឹត្យ លេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច មាត្រា ១៨។

[៤២] ដូចគ្នាខាងលើ មាត្រា ៤។

[៤៣] នេះគឺជាការទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរាប់បញ្ចូលទាំងការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដី ក្នុងតំបន់ត្រួតពិនិត្យឡើងវិញ និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។ អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច មាត្រា ៤២។

[៤៤] ព័ត៌មានត្រូវបានស្នើសុំជាលាយលក្ខអក្សរពីក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ អំពីស្ថានភាពនៃសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច និងអំពីការវិវឌ្ឍន៍រីកចម្រើននៃលេខាធិការដ្ឋានបច្ចេកទេស (រាប់ទាំងព័ត៌មានអំពីការពិនិត្យមើលឡើងវិញ នូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ សម្បទានដីសេដ្ឋកិច្ចណាខ្លះ ដែលមានទំហំលើសពី ១០.០០០ ហិកតា និងសម្បទានដីសេដ្ឋកិច្ចណាខ្លះមានទំហំតិចជាង ១.០០០ ហិកតា) ប៉ុន្តែមិនមានមានការឆ្លើយតបណាមួយត្រូវបានទទួលនោះទេ។ ដូច្នេះ នៅខណៈពេលសរសេររបាយការណ៍នេះ ព័ត៌មានជាផ្លូវការអំពីការវិវឌ្ឍន៍នៃសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច និងការងាររបស់លេខាធិការដ្ឋានបច្ចេកទេស គឺផ្អែកលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ ដែលបច្ចុប្បន្នមានទិន្នន័យត្រឹម ឆ្នាំ២០១០ (លើកលែងតែស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទានដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ គិតត្រឹមថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១២)។

ខុសត្រូវផងដែរ ក្នុងការតាមឃ្លាំមើល និងការធ្វើអធិការកិច្ចលើប្រភពបំពុល និងអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីឲ្យមានការផ្តន្ទាទោសចំពោះការរំលោភច្បាប់ស្តីពីការបំពុលបរិស្ថានរបស់កម្ពុជា។[៤៥]

២៩. ក្រសួងបរិស្ថាន ដើរតួនាទីសំខាន់ក្នុងការអនុម័តយល់ព្រមលើគម្រោងអភិវឌ្ឍន៍ធំៗទាំងអស់ រាប់ទាំងប្រភេទផ្សេងៗនៃសម្បទានដីផងដែរ។ ជាពិសេស ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលចែងថា រាល់គម្រោងអភិវឌ្ឍន៍របស់ឯកជន ឬ សាធារណៈ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[៤៦] ក្រសួងបរិស្ថាន មានភារកិច្ចពិនិត្យ និងវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងធានាឲ្យមានការប្រតិបត្តិតាមការវាយតម្លៃទាំងនេះ។ នេះរាប់ទាំង ការតាមដាន ការឃ្លាំមើលពេញលេញ និងការចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាន ក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង។[៤៧] អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានរាយបញ្ជីគម្រោងគ្រប់ប្រភេទ ដែលតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមមាន ផ្នែកផលិតផលពីឈើ ផ្នែកផលិតក្រដាស វិស័យកសិកម្ម ផ្នែកផលិតផលពីរ៉ែ វារីអគ្គីសនី រោងចក្រអគ្គីសនី វិស័យទេសចរណ៍ និងគម្រោងហេត្ថរចនាសម្ព័ន្ធផ្សេងៗ។[៤៨] ច្បាប់ជាក់លាក់មួយចំនួនទៀត ក៏មានចែងផងដែរថា ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងអនុម័តយល់ព្រមលើគម្រោងសម្បទានណាមួយ។[៤៩]

៣០. ក្រសួងបរិស្ថាន ក៏មានតួនាទីគ្រប់គ្រងតំបន់ការពារធម្មជាតិរបស់កម្ពុជាផងដែរ។[៥០] ដោយសារគម្រោងអភិវឌ្ឍន៍ជាច្រើន ត្រូវបានអនុម័តយល់ព្រមនៅលើតំបន់ដែលស្ថិតនៅក្នុង ឬ នៅជាប់នឹងតំបន់ការពារធម្មជាតិនោះ ដូច្នេះ តួនាទីនេះសំខាន់ណាស់។ ដូចដែលមានពិភាក្សានៅផ្នែកខាងក្រោមនៃរបាយការណ៍នេះ ក្រសួងបរិស្ថាន មានតួនាទីស្នូលក្នុងដំណើរការនៃការកំណត់តំបន់គ្រប់គ្រង ស្ថិតនៅក្នុងតំបន់ការពារ ឲ្យទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដែលអាចបើកតំបន់ទាំងនេះសម្រាប់ការវិនិយោគ និងការអភិវឌ្ឍន៍តាមរយៈសម្បទាន និងការព្រមព្រៀងផ្សេងទៀត។ នៅពេលកំពុងសរសេររបាយការណ៍នេះ ភាពមិនច្បាស់លាស់នៅមាននៅឡើយ អំពីដំណើរការដែលកំពុងអនុវត្ត សម្រាប់ការផ្តល់សម្បទានទាំងនេះ និងអំពីថា តើស្ថាប័នណាជាអ្នកពិនិត្យវាយតម្លៃចុងក្រោយ និងអនុម័តយល់ព្រមលើគម្រោងនោះ។ អនុក្រឹត្យមួយដែលចេញដោយរដ្ឋាភិបាល ក្នុងឆ្នាំ២០០៧ ចែងថា ក្នុងករណីនៃការជួល ដែលផ្តល់ដោយរាជរដ្ឋាភិបាល ហើយដីជាកម្មវត្ថុនៃការជួលនៅពុំទាន់មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅឡើយនោះ កិច្ចសន្យាជួល ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ឬ អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ដែលគ្រប់គ្រងដីនោះ ដែលអាចរាប់បញ្ចូលទាំង រដ្ឋមន្ត្រីក្រសួង

---

[៤៥] អនុក្រឹត្យ លេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ ក្រសួងបរិស្ថាន មាត្រា ៣។

[៤៦] ច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ មាត្រា ៦។

[៤៧] អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

[៤៨] ដូចគ្នាខាងលើ ឧបសម្ព័ន្ធ។

[៤៩] សូមមើលដូចជា អនុក្រឹត្យស្តីពី សម្បទានដីសេដ្ឋកិច្ច មាត្រា ៤ (៣)។ ច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ មាត្រា ២១ (២)។ ច្បាប់ស្តីពី ព្រៃឈើ មាត្រា ៤។

[៥០] ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ មាត្រា ៤។ ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ។

បរិស្ថានផងដែរ កាលណាពាក់ព័ន្ធនិងតំបន់ការពារធម្មជាតិ។[៥១] ទោះជាយ៉ាងណាក៏ដោយ អនុក្រឹត្យនេះ មិនបានចែងលំអិតអំពីថាតើ អាជ្ញាធរមួយណាដែលមានភារកិច្ចពិតប្រាកដ ក្នុងការអនុម័តយល់ព្រមលើកិច្ចសន្យាជួលនេះ ឬ ថាតើត្រូវអនុវត្តតាមនីតិវិធីអ្វីខ្លះ។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ផ្តល់អាណត្តិឲ្យក្រសួងបរិស្ថាន ជាអ្នករៀបចំបង្កើតគណៈកម្មាធិការជាតិ សម្រាប់ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ(NCRPAM) ដែលមាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន ដើម្បីដោះស្រាយទំនាស់ដែលកើតចេញពីគម្រោងវិនិយោគនៅក្នុងតំបន់ការពារធម្មជាតិទាំងនោះ ។[៥២]

## ១.៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ត្រូវបានផ្តល់អាណត្តិឲ្យជួយដល់រដ្ឋាភិបាលក្នុងការណែនាំ និងការគ្រប់គ្រងសេដ្ឋកិច្ច និងក្នុងកិច្ចការហិរញ្ញវត្ថុ រាប់ទាំងការបង្កើតគោលនយោបាយ និងការគ្រប់គ្រងវិនិយោគ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងសមភាពសង្គម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមផងដែរក្នុងការរៀបចំ ការប្រតិបត្តិ និងការតាមឃ្លាំមើលការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមឃ្លាំមើលចំណូលពីថវិកាជាតិ និងគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ។[៥៣] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានផ្តល់អំណាចឲ្យចុះហត្ថលេខាលើកិច្ចសន្យាសម្បទានដីជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត ឬប្រធានស្ថាប័ន ឬ អភិបាលខេត្ត/ក្រុងនានា ដែលជាអជ្ញាធរគ្រប់គ្រងដីដែលពុំទាន់មានវិញ្ញាបនបត្រសម្គាល់សិទ្ធិកាន់កាប់ ស្របតាមលក្ខខណ្ឌកំណត់ជាក់លាក់។[៥៤]

## ១.៤ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៣២. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) មានភារកិច្ចមួយចំនួនក្នុងចំណោមភារកិច្ចដទៃផ្សេងទៀត ក្នុងការចេញអាជ្ញាប័ណ្ណធនធានរ៉ែ។ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០០១ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានភារកិច្ចគ្រប់គ្រង និងពិនិត្យលើប្រតិបត្តិការរុករករ៉ែទាំងអស់ ដើម្បីធានាការអនុវត្តស្របតាមច្បាប់នេះ។[៥៥] អាជ្ញាប័ណ្ណធនធានរ៉ែ រួមមាន ៦ ប្រភេទគឺៈ អាជ្ញាប័ណ្ណសិប្បកម្ម ធនធានរ៉ែ[៥៦] អាជ្ញាប័ណ្ណ

[៥១] អនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ជាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ច មាត្រា ៥ ចែងថា "មានតែអចលនវត្ថុដែលបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ ទើបអាចដាក់ជាកម្មវត្ថុនៃការធ្វើសម្បទាន ឬការជួលរយៈពេលវែងបាន។ ក្នុងករណីនៃការជួលដែលផ្តល់ដោយរាជរដ្ឋាភិបាល ហើយដីជាកម្មវត្ថុនៃការជួល នៅពុំទាន់មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុទេ ឬ បណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនៅឡើយនោះ កិច្ចសន្យាជួល ត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ឬ អភិបាលខេត្តក្រុងពាក់ព័ន្ធ ដែលជាអាជ្ញាធរគ្រប់គ្រងដីនោះ"។

[៥២] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ មាត្រា ២០។

[៥៣] អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[៥៤] អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ជាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ច មាត្រា ៥។

[៥៥] ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ ឆ្នាំ ២០០១ មាត្រា ១៥។

អណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ[៥៧] អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ អាជ្ញាប័ណ្ណស្វែងរុករក អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។[៥៨] ដើម្បីបានអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្រុមហ៊ុនត្រូវតែបង្ហាញថា ខ្លួនមានលទ្ធភាពគ្រប់គ្រាន់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីប្រតិបត្តិការគម្រោងនោះ។ អ្នកដាក់ពាក្យសុំ ក៏ត្រូវអនុវត្តតាមការកំណត់មួយចំនួនផងដែរ ដូចជា៖ ការសិក្សាអំពីសមិទ្ធិលទ្ធភាព និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការបង្កើតគម្រោងការពារសុខភាព និងសុវត្ថិភាពដល់កម្មករ ការបង្កើតគម្រោងអប់រំ បណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ និងការរៀបចំគម្រោងសម្រាប់ ការបិទបញ្ចប់ប្រតិបត្តិការ (ឬ បិទសកម្មភាពគម្រោង) ស្វែងរុករករ៉ែ ហើយនិងការស្តារបរិស្ថានដែលប៉ះពាល់នៅជុំវិញ តំបន់អណ្តូងរ៉ែនោះឡើងវិញ។[៥៩]

## ១.៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣៣. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ត្រូវបានបង្កើតឡើង ដោយច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤ ដែលផ្តល់អំណាចឲ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ចខ្ពស់បំផុត ក្នុងការពិនិត្យសម្រេចលើការវិនិយោគវិស័យឯកជន និងវិស័យសាធារណៈនៅកម្ពុជា។[៦០] ក្រុមប្រឹក្សានេះ មានសមាសភាពនាយករដ្ឋមន្ត្រី ជាប្រធាន និងមានទេសរដ្ឋមន្ត្រីទាំងឡាយមកពីក្រសួងស្ថាប័នពាក់ព័ន្ធនានា។[៦១] គណៈកម្មាធិការវិនិយោគកម្ពុជា និង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា គឺជាសេនាធិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ការវិនិយោគវិស័យឯកជន ពិនិត្យលើគម្រោងវិនិយោគនៅក្នុង និងនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសរៀងៗខ្លួន។ គណៈកម្មាធិការទាំងពីរនេះ មានភារកិច្ចពិនិត្យសំណើវិនិយោគ រាប់ទាំងសំណើសម្បទានដី និងផ្តល់ឲ្យមាននូវការលើកទឹកចិត្តដល់គម្រោងវិនិយោគទាំងឡាយណាដែលបំពេញបានតាមលក្ខខណ្ឌតម្រូវ ដែលបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤។ អនុក្រឹត្យស្តីពីការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចែងថា រាល់ការវិនិយោគដែលមានទំហំទុនវិនិយោគច្រើនជាង ៥០លាន ដុល្លារអាមេរិច ត្រូវតែបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រី ហើយ

---

[៥៦] ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ត្រូវបានដំណើរការទៅតាមរយៈ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងតំបន់ ដែលអាជ្ញាប័ណ្ណនោះស្ថិតនៅ (មាត្រា ១៤ នៃច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ )។

[៥៧] អាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ផ្តល់ឲ្យក្រុមហ៊ុននូវសិទ្ធិស្វែងរុករកធនធានរ៉ែ សំណង់ មានជាអាទិ៍ខ្សាច់ ក្រួស ថ្មសំណង់ ឡាតេរីត ស៊ីម៉ង់ ដីឥដ្ឋ ថ្មកំបោរ និងថ្មម៉ាប (មាត្រា ១១(២) នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ)។ ការអនុញ្ញាតិឲ្យបូមខ្សាច់ពីស្ទឹង និងសមុទ្រ ក៏ត្រូវបានផ្តល់ឲ្យផងដែរ តាមរយៈអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម។ អាជ្ញាប័ណ្ណអាជីកម្មរ៉ែត្បូងថ្មមានតម្លៃ ផ្តល់ឲ្យក្រុមហ៊ុននូវសិទ្ធិស្វែងរុករករ៉ែត្បូងថ្មមានតម្លៃ មានជាអាទិ៍ ពេជ្រ ត្បូងទទឹម ត្បូងកណ្តៀង និងរ៉ែត្បូងថ្មមានតម្លៃទាំងឡាយផ្សេងទៀត។ អាជ្ញាប័ណ្ណទាំងពីរប្រភេទនេះ គ្របដណ្តប់ទាំងលើការស្វែងរុករក និងការធ្វើអាជីវកម្ម ព្រមទាំងតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានផងដែរ។

[៥៨] ចំពោះក្រុមហ៊ុនដែលស្វែងរុករកធនធានរ៉ែមានតម្លៃ មានជាអាទិ៍ រ៉ែមាស ឬ រ៉ែបុកស៊ីត ជាលក្ខណៈឧស្សាហកម្ម ត្រូវតែទទួលបាននូវអាជ្ញាប័ណ្ណចំនួនពីរសំខាន់ គឺអាជ្ញាប័ណ្ណស្វែងរុករក (ដែលផ្តល់សិទ្ធិឲ្យក្រុមហ៊ុនធ្វើការស្វែងរុករកធនធានរ៉ែ) និងអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ (ដែលផ្តល់សិទ្ធិឲ្យក្រុមហ៊ុនចាប់ផ្តើមស្វែងរុករកធនធានរ៉ែមានតម្លៃជាលក្ខណៈឧស្សាហកម្ម)។ ដើម្បីដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ជាបឋម ក្រុមហ៊ុនត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដែលជាស្ថាប័នទទួលបន្ទុកក្នុងការពិនិត្យ និងអនុម័តយល់ព្រមលើគម្រោងអភិវឌ្ឍន៍សំខាន់ៗ។ បន្ទាប់ពីមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) នឹងចេញអាជ្ញាប័ណ្ណឲ្យក្រុមហ៊ុននោះ។

[៥៩] ច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ ឆ្នាំ២០០១ មាត្រា ១១(៦) និង មាត្រា ២១។

[៦០] ច្បាប់ស្តីពី វិនិយោគ ឆ្នាំ១៩៩៤ មាត្រា ៣ និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី វិនិយោគ ឆ្នាំ២០០៣។

[៦១] អនុក្រឹត្យ លេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាត្រា ១។

ដែលអនុវត្តដូចគ្នានេះដែរ ចំពោះគម្រោងរុករក និងការធ្វើអាជីវកម្មធនធានរ៉ែ និងធនធានធម្មជាតិ គម្រោងដែលអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន និងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។[៦២] ដូច្នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ និងការអនុម័តយល់ព្រមលើគម្រោងវិនិយោគសម្បទានដី។

## ១.៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣៤. ច្បាប់ភូមិបាលឆ្នាំ២០០១ បានកំណត់ថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ជាអង្គភាពដែលមានភារកិច្ចចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងគ្រប់គ្រងរដ្ឋបាលសុរិយោដីលើដីគ្រប់ប្រភេទ រាប់ទាំងដីរបស់រដ្ឋដែលរាប់បញ្ចូលទាំង ដីឯកជនរបស់រដ្ឋដែលអាចត្រូវបានផ្តល់សម្បទាន។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចធ្វើនិយ័តកម្មដី នៅពេលមានការស្នើសុំពីលេខាធិការដ្ឋានបច្ចេកទេសសម្បទានសេដ្ឋកិច្ច ។ នេះរាប់ទាំង ការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដី ក្នុងតំបន់មានការត្រួតពិនិត្យឡើងវិញ ការវាស់វែង និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។ សម្បទានដី ឬ ការជួលរយៈពេលវែង ត្រូវធ្វើលេខាចារឹក នៅលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ លើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និងក្រសួងនេះ ត្រូវចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង ឬ វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ។[៦៣] រហូតមកទល់ពេលនេះ ក្រសួងនេះ បានចុះបញ្ជីសម្បទានដីសេដ្ឋកិច្ចបានចំនួន ១៨ ទីតាំងហើយ ដែលមានផ្ទៃដីសរុប ១០១.០០០ ហិកតា។[៦៤]

# ឃ. អន្តរកម្មជាមួយច្បាប់ និងបទប្បញ្ញត្តិដទៃទៀត ដែលគ្រប់គ្រប់លើសម្បទានដី

## ១.១ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

៣៥. ក្នុងឆ្នាំ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ បានកំណត់តំបន់ការពារធម្មជាតិចំនួន ២៣ កន្លែង។ អនុក្រឹត្យចេញពេលក្រោយមកទៀត បានបន្ថែមតំបន់មួយចំនួនទៀត ទៅក្នុងបញ្ជីតំបន់ការពារធម្មជាតិរបស់កម្ពុជា និងបានកែសម្រួលទំហំតំបន់ការពារធម្មជាតិទាំង ២៣ ខាងដើម។ បច្ចុប្បន្ននេះ មិនទាន់មានជាសាធារណៈទេនូវបញ្ជីតំបន់ការពារធម្មជាតិ និងព្រំប្រទល់នៃតំបន់ទាំងនោះ។ ព្រះរាជក្រឹត្យ ឆ្នាំ១៩៩៣ បែងចែកតំបន់ការពារធម្មជាតិជាបួនប្រភេទផ្សេងគ្នាគឺ តំបន់ឧទ្យានធម្មជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ទទួលរងនូវការប្រើប្រាស់ច្រើនមុខ។

[៦២] ដូចគ្នាខាងលើ មាត្រា ១១។

[៦៣] អនុក្រឹត្យ លេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី សម្បទានដីសេដ្ឋកិច្ច មាត្រា ៤ (១) ចែងថា មុនពេលផ្តល់ដីសម្បទានសេដ្ឋកិច្ច ដីនោះត្រូវតែបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពី ការគ្រប់គ្រងដីរដ្ឋ និង អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី ឬ អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។ មាត្រា ២ នៃអនុក្រឹត្យស្តីពី ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ បានផ្តល់តួនាទីឲ្យអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវការណែនាំ សម្របសម្រួល និងពិនិត្យតាមដានការអនុវត្តអនុក្រឹត្យនេះ ។ សូមមើលផងដែរ អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០០៧ ស្តីពី ការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬ សិទ្ធិលើសម្បទានដីសេដ្ឋកិច្ច មាត្រា ៦។

[៦៤] លិខិតលេខ ៥៥៦ ជនស/អកគជ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឆ្លើយតបនឹងលិខិតស្នើសុំរបស់អ្នករាយការណ៍ពិសេស ទាក់ទងនឹងដីសម្បទាននៅក្នុងប្រទេសកម្ពុជា។

៣៦. ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ចូលជាធរមានក្នុងខែមករា ឆ្នាំ២០០៨ ដែលច្បាប់នេះ កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ។[៦៥] តំបន់ការពារធម្មជាតិបួនប្រភេទខាងដើម ត្រូវបានពង្រីកបន្ថែម ដែលបច្ចុប្បន្ននេះរួមមាន៖[៦៦] តំបន់ឧទ្យានជាតិ[៦៧] តំបន់ដែនជម្រកសត្វព្រៃ[៦៨] តំបន់ការពារទេសភាព[៦៩] តំបន់ប្រើប្រាស់ច្រើនយ៉ាង[៧០] តំបន់រ៉ាមសារ[៧១] តំបន់ស្នូលនៃបបនីយជីវមណ្ឌល[៧២] តំបន់បេតិកភណ្ឌជាតិ[៧៣] តំបន់ឧទ្យានជាតិសមុទ្រ[៧៤] ដែលបានកំណត់ដោយច្បាប់ពីមុនស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន។[៧៥]

---

[៦៥] ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ មាត្រា ១។

[៦៦] ដូចគ្នាខាងលើ មាត្រា ៧។

[៦៧] តំបន់ឧទ្យានជាតិ ជាតំបន់អភិរក្សសម្រាប់ធម្មជាតិ និងសម្រាប់ទស្សនីយភាពទេសភាព និងត្រូវបានការពារសំរាប់គោលដៅវិទ្យាសាស្ត្រ ការអប់រំ និង ការកំសាន្ត រាប់បញ្ចូលទាំង៖ ឧទ្យានជាតិបុទុមសាគរ (ខេត្តកោះកុង ទំហំ ១៧១.២៥០ ហិកតា) ឧទ្យានជាតិគិរីរម្យ (ខេត្តកំពង់ស្ពឺ និង កោះកុង ទំហំ ៣៥.០០០ ហិកតា) ឧទ្យានជាតិបូកគោ (ខេត្តកំពត ទំហំ ១៤០.០០០ ហិកតា) ឧទ្យានជាតិកែប (ខេត្តកែប ទំហំ ៥.០០០ ហិកតា) ឧទ្យានជាតិរាម (ខេត្តព្រះសីហនុ ទំហំ ១៧១.២៥០ ហិកតា) ឧទ្យានជាតិភ្នំគូលែន (ខេត្តសៀមរាប ទំហំ ៣៧.៥០០ ហិកតា) ឧទ្យានជាតិវីរៈជ័យ (ខេត្តរតនៈគិរី ទំហំ ៣៣២.៥០០ ហិកតា)។

[៦៨] តំបន់ដែនជម្រកសត្វព្រៃ ជាដែនធម្មជាតិដែលធានានូវលក្ខខណ្ឌធម្មជាតិចាំបាច់សម្រាប់ការការពារប្រភេទសត្វព្រៃ រុក្ខជាតិ និង បរិស្ថានភូមិសាស្ត្រ មានដូចជា៖ ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (ខេត្តកោះកុង ពោធិសាត់ និង កំពង់ឆ្នាំង ទំហំ ២៥៣.៧៥០ ហិកតា) ពាមក្រសោប (ខេត្តកោះកុង ទំហំ ២៣.៧៥០ ហិកតា) ដែនជម្រកសត្វព្រៃភ្នំសំកុស (ខេត្តកោះកុង ទំហំ ៣៣៣.៧៥០ ហិកតា) ដែនជម្រកសត្វព្រៃរនាមដូនសំ (ខេត្តបាត់ដំបង ទំហំ ១៧៨.៧៥០ ហិកតា) ដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព (ខេត្តសៀមរាប និងខេត្តព្រះវិហារ ទំហំ ៤០២.៥០០ ហិកតា) ដែនជម្រកសត្វព្រៃបឹងពែរ (ខេត្តកំពង់ធំ ទំហំ ២៤២.៥០០ ហិកតា) ដែនជម្រកសត្វព្រៃលំផាត់ (ខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី ទំហំ ២៥០.០០០ ហិកតា) ដែនជម្រកសត្វព្រៃភ្នំព្រេច (ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ទំហំ ២២២.៥០០ ហិកតា) ដែនជម្រកសត្វព្រៃភ្នំណាមលៀរ (ខេត្តមណ្ឌលគិរី ទំហំ ៤៧.៥០០ ហិកតា) ដែនជម្រកសត្វព្រៃស្នួល (ខេត្តក្រចេះ ទំហំ ៧៥.០០០ ហិកតា)។

[៦៩] តំបន់ការពារទេសភាព ជាតំបន់ដែលត្រូវថែទាំទេសភាពធម្មជាតិ សំរាប់រម្មណីយដ្ឋានកំសាន្ត និងទេសចរណ៍ ដែលរួមមាន៖ តំបន់អង្គរ (ខេត្តសៀមរាប ទំហំ ១០.៨០០ ហិកតា) បន្ទាយឆ្មារ (ខេត្តបន្ទាយមានជ័យ ទំហំ ៨១.២០០ ហិកតា) ព្រះវិហារ (ខេត្តព្រះវិហារ ទំហំ ៥.០០០ ហិកតា)។

[៧០] តំបន់ប្រើប្រាស់ច្រើនយ៉ាង គឺជាតំបន់ដែលចាំបាច់សម្រាប់ភាពស្ថិតស្ថេរនៃ ប្រភពទឹក ព្រៃឈើ សត្វព្រៃ និង ត្រី និងសម្រាប់ការកំសាន្ត ព្រមទាំងសម្រាប់ការអភិរក្សធម្មជាតិ ក្នុងគោលដៅធានាការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលមានដូចជា៖ ដងពែង (ខេត្តកោះកុង ទំហំ ២៧.៧០០ ហិកតា) សំឡូត (ខេត្ត បាត់ដំបង ទំហំ ៦០.០០០ ហិកតា) ទន្លេសាប (ខេត្តកំពង់ឆ្នាំង កំពង់ធំ សៀមរាប បាត់ដំបង និង ពោធិសាត់ ទំហំ ៣១៦.២៥០ ហិកតា)។

[៧១] យោងតាមអនុសញ្ញារ៉ាមសា (អនុសញ្ញាស្តីពីសារៈសំខាន់ជាលក្ខណៈអន្តរជាតិនៃតំបន់ដីសើម) តំបន់រ៉ាមសា សំដៅដល់តំបន់ដីសើម ដែលគេចាត់ទុកថាជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬ ជីវៈចម្រុះ ជាពិសេសតំបន់ដែលបម្រើជាទីជម្រកសម្រាប់ពពួកសត្វស្លាបទឹក ដែលរងការគម្រាមកំហែង។ ឧទាហរណ៍៖ ទន្លេសាប និង បឹងឆ្មារ ត្រូវបានរាប់បញ្ចូលនៅក្នុងបញ្ជីសារៈសំខាន់ជាលក្ខណៈអន្តរជាតិនៃតំបន់ដីសើម ("បញ្ជីរ៉ាមសា") នៅក្នុងអនុសញ្ញាស្តីពីសារៈសំខាន់ជាលក្ខណៈអន្តរជាតិនៃតំបន់ដីសើម (រ៉ាមសា ប្រទេសអៀរ៉ង់ ឆ្នាំ១៩៧១)។

[៧២] តំបន់ឋបនីយជីវមណ្ឌល សំដៅដល់តំបន់តំណាងឲ្យប្រព័ន្ធអេកូឡូស៊ី ដែលមានសារៈសំខាន់ និងពុំរងនូវការខូចខាតខ្លាំង ហើយព័ទ្ធជុំវិញដោយតំបន់ប្រើប្រាស់ដោយចីរភាព ដែលអនុញ្ញាតិឲ្យមានសកម្មភាពមនុស្សក្នុងកម្រិតមួយជាកំណត់។ តំបន់នេះ ត្រូវបានបង្កើតឡើងដើម្បី ១)-អភិរក្សជីវចម្រុះ ទេសភាព សណ្ឋានដី និងប្រព័ន្ធអេកូឡូស៊ី រាប់បញ្ចូលទាំងធនធានសេនេទិច ប្រភេទរុក្ខជាតិ ត្រី និងសត្វ ព្រមទាំងស្តារឡើងវិញនូវបរិស្ថាន ជីវសាស្ត្រ និង ទីជម្រក ២)-គាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍន៍ខាងផ្នែកអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គម និង វប្បធម៌ ៣)-គាំទ្រចំពោះសកម្មភាពនានា រាប់ទាំងការអនុវត្តគម្រោងនៃការណែនាំបង្ហាញ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអង្កេត ដើម្បីតាមដានអំពីបម្រែបម្រួលបរិស្ថាន នៅក្នុងទំនាក់ទំនងជាមួយនឹងការអភិរក្ស និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ តំបន់ឋបនីយជីវមណ្ឌល ទន្លេសាប ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ ដែលគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ១.៤៨១.២៥៧ ហិកតា និង មានតំបន់ស្នូលចំនួនបី (ទំហំ ៧០.៨៣៧ ហិកតា) និងតំបន់ទ្រនាប់មួយ (ទំហំ ៥១០.៧៦៨ ហិកតា)។

[៧៣] តំបន់បេតិកភណ្ឌធម្មជាតិ សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬ ដែនទឹកដែលមានលក្ខណៈពិសេសពីធម្មជាតិ ឬពាក់កណ្តាលកែច្នៃធម្មជាតិ និងមានតម្លៃលេចធ្លោ ឬប្លែកពីគេ ដោយសារតំបន់នោះមានដោយកម្រ មានគុណភាពជាតំណាងឲ្យប្រព័ន្ធធម្មជាតិនានា ឬ មានគុណភាពខាងផ្នែក

៣៧. ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ បានកំណត់ផងដែរអំពីប្រព័ន្ធថ្មីនៃតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិនីមួយៗ ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ។[៧៦] ច្បាប់នេះ ចែងថា តំបន់ការពារធម្មជាតិនីមួយៗ បែងចែកជាបួន(៤)តំបន់គ្រប់គ្រង គឺ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ មិនអនុញ្ញាតឲ្យមានការកាប់ឆ្ការឈូសឆាយ ឬ ការសាងសង់នៅក្នុងតំបន់ស្នូល ឬ តំបន់អភិរក្សឡើយ ហើយការអភិវឌ្ឍនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ឬ តំបន់សហគមន៍ អាចអនុញ្ញាតបានតែដោយមានការអនុម័តយល់ព្រមពីរដ្ឋាភិបាល តាមការស្នើសុំរបស់ក្រសួងបរិស្ថាន។[៧៧] ការអភិវឌ្ឍណាមួយនៅក្នុងតំបន់ទាំងនេះ ឬ នៅក្នុងតំបន់ជិតខាងតំបន់ការពារធម្មជាតិ ត្រូវតែមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុនសិន។[៧៨] នៅក្នុងរយៈកាលប៉ុន្មានឆ្នាំថ្មីៗនេះ រដ្ឋាភិបាល បានចេញអនុក្រឹត្យជាច្រើន ដោយមានការយល់ព្រមពីក្រសួងបរិស្ថាន ធ្វើការកំណត់ផ្ទៃដីនៅក្នុងតំបន់ការពារធម្មជាតិឲ្យទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុម័តយល់ព្រមលើគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់ទាំងនោះ ដែលជាទូទៅគឺសម្រាប់គោលដៅកសិ-ឧស្សាហកម្ម (មានពិភាក្សាបន្តនៅផ្នែកទី IV (គ))។

៣៨. ច្បាប់នេះកំណត់នូវលក្ខខណ្ឌសម្រាប់ ការបង្កើត ឬ ការរៀបចំកែប្រែ តំបន់ការពារធម្មជាតិណាមួយ និងចែងថា ការសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ[៧៩] ប៉ុន្តែការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រងបែងចែកនីមួយៗ អាចធ្វើទៅបាន អាស្រ័យដោយមានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់អំពីប្រព័ន្ធអេកូឡូស៊ី ដែលមានការប្រែប្រួល ឬ មានការគម្រាមកំហែង និងត្រូវតែអនុលោមតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។[៨០]

---

សោភ័ណភាព ឬ សារៈសំខាន់ខាងផ្នែកវប្បធម៌។ តំបន់នេះ ត្រូវបានបង្កើតឡើងដើម្បី ១)-ការពារ និងធានានូវនិរន្តរភាពនៃមជ្ឈដ្ឋានធម្មជាតិ ដោយសារតែសារៈសំខាន់ពីធម្មជាតិរបស់វា ភាពប្លែក(មានតែមួយ) និងភាពតំណាងឲ្យប្រព័ន្ធអេកូឡូស៊ី ព្រមទាំងសារៈសំខាន់របស់វាក្នុងជំនួយផ្នែកចិត្តវិទ្យា ឬ សារៈសំខាន់ដែលបានមកពីការប្រមូលផ្តុំនូវកត្តាទាំងនេះ ២)-ផ្តល់កាលានុវត្តភាពសម្រាប់ការស្រាវជ្រាវ ការអប់រំ ការពន្យល់អំពីធម្មជាតិ ព្រមទាំងការចូលរួមជាសាធារណៈនៅក្នុងកម្រិត ដែលអាចធានាភាពស្របគ្នាជាមួយនឹងចំនុចទី១ ខាងលើ ៣)-បំបាត់ និងទប់ស្កាត់ការប្រើប្រាស់ និងការកាន់កាប់ណាដែលមិនស្ថិតនៅក្នុងបន្ទាត់តែមួយ ឬ ធ្វើឲ្យអន្តរាយដល់គោលដៅនៃការបង្កើតតំបន់ការពារធម្មជាតិ ៤)-ផ្តល់ឲ្យប្រជាពលរដ្ឋដែលរស់នៅ ក្នុងតំបន់បេតិកភ័ណ្ឌធម្មជាតិនូវអត្ថប្រយោជន៍ (ប្រសិនជាមាន) នៅក្នុងកម្រិតមួយដែលធានាភាពស្របគ្នា ជាមួយនឹងគោលដៅនៃការគ្រប់គ្រងដទៃទៀត។

[៧៤] តំបន់ឧទ្យានជាតិសមុទ្រ សំដៅដល់តំបន់ឆ្នេរសមុទ្រដែលទទួលឥទ្ធិពលជំនោរសមុទ្រ លាយឡំជាមួយនឹងទឹកពីព្រៃភ្នំ រួមទាំង កោះគ្របដណ្តប់ដោយព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងមច្ឆាជាតិគ្រប់ប្រភេទ មានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ។ តំបន់ឧទ្យានជាតិសមុទ្រ ត្រូវបានបង្កើតឡើងដើម្បី ១)-ថែរក្សា និងការពារធនធានសមុទ្រ និងមុខងាររបស់ព្រៃឈើ ២)-ថែរក្សា និងការពារគុណភាពនៃបរិស្ថានសមុទ្រសម្រាប់រយៈពេលវែង ៣)-ថែរក្សា និងការពារតំបន់ប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ព្រមទាំង បុព្វសិទ្ធិធម្មជាតិរបស់សមុទ្រ ៤)-ផ្តល់កាលានុវត្តភាពសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ ការអប់រំ ការបង្កើតថ្មី និងអេកូទេសចរណ៍សមុទ្រ។

[៧៥] តំបន់ការពារធម្មជាតិ ត្រូវបានកំណត់និយមន័យពីមុនដោយបញ្ញត្តិនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ និងព្រះរាជក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០១។

[៧៦] ច្បាប់ស្តីពី តំបន់កាពារធម្មជាតិ ឆ្នាំ២០០៨ ជំពូកទី៤។

[៧៧] ដូចគ្នាខាងលើ មាត្រា ៣៦។

[៧៨] ដូចគ្នាខាងលើ មាត្រា ៤៤។

[៧៩] ដូចគ្នាខាងលើ មាត្រា ៨។

[៨០] ដូចគ្នាខាងលើ មាត្រា ១៣។

ក្រសួងបរិស្ថាន ទទួលបន្ទុករៀបចំធ្វើផែនទីតំបន់ការពារធម្មជាតិ ដោយមានការចូលរួមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងស្ថានប័នពាក់ព័ន្ធ។[៨១]

៣៩. ជំពូកទី ៦ នៃច្បាប់នេះ ចែងអំពីការចូលរួម និងសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច និងបញ្ជាក់ថា រដ្ឋទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនារបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុង និងជាប់តំបន់ការពារធម្មជាតិ។ ច្បាប់នេះកំណត់ភារកិច្ចឲ្យក្រសួងបរិស្ថានមានសិទ្ធិប្រគល់ដីផ្នែកណាមួយឲ្យទៅសហគមន៍ដែលរស់នៅក្នុង និងជាប់តំបន់ការពារធម្មជាតិ ដើម្បីរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ។[៨២] គិតមកទល់ចុងឆ្នាំ២០១១ ក្រសួងបរិស្ថានបង្កើតសហគមន៍តំបន់ការពារធម្មជាតិបានចំនួន ១០២ សហគមន៍ ដែលក្នុងនេះ មានទាំងសហគមន៍របស់ជនជាតិដើមភាគតិចចំនួន ២៣ ផងដែរ។[៨៣]

## ១.២ ច្បាប់ស្តីពីព្រៃឈើ

៤០. ច្បាប់ស្តីពីព្រៃឈើ អនុញ្ញាតឲ្យផ្តល់សម្បទានព្រៃ។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីខែមករា ឆ្នាំ២០០២ មក មានការដាក់ចេញនូវវិធានការផ្អាកការកាប់ឈើជាបណ្តោះអាសន្ន នៅក្នុងតំបន់ព្រៃសម្បទាន។[៨៤] លោកនាយករដ្ឋមន្ត្រី បានថ្លែងនៅក្នុងខែមិថុនា ឆ្នាំ២០១២ ថា វិធានការនេះនៅតែបន្តអនុវត្ត។[៨៥] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងព្រៃសម្បទាន ចែងថា ព្រៃសម្បទានដែលត្រូវបានដកហូត ឬ ប្រគល់មកវិញកន្លងមក ត្រូវរក្សាទុកជាតំបន់ព្រៃការពារធម្មជាតិ និងមិនអាចបង្វែរទៅជាសម្បទានដីសេដ្ឋកិច្ច ឬ ផ្តល់ទៅឲ្យក្រុមហ៊ុនណាផ្សេងទៀតបានឡើយ។ ច្បាប់ស្តីពី ព្រៃឈើ មាត្រា២៩ ហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រមានតម្លៃ ឬ ប្រភេទឈើដែល ប្រជាជនមូលដ្ឋានចោះយកជ័រ តាមប្រពៃណី។ ជំពូកទី៩ នៃច្បាប់នេះ ទទួលស្គាល់ និង ធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ក្នុងការប្រមូល និងការប្រើប្រាស់អនុផលព្រៃឈើ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីនេះ រួមមាន ការច្រូតយកស្មៅ ឬ លែងសត្វពាហនៈឲ្យស៊ីស្មៅក្នុងព្រៃ និងសិទ្ធិដោះដូរ ឬ លក់អនុផលព្រៃឈើ។ ជំពូកទី៩ នៃច្បាប់នេះ ក៏អនុញ្ញាតឲ្យរក្សាទុកផ្នែកណាមួយនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ជាព្រៃសហគមន៍ផ្តល់ឲ្យ សហគមន៍មូលដ្ឋានរស់នៅក្នុង ឬ ក្បែរដែនព្រៃនោះនូវសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃប្រកបដោយចីរភាព។ គិតត្រឹមខែធ្នូ ឆ្នាំ២០១១ តំបន់ព្រៃសហគមន៍សរុបចំនួន២៨១ កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីព្រៃសរុប ២៤៤.២៦៥ ហិកតា ស្ថិតក្នុងខេត្តចំនួន១៨ ត្រូវបានស្គាល់

---

[៨១] ដូចគ្នាខាងលើ មាត្រា ១៤។

[៨២] ដូចគ្នាខាងលើ មាត្រា ២៥។

[៨៣] ព័ត៌មានទទួលបាន អំឡុងពេលកិច្ចប្រជុំ ខែឧសភា ឆ្នាំ ២០១២ ជាមួយនឹងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ យោងតាមប្រសាសន៍របស់លោករដ្ឋមន្ត្រី នៅក្នុងចំណោមសហគមន៍តំបន់ការពារធម្មជាតិចំនួន ១០២ មាន ១៩៧ ភូមិ ដែលមានការចូលរួមពីប្រជាពលរដ្ឋចំនួន ២៤.៨៨៧ គ្រួសារ។ ហើយនៅក្នុងចំណោម ១០២ សហគមន៍នេះ មានសហគមន៍ចំនួន ២៣ ឬ ៤.៤៤៩ គ្រួសារ ជាជនជាតិដើមភាគតិច។

[៨៤] នៅខែមករា ឆ្នាំ២០០២ លោកនាយករដ្ឋមន្ត្រី បានប្រកាសអំពីការផ្អាកការកាប់ឈើ ដែលស្របជាមួយនឹងសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពី គោលនយោបាយជាតិលើវិស័យព្រៃឈើ ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០២។ សូមមើលគេហទំព័រៈ http://www.forestry.gov.kh/Law/ForestPolicy.html.

[៨៥] សន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០១១ ស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣។

ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ។[៨៦]

## ១.៣ ច្បាប់ស្តីពីបរិស្ថាន

៤១. ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ តម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈ។[៨៧] ក្រសួងពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថាន មុននឹងចេញសេចក្តីសម្រេចនានា ឬ ធ្វើសកម្មភាពផ្សេងៗទាក់ទិនដល់ការអភិរក្ស ការអភិវឌ្ឍន៍ ឬ ការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ។[៨៨] ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ និងផ្តល់យោបល់ជូនក្រសួងពាក់ព័ន្ធ ដើម្បីធានាឲ្យធនធានធម្មជាតិត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។[៨៩]

៤២. អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩ កំណត់បន្ថែមទៀតអំពីនីតិវិធីសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោង ឬ សកម្មភាពរបស់ឯកជន ឬ សាធារណៈគ្រប់ប្រភេទ ឬ ទំហំគម្រោង និងត្រូវមានការចូលរួមពិគ្រោះយោបល់ពីសហគមន៍ដែលរងផលប៉ះពាល់។[៩០] អនុក្រឹត្យ ប្រគល់ភារកិច្ចនេះឲ្យក្រសួងបរិស្ថាន ពិនិត្យ និងវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងធានាការអនុវត្តនេះតាមរយៈការតាមដាន និងការឃ្លាំមើល។[៩១] មាត្រា ៤ នៃអនុក្រឹត្យនេះ ចែងថា គម្រោងអាចត្រូវបានអនុម័តដោយស្ថាប័ន និងក្រសួងដែលមានសិទ្ធិ បន្ទាប់ពីក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចមក។ នៅអំឡុងពេលសរសេររបាយការណ៍នេះ ក្រសួងបរិស្ថាន កំពុងដំណើរការព្រាងសេចក្តីព្រាងច្បាប់មួយស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ នៅមិនទាន់មានជាសាធារណៈនៅឡើយ ប៉ុន្តែបើតាមសេចក្តីរាយការណ៍ថា សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំតាក់តែងឡើង សម្រាប់ដាក់ឲ្យមានការពិគ្រោះយោបល់នៅថ្ងៃអនាគត ។

## ១.៤ ច្បាប់ស្តីពីវិនិយោគ

៤៣. ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា មានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺជាគម្រោងវិនិយោគទាំងឡាយណាដែលទទួល

---

[៨៦] កិច្ចព្រមព្រៀងព្រៃសហគមន៍ ព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលព្រៃឈើ ខែមករា ឆ្នាំ២០១២ ស្ថិតិសហគមន៍ព្រៃឈើកម្ពុជា ឆ្នាំ២០១១។

[៨៧] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ មាត្រា ៦ និង មាត្រា ៧។

[៨៨] ដូចគ្នាខាងលើ មាត្រា ១០។

[៨៩] ដូចគ្នាខាងលើ មាត្រា ៩។

[៩០] អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មាត្រា ១ ចែងថា ការវាយតម្លៃហេតុប៉ះពាល់ត្រូវតែ "បំផុសឲ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង"។

[៩១] ដូចគ្នាខាងលើ មាត្រា ៣។

បានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)។[៩២] ច្បាប់នេះ បានកំណត់របបវិនិយោគបរទេស និងបានផ្ដល់ក្របខ័ណ្ឌសម្រាប់ការលើកទឹកចិត្ត (រាប់ទាំងការលើកលែងពន្ធគយ និងពន្ធអាករ) សម្រាប់ការវិនិយោគ វិស័យឯកជនដោយផ្ទាល់ ដែលរួមមានការអភិវឌ្ឍន៍វិស័យកសិ-ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការការពារបរិស្ថាន និង ទេសចរណ៍។[៩៣] ជំពូកទី៦ ចែងថា ការប្រើប្រាស់ដីត្រូវបានអនុញ្ញាតឲ្យចំពោះអ្នកវិនិយោគទាំងអស់ ប៉ុន្តែកម្មសិទ្ធិដីធ្លី សម្រាប់បម្រើឲ្យគោលបំណងនៃសកម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគ ដែលមានសញ្ជាតិជាខ្មែរ តែប៉ុណ្ណោះ អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាល។ អ្នកវិនិយោគទាំងអស់ ត្រូវបានអនុញ្ញាតិឲ្យចុះកិច្ចសន្យាជួល រយៈពេលគ្មានកំណត់ រយៈពេលខ្លី រយៈពេលវែង ស្ថិតក្រោមបញ្ញត្តិច្បាប់ជាធរមាន ដែលគ្រប់គ្រងលើកិច្ចសន្យាជួល បើទោះបីជា ច្បាប់បានចែងថា ម្ចាស់សម្បទាន មិនអាចទុកចោល ឬ ផ្ទេរដីសម្បទានដែលអសកម្មទៅតតីយជនណា មួយក្តី។ ជំពូកទី៨ នៃច្បាប់នេះចែងថា វិវាទណាមួយដែលទាក់ទងនឹងកិច្ចការវិនិយោគ ដំបូង គឺត្រូវដោះស្រាយដោយ ការសម្រុះសម្រួល តាមរយៈការពិគ្រោះយោបល់គ្នារវាងភាគីជម្លោះទាំងឡាយ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ប្រសិន ជា វិវាទមិនអាចដោះស្រាយតាមរយៈការសម្រុះសម្រួល ក្នុងអំឡុងពេលពីរខែទេ វិវាទនេះ អាចលើកមកដាក់ជូន ក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្ដល់យោបល់ ឬ ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឬ ដោះស្រាយតាមផ្លូវតុលាការ។ ទោះជា យ៉ាងណាក៏ដោយ ការនេះមិនអនុវត្តចំពោះទំនាស់ដីធ្លីទេ ព្រោះថា ទំនាស់ប្រភេទនេះ ត្រូវដោះស្រាយតាមបទប្បញ្ញត្តិ ច្បាប់ជាធរមាន ដែលមានចែងក្នុងច្បាប់ភូមិបាល និង/ឬ ក្នុងក្រមរដ្ឋប្បវេណី។

## ១.៥ ច្បាប់ផ្សេងៗទាក់ទងនឹងឧស្សាហកម្មនិស្សារណកម្ម

៤៤. ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០០១ គ្រប់គ្រងលើរាល់សកម្មភាពទាក់ទងនឹង ប្រតិបត្តិការធនធានរ៉ែ ការស្វែងរុករក និងការធ្វើអាជីវកម្មធនធានរ៉ែ (ទោះបីជាច្បាប់នេះ មិនគ្រប់ដណ្ដប់លើវិស័យប្រេង កាត និងឧស្ម័នក្តី)។ ការស្វែងរុករក និងជីកយករ៉ែនៅលើដីដែលកំណត់ជាតំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្ត្រ តំបន់ បេតិកភ័ណ្ឌជាតិ ត្រូវហាមឃាត់ ហើយរាល់សកម្មភាពស្វែងរុករក និងជីកយករ៉ែនៅលើដីដែលកំណត់ថាជា "តំបន់ការ ពារ តំបន់ដែនបម្រុង ឬ តំបន់ហាមឃាត់" ត្រូវតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ច ដែល មានតួនាទីគ្រប់គ្រងលើតំបន់នោះ។[៩៤] ច្បាប់នេះ កំណត់លក្ខខណ្ឌតម្រូវផងដែរ ឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផ្តល់សំណងសមរម្យ និងយុត្តិធម៌ដល់ម្ចាស់ដី ដែលដីរបស់ខ្លួនរងផលប៉ះពាល់។[៩៥] ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២ អនុញ្ញាតិការស្វែងរុករក និងជីកយករ៉ែនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ប៉ុន្តែទោះជាដូច្នេះក្តី ប្រតិបត្តិការ ស្វែងរុករក

[៩២] ច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤ ( ត្រូវបានវិសោធនកម្ម ដោយច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីវិនិយោគ ឆ្នាំ២០០៣) មាត្រា ១។

[៩៣] ដូចគ្នាខាងលើ មាត្រា ១២-១៤។

[៩៤] ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ ឆ្នាំ២០០១ មាត្រា ៧ និង មាត្រា ៨។

[៩៥] ដូចគ្នាខាងលើ មាត្រា ៧ និង មាត្រា ២៥ ។ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីកម្មធនធានរ៉ែ ក៏កំណត់ផងដែរ នូវតម្រូវការចាំបាច់មួយចំនួន សម្រាប់អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ (សម្បទានិក) ឬ អ្នកចុះកិច្ចសន្យាបន្ត ក្នុងការទទួលខុសត្រូវលើការដំណើរការប្រតិបត្តិការស្វែងរុករក និងធ្វើ អាជីវកម្មធនធានរ៉ែ ឲ្យបានត្រឹមត្រូវ រួមទាំងការការពារបរិស្ថាន ដោយស្របជាមួយនឹងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធាន ធម្មជាតិ ការសិក្សា និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែ និងការធានាផ្នែកហិរញ្ញវត្ថុ ធានា ការពារសុខភាព និងសុវត្ថិភាពពលករដែលនឹងមានលំអិត នៅក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាព និងសុវត្ថិភាពក្នុងអណ្តូងរ៉ែ រាប់បញ្ចូល ទាំងការការពារគ្រោះថ្នាក់ បែបបទរាយកាណ៍ស្តីពីគ្រោះថ្នាក់នេះ ការពារសុវត្ថិភាពដល់សាធារណជន នៅក្នុង និងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹង លំអិតក្នុងផែនការអណ្តូង រ៉ែ ធ្វើការអប់រំបណ្តុះបណ្តាល និងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ ដែលនឹងលំអិតនៅក្នុងកម្មវិធីផ្តល់ការងារអប់រំបណ្តុះ បណ្តាល ប្រើប្រាស់ឲ្យអស់លទ្ធភាពនូវទំនិញ និងសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមទីកន្លែង និងពេលវេលាសមស្រប (មាត្រា ២១)។

និងជីកយករ៉ែណាមួយដែលបានស្នើឡើង ជាបន្ថែមលើ ច្បាប់ដទៃទៀតដែលពាក់ព័ន្ធ ត្រូវតែ "មានការសិក្សា វាយតម្លៃជាមុន" ពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។[៩៦] ពង្រាងគោលនយោបាយស្ដីពី ការស្វែងរុករក និង ជីកយករ៉ែ ត្រូវបានគេរាយការណ៍ថា បាននិងកំពុងតែដំណើរការរៀបចំតាក់តែង។

៤៥. បច្ចុប្បន្ននេះ ប្រេងកាត និងឧស្ម័ន ត្រូវបានគ្រប់គ្រងដោយ បទប្បញ្ញត្តិប្រេងកាត ឆ្នាំ១៩៩១ និងវិសោធនកម្មនៃបទប្បញ្ញត្តិនេះឆ្នាំ១៩៩៨ និងឆ្នាំ១៩៩៩។[៩៧] ស្ថិតក្រោមបទប្បញ្ញត្តិខាងដើម ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល គឺជាអាជ្ញាធររដ្ឋបាលទទួលខុសត្រូវគ្រប់គ្រងលើធនធានប្រេងកាត។ ប៉ុន្តែក្នុងឆ្នាំ១៩៩៨ អាជ្ញាធរនេះ បានប្ដូរឈ្មោះមកជា អាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA)[៩៨] ដែលបច្ចុប្បន្ននេះ ទទួលបន្ទុកវាយតម្លៃលើលិខិតដេញថ្លៃ និង ផ្ដល់យោបល់ជូនរដ្ឋាភិបាលអំពី កិច្ចព្រមព្រៀងប្រេងកាត ដែលនឹងត្រូវផ្ដល់ទៅឲ្យក្រុមហ៊ុនជាក់លាក់មួយចំនួន។[៩៩] បច្ចុប្បន្ននេះ មិនមានច្បាប់ជាក់លាក់ណាមួយគ្រប់គ្រងលើវិស័យប្រេងកាត និងឧស្ម័នទេ ប៉ុន្តែមានសេចក្ដីរាយការណ៍ថា អាជ្ញាធរប្រេងកាតជាតិកម្ពុជា និងក្រុមប្រឹក្សាអ្នកច្បាប់ បាននិងកំពុងធ្វើសេចក្ដីព្រាងច្បាប់មួយនេះ ប៉ុន្តែនៅពេលកំពុងសរសេររបាយការណ៍នេះ សេចក្ដីព្រាងច្បាប់នេះមិនមានជាសាធារណៈទេ ហើយរហូតមកទល់ពេលនេះ មិនមានការពិនិត្យ ឬ ការពិគ្រោះយោបល់ជាសាធារណៈនៅឡើយ។ម្យ៉ាងវិញទៀត មានសេចក្ដីរាយការណ៍ថា មានការពិគ្រោះយោបល់ថ្នាក់អន្តរក្រសួង លើពង្រាងគោលនយោបាយស្ដីពីប្រេងកាត។

៤៦. បទប្បញ្ញត្តិប្រេងកាត កំណត់លក្ខខណ្ឌសម្រាប់ការអញ្ជើញចូលរួមដេញថ្លៃ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើលិខិតដេញថ្លៃ និងការចរចាជាមួយអ្នកដេញថ្លៃ និងការសម្រេចយល់ព្រមលើលិខិតដេញថ្លៃក្រោយទៀត។ ថេរវេលាអតិបរមានៃរយៈពេលស្វែងរុករកមានកម្រិត ៤ ឆ្នាំ នៃកិច្ចសន្យា បន្ទាប់ពីនេះ អាចពន្យាបានពីរលើក ដែលមួយលើកៗមានកម្រិតពីរឆ្នាំនៃកិច្ចសន្យា។[១០០] ប្រសិនជាការស្វែងរុករកឃើញថា ធនធានប្រេងកាតមានកម្រិត ពាណិជ្ជកម្មក្រុមហ៊ុន ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតផលិតកម្ម ដោយភ្ជាប់ជាមួយនូវកម្មវិធីការងារលំអិត និងថវិកានៃកិច្ចអភិវឌ្ឍន៍។ គ្មានការបង្កើតប្រតិបត្តិការបន្ថែមណាមួយអាចផ្ដើមធ្វើបានទេ លុះត្រាតែបានចេញលិខិតអនុញ្ញាតផលិតកម្ម។ អនុលោមតាមបទប្បញ្ញត្តិនេះ ថេរវេលានៃរយៈពេលផលិតកម្មមួយត្រូវផុតកំណត់រយៈពេល ៣០ ឆ្នាំ ក្រោយកាលបរិច្ឆេទដែលមានជាធរមាន បន្ទាប់ពីនោះ អាចពន្យាបន្ថែមរយៈពេលផលិតកម្មបាន ៥ ឆ្នាំទៀត ប្រសិនបើ ផលិតកម្មកម្រិតពាណិជ្ជកម្មនៃការដ្ឋាននៅតែអាចអនុវត្តបាននៅពេលផុតកំណត់នោះ។[១០១] បទប្បញ្ញត្តិនេះ បានកំណត់លក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិការប្រេងកាត រាប់ទាំង ការការពារ សុវត្ថិភាព សន្តិសុខ និងបរិស្ថាន។[១០២] ដូចគម្រោងអភិវឌ្ឍន៍ធំៗដទៃ

[៩៦] ច្បាប់ស្ដីពី ព្រៃឈើ ឆ្នាំ២០០២ មាត្រា ៣៥។

[៩៧] សម្រាប់ស្ថានភាពបច្ចុប្បន្ននៃច្បាប់ប្រេងកាត និងវិសោធនកម្មបទប្បញ្ញត្តិប្រេងកាត ឆ្នាំ១៩៩១ សូមមើលគេហទំព័របស់ អាជ្ញាធរប្រេងកាតជាតិកម្ពុជា៖ http://www.cnpa.gov.kh/index.php?option=com_content&view=article&id=66&Itemid=142

[៩៨] ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជាបច្ចុប្បន្នគឺ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

[៩៩] ព្រះរាជក្រឹត្យ លេខ ជស/រតក/០១៩៨/០២០ ២២ ស្ដីពី ការបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា ខែមករា ឆ្នាំ១៩៩៨។

[១០០] បទប្បញ្ញត្តិប្រេងកាត ឆ្នាំ១៩៩១ ជំពូកទី ៤។

[១០១] ដូចគ្នាខាងលើ ជំពូកទី ៥។

[១០២] ដូចគ្នាខាងលើ ជំពូកទី ៦។

ទៀតដែរ រាល់ប្រតិបត្តិការប្រេងកាតនិងឧស្ម័នត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំងស្រុង។[១០៣]

## ១.៦ ច្បាប់ផ្សេងៗទាក់ទងនឹងវារីអគ្គីសនី

៤៧. បច្ចុប្បន្ននេះ មិនទាន់មានច្បាប់ជាក់លាក់ណាមួយទស្តីពី វារីអគ្គីសនីនៅកម្ពុជា បើទោះជាមានច្បាប់មួយចំនួនចែងអំពី ការអភិវឌ្ឍន៍ និងប្រតិបត្តិការគម្រោងបែបនេះ រាប់ទាំងច្បាប់ពាក់ព័ន្ធនឹងវិនិយោគអគ្គីសនី ដីធ្លី ព្រៃឈើ ធនធានទឹក និងបរិស្ថានក្តី។ ដោយសារកម្ពុជានៅមិនទាន់មានសមត្ថភាពបច្ចេកទេស ឬ ហិរញ្ញវត្ថុ ដើម្បីរៀបចំគម្រោងសាងសង់ និងប្រតិបត្តិការគម្រោងវារីអគ្គីសនីទ្រង់ទ្រាយធំ ដូច្នេះរាល់គម្រោងទ្រង់ទ្រាយធំទាំងអស់ នាពេលបច្ចុប្បន្ន ដែលកំពុងដំណើរការរៀបចំបង្កើត គឺស្ថិតក្រោមកិច្ចព្រមព្រៀងមួយ ដែលហៅថា "សាងសង់ ប្រតិបត្តិការ ផ្ទេរ" (BOT) ដែលមានរយៈពេល ២៥ ឆ្នាំ និងវែងជាងនេះ ហើយរាល់គម្រោងវារីអគ្គីសនីទ្រង់ទ្រាយធំដែលមានស្រាប់ទាំងអស់ដែល បច្ចុប្បន្នកំពុងប្រតិបត្តិការ ឬ ស្ថិតក្នុងការអភិវឌ្ឍន៍ ទទួលបានថវិការពីចិន និងប្រតិបត្តិការដោយចិន។[១០៤]

៤៨. ដើម្បីបង្កើតគម្រោងវារីអគ្គីសនីមួយ ជំហានដំបូងគឺត្រូវចុះអនុស្សារណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីរៀបចំ និងសិក្សាអំពីសមិទ្ធិលទ្ធភាព ហើយបន្ទាប់មកមានជំហានជាបន្តបន្ទាប់ទៀតដើម្បីឈានទៅបង្កើតគម្រោង ហើយដែលវាត្រូវមាន ការអនុម័តយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ម្យ៉ាងវិញទៀត តាមច្បាប់ស្តីពីការគ្រប់គ្រងធានធានទឹក ឆ្នាំ២០០៧ រាល់គម្រោងវារីអគ្គីសនីទាំងអស់ ត្រូវមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត។[១០៥] ដូចគម្រោងអភិវឌ្ឍន៍ធំៗដទៃទៀតដែរ រាល់គម្រោងវារីអគ្គីសនីទាំងអស់ ត្រូវស្ថិតក្នុងកម្មវត្ថុនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុន មុនមានការអនុម័តយល់ព្រម ហើយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តតាមនីតិវិធីដែលបានកំណត់ដោយក្រសួងបរិស្ថាន។[១០៦]

# ង. កម្មសិទ្ធិដីធ្លី និងសិទ្ធិភោគៈ

៤៩. របបខ្មែរក្រហមគ្រប់គ្រងអំណាចនៅកម្ពុជា ចន្លោះពីឆ្នាំ១៩៧៥ និង១៩៧៩ បានរំលាយកម្មសិទ្ធិឯកជនទាំងអស់ ដែលផលវិបាកនេះមានរហូតមកទល់សព្វថ្ងៃនេះ។ ប្រជាជនកម្ពុជាច្រើនលាននាក់ នៅខ្វះឯកសារ និង ការទទួលស្គាល់ពេញលេញអំពីសិទ្ធិកម្មសិទ្ធិរបស់ខ្លួន ដែលភ្ជាប់ដោយប័ណ្ណកម្មសិទ្ធិដីធ្លី។ ដោយទទួលស្គាល់ពីអវត្តមាននៃការចុះបញ្ជីដីធ្លី និងប័ណ្ណកម្មសិទ្ធិដីធ្លីជាទូទៅ ជំពូកទី៤ នៃច្បាប់ភូមិបាល ទទួលស្គាល់សិទ្ធិភោគៈរបស់បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ ចាប់ពីប្រាំឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុន្តែមិនទាន់មានការទទួលស្គាល់ជាផ្លូវការ ថាជាកម្មសិទ្ធិករនៃដីនោះ

---

[១០៣] ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ មាត្រា ៦ និង អនុក្រឹត្យស្តីពី កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩។

[១០៤] សេចក្តីសង្ខេបអំពីវារីអគ្គីសនី ខែតុលា ឆ្នាំ ២០១១ របស់គម្រោង Open Development Cambodia សូមមើលគេហទំព័រះ http://www.opendevelopmentcambodia.net/briefings/hydropower/http://www.opendevelopmentcambodia.net/briefings/hydropower

[១០៥] ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៧ មាត្រា ១២។

[១០៦] ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ មាត្រា ៦ និង អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩។

នៅឡើយ។ ប្រសិនជា អ្នកកាន់កាប់ដីឯកជន មានភស្តុតាងបញ្ជាក់ថា ការកាន់កាប់ដីរបស់ខ្លួនបានបំពេញគ្រប់លក្ខខណ្ឌតាមច្បាប់ គាត់មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។[១០៧]

៥០. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមានការជួយឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ និង អាជ្ញាធរនានា បានសម្រេចសមិទ្ធផលធំធេង ទាំងលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ព្រមទាំងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងបានខិតខំព្យាយាម និងដោះស្រាយស្ថានការណ៍នៃអ្នកតាំងទីលំនៅមិនរៀបរយ តាមរយៈគោលនយោបាយ និងបទបញ្ញាថ្មី។[១០៨] អ្នកផ្តល់ជំនួយបរទេស រាប់ទាំងធនាគារពិភពលោក រដ្ឋាភិបាលអាឡឺម៉ង់ (តាមរយៈអង្គការជីអាយហ្សេត (GIZ) ដែលពីមុនគេស្គាល់ថាជា ជីធីហ្សេត(GTZ) និង ឌីអ៊ីឌី (DED)) រដ្ឋាភិបាលហ្វាំងឡង់ (តាមរយៈហ្វីនម៉ាប (Finnmap) រដ្ឋាភិបាលកាណាដា (តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា) ក៏ដូចជា រដ្ឋាភិបាលដាណឺម៉ាក(Danida) និងសហគមន៍អឺរ៉ុប បានចូលរួមវិភាគទានយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់កម្មវិធីទាំងនេះ ទាំងនៅតំបន់ទីប្រជុំជន ទាំងនៅតំបន់ជនបទ តាមរយៈការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរខេត្តនានា នៅក្នុងគោលនយោបាយមួយចំនួន និងកម្មវិធីបែងចែកដី ចុះបញ្ជីដី និង ផ្តល់ប័ណ្ណកម្មសិទ្ធិដី។ កម្មវិធីគន្លឹះមួយចំនួន រាប់ទាំងគម្រោងរៀបចំដែនដី និង រដ្ឋបាលដីធ្លី (LMAP) កម្មវិធីចុះបញ្ជីដីតាមលក្ខណៈជាប្រព័ន្ធ និងលក្ខណៈដាច់ដោយដុំ ពីឆ្នាំ ២០០២-២០០៩ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (LASED) គាំទ្រ និងបែងចែកដីធ្លីឡើងវិញដល់គ្រួសារក្រីក្រដែលខ្វះខាតដីធ្លី តាមរយៈគម្រោងសម្បទានដីសង្គមកិច្ច និង កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) ដែលជាកម្មវិធីបន្តវេនពីគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP)។

៥១. យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (អជជយ) គិតមកដល់ឆ្នាំ ២០១០ ក្រសួង បានចេញប័ណ្ណកម្មសិទ្ធិដីសរុបចំនួន ១.៦៦៤.២៩៧ ប័ណ្ណ ដែលក្នុងនោះមានបីភាគបួន (៣/៤) នៅតំបន់ជនបទ និង មួយភាគបួន (១/៤) នៅតំបន់ទីប្រជុំជន។ ក្នុងចំណោមប័ណ្ណកម្មសិទ្ធិដីដែលបានផ្តល់សរុបទាំងនេះ មានប័ណ្ណចំនួន ១.០៧០.៦៦៥ បានចេញឲ្យតាមរយៈ ការចុះបញ្ជីដីតាមលក្ខណៈជាប្រព័ន្ធ និង ៥៩៣.៦៤៥ ប័ណ្ណ តាមរយៈការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។[១០៩] គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១១ កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី បានផ្តល់ប័ណ្ណកម្មសិទ្ធិដីចំនួន ១.៧៤០.៨៣៩ ប័ណ្ណ ហើយកម្មវិធីនេះនៅបន្តធ្វើ ដែលបច្ចុប្បន្ននេះចំនួននៃប័ណ្ណកម្មសិទ្ធិដីដែលបានចេញផ្តល់ឲ្យអាចនឹងកើនឡើងថែមទៀត។[១១០] ទន្ទឹមនឹងមានការរីកចម្រើនខ្លាំង ក៏មានកង្វល់អំពីគ្រួសារ និងសហគមន៍ជាច្រើនដែលត្រូវបានគេដាត់ចេញពីកម្មវិធីទាំងនេះ ដូចមានពិភាក្សានៅផ្នែកខាងក្រោម។ ជាងនេះទៅទៀត កម្មវិធីធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីមួយឆាប់រហ័ស ដែលត្រូវបានផ្តួចផ្តើមដោយលោកនាយករដ្ឋមន្ត្រី នៅក្នុងខែមិថុនា ឆ្នាំ២០១២ ហើយត្រូវបានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តយ៉ាងលឿន ដោយមានការជួយជ្រោមជ្រែងពីមន្ត្រីស្ម័គ្រចិត្តយុវជន នៅ

[១០៧] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៣០ ។ មាត្រា ៣៨ នៃច្បាប់នេះ បានកំណត់លក្ខខណ្ឌសម្រាប់សិទ្ធិទាំងនេះ ដែលហៅថា សិទ្ធិភោគៈ ត្រូវតែ "បានកាន់កាប់ដោយពិតប្រាកដ គ្មានហឹង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុច្ចរិត" ។

[១០៨] ជាឧទាហរណ៍ ការកត់សំគាល់អំពី ការអនុម័តសារាចរស្តីពី ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងតាមទីប្រជុំជន (សារាចរលេខ ០៣) នៅខែឧសភា ឆ្នាំ២០១០ ។

[១០៩] រាជរដ្ឋាភិបាលកម្ពុជា ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ជំពូក ២ ទំព័រ ៣៤ កថាខ័ណ្ឌទី១១១ ។

[១១០] កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) *ដីជាជីវិត៖ ព្រឹត្តប័ត្ររបស់កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី* លេខ ២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

ថ្នាក់ខេត្ត និងក្រុមយុវជនស្ម័គ្រចិត្ត ដែលបានជ្រើសរើសជាពិសេសសម្រាប់គោលបំណងនេះ ដែលនឹងមានពិភាក្សាលំអិតបន្ថែមទៀតផងដែរនៅផ្នែកខាងក្រោម។

## ច. សិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច

៥២. ជំពូកទី៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចលើដីកម្មសិទ្ធិសមូហភាព។ ដីរបស់ជនជាតិដើមភាគតិច រួមមាន ដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្ម និងដីទាំងអស់ដែលមានទាំងដីដែលកំពុងដាំដុះជាក់ស្តែង និងដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ។ ច្បាប់ភូមិបាល មាត្រា ២៣ ចែងថា ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ សហគមន៍ជនជាតិដើមភាគតិចបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី។ នៅពេលដែលសហគមន៍ជនជាតិដើមភាគតិច បានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ជានីតិបុគ្គលរួចហើយ សហគមន៍ទាំងនោះ អាចដាក់ពាក្យសុំចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពបាន។ ក្នុងឆ្នាំ២០០៩ រដ្ឋាភិបាលបានបញ្ជាក់បន្ថែមទៀតនៅក្នុងគោលនយោបាយស្តីពីជនជាតិដើមភាគតិច[១១១] និង បានបង្កើតនីតិវិធីសម្រាប់អនុវត្តសិទ្ធិរបស់ពួកគេ ដើម្បីបានចុះបញ្ជីដីនិងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។[១១២]

៥៣. ការអនុម័តអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ក្នុងខែមេសា ឆ្នាំ២០០៩ ញ៉ាំងឲ្យមានគំនិតផ្តួចផ្តើមច្រើនថែមទៀត ដោយក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អ្នកផ្តល់ជំនួយទ្វេភាគី អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) នានា ដើម្បីជួយដល់សហគមន៍ជនជាតិដើមភាគតិច ស្វះស្វែងរកចុះបញ្ជីជានីតិបុគ្គល និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ អនុក្រឹត្យនេះ កំណត់គោលការណ៍ នីតិវិធី និងយន្តការសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព និងបញ្ចូលជំហានលំអិតមួយចំនួនសម្រាប់ ការវាស់វែងកំណត់ព្រំប្រទល់ដី ការធ្វើអង្កេតដី និងការផ្សព្វផ្សាយជាសាធារណៈ។

៥៤. ទោះបីជា សហគមន៍ជនជាតិដើមភាគតិច បានខិតខំប្រឹងប្រែងស្វះស្វែងចុះបញ្ជីជានីតិបុគ្គល និងជាចុងក្រោយត្រូវដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពក្តី ក៏សម្បទានដីសេដ្ឋកិច្ច នៅតែត្រូវបានបន្តផ្តល់នៅលើដីដែលសហគមន៍ទាំងនោះបានអះអាងសិទ្ធិលើដីនោះផងដែរ។ ទោះជាដូច្នេះក្តី ក្នុងខែឧសភា ឆ្នាំ២០១១ ក្រសួងមហាផ្ទៃ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញសារាចរអន្តរក្រសួងមួយដ៏គួរឲ្យស្វាគមន៍ ស្តីពីការការពារជាបណ្តោះអាសន្នចំពោះសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ។ សារាចរនេះ មានគោលដៅការពារដីរបស់ជនជាតិដើមភាគតិច ដែលកំពុងរង់ចាំការបញ្ចប់ដំណើរការមួយដ៏វែងឆ្ងាយនៃការផ្តល់កម្មសិទ្ធិដីសមូហភាព។[១១៣]

---

[១១១] គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច រៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ អនុម័តយល់ព្រមដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩។ សារាចរណែនាំ របស់ក្រសួងអភិវឌ្ឍន៍ជនបទស្តីពី នីតិវិធី និងវិធីសាស្ត្រ អនុវត្តគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍន៍ និងការកំណត់អត្តសញ្ញាណកម្មសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩។

[១១២] អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ ស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគ។

[១១៣] ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សារាចរអន្តរក្រសួង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ស្តីពីវិធានការការពារជាបណ្តោះអាសន្ននូវដីដែលសហគមន៍ជនជាតិដើមភាគតិចស្នើសុំចុះបញ្ជីដី ក្នុងពេលរង់ចាំការចុះបញ្ជីដីនោះជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ត្រូវបានបញ្ចប់តាមនីតិវិធី។

## ឆ. ការពិនិត្យមើលត្រួសៗលើយន្តការដោះស្រាយទំនាស់ដីធ្លីដែលមានស្រាប់

៥៥. យន្តការផ្លូវការសម្រាប់ដោះស្រាយទំនាស់ពាក់ព័ន្ធនឹងសិទ្ធិដីធ្លី មានចំនួន ៥ (ប្រាំ) នៅកម្ពុជា គឺ ក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មាធិការរដ្ឋបាល អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គណៈកម្មការសុរិយោដី និងតុលាការ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ មានតួនាទីត្រឹមតែជាអ្នក "ផ្សះផ្សាការខ្វែងមតិយោបល់គ្នា" រវាងប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ ប៉ុន្តែមិនមានសិទ្ធិសម្រេចឡើយ។[១១៤] ទោះជាមិនមានលក្ខខណ្ឌតម្រូវណាមួយក្តី ក្នុងការអនុវត្តជាក់ស្តែង ករណីភាគច្រើន ត្រូវបានដាក់ជូនក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើការដោះស្រាយ មុននឹងបញ្ជូនទៅថ្នាក់ខ្ពស់ជាងនេះ។

៥៦. គណៈកម្មការរដ្ឋបាល ត្រូវបានបង្កើតឡើងនៅគ្រប់តំបន់ដែលមានដំណើរការនៃការចុះបញ្ជីដីតាមលក្ខណៈជាប្រព័ន្ធ និងជាយន្តការដោះស្រាយទំនាស់ថ្នាក់ដំបូង ក្នុងករណីដែលទំនាស់នោះកើតឡើងអំឡុងពេល នៃដំណើរការចុះបញ្ជីដីធ្លី។ គណៈកម្មការរដ្ឋបាល មិនមានអំណាចក្នុងការចេញសេចក្តីសម្រេចណាមួយឡើយ ហើយអាចត្រឹមតែសុំការជួយសហការពីភាគីទំនាស់ ដើម្បីដោះស្រាយទំនាស់របស់ខ្លួនតែប៉ុណ្ណោះ។[១១៥] ប្រសិនបើ គណៈកម្មការរដ្ឋបាល មិនអាចដោះស្រាយទំនាស់ណាមួយបាន គណៈកម្មការនេះត្រូវបញ្ជូនករណីរឿងនោះទៅគណៈកម្មការសុរិយោដី ដើម្បីចាត់ការបន្ត។

៥៧. ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា វិវាទរវាងភោគីចំពោះអចលនវត្ថុមួយនឹងត្រូវដាក់ឲ្យស៊ើបអង្កេត និងដោះស្រាយដោយគណៈកម្មការសុរិយោដី[១១៦] ដែលបានបង្កើតជាផ្លូវការក្នុងខែឧសភា ឆ្នាំ២០០២ ដោយអនុក្រឹត្យមួយ។[១១៧] គណៈកម្មការសុរិយោដី មានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនទ្រព្យ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ព្រមទាំងវិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ សម្រាប់ការចុះបញ្ជីដីតាមលក្ខណៈជាប្រព័ន្ធ និង វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចផ្សះផ្សាសម្រុះសម្រួលបាន ដោយគណៈកម្មការរដ្ឋបាល។[១១៨] គណៈកម្មការសុរិយោដីមានរចនាសម្ព័ន្ធដូចតទៅ៖ គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គ.ស.ជ) គណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង (គ.ស.ខ.ក) ដែលមាននៅទូទាំង ២៤ ខេត្ត/ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ (គ.ស.ស.ខ) ដែលមាននៅគ្រប់ ១៩៤ ស្រុក /ខណ្ឌ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ មានភារកិច្ចត្រឹមតែជួយសម្រុះសម្រួលវិវាទប៉ុណ្ណោះ ហើយក្នុងករណីដែលមិនអាចឈានដល់ការព្រមព្រៀងគ្នាទេ ត្រូវបញ្ជូនករណីវិវាទនោះទៅដោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង។ កន្លងមក គណកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង មានភារកិច្ចត្រឹមតែសម្រុះសម្រួលវិវាទប៉ុណ្ណោះ[១១៩] ប៉ុន្តែនៅចុងឆ្នាំ២០០៩ គណៈកម្មការនេះ ត្រូវបានធ្វើប្រតិភូកម្មអំណាចឲ្យចេញសេចក្តីសម្រេច

---

[១១៤] អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពី ការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សា ឃុំ-សង្កាត់ មាត្រា ៦១។

[១១៥] តួនាទី និងភារកិច្ចរបស់គណៈកម្មការរដ្ឋបាល ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

[១១៦] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៤៧។

[១១៧] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី មាត្រា ២ និង មាត្រា ៣។

[១១៨] ដូចគ្នាខាងលើ មាត្រា ៣។

[១១៩] ដូចគ្នាខាងលើ មាត្រា ១៣។

ក្នុងករណីមិនអាចសម្រុះសម្រួលបាន។[១២០] ប្រសិនជាករណីនេះ នៅតែមិនអាចដោះស្រាយនៅថ្នាក់ខេត្ត/ក្រុងបាន ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលគណៈកម្មការនេះមានអំណាចចេញសេចក្ដីសម្រេច។[១២១] ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្ដឹងទៅតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។[១២២]

៥៨. គណៈកម្មការសុរិយោដី មិនមានអំណាចដោះស្រាយវិវាទដីធ្លីដែលជាដីបានចុះបញ្ជីសុរិយោដីរួចហើយនោះឡើយ វិវាទលើដីធ្លីដែលចុះបញ្ជីត្រូវដោះស្រាយដោយតុលាការ។ វិវាទទាក់ទងនឹងទំនាស់កិច្ចសន្យា ឬ មរតក ក៏ត្រូវបញ្ជូនទៅតុលាការផងដែរ ទោះបីជាដីនោះបាន ឬ មិនបានចុះបញ្ជីសុរិយោដីក្ដី។[១២៣]

៥៩. នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៦ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។[១២៤] ស្ថាប័ននេះ (មិនត្រូវបានគេគិតដល់ទេ នៅពេលដែលមានការរៀបចំធ្វើសេចក្ដីព្រាងច្បាប់ភូមិបាល) មិនមានឋានៈមួយច្បាស់លាស់ នៅក្នុងក្របខ័ណ្ឌស្ថាប័នដែលមានស្រាប់ សម្រាប់ដោះស្រាយទំនាស់ដីធ្លីឡើយ។ អាជ្ញាធរនេះមានអាណត្តិដោះស្រាយទំនាស់ដីធ្លីដែល "ហួសសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ" និង "ទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋទាក់ទងនឹងទំនាស់ដីធ្លី"។[១២៥] មានព័ត៌មានតិចតួចអំពីការប្រព្រឹត្តទៅរបស់ស្ថាប័ននេះ ហើយក៏មិនដឹងថាមានពាក្យបណ្ដឹងចំនួនប៉ុន្មានករណី ដែលអាជ្ញាធរនេះបានទទួល និងដោះស្រាយកន្លងមកដែរ។

---

[១២០] ប្រកាសលេខ ៣២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្ដីពីការ ធ្វើប្រតិភូកម្មអំណាចទៅឲ្យក្រុមប្រឹក្សារាជធានី-ខេត្ត ប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្ត ដើម្បីធ្វើសេចក្ដីសម្រេចលើវិវាទដីធ្លី នៅក្នុងយន្តការរបស់គណៈកម្មការសុរិយោដី។ សារាចរលេខ ០១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ស្ដីពីការអនុវត្តន៍នីតិវិធី សម្រាប់ការធ្វើសេចក្ដីសម្រេចលើវិវាទដីធ្លី នៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-រាជធានី។

[១២១] អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី មាត្រា ១៩។

[១២២] ដូចគ្នាខាងលើ មាត្រា ២ និងមាត្រា ៣។

[១២៣] ប្រកាសរួមលេខ ៣ របស់ក្រសួងយុត្តិធម៌ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្ដីពីការកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងវិវាទដីធ្លី មាត្រា ១ និង មាត្រា ៤។

[១២៤] ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ បានកំណត់ថា សមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានដូចជា តំណាងរបស់នាយករដ្ឋមន្ត្រី ១ រូប ជាប្រធាន, រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាអនុប្រធានទី១, រួមជាមួយនឹងសមាជិកមកពីក្រសួងសំខាន់ៗដទៃទៀត, តំណាងមកពីកងកម្លាំងនគរបាល និងយោធា ព្រមទាំងសមាជិកដទៃទៀត។ បន្ទាប់មក នៅខែមីនា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយតែងតាំង មន្ត្រីទៅតាមមុខតំណែងដែលមានកំណត់នៅក្នុងព្រះរាជក្រឹត្យ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺជាក្រុមប្រឹក្សាមួយដែលមានសមាសភាពមន្ត្រីជាន់ខ្ពស់ចំនួន ២៥ រូប ដែលភាគច្រើនជាមន្ត្រីរដ្ឋាភិបាល។ អាជ្ញាធរនេះ ក៏បញ្ចូលផងដែរនូវតំណាងមកពីរដ្ឋសភាជាតិ និងមេធាវីរាជរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអញ្ជើញឲ្យចាត់តាំងតំណាងមួយរូប ប៉ុន្តែត្រូវបានបដិសេធនៅក្នុងការចាត់តាំងនេះ។ អាជ្ញាធរនេះ ត្រូវបានដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ជា ប្រធាន និងមានអនុប្រធានដូចជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ (ឯកឧត្តម អ៊ឹម ឈុនលឹម) រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា និង អធិការកិច្ច (លោកជំទាវ ម៉ែន សំអន) និងសមាជិករបស់គណៈបក្សប្រឆាំងមួយរូប (ឯកឧត្តម អេង ឆៃអ៊ាង)។ ព្រះរាជក្រឹត្យដែលបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (NALDR) ក៏បានបង្កើតផងដែរនូវអគ្គលេខាធិការដ្ឋានមួយសម្រាប់ជាភ្នាក់ងារអនុវត្តន៍ដ៏មានប្រសិទ្ធភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

[១២៥] ការកំណត់អំពីវិធាន និងនីតិវិធីធ្វើការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨។

## ជ. ការប្រែប្រួលថ្មីៗ នៃច្បាប់ និងគោលនយោបាយ

៦០. លោកនាយករដ្ឋមន្ត្រី បានផ្តួចផ្តើមបង្កើតគោលនយោបាយមួយចំនួនទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច នៅក្នុងឆមាសទីមួយនៃឆ្នាំ ២០១២។ ក្នុងខែមីនា ឆ្នាំ២០១២ គណៈរដ្ឋមន្ត្រីបានសម្រេចថា ជាគោលការណ៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចុះបញ្ជីដី ជាដីរដ្ឋ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមនីតិវិធីនៃក្របខ័ណ្ឌច្បាប់ជាធរមាន មុនការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។ បើយោងតាមលិខិតរបស់គណៈរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម បានយល់ព្រមថា មុនការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចណាមួយ ត្រូវចុះបញ្ជីដីពាក់ព័ន្ធ និងចុះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីជាមុនសិន។ ការងារនេះត្រូវអនុវត្តស្របតាមក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ហើយត្រូវប្រើពេលវេលាពី ៤ ទៅ ៥ ខែ ដើម្បីបញ្ចប់ដំណើរការនេះ។[១២៦]

៦១. នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រី បានចេញបទបញ្ជាមួយផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ច និងបានជម្រុញផងដែរឲ្យពិនិត្យមើលឡើងវិញនូវសម្បទានដីដែលមានស្រាប់។[១២៧] ចំពោះសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ បទបញ្ជានេះ បានណែនាំដល់អាជ្ញាធរពាក់ព័ន្ធទាំងអស់ឲ្យអនុវត្តបន្ថែមទៀតនូវគោលនយោបាយរូបមន្ត "ស្បែកខ្លា" ដែលជាការវាស់វែងដីសម្បទានដោយកាត់ចេញផ្ទៃដីដែលមានការកាន់កាប់រួចហើយ។ ការធ្វើបែបនេះ គឺក្នុងគោលដៅកាត់បន្ថយផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ចទៅលើដីសហគមន៍ និង កាត់បន្ថយការរំខានដល់ការចិញ្ចឹមជីវិតរបស់សហគមន៍ជនបទ។ បទបញ្ជានេះបានចែងផងដែរថា សម្បទានដីអាចនឹងត្រូវដកហូតយកមកវិញពីក្រុមហ៊ុនណា ដែលមិនអនុវត្តតាមនីតិវិធី និងកិច្ចសន្យាសម្បទានជាធរមាន ដោយគ្រាន់តែធ្វើការកាប់ឈើខុសច្បាប់ ទន្ទ្រានដីបន្ថែម ឬ ទុកដីទំនេរចោលសម្រាប់លក់បន្ត។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រី បានថ្លែងសន្ទរកថា នៅក្នុងពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ ២០១១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ដែលលោកបានជម្រុញការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ "ស្បែកខ្លា" តាមរយៈកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី ដល់គ្រួសារប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។

៦២. នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១២ រាជរដ្ឋាភិបាល បានប្រាប់ឲ្យខ្ញុំដឹងជាលាយលក្ខណ៍អក្សរថា លោកនាយករដ្ឋមន្ត្រី បានណែនាំដល់អាជ្ញាធរពាក់ព័ន្ធនានា ឲ្យពន្លឿនការចុះវាស់វែងដីដើម្បីផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៥០.០០០ គ្រួសារ នៅទូទាំងប្រទេស ដែលកំពុងរស់នៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃ និងលើដីរដ្ឋលើផ្ទៃដីសរុបទំហំ ១,២ លាន ហិកតា។ ខ្ញុំត្រូវបានប្រាប់ឲ្យដឹងថា ការអនុវត្តគំនិតផ្តួចផ្តើមថ្មីនេះ បាននិងកំពុងដំណើរការល្អ បន្ទាប់ពីការបញ្ជូនយុវជនស្ម័គ្រចិត្តចំនួន ១.៥០០ នាក់ ហើយថា យុវជនចំនួន ១.១០០ នាក់ បានដាក់ពង្រាយរួចហើយ នៅតាមបណ្តាខេត្តមួយចំនួនដូចជា បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ កំពត ក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងព្រះវិហារ តាំងពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ មក។ ខ្ញុំក៏ត្រូវបានប្រាប់ផងដែរថា យុវជនស្ម័គ្រចិត្តមួយក្រុមទៀត ដែលមានចំនួន ៤២០ នាក់ នឹងត្រូវដាក់ពង្រាយនៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០១២ ទៅខេត្តឧត្តរមានជ័យ

[១២៦] លិខិតលេខ ២៩៨ សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។

[១២៧] បទបញ្ជាលេខ ០១ បប របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច។

កោះកុង ពោធិសាត់ និងព្រះវិហារ។[១២៨]

៦៣. បន្ទាប់ពីសន្ទរកថារបស់លោកនាយករដ្ឋមន្ត្រីនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ មក មានឯកសារផ្លូវការមួយចំនួន ត្រូវបានចេញជាបន្តបន្ទាប់ទាក់ទងនឹងការអនុវត្តគម្រោងថ្មីនេះ រាប់ទាំងសេចក្តីសម្រេចរបស់រដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ បង្កើតគណៈកម្មាធិការមួយ ដើម្បីត្រួតពិនិត្យមើលការអនុវត្តបទបញ្ជានេះ។ គណៈកម្មាធិការនេះ ត្រូវរាយការណ៍ជូននាយករដ្ឋមន្ត្រី ដើម្បីធ្វើសំណើរសុំការអនុម័តយល់ព្រមលើការស្នើសុំខ្សៀលដីចេញពីផ្ទៃដី ព្រៃសម្បទាន សម្បទានដីសេដ្ឋកិច្ច និងដីរបស់រដ្ឋ ហើយយកដីដែលបានខ្សៀលចេញនោះធ្វើការបែងចែកឲ្យប្រជាពលរដ្ឋដើម្បីឲ្យពួកគាត់ក្លាយជាម្ចាស់ដីនោះស្របច្បាប់។[១២៩] ទន្ទឹមនឹងបទបញ្ជាអំពីសម្បទានដីសេដ្ឋកិច្ច ខែឧសភា ឆ្នាំ២០១២ បង្ហាញពីជំហានមួយដ៏សំខាន់លើទិសដៅមួយត្រឹមត្រូវក្នុងវិស័យកំណែទម្រង់ដីធ្លី និង អាចសម្រេចសមិទ្ធផលដ៏ធំធេងមួយចំពោះការបែងចែកដីធ្លីជូនប្រជាពលរដ្ឋក្រីក្រនៅតាមតំបន់ជនបទក្តី ក៏ការអនុវត្តនេះ ធ្វើឲ្យមានកង្វល់អំពីសុខដុមនីយកម្មរបស់វាជាមួយនឹងច្បាប់ នីតិវិធី និងគោលនយោបាយខាងរដ្ឋបាលដីធ្លី និងបណ្ណកម្មសិទ្ធិដីធ្លី ដែលកំពុងនៅជាធរមាន។ បញ្ហានេះមានពិភាក្សាលំអិតជាបន្ថែមទៀត នៅផ្នែកខាងក្រោម។

## ឈ. សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិដែលកំពុងរង់ចាំការអនុម័ត

៦៤. នៅដើមឆ្នាំ ២០១០ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញសេចក្តីព្រាងគោលនយោបាយមួយស្តីពីលំនៅដ្ឋាន ដែលក្នុងនោះមានការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពាន។ នៅពេលកំពុងសរសេររបាយការណ៍នេះ គោលនយោបាយនេះកំពុងរង់ចាំការពិនិត្យបញ្ចប់ដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងការអនុម័តយល់ព្រមពីគណៈរដ្ឋមន្ត្រី។ ក្រសួងនេះ បានចេញផងដែរនូវពង្រាងអនុក្រឹត្យមួយស្តីពីនគរូបនីយកម្ម នៅចុងឆ្នាំ២០១១ និងមានការផ្តល់យោបល់លំអិតលើសេចក្តីព្រាងអនុក្រឹត្យនេះដោយដៃគូពិភាក្សានានា នៅក្នុងដំណើរការនៃការពិគ្រោះយោបល់ជាសាធារណៈ ប៉ុន្តែសេចក្តីព្រាងដែលបានធ្វើបច្ចុប្បន្នភាព មិនទាន់បានផ្សព្វផ្សាយនៅឡើយទេ នៅពេលកំពុងសរសេររបាយការណ៍នេះ។

៦៥. ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបើកកិច្ចប្រជុំមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម ប៉ុន្តែអ្នកពាក់ព័ន្ធផ្សេងៗបានរាយការណ៍ថា មានដំណើរការពិគ្រោះយោបល់មួយបិទទ្វារ និងមានចំណុចដែលជាបញ្ហាធំៗមួយចំនួន ដែលអាចធ្វើឲ្យអន្តរាយដល់ក្របខ័ណ្ឌគតិយុត្តជាធរមានដែលគ្រប់គ្រងលើដីធ្លី រាប់ទាំងច្បាប់ភូមិបាល ឆ្នាំ២០០១ ផងដែរ។ របាយការណ៍របស់ដៃគូអភិវឌ្ឍន៍បង្ហាញថា សេចក្តីព្រាងច្បាប់នេះក្នុងសភាពបច្ចុប្បន្នរបស់វា អាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់អ្នកកាន់កាប់ដី និងការប្រកបការងារកសិកម្ម ដោយសារការដាក់កម្រិតលើដីអភិវឌ្ឍន៍កសិកម្មថ្មី។ ម្យ៉ាងវិញទៀត សេចក្តីព្រាងច្បាប់នេះ បញ្ចូលបទប្បញ្ញត្តិនៃទោសព្រហ្មទណ្ឌសម្រាប់ចោទប្រកាន់បុគ្គលណាម្នាក់ ដែលប្រព្រឹត្តផ្ទុយនឹងប្រព័ន្ធដែលបានកំណត់សម្រាប់ ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម។ វាក៏អាចអនុញ្ញាតឲ្យមានការផ្ទេរទៅជា សម្បទានដីសេដ្ឋកិច្ច និង សម្បទានដីសង្គមកិច្ច ឬ ផ្ទេរមកពីសម្បទានដីសេដ្ឋកិច្ច និង សម្បទានដីសង្គមកិច្ច ដែលអាចបង្កការលំបាកដល់អ្នកកាន់កាប់ដីមួយចំនួន។

[១២៨] លិខិតពីរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ ឯកឧត្តម អ៊ុច បូរិទ្ធ ផ្ញើជូន លោក សុរិយា ស៊ូប៊ែឌី ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០១២ ។

[១២៩] សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ២៤ សសរ ចុះថ្ងៃទី ២៥ ខែមីថុនា ឆ្នាំ២០១២។

# IV. ក្របខ័ណ្ឌច្បាប់អន្តរជាតិ

## ក. ការវិវឌ្ឍន៍នៅក្នុងប្រព័ន្ធច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា

៦៦. រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៣១ ដំកល់កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងច្បាប់ និងគោលនយោបាយជាតិ។[១៣០] ការអនុវត្តន៍ដោយផ្ទាល់នៃបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងតុលាការកម្ពុជាត្រូវបានបញ្ជាក់ច្បាស់បន្ថែមទៀតតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងឆ្នាំ ២០០៧។[១៣១] ចាប់តាំងពីឆ្នាំ ២០០៧ មក មានការវិវឌ្ឍន៍មួយចំនួនទាក់ទងនឹងសម្បទានដីនៅថ្នាក់អន្តរជាតិ ហើយដែលមានការពាក់ព័ន្ធទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិរបស់កម្ពុជា និងការវិវឌ្ឍន៍ខាងគោលនយោបាយ ច្បាប់ និងការអនុវត្តនៅថ្នាក់ជាតិ របស់ខ្លួន។

៦៧. ក្នុងខែកញ្ញា ឆ្នាំ២០០៧ កម្ពុជាបានបោះឆ្នោតគាំទ្រសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP)[១៣២] ដែលផ្តល់ឲ្យមានបទដ្ឋានគតិយុត្តអន្តរជាតិជាមូលដ្ឋានគ្រឹះមួយ សម្រាប់ក្របខ័ណ្ឌច្បាប់របស់រដ្ឋាភិបាលស្តីពី ការទទួលស្គាល់ និងការចុះបញ្ជីជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេក្នុងការកាន់កាប់ការប្រើប្រាស់ និងការអភិវឌ្ឍន៍ដីសមូហភាពជាប្រពៃណី និងមានការទទួលស្គាល់ប្រព័ន្ធកាន់កាប់ដីជាប្រពៃណីរបស់ពួកគេ។ ការអនុម័តទទួលយកសេចក្តីប្រកាសនេះ បង្ហាញពីលទ្ធផលដែលបានមកពីការតស៊ូមតិអស់កាលជាច្រើនទសវត្សរ៍កន្លងមកនេះ ដើម្បីទាមទារសិទ្ធិជនជាតិដើមភាគតិច និងកំណត់យ៉ាងច្បាស់អំពីសិទ្ធិលើដីធ្លី វប្បធម៌ ការចិញ្ចឹមជីវិត និងការពិគ្រោះយោបល់។[១៣៣]

៦៨. គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ ឆ្នាំ២០០៧ ស្តីពីសិទ្ធិទាក់ទងនឹងការបណ្តេញចេញ និងការតាំងទីលំនៅថ្មីផ្អែកលើការអភិវឌ្ឍន៍ ដែលបានរៀបចំចងក្រងឡើងដោយអ្នករាយការណ៍ពិសេសស្តីពី សិទ្ធិមាន

---

[១៣០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ ចែងថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ"។

[១៣១] សេចក្តីសំរេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

[១៣២] សេចក្តីសំរេចរបស់មហាសន្និបាត លេខ ៦១/២៩៥ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧។

[១៣៣] សេចក្តីប្រកាសទទួលស្គាល់សិទ្ធិស្វ័យសំរេចរបស់ជនជាតិដើមភាគតិច (មាត្រា ៣) ដូចជា ការធ្វើសេចក្តីសំរេចចិត្តអំពី ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី, សិទ្ធិទទួលបានការការពារពីការបណ្តេញចេញដោយបង្ខំ (មាត្រា ១០), សិទ្ធិទទួលបានការការពារប្រឆាំងនឹងការបង្ខំឲ្យរស់នៅលាយឡំជាមួយសហគមន៍ផ្សេង ឬការបំផ្លាញវប្បធម៌របស់ពួកគេ (មាត្រា ៨) និងដោយមានភាពពាក់ព័ន្ធគ្នាជាមួយ សិទ្ធិក្នុងការថែរក្សា និងការពារប្រពៃណី និងទំនៀមទំលាប់របស់ខ្លួន (មាត្រា ១១) ប្រពៃណីខាងជំនឿ និងសាសនា (មាត្រា ១២) និងការអនុវត្តន៍ខាងជំនឿសាសនា និងប្រពៃណីរបស់ពួកគេដែលមានទំនាក់ទំនងជាមួយនឹងដីធ្លី (មាត្រា ២៥) ព្រមទាំងសិទ្ធិលើដីធ្លីជាពិសេសរបស់ពួកគេ (មាត្រា ២៦)។ មាត្រា ២៩ និងមាត្រា ៣២ គូសបញ្ជាក់អំពីតម្រូវការរបស់រដ្ឋ ក្នុងការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច និងទទួលបានការយល់ព្រមដោយសេរី និងដោយបានប្រាប់ឲ្យដឹងជាមុន មុននឹងអនុម័ត និងអនុវត្តវិធានការច្បាប់ ឬ វិធានការរដ្ឋបាល ឬ គម្រោងនានា ដែលអាចប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិរបស់គេ ជាពិសេស "សម្រាប់គម្រោងទាំងឡាយណាដែលប៉ះពាល់ដល់ដីធ្លី ឬ ដែនដី និង ធនធានផ្សេងទៀតរបស់ពួកគេ"។ មាត្រា ២៩ គូសបង្ហាញអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច នៅក្នុងការអភិរក្ស និងការពារបរិស្ថាន និងសមត្ថភាពផលិតកម្មលើដីធ្លី ដែនដី និងធនធាននានារបស់ពួកគេ។ ជាទីបញ្ចប់ សេចក្តីប្រកាសក៏បានគូសបញ្ជាក់ផងដែរអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការទទួលបានដំណោះស្រាយត្រឹមត្រូវ ប្រសិនបើពួកគេត្រូវបានគេដកហូតមធ្យោបាយក្នុងការចិញ្ចឹមជីវិត និងការអភិវឌ្ឍន៍ (មាត្រា ២០, ២៨, ៣២, ៤០)។ សូមមើលផងដែរ របាយការណ៍របស់តំណាងពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច A/HRC/9/9 ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨។

លំនៅដ្ឋានសមរម្យ កំណត់បទដ្ឋានអប្បបរមាស្តីពី ការតាំងទីនៅថ្មី នៃប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសម្បទានដី។[១៣៤] គោលការណ៍ណែនាំនេះ ស្នើឲ្យរដ្ឋនានា រិះរកជម្រើសគ្រប់បែបយ៉ាងដែលអាចមានជំនួសឲ្យការបណ្តេញចេញ និងធានាឲ្យមានការពិគ្រោះយោបល់ និងការចូលរួមយ៉ាងពេញលេញពីសហគមន៍ដែលរងផលប៉ះពាល់ នៅទូទាំងដំណើរការទាំងមូល ក៏ដូចជា ជួសជុល និងផ្តល់សំណងការខូចខាតសមរម្យដល់ប្រជាពលរដ្ឋដែលត្រូវបានគេឲ្យទៅតាំងទីលំនៅថ្មី ឬ ដែលបាត់បង់ដីធ្លី។[១៣៥]

៦៩. គោលការណ៍អប្បបរមាស្តីពីសិទ្ធិមនុស្ស អនុវត្តចំពោះលទ្ធកម្មដី ឬ ការជួលដីទ្រង់ទ្រាយធំ ដែលបានរៀបចំចងក្រងឡើងដោយ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានម្ហូបអាហារ ក៏និយាយជាពិសេសផងដែរក្នុងបទរិបទនេះ។[១៣៦] គោលដៅចម្បងនៃគោលការណ៍នេះគឺ ដើម្បីធានាថា ការចរចាឈានទៅដល់ការផ្តល់លទ្ធកម្មដី ឬ ការជួលដី ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវខាងនីតិវិធីមួយចំនួន រាប់ទាំងការចូលរួមពីសហគមន៍មូលដ្ឋានដែលពួកគេទទួលបានព័ត៌មានគ្រប់គ្រាន់។ គោលការណ៍ទាំងនេះ ស្វះស្វែងដើម្បីធានាផងដែរនូវការចែងចែកផលកម្រៃសមរម្យ និងលក្ខខណ្ឌដែលថា ទោះជាក្នុងករណីណាក៏ដោយ ក៏ទំនាក់ទំនងពាណិជ្ជកម្មបែបនេះ មិនត្រូវមានអនុភាពលុបលើកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋឡើយ។

៧០. ក្នុងឆ្នាំ២០០៩ នាសម័យប្រជុំបូកសរុបលទ្ធផលនៃរបាយការណ៍សកលតាមកាលកំណត់លើកទីមួយរបស់ខ្លួនដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជា បានទទួលយកអនុសាសន៍ទាំង ៩១ ចំណុចដែលរដ្ឋសមាជិកទាំងឡាយបានផ្តល់។[១៣៧] ក្នុងចំណោមអនុសាសន៍ទាំងនេះ មានអនុសាសន៍ជាក់លាក់មួយចំនួនទាក់ទងនឹងបញ្ហាដីធ្លី ដូចជាសេចក្តីត្រូវការឲ្យៈ អនុវត្តកំណែទម្រង់ប្រព័ន្ធតុលាការ ដើម្បីដោះស្រាយបញ្ហាដីធ្លី បង្កើនកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការទទួលបានដោយយុត្តិធម៌ នូវកម្មសិទ្ធិលើដីធ្លី និង បង្ការទប់ស្កាត់ការបណ្តេញចេញដោយបំពាន ប្រសិនជាមិនអនុវត្តវិធានការផ្អាកជាបណ្តោះអាសន្ន និងធ្វើការកែប្រែគោលនយោបាយ និងការអនុវត្តទាក់ទងនឹងការតាំងទីលំនៅថ្មី និងការផ្លាស់ប្តូរទីលំនៅ។[១៣៨]ម្យ៉ាងវិញទៀត ក្នុងឆ្នាំ២០០៩ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ១២/២៥ ស្តីពីសេវាប្រឹក្សាយោបល់ និងការជួយឧបត្ថម្ភផ្នែកបច្ចេកទេសសម្រាប់ កម្ពុជា បន្តពីសេចក្តីសម្រេចចិត្តទាំងឡាយកន្លងមក បានស្នើយ៉ាងទទូចដល់រដ្ឋាភិបាលឲ្យ "បង្កើនកិច្ចខិតប្រឹងប្រែងរបស់ខ្លួនដើម្បីដោះស្រាយដោយសមធម៌ និងឆាប់រហ័សនូវបញ្ហាកម្មសិទ្ធិដីធ្លីក្នុងលក្ខណៈបើកចំហរ និង ដោយយុត្តិធម៌ ស្រប

---

[១៣៤] គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពី ការបណ្តេញចេញផ្អែកលើមូលដ្ឋាននៃការអភិវឌ្ឍន៍ និងការចាកចេញដោយបង្ខំចិត្ត, ឧបសម្ព័ន្ធ ១ នៃរបាយការណ៍តំណាងពិសេសស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពសមរម្យ A/HRC/ 4/18។

[១៣៥] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបោះពុម្ពផ្សាយ "សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ និងគោលការណ៍ណែនាំស្តីពី ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី" នៅខែធ្នូ ឆ្នាំ២០០៩ ជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយដែលអាចរកបាននៅលើគេហទំព័រៈ http://cambodia.ohchr.org/WebDOCs/DocPublications/EvictionsGuidelines/EvictionGuidelines-EN.pdf និង http://cambodia.ohchr.org/WebDOCs/DocPublications/ EvictionsGuidelines/EvictionGuidelines-Kh.pdf.

[១៣៦] គោលការណ៍អប្បបរមាស្តីពីសិទ្ធមនុស្ស អនុវត្តចំពោះលទ្ធកម្មដីទ្រង់ទ្រាយធំ ឬ ការជួលដី, ឧបសម្ព័ន្ធ នៃរបាយការណ៍របស់អ្នករាយការពិសេសស្តីពីសិទ្ធិមានម្ហូបអាហារ, A/HRC/13/33/Add.2 ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៩។

[១៣៧] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, របាយការណ៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នាសម័យប្រជុំលើកទី ១៣, A/HRC/13/56 ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១១ កថាខ័ណ្ឌទី ៣៥៥ ដល់ កថាខ័ណ្ឌទី ៣៦៩។

[១៣៨] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, របាយការណ៍របស់ក្រុមការងារទទួលបន្ទុកពិនិត្យរបាយការណ៍សកលតាមកាលកំណត់របស់កម្ពុជា A/HRC/13/4 ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១២ អនុសាសន៍ទី ៣៨, ៦០, ៦១, ៦២, ៦៣, ៦៤, ៦៥, ៦៦, ៦៧ និង ៦៨។

តាមច្បាប់ភូមិបាល ឆ្នាំ២០០១ ដោយពង្រឹងការអនុវត្តច្បាប់នេះ តាមរយៈការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ ដើម្បីស្រាយបំភ្លឺនីតិវិធីដែលពាក់ព័ន្ធនានា ក៏ដូចជា ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពនៃស្ថាប័នពាក់ព័ន្ធ ដូចជា អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់ស្រុក។[១៣៩] យោបល់ទាំងអស់នេះត្រូវបានលើកឡើងផងដែរ នៅក្នុងសេចក្តីសម្រេចចិត្ត ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[១៤០]

៧១. នៅក្នុងសេចក្តីសង្កេតចុងក្រោយ ឆ្នាំ២០១០ របស់ខ្លួន គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍ (CERD) បានសំដែងកង្វល់អំពី "របាយការណ៍ថា មានការផ្តល់សម្បទានយ៉ាងឆាប់រហ័សលើដីធ្លី ដែលជនជាតិដើមភាគតិច បាននិងកំពុងកាន់កាប់ជាប្រពៃណី ដោយគ្មានធ្វើការពិចារណាពេញលេញ ឬ ការប្រើប្រាស់អស់លទ្ធភាពនៃនីតិវិធី ដែលមានចែងក្រោមច្បាប់ភូមិបាល និងអនុក្រឹត្យពាក់ព័ន្ធ (មាត្រា២ និង មាត្រា៥)" ហើយបានស្នើថា រដ្ឋាភិបាលអនុម័តវិធានការការពារ (ដូចជា ពន្យាការផ្តល់ដីសម្បទាន)។[១៤១] គណៈកម្មាធិការនេះ បានសំដែងកង្វល់ផងដែរអំពី ការបំភិតបំភ័យ និងសកម្មភាពហឹង្សាទៅលើជនជាតិដើមភាគតិច នៅអំឡុងពេលមានការបណ្តេញចេញដោយបំពាន ឬទំនាស់ដីធ្លីដែលប៉ះពាល់ដល់ពួកគេ និងបានស្នើថា រដ្ឋាភិបាលផ្តល់កិច្ចការពារពេញលេញប្រឆាំងនឹងការវាយប្រហារលើរាងកាយ និងការបំភិតបំភ័យ នៅខណៈពេលដែលសហគមន៍នានាស្វែងរកការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីទាមទារសិទ្ធិលើដីសហគមន៍។[១៤២]

៧២. នៅក្នុងសេចក្តីសង្កេតចុងក្រោយរបស់ខ្លួនស្តីពីប្រទេសកម្ពុជា នៅក្នុងខែមិថុនាឆ្នាំ ២០១១ គណៈកម្មាធិការសិទ្ធិកុមារ (CRC) បានសំដែង "កង្វល់យ៉ាងខ្លាំងអំពីគ្រួសារប្រជាពលរដ្ឋ និងកុមាររាប់ពាន់នាក់ ជាពិសេស គ្រួសារប្រជាពលរដ្ឋក្រីក្រនៅទីប្រជុំជន កសិករប្រកបរបរកសិកម្មខ្នាតតូច និងសហគមន៍ជនជាតិដើមភាគតិច នៅតែបន្តរងនូវការដកហូតសិទ្ធិលើដីធ្លី ដោយសារតែ ការដណ្តើមយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ ពីសំណាក់បុគ្គលមួយចំនួន

[១៣៩] សេចក្តីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ១២/២៥, A/HRC/12/L.18 ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០៩ កថាខ័ណ្ឌទី ៥ (ឃ)

[១៤០] សេចក្តីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ A/HRC/១៨/L.២៥ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១១ កថាខ័ណ្ឌទី ៥ (ង)

[១៤១] សេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍៖ ប្រទេសកម្ពុជា, CERD/C/KHM/CO/8-13 ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ កថាខ័ណ្ឌទី ១៦៖ "គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវធានាថាខ្លួននឹងធ្វើឲ្យសម្រេចបាននូវតុល្យភាពដ៏ត្រឹមត្រូវរវាងការអភិវឌ្ឍន៍ និងសិទ្ធិរបស់ប្រជាពលរដ្ឋខ្លួន ហើយថា ការអភិវឌ្ឍន៍សេដ្ឋកិច្ច មិនត្រូវធ្វើឲ្យអន្តរាយដល់សិទ្ធិរបស់ជន និងក្រុមងាយរងគ្រោះដែលត្រូវបានការពារដោយអនុសញ្ញានេះ។ គណៈកម្មាធិការ ផ្តល់អនុសាសន៍ផងដែរថា រដ្ឋភាគី ត្រូវបង្កើតវិធានការការពារសមស្រប ដូចជា ការពន្យារពេលចំពោះ ការចេញផ្តល់សម្បទាននៅលើដីដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ ដែលពួកគេបានស្នើសុំចុះបញ្ជីតាមច្បាប់ដើម្បីនឹងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ហើយការអនុញ្ញាតនូវសម្បទានអាចធ្វើបាន រហូតទាល់តែមានការពិនិត្យវាយតំលៃ និង សម្រេចអំពីបញ្ហានៃប័ណ្ណកម្មសិទ្ធិសមូហភាព និងសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ ការអភិវឌ្ឍ គ្រប់គ្រង និងប្រើប្រាស់ដីសហគម៌ បន្ទាប់ពីមានការពិគ្រោះយោបល់ និងមានការយល់ព្រមជាមុនពីពួកគេ " ។

[១៤២] ដូចគ្នាខាងលើ កថាខ័ណ្ឌទី ១៧ "គណៈកម្មាធិការ ជំរុញឲ្យរដ្ឋភាគី ផ្តល់កិច្ចការពារពេញលេញចំពោះក្រុមងាយរងគ្រោះ ប្រឆាំងនឹងការវាយប្រហារលើរូបកាយ និងការគំរាមកំហែង ដោយសារពួកគេស្វះស្វែងអនុវត្តសិទ្ធិរបស់ខ្លួន និងដោយសារពួកគេមានទំនាក់ទំនងជាមួយដីសហគមន៍របស់ខ្លួន។ គណៈកម្មាធិការ ក៏ជំរុញឲ្យរដ្ឋភាគី នាំយកជនល្មើសនៃការរំលោភបំពានសិទ្ធិមនុស្សនានាទៅកាត់ទោសតាមច្បាប់។ នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យប្រព័ន្ធយុត្តិធម៌ មានភាពល្អប្រសើរឡើង រដ្ឋភាគី ត្រូវតែធានានូវប្រសិទ្ធភាពកាន់តែច្រើនឡើងនៃប្រព័ន្ធតុលាការ ក្នុងការធានាដល់ការទៅប្រើប្រាស់ប្រព័ន្ធតុលាការដោយសមភាពសម្រាប់ទាំងអស់គ្នា រាប់បញ្ចូលទាំងក្រុមជនភាគតិច និងជនជាតិដើមភាគតិច ស្របតាមអនុសាសន៍ទូទៅរបស់គណកម្មាធិការនេះ លេខ ៣១ (ឆ្នាំ២០០៥) ស្តីពី ការទប់ស្កាត់ការរើសអើងពូជសាសន៍ នៅក្នុងរដ្ឋបាល និងការប្រព្រឹត្តទៅ នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ" ។

ដែលមានអំណាច″[១៤៣] ហើយគណៈកម្មាធិការនេះបានស្នើថា កម្ពុជា "បង្កើតឲ្យមានវិធានការផ្អាកជាបណ្ដោះអាសន្ននូវការបណ្ដេញចេញ រហូតទាល់តែមានការកំណត់ច្បាស់លាស់អំពី ភាពត្រឹមត្រូវតាមច្បាប់នៃការទាមទារសិទ្ធិលើដីធ្លី ជាមុនសិន″ ។[១៤៤]

## ខ. ការវិវឌ្ឍន៍ជាអន្តរជាតិទាក់ទងនឹងការទទួលខុសត្រូវខាងសិទ្ធិមនុស្សរបស់សហគ្រាសពាណិជ្ជកម្ម

៧៣. ចាប់តាំងពីរបាយការណ៍តំណាងពិសេស (SRSG) ឆ្នាំ២០០៧ មក មានការវិវឌ្ឍន៍ជាច្រើននៅលើឆាកអន្តរ-ជាតិទាក់ទងនឹងភារកិច្ចរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដោយភាគីទីបី រាប់ទាំងវិស័យឯកជនផងដែរ និងការទទួលខុសត្រូវរបស់សហគ្រាសពាណិជ្ជកម្ម។[១៤៥] នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តជាឯកច្ឆ័ននូវគោលការណ៍ណែនាំស្ដីពីធុរៈកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិស្ដីពី "ការការពារ ការគោរព និងការដោះស្រាយ″។[១៤៦] ទោះបីជាគោល-ការណ៍នេះ មិនមែនជាឯកសារភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ក្ដី ក៏ការអនុម័តនេះបានបង្កើតគោលការណ៍ណែនាំ ដែលមានតម្លៃជាបទដ្ឋានសាកល សម្រាប់ការការពារ និងការដោះស្រាយហានិភ័យនៃផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស ពាក់ព័ន្ធនឹងសកម្មភាពរបស់ធុរកិច្ច ។[១៤៧]

---

[១៤៣] សេចក្ដីសង្កេតចុងក្រោយនៃគណៈកម្មាធិការសិទ្ធិកុមារ៖ ប្រទេសកម្ពុជា, CRC/C/KHM/CO/2 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ កថាខ័ណ្ឌទី៦១។

[១៤៤] ដូចគ្នាខាងលើ កថាខ័ណ្ឌទី ៦២ "គណៈកម្មាធិការ ជម្រុញឲ្យរដ្ឋភាគី បង្កើតបទដ្ឋានថ្នាក់ជាតិមួយ ដើម្បីផ្អាកការបណ្ដេញចេញជាបណ្ដោះអាសន្ន រង់ចាំរហូតដល់មានការសម្រេចអំពីភាពស្របច្បាប់នៃការទាមទារសិទ្ធិដីធ្លី ត្រូវបានធ្វើឡើង។ គណៈកម្មាធិការ ជម្រុញឲ្យរដ្ឋភាគី ធានាផងដែរថា ក្រុមគ្រួសារ ព្រមទាំងកូនៗរបស់ពួកគេ មិនត្រូវក្លាយជាជនគ្មានផ្ទះសម្បែង ដែលបណ្ដាលមកពីការបណ្ដេញចេញ សម្រាប់សកម្មភាពឯកជន និងការអភិវឌ្ឍន៍ នោះឡើយ។ គណៈកម្មាធិការ ផ្ដល់អនុសាសន៍ថា រដ្ឋភាគីគួរអនុវត្តឲ្យបានពេញលេញនូវ អនុសាសន៍នានារបស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ទាក់ទិននឹងការទទួលបានសិទ្ធិដីធ្លី និងជីវភាពរស់នៅសមរម្យ (A/HRC/4/36 និង A/HRC/7/42)″។

[១៤៥] មុនការអភិវឌ្ឍន៍នូវគោលការណ៍នេះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានធ្វើការជួបជុំជាសកលដោយស្ម័គ្រចិត្តមួយ (Voluntary Global Compact) នៅឆ្នាំ ២០០០ ជាវេទិការសកលមួយដែលកោះប្រជុំអ្នកជំនួញទាំងឡាយ ជាមួយភ្នាក់ងារអង្គការសហប្រជាជាតិ វិស័យការងារ និងអង្គការសង្គមស៊ីវិល ក្នុងការគាំទ្រលើ សិទ្ធិមនុស្ស ការងារ បរិស្ថាន និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។ នៅឆ្នាំ ២០០៥ គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ដែលត្រូវបានជំនួសដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅឆ្នាំ២០០៦) បានតែងតាំងតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិមួយរូប ឲ្យទទួលបន្ទុកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសពាណិជ្ជកម្ម ដទៃទៀតដែលលោកត្រូវបានផ្ដល់ឲ្យនូវអណត្តិការងារ ក្នុងការកំណត់ និងស្រាយបំភ្លឺអំពី បទដ្ឋាននៃការទទួលខុសត្រូវ និងគណនេយ្យភាព របស់សាជីវកម្មពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងអំពីតួនាទីរបស់រដ្ឋផងដែរ ។

[១៤៦] សូមមើល សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/17/L.1/Rev.1 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១។ គោលការណ៍ណែនាំស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍ឆ្នាំ ២០១១ របស់តំណាងពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស A/HRC/17/ 31, អាចរកអានបាននៅគេហទំព័រ៖ http://www2.ohchr.org/english/bodies/hrcouncil/ docs/17session/A.HRC.17.31_en.pdf

[១៤៧] ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបោះពុម្ពផ្សាយ "គោលការណ៍ណែនាំស្ដីពី ធុរកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខណ្ឌអង្គការសហប្រជាជាតិស្ដីពី 'ការការពារ ការគោរព និងដំណោះស្រាយ′″ នៅខែធ្នូ ឆ្នាំ២០១១ មានទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយដែលអាចរកបាននៅគេហទំព័រ៖ http://cambodia.ohchr.org/ WebDOCs/DocPublications/Business-and -HR-Guidelines/Business%20and%20Human%20Rights_English.pdf និង http://cambodia.ohchr.org/WebDOCs/DocPublications/ Business-and-HR-Guidelines/Business%20and%20 Human%20Rights_Khmer.pdf.

៧៤. គោលការណ៍ណែនាំនេះ មានចំនួន ៣១ បទដ្ឋាន[១៤៨] គាំទ្រដល់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយរបស់អង្គការសហប្រជាជាតិស្តីពី "ការការពារ ការគោរព និងការដោះស្រាយ"។[១៤៩] បទដ្ឋានទាំងនេះ មានមូលដ្ឋានលើការទទួលស្គាល់កាតព្វកិច្ចស្រាប់របស់រដ្ឋ ក្នុងការគោរព ការការពារ និងការបំពេញសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ អាស្រ័យហេតុនេះ បទដ្ឋានស្តីពីធុរៈកិច្ច និងសិទ្ធិមនុស្ស ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រទេសកម្ពុជា តាមរយៈការប្តេជ្ញាចិត្តតាមច្បាប់អន្តរជាតិ និងច្បាប់ជាតិរបស់ខ្លួន។ គោលការណ៍ណែនាំនេះ អនុវត្តចំពោះសហគ្រាសពាណិជ្ជកម្ម ទាំងសហគ្រាសឆ្លងដែន និងទាំងសហគ្រាសដទៃផ្សេងទៀត ដោយមិនគិតពីទំហំ វិស័យ ទីតាំង កម្មសិទ្ធិ និងរចនាសម្ព័ន្ធឡើយ។ ដូច្នេះ សហគ្រាស *ទាំងអស់* ដែលពាក់ព័ន្ធនឹងសម្បទានដីនៅកម្ពុជា (រដ្ឋម្ចាស់ផ្ទះ) រាប់ទាំងប្រតិបត្តិការរបស់សហគ្រាសពាណិជ្ជកម្ម មកពីបរទេសផង (រដ្ឋសាមី) មានការទទួលខុសត្រូវក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិ-មនុស្ស។

៧៥. ក្រុមការងារថ្មីរបស់អង្គការសហប្រជាជាតិផ្នែកធុរៈកិច្ច និងសិទ្ធិមនុស្ស ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ ដើម្បីទទួលភារៈកិច្ចលើកកំពស់គោលការណ៍ណែនាំនេះ ការអនុម័តគោលការណ៍នេះបានឈានទៅដល់ការរួមបញ្ចូលគ្នាតែមួយនូវបទដ្ឋាន និងគំនិតផ្តួចផ្តើមសកលស្តីពី ធុរៈកិច្ច និងសិទ្ធិមនុស្ស រួមមាន បទដ្ឋានរបស់ស្ថាប័ននានា ដូចជាសេចក្តីណែនាំស្តីពីការទទួលខុសត្រូវរបស់សាជីវកម្ម នៃអង្គការបទដ្ឋានអន្តរជាតិ (ISO) គោលការណ៍ណែនាំស្តីពីសហគ្រាសពហុជាតិនៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ក្របខ័ណ្ឌនិរន្តរភាពរបស់យូអិនគ្លូបលកំផែក (UN Global Compact) និងរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងចំណោមបទដ្ឋានដទៃទៀត។[១៥០]

---

[១៤៨] ទាំងនេះជាផលិតផលនៃការស្រាវជ្រាវ និងការពិគ្រោះយោបល់ទូលំទូលាយរយៈពេល ៦ ឆ្នាំ ដែលមានការចូលរួមពីរដ្ឋាភិបាល សហគ្រាសពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម អង្គការសង្គមស៊ីវិល បុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ និងវិនិយោគិន។ សេចក្តីសង្ខេបនៃការពិគ្រោះយោបល់ អាចរកបានពីក្នុងបញ្ជីនៃរបាយការណ៍របស់តំណាងពិសេសលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និង សហគ្រាសពាណិជ្ជកម្មដទៃទៀត លោកសាស្ត្រាចារ្យ ចន រ៉ាក់គី (John Ruggie)៖ http://www.ohchr.org/EN/Issues/TransnationalCorporations/ Pages/Reports.aspx ។ របាយការណ៍នេះ គូសបញ្ជាក់អំពី ដំណាក់កាលទាំងឡាយ ដែលរដ្ឋត្រូវចាត់វិធានការ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្សរបស់ធុរកិច្ច ផ្តល់បទដ្ឋានសម្រាប់ដៃគូនានានៅក្នុងការឃ្លាំមើល និងវាយតម្លៃអំពីដំណាក់កាលទាំងនេះ និងបង្ហាញអំពីរបៀប ឬមធ្យោបាយ ដែលធុរកិច្ច អាចយល់ដឹង និងបង្ហាញទៅកាន់អ្នកដទៃថា ខ្លួនគោរពសិទ្ធិមនុស្ស និងកាត់បន្ថយហានិភ័យដែលបណ្តាលមកពី ឬការចូលរួមចំណែកធ្វើឲ្យមានទុក្ខទោសដល់សិទ្ធិមនុស្ស។ របាយការណ៍នេះ ក៏មានចែងអំពីអ្វីដែលទាំងរដ្ឋ និងសហគ្រាសពាណិជ្ជកម្ម ត្រូវប្រតិបត្តិ ដើម្បីបង្កើនលទ្ធភាពនៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់បុគ្គលទាំងឡាយណាដែលបានទទួលរងទុក្ខទោស។

[១៤៩] ក្របខ័ណ្ឌគោលនយោបាយ "ការការពារ ការគោរព និងដំណោះស្រាយ" ត្រូវបានស្វាគមន៍ជាឯកច្ឆ័ន្ទ នៅឆ្នាំ២០០៨ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ រួមមាន ១)-ភារកិច្ចរបស់រដ្ឋក្នុងការការពារទប់ទល់នឹងការរំលោភសិទ្ធិមនុស្សដោយភាគីទី៣ រាប់ទាំងសហគ្រាសពាណិជ្ជកម្ម តាមរយៈ គោលនយោបាយ បទប្បញ្ញត្តិច្បាប់ និងការវិនិច្ឆ័យ។ ២)-ការទទួលខុសត្រូវរបស់សាជីវកម្ម ក្នុងការគោរពសិទ្ធិមនុស្ស ដែលមានន័យថា សហគ្រាសពាណិជ្ជកម្មត្រូវប្រព្រឹត្តដោយត្រឹមត្រូវ ជៀសវាងការរំលោភសិទ្ធិនានារបស់អ្នកដទៃ និងដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃសកម្មភាពរបស់ពួកគេ។ និង ៣)-សេចក្តីត្រូវការឲ្យមាននូវការទទួលបានដំណោះស្រាយកាន់តែប្រសើរឡើងចំពោះជនរងគ្រោះដែលទទួលរងការរំលោភបំពានពីធុរកិច្ច ទាំងតាមប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ។ សូមមើល "ការការពារ ការគោរព និងដំណោះស្រាយ៖" ក្របខ័ណ្ឌសម្រាប់ធុរកិច្ច និងសិទ្ធិមនុស្ស, របាយការណ៍តំណាងពិសេសលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសពាណិជ្ជកម្មដទៃទៀត (A/HRC/8/5) និងសេចក្តីសង្ខេបនៃ កិច្ចចរចានៃ ដៃគូពហុភាគី ៥ភាគី (Five Multi-Stakeholders Negotiations) (A/HRC/8/5/Add.1) ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨។

[១៥០] របាយការណ៍របស់ក្រុមការងារអង្គការសហប្រជាជាតិទទួលបន្ទុកខាងធុរកិច្ច និងសិទ្ធិមនុស្ស A/HRC/20/29 ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ សូមមើលគេហទំព័រ៖ http://www.ohchr.org/Documents/Issues/Business/A.HRC.20.29_AEV.pdf.

៧៦. គោលនយោបាយឆ្នាំ ២០១១ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងបទដ្ឋានប្រតិបត្តិស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន ទទួលស្គាល់ "ការយល់ជារួមជាអន្តរជាតិមួយបានលេចត្រដែតឡើង ដែលថា វិស័យឯកជន មានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស" រាប់ទាំងការព្យាយាមជួយបិទភ្ជិតចន្លោះប្រហោងខាងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបំពានផងដែរ។[១៥១] ហើយនៅពេលថ្មីៗបំផុតនេះ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានប្រកាសថា ការសិក្សាតាមគោលរឿងដំបូង ដោយគណៈកម្មការអន្តររដ្ឋាភិបាលថ្មីស្តីពីសិទ្ធិមនុស្សខ្លួននឹងផ្តោតជាសំខាន់លើវិស័យធុរៈកិច្ច និងសិទ្ធិមនុស្ស ក្នុងលក្ខណៈមួយដែលស្របទាំងស្រុងទៅនឹងក្របខ័ណ្ឌអង្គការសហប្រជាជាតិជាពិសេសគោលការណ៍ណែនាំនេះ។[១៥២] បណ្តុំនៃបទដ្ឋានទាំងនេះ អនុវត្តដោយផ្ទាល់ចំពោះបរិបទកម្ពុជា ជាពិសេសចំពោះសហគ្រាសពាណិជ្ជកម្មដីច្រើនសន្ធឹកសន្ធាប់ (រាប់ទាំងសហគ្រាសជាតិ និងអន្តរជាតិ និងសហគ្រាសទាំងឡាយដែលរដ្ឋគ្រប់គ្រងមួយផ្នែក ឬទាំងមូល) ដែលពាក់ព័ន្ធនឹងសម្បទានដី។[១៥៣]

## គ. បទដ្ឋានអន្តរជាតិ សម្រាប់ការបង្ការ និងការដោះស្រាយផលប៉ះពាល់សិទ្ធិមនុស្ស

៧៧. មានបទដ្ឋានច្រើនអនេក ដែលចែងអំពីកាតព្វកិច្ចច្បាប់អន្តរជាតិរបស់រដ្ឋនានាក្នុងការដោះស្រាយហេតុប៉ះពាល់សង្គម និងបរិស្ថាន។[១៥៤] មានបទដ្ឋានមួយចំនួនផងដែរ ទាក់ទងនឹងអំពើពុករលួយ និងសិទ្ធិទទួលបានព័ត៌មាន និង

---

[១៥១] សូមមើល សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) "បច្ចុប្បន្នភាពនៃគោលនយោបាយ និងបទដ្ឋានអនុវត្តស្តីពី និរន្តរភាពបរិស្ថាន និងសង្គម និងគោលនយោបាយស្តីពីការទទួលបានព័ត៌មាន របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ" ខែមេសា ឆ្នាំ២០១២ កថាខ័ណ្ឌទី៩ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖ "មានការលេចឡើងនូវការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទជាលក្ខណៈអន្តរជាតិមួយថា វិស័យឯកជន ត្រូវមានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស។ សាជីវកម្មជាច្រើន មិនថាជាអតិថិជន ឬមិនមែនជាអតិថិជន របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ កាន់តែទទួលស្គាល់ច្រើនឡើងៗអំពីភាពសំខាន់នៃការធ្វើសមាហរណកម្មកាន់តែខ្លាំងឡើងនូវសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងធុរកិច្ច ទៅក្នុងសកម្មភាពនៃការអនុវត្តត្រឹមត្រូវរបស់ខ្លួន។ គោលនយោបាយនិរន្តរភាពបច្ចុប្បន្នកម្ម បានស្នើឡើងថា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បន្តពឹងផ្អែកលើបទដ្ឋានអនុវត្ត ដែលគ្របដណ្តប់យ៉ាងពេញលេញលើបញ្ហាសិទ្ធិមនុស្សដែលពាក់ព័ន្ធទៅនឹងធុរកិច្ច។ ទោះជាយ៉ាងនេះក្តី សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក៏បានដាក់សំណើផងដែរ ឲ្យមានការទទួលស្គាល់យ៉ាងច្បាស់លាស់អំពី ការទទួលខុសត្រូវរបស់វិស័យឯកជន នៅក្នុងការគោរពសិទ្ធិមនុស្ស និងទទួលស្គាល់ថា វាអាចមានភាពសមស្របសម្រាប់អតិថិជនរបស់ខ្លួន នៅក្នុងការប្រតិបត្តិនីតិវិធីដ៏ត្រឹមត្រូវជាបន្ថែមទៀត នៅក្នុងកាលៈទេសៈនៃការមានហានិភ័យខ្ពស់មួយចំនួន។ មានភាពខ្វះចន្លោះជាក់លាក់មួយចំនួន នៅក្នុងបទដ្ឋានអនុវត្តនាពេលបច្ចុប្បន្ន ដូចជា ការជួញដូរមនុស្ស ការបណ្តេញចេញដោយបំពាន និង សិទ្ធិទទួលបានមរតកវប្បធម៌របស់សហគមន៍ ត្រូវបានបំពេញចូលទៅក្នុងបទដ្ឋានអនុវត្តដែលបានស្នើឡើងនេះហើយ។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានធ្វើការជាមួយមន្ត្រី និងអ្នកគ្រប់គ្រងធនាគារ ដើម្បីអភិវឌ្ឍន៍វិធីសាស្ត្រនេះ និងលើភាសាជាក់លាក់មួយ"។

[១៥២] កំណត់សំគាល់ដោយលោក រ៉ាហ្វិនឌី ដ្យាមីន (Rafendi Djamin) តំណាងរបស់ប្រទេសឥណ្ឌូនេស៊ី នៅគណៈកម្មការអន្តររដ្ឋាភិបាល ស្តីពីសិទ្ធិមនុស្សរបស់អាស៊ាន នាវេទិកាអាស៊ីប៉ាស៊ីហ្វិកនៃសន្និសីទថ្នាក់តំបន់នៃវិទ្យាស្ថានសិទ្ធិមនុស្សថ្នាក់ជាតិ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស នៅថ្ងៃទី ១១-១៣ ខែតុលា ឆ្នាំ២០១១ នៅទីក្រុងសេអ៊ូល កូរ៉េខាងត្បូង។

[១៥៣] មានការកត់សំគាល់ផងដែរថា គណៈកម្មាធិការបំបាត់ការរើសអើងពូជសាសន៍ នៅក្នុងសេចក្តីសង្កេតចុងក្រោយរបស់ខ្លួនឆ្នាំ ២០១០ បានលើកទឹកចិត្តដល់ស្ថាប័នពាណិជ្ជកម្មទាំងឡាយដែលពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច "ធ្វើការពិចារណាទៅលើការទទួលខុសត្រូវផ្នែកសង្គម ចំពោះសាជីវកម្មរបស់ខ្លួន ដោយសារតែវាទាក់ទងជាមួយនឹងសិទ្ធិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន"។ សូមមើល CERD/C/KHM/CO/8-13 កថាខ័ណ្ឌទី១៧ ។

[១៥៤] បន្ថែមលើកាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិ សេចក្តីយោងនានា អាចរកបាននៅក្នុងច្បាប់បរិស្ថានអន្តរជាតិ ឧទាហរណ៍ អនុសញ្ញាស្តីពីជីវចម្រុះ ដែលប្រទេសកម្ពុជា បានយល់ព្រមនៅឆ្នាំ ១៩៩៥។ មាត្រា ៨ គ្របដណ្តប់លើ ការបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិមួយ និងមាត្រា ១៤ គ្របដណ្តប់លើការវាយតម្លៃពីផលប៉ះពាល់ និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ។

តម្លាភាពដោយចំៗ។[១៥៥] ម្យ៉ាងវិញទៀត ក្រោមកាតព្វកិច្ចអន្តរជាតិ សហគ្រាសពាណិជ្ជកម្មទាំងអស់ត្រូវអនុវត្តគោលការណ៍នៃ "ការយកចិត្តទុកដាក់ត្រឹមត្រូវ" ដែលត្រូវកំណត់ បង្ការ កាត់បន្ថយ និងបង្ហាញពីភាពត្រឹមត្រូវក្នុងការដោះស្រាយផលប៉ះពាល់អវិជ្ជមានរបស់ខ្លួនទៅលើសិទ្ធិមនុស្ស។[១៥៦] មិនត្រឹមតែសហគ្រាសពាណិជ្ជកម្មទេ ដែលត្រូវមានការទទួលខុសត្រូវនេះ ប៉ុន្តែរដ្ឋនានាត្រូវបានតម្រូវឲ្យការពារប្រឆាំងនឹងការរំលោភបំពាន តាមរយៈគោលនយោបាយ និងបទបញ្ញត្តិដែលមានប្រសិទ្ធភាពទាក់ទងនឹងសកម្មភាពរបស់ធុរកិច្ច។ ដូចបានកត់សំគាល់ពីខាងដើម រដ្ឋទាំងឡាយ មានភារកិច្ចការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សពីសំណាក់ភាគីទីបីនៅក្នុងប្រទេស ឬ តំបន់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ លើសពីនេះទៀត រដ្ឋនានា ត្រូវបានតម្រូវដោយកាតព្វកិច្ចអន្តរជាតិឲ្យធ្វើការត្រួតពិនិត្យឲ្យបានគ្រប់គ្រាន់ នៅពេលចុះកិច្ចសន្យាជាមួយ ឬ ធ្វើច្បាប់សម្រាប់សហគ្រាសពាណិជ្ជកម្មផ្សេងៗ។[១៥៧]

៧៨. កិច្ចដំណើរការសម្រាប់ទាំង រដ្ឋ និងសហគ្រាសពាណិជ្ជកម្ម គួរបញ្ចូលនូវ ការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សជាក់ស្តែង និងដែលអាចកើតមាន ការដាក់បញ្ចូល និងចាត់វិធានការទៅលើបញ្ហាដែលបានរកឃើញ ការតាមដាន ការឆ្លើយតប និងការសន្ទនាគ្នាអំពីរបៀបដោះស្រាយផលប៉ះពាល់។[១៥៨] ការវាយតម្លៃនេះអនុវត្តទាំងអស់ ទាំងចំពោះគម្រោងដែលរដ្ឋជាអ្នកប្រតិបត្តិការ ទាំងគម្រោងដែលអ្នកផ្តល់ជំនួយប្រតិបត្តិការ និងទាំងចំពោះសហគ្រាសពាណិជ្ជកម្មផ្សេងៗ ដោយមិនគិតពីទំហំ (ទោះជាវាជា សាជីវកម្មឆ្លងដែន សាជីវកម្មពហុជាតិ ឬ សហគ្រាសខ្នាតតូច ឬ ខ្នាតមធ្យម) វិស័យ រចនាសម្ព័ន្ធ សិទ្ធិកម្មសិទ្ធិ ឬ ប្រទេសដែលសាជីវកម្ម ឬ សហគ្រាសនោះតាំងនៅ ឬ ធ្វើប្រតិបត្តិការ (កម្ពុជា ឬបរទេស)។ ក្នុងបរិបទនៃសម្បទានដី គេអាចសំដៅដោយផ្ទាល់ដល់ផលប៉ះពាល់បរិស្ថាន និងសង្គម ការវាយតម្លៃពាក់ព័ន្ធនឹងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យអំពីផលដែលអាចប៉ះពាល់ដល់ក្រុម និងអ្នកពាក់ព័ន្ធដទៃផ្សេងទៀត។

៧៩. ម្យ៉ាងវិញទៀត ការវាយតម្លៃផលប៉ះពាល់ គួរតែជាដំណើរការមួយដែលមានការចូលរួម ហើយការធ្វើផែនការអភិវឌ្ឍន៍ទៀតសោធន៍ គួរតែរួមបញ្ចូលបុគ្គលទាំងឡាយដែលនឹងរងផលប៉ះពាល់។ ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាល (ICCPR) និងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) ទទួលស្គាល់សិទ្ធិបុគ្គល និងប្រជាជនគ្រប់រូប ក្នុងការ "បន្តការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនដោយសេរី"។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពី សិទ្ធិអភិវឌ្ឍន៍[១៥៩] បង្កើតនូវមូលដ្ឋានសម្រាប់ការចូលរួម និងការពិគ្រោះយោបល់ក្នុងដំណើរការអភិវឌ្ឍន៍ ដែលត្រូវបានបំពេញបន្ថែម ដោយចែងយោងក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលលើកកំពស់ការយល់ព្រមដោយសេរីជាមុន និងដោយមាន

---

[១៥៥] សន្ធិសញ្ញាប្រឆាំងអំពើពុករលួយរបស់អង្គការសហប្រជាជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ការយល់ព្រមកាលពីខែកញ្ញា ឆ្នាំ២០០៧ ជាឧទាហរណ៍ ការរៀបរាប់អំពីលក្ខខណ្ឌតម្រូវនូវការរាយការណ៍ជាសាធារណៈ ដែលមានកំណត់នៅក្នុងមាត្រា១០ និងការចូលរួមរបស់សង្គម ដែលមានកំណត់នៅក្នុងមាត្រា ១៣។

[១៥៦] គោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស កថាខ័ណ្ឌទី ១៧ ដល់ កថាខ័ណ្ឌទី ២៤។

[១៥៧] ដូចគ្នាខាងលើ មាត្រា ៥។

[១៥៨] ដូចគ្នាខាងលើ មាត្រា ១៧។

[១៥៩] សេចក្តីសំរេចចិត្តរបស់អង្គការសហប្រជាជាតិ A/RES/41/128 ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨៦ មាត្រា ១ ចែងថា "ជនគ្រប់រូប មានសិទ្ធិចូលរួមចែករំលែក និងទទួលផលពីការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និង នយោបាយ"។

ព័ត៌មានគ្រប់គ្រាន់។[១៦០] ភាសានេះ ត្រូវបានបញ្ចូលទៅក្នុងបទដ្ឋានអន្តរជាតិដទៃទៀត ឧទាហរណ៍ គោលនយោបាយ បច្ចុប្បន្នកម្ម ឆ្នាំ ២០១១ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងបទដ្ឋានប្រតិបត្តិស្តីពីនិរន្តរភាពសង្គម និង បរិស្ថាន។[១៦១]

៨០. ក្រៅពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់រដ្ឋ និងសហគ្រាសពាណិជ្ជកម្ម មានហេតុផលជាក់ស្តែង ហេតុផលខាងប្រតិបត្តិការ និងភស្តុភា សម្រាប់ការរួមបញ្ចូលលក្ខខណ្ឌតម្រូវទាំងនេះទៅក្នុងសកម្មភាពពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ ហើយរដ្ឋាភិបាលជាច្រើនបានបញ្ចូលបទដ្ឋានទាំងនេះ ទៅក្នុងគោលនយោបាយ និងច្បាប់ជាតិរបស់ខ្លួន និងមានក្រុមហ៊ុនជាច្រើន ក៏បានបញ្ចូលបទដ្ឋានទាំងនេះទៅក្នុងបទដ្ឋានប្រតិបត្តិការរបស់ខ្លួនផងដែរ។[១៦២]

# V. ទិដ្ឋភាពទូទៅនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀតនៅកម្ពុជា

## ក. ចំនួនផ្លូវការនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតដែលបានផ្តល់ (ទិដ្ឋភាពទូទៅ)

៨១. យោងតាមស្ថិតិផ្លូវការដែលមានសម្រាប់ឆ្នាំ ១៩៩៨ លើផ្ទៃដីសរុប ១៨,១ លានហិកតា របស់កម្ពុជា ដែលក្នុងនោះមានផ្ទៃដី ៦,៥ លានហិកតា ជាដីដែលអាចដាំដុះបាន និងផ្ទៃដីរហូតដល់ ២,៧ លានហិកតា ជាដីដែលអាចបង្កបង្កើនផលបានគួរសម។[១៦៣] ចំនួនសម្បទានដីសេដ្ឋកិច្ច ដែលបានរាយបញ្ជីឈ្មោះក្នុងរបាយការណ៍តំណាងពិសេសទាំងពីរកន្លងមក បានផ្អែកលើព័ត៌មានផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រភពព័ត៌មានផ្លូវការផ្សេងទៀត រាប់ទាំងអាជ្ញាធរមូលដ្ឋានផងដែរ។ របាយការណ៍តំណាងពិសេសឆ្នាំ ២០០៤ បានរាយបញ្ជីឈ្មោះសម្បទានដីសេដ្ឋកិច្ច ចំនួន ៦៤ ដែលបានផ្តល់ ឬ ដែលបានអនុម័តយល់ព្រមនៅក្នុង ១៣ ខេត្ត។ ផ្អែកលើព័ត៌មានពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដែលបានផ្តល់ជូននៅដើមឆ្នាំ២០០៧ បង្ហាញថា ចាប់ពី ឆ្នាំ ១៩៩២ ដល់ខែធ្នូ ឆ្នាំ ២០០៦ រដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ច ចំនួន៩៧ ក្នុង ១៦ ខេត្ត/ក្រុង។ ក្នុងនោះមានសម្បទានចំនួន ៩ ដែលគណៈរដ្ឋមន្ត្រីបានឯកភាពជាគោលការណ៍ ដែលគ្រប់ដណ្តប់លើផ្ទៃដី ៦៤.២០៨ ហិកតា។ របាយការណ៍តំណាងពិសេសឆ្នាំ ២០០៧ បានរាយបញ្ជីឈ្មោះសម្បទានដីសេដ្ឋកិច្ច ចំនួន៥៩ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ

---

[១៦០] សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) មាត្រា ៣២ (២)។ សម្រាប់ការណែនាំការអនុវត្តជាក់ស្តែង សូមមើល Oxfam *គោលការណ៍ណែនាំស្តីពីការយល់ព្រមដោយសេរី និងបានប្រាប់ឲ្យដឹងជាមុន* ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០។

[១៦១] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បទដ្ឋានអនុវត្ត ចំណុចទី ៧។

[១៦២] សម្រាប់សេចក្តីអត្ថាធិប្បាយស្តីពី អត្ថប្រយោជន៍នៃគោលនយោបាយសិទ្ធិមនុស្សសម្រាប់ធុរកិច្ច សូមមើល មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស "សេចក្តីអត្ថាធិប្បាយស្តីពីគោលនយោបាយសិទ្ធិមនុស្ស" នៅគេហទំព័រ៖ http://www.business-humanrights.org/ToolsGuidancePortal/Policies/Commentaries ហើយចំពោះបញ្ជីឈ្មោះក្រុមហ៊ុន ដែលបានដាក់បញ្ចូលសិទ្ធិមនុស្សទៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន សូមមើល "សេចក្តីថ្លែងការណ៍គោលនយោបាយរបស់ក្រុមហ៊ុនស្តីពីសិទ្ធិមនុស្ស" នៅលើគេហទំព័រ៖ http://www.business-humanrights.org/Documents/Policies. សម្រាប់បញ្ជីឈ្មោះក្រុមហ៊ុនដែលជាសមាជិកនៃកិច្ចផ្តួចផ្តើមជាសកលស្តីពីសិទ្ធិមនុស្ស (Global Business Initiative on Human Rights) សូមមើលគេហទំព័រ៖ http://www.global-business-initiative .org/ Members.html ។ ក្នុងចំណោមសមាជិកទាំងអស់នេះ យ៉ាងហោចណាស់មានក្រុមហ៊ុន Chevron, ក្រុមហ៊ុន Sime Darby, ក្រុមហ៊ុន General Electric, ក្រុមហ៊ុន Unilever, ក្រុមហ៊ុន Coca Cola, ក្រុមហ៊ុន Novo Nordisk, និង ក្រុមហ៊ុន Total ដែលប្រតិបត្តិការនៅកម្ពុជា។

[១៦៣] សូមមើលវិទ្យាស្ថានជាតិស្ថិតិ *ជំរឿនប្រជាពលរដ្ឋទូទៅនៅកម្ពុជា ឆ្នាំ១៩៩៨ ចំនួនសរុបបណ្តោះអាសន្ននៃប្រជាពលរដ្ឋ* ទំព័រ ៣។ វិទ្យាស្ថានធនធានអភិវឌ្ឍន៍កម្ពុជា ការសិក្សាស្រាវជ្រាវអំពី *ការកាន់កាប់ដីធ្លីនៅកម្ពុជា៖ បច្ចុប្បន្នភាពនៃទិន្នន័យ* ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០១ បានបញ្ជាក់ថា មានដីកសិកម្ម ទំហំ ៣,៩ លាន ហិកតា។

ឆ្នាំ២០០៦ (កិច្ចសន្យាសម្បទានជាច្រើន ត្រូវបានលុបចោល ចាប់ពីឆ្នាំ១៩៩២ ដល់ចុងឆ្នាំ ២០០៦) ដែលគ្របដណ្តប់លើផ្ទៃដីទំហំ ៩៤៣.០៦៩ ហិកតា ក្នុង ១៥ ខេត្ត។

៨២. ទិន្នន័យផ្លូវការដែលមានជាសាធារណៈតែមួយគត់អំពី សម្បទានដីសេដ្ឋកិច្ច ត្រូវបានបង្ហោះលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ប៉ុន្តែព័ត៌មានដែលផ្តល់ឲ្យរួមទាំង ព័ត៌មានរបស់ក្រុមហ៊ុន មិនបានធ្វើបច្ចុប្បន្នភាពទៀងទាត់ឡើយ ហើយទិន្នន័យអំពីសម្បទានដីសេដ្ឋកិច្ច មិនបានផ្តល់ឲ្យពេញលេញទេ។ ក្នុងខែមិថុនា ឆ្នាំ ២០១២ មានតារាងស្ថិតិមួយស្តីពីក្រុមហ៊ុនវិនិយោគដីសម្បទានដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ត្រូវបានបង្ហោះលើគេហទំព័ររបស់ក្រសួងនេះ ដែលតារាងនេះមានរាយបញ្ជីឈ្មោះក្រុមហ៊ុនចំនួន ១១៧ ដោយមានផ្ទៃដីទំហំ ១.១៨១.៥២២ ហិកតា ដែលត្រូវបានផ្តល់សម្បទាន ចាប់ពីខែមករា ឆ្នាំ១៩៩៦ ដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០១២។[១៦៤] តារាងនេះមានរាយបញ្ជីឈ្មោះ ក្រុមហ៊ុនចំនួន ២៤ ដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅក្នុងឆ្នាំ២០១១ មានក្រុមហ៊ុនចំនួន ១៥ ក្នុងឆ្នាំ២០១០ មានក្រុមហ៊ុនចំនួន ១៨ ក្នុងឆ្នាំ ២០០៩ មានក្រុមហ៊ុនចំនួន ១៥ ក្នុងឆ្នាំ ២០០៨ មានក្រុមហ៊ុនចំនួន ៥ ក្នុងឆ្នាំ ២០០៧ មានក្រុមហ៊ុនចំនួន ១៧ ក្នុងឆ្នាំ ២០០៦ មានក្រុមហ៊ុនចំនួន ៨ ក្នុងឆ្នាំ ២០០៥ មានក្រុមហ៊ុនចំនួន ២ ក្នុងឆ្នាំ ២០០៤ មានក្រុមហ៊ុនចំនួន ៦ ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០១ និងមានក្រុមហ៊ុនចំនួន ៧ ចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ១៩៩៩។ តារាងស្ថិតិរាយបញ្ជីឈ្មោះក្រុមហ៊ុនចំនួន ៤ ដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ក្នុងឆ្នាំ ២០១២ ដែលកិច្ចសន្យាមួយ ក្នុងចំណោមនោះបានចុះក្រោយបទបញ្ជាចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីការផ្អាកជាបណ្តោះអាសន្នការផ្តល់ដីសម្បទានសេដ្ឋកិច្ច។[១៦៥] យោងតាមអនុក្រឹត្យដែលបានបោះពុម្ពផ្សាយក្នុងព្រះរាជកិច្ច ដោយគណៈរដ្ឋមន្ត្រី មានសម្បទានដីសេដ្ឋកិច្ចចំនួន ៥ ផ្សេងទៀត ដែលត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឯកជន នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ដែលសម្បទានដីទាំងនេះស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។[១៦៦] ដោយសារភាពមិនប្រក្រតីនៃទិន្នន័យផ្លូវការដែលមានស្រាប់ ដូច្នេះចំនួនសម្បទានដីទាំងអស់ដែលអាចជឿទុកចិត្តបាន គឺមិនមាននោះទេ។

៨៣. ទោះបីជាទិន្នន័យអំពីសម្បទានដីសេដ្ឋកិច្ច ដែលមាននៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ ត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងខែមិថុនា ឆ្នាំ ២០១២ ហើយក្តី ក៏តារាងស្ថិតិសម្បទានដីសេដ្ឋកិច្ច មិនបានបញ្ចូល

---

[១៦៤] ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ, "ព័ត៌មាន" សម្បទានដីសេដ្ឋកិច្ច មានតែជាភាសាអង់គ្លេស ចូលមើលចុងក្រោយ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២៖ http://www.elc.maff.gov.kh/en/news/122-2012-06-25-12-13-35.html

[១៦៥] យោងតាមតារាងស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រុមហ៊ុនចិនមួយឈ្មោះ ឆាយណា ហ្គ្រេត ខូស (China great Cause) ត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ច ទំហំ ៥.៩៨០ ហិកតា សម្រាប់ដាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម នៅខេត្តព្រះវិហារ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ ២០១២។

[១៦៦] អនុក្រឹត្យ បានកំណត់ដីនៅក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ឲ្យក្រុមហ៊ុនឯកជន។ សម្បទានដីដែលត្រូវបានផ្តល់ទាំងនោះមានដូចតទៅ៖ ក្រុមហ៊ុន A2A ថោន (A2A Town) ទំហំ ៧,៦៦៨ ហិកតា សម្រាប់ទេសចរណ៍ធម្មជាតិ នៅឧទ្យានជាតិគិរីរម្យ នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ ២០១២, ក្រុមហ៊ុន BSC អ៊ីមផត អិចផត ខូអិលធីឌី (BSC Import Export Co., Ltd) ទំហំ ៤.៥៥៧ ហិកតា សម្រាប់ដំណាំកសិ-ឧស្សាហកម្ម នៅដែនជម្រកសត្វព្រៃរនាមដូនសំ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២, ក្រុមហ៊ុន ឃុន សៀ អ៊ីមផត អិចផត (Khun Sea Import Export) ទំហំ ៨.២០០ ហិកតា សម្រាប់ដំណាំកៅស៊ូ នៅដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២, ក្រុមហ៊ុន មេត្រីភាព កសិ-ឧស្សាហកម្ម ទំហំ ៨.៥២០ ហិកតា សម្រាប់ដំណាំកៅស៊ូ និងចិញ្ចឹមសត្វ នៅដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២, ក្រុមហ៊ុន វ័ត្ន សុខន អ៊ិនខមភើរេសិន ទំហំ ៩.០០០ ហិកតា សម្រាប់ដំណាំកៅស៊ូ នៅក្នុងដែនជម្រកសត្វព្រៃលំផាត់ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២, និងក្រុមហ៊ុន លឹម រ៉ូយ៉ាល់ ជ័ញ ស្តុក (Lim Royal Joint Stock) ទំហំ ៩.០៦៨ ហិកតា សម្រាប់ដំណាំកសិ-ឧស្សាហកម្ម នៅដែនជម្រកសត្វព្រៃភ្នំព្រេច នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២។

ចំនួនច្រើនក្រាសក្រៃលនៃសម្បទានដីកសិកម្ម ដែលគេដឹងថាមាន ដែលក្នុងករណីខ្លះសម្បទានដីទាំងនោះ ត្រូវបានផ្តល់ឲ្យរយៈពេលជាច្រើនឆ្នាំមកហើយ។ ភាគច្រើននៃការអភិវឌ្ឍន៍ទាំងនេះ រាប់ទាំងសម្បទានដីដែលបានផ្តល់ នៅក្នុងតំបន់ការពារធម្មជាតិ គឺជាគម្រោង ឬ សម្បទានដី ដែលត្រូវបានអនុក្រឹត្យ ចេញកំណត់តំបន់ទាំងនេះ ជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ការវិនិយោគលើវិស័យកសិកម្ម។ វាអាចថា សម្បទានទាំងនេះ ត្រូវបានផ្តល់ឲ្យក្រុមហ៊ុន ដោយអាជ្ញាធរផ្សេងក្រៅពីក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ ដោយហេតុនេះហើយទើបសម្បទានទាំងនេះ មិនត្រូវបានបញ្ចូលទៅក្នុងតារាងស្ថិតិសម្បទានដីសេដ្ឋកិច្ចរបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ ប៉ុន្តែប្រការដែលជាកង្វល់ខ្លាំងនោះគឺ គម្រោងទាំងនេះមិនត្រូវបានចងក្រងជាឯកសាររឹងមាំនិងស្របគ្នាជាផ្លូវការទេ។

៨៤. ចំពោះការផ្តល់សម្បទានដីសង្គមកិច្ចវិញ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាយការណ៍ថា បានបែងចែកដីធ្លីដល់ប្រជាពលរដ្ឋស៊ីវិលផង និងអតីតយុទ្ធជនផង។ ឧទាហរណ៍ ក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ក្រៅពីការផ្តល់ដីជាអំណោយនោះ កម្មវិធីសម្បទានដីសង្គមកិច្ច បានបែងចែកដីធ្លីជូនប្រជាពលរដ្ឋចំនួន ៥០ គ្រួសារ ក្នុងខេត្ត កំពត, ២៨៨ គ្រួសារ ក្នុងខេត្តឧត្តរមានជ័យ, ១៧៤ គ្រួសារ ក្នុងខេត្តស្វាយរៀង និង ២២៥ គ្រួសារ ក្នុងខេត្ត កំពង់ចាម។ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍នានា គ្រួសារប្រជាពលរដ្ឋជាច្រើនទៀតបានទទួលដីធ្លី ដែលក្នុងនោះមាន ២.២៨៥ គ្រួសារ ក្នុងខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តកំពង់ធំ (ដោយមានការជួយឧបត្ថម្ភគាំទ្រពីអង្គការ ជីអាយហ្សេត (GIZ)), មាន ៥១០ គ្រួសារ ក្នុងខេត្តបាត់ដំបង (ដោយមានការជួយឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន (JICA)), និង ៤០៥ គ្រួសារទៀត ក្នុងខេត្តបាត់ដំបង (ដោយមានការឧបត្ថម្ភពីអង្គការលំនៅ ដ្ឋានមនុស្សជាតិ), ៥១០ គ្រួសារ ក្នុងខេត្តកំពង់ស្ពឺ (ដោយមានការជួយឧបត្ថម្ភគាំទ្រពីអង្គការជីវិតថ្លៃថ្នូរ) និង ៨៩៣ គ្រួសារ ក្នុងខេត្តកំពង់ឆ្នាំង (ដោយមានការជួយឧបត្ថម្ភគាំទ្រពីអង្គការជីវិតថ្លៃថ្នូរ)។ ក្នុងទម្រង់នៃការធ្វើនិយ័តកម្មដីរដ្ឋ ក្នុងតំបន់ព្រៃ មានផ្ទៃដីទំហំ ១១.៨២៨ ហិកតា ត្រូវបានបែងចែកឲ្យប្រជាពលរដ្ឋចំនួន ៣.៧៩០ គ្រួសារ ក្នុងខេត្ត ក្រចេះ, ផ្ទៃដីទំហំ ៦.២៥៧ ហិកតា បែងចែកឲ្យប្រជាពលរដ្ឋចំនួន ៤.២៣៩ គ្រួសារ ក្នុងខេត្តបន្ទាយមានជ័យ, ផ្ទៃដី ទំហំ ៤.៩២៩ ហិកតា ឲ្យប្រជាពលរដ្ឋចំនួន ២.១៥៣ គ្រួសារ ក្នុងខេត្តកំពង់ចាម, ផ្ទៃដីទំហំ ២២២ ហិកតា ឲ្យប្រជា ពលរដ្ឋចំនួន ២៧០ គ្រួសារ ក្នុងខេត្តឧត្តរមានជ័យ ហើយនិងទំហំដីច្រើនហិកតាទៀត ដែលគ្មានតួលេខច្បាស់លាស់ ត្រូវបានបែងចែកឲ្យប្រជាពលរដ្ឋចំនួន ៣.៤៧៦ គ្រួសារ ក្នុងខេត្តបាត់ដំបង។ តាមរបាយការណ៍របស់ក្រសួងនេះ ផ្ទៃដីសរុបដែលបានបែងចែកឲ្យគ្រួសារប្រជាពលរដ្ឋក្រីក្រតាមគ្រប់រូបភាព មានទំហំ ១៩៤.៨២០ ហិកតា ឲ្យដល់ប្រជាពលរដ្ឋចំនួន ៣០.៥៨៨ គ្រួសារ រាប់ទាំងផ្ទះសម្បែងចំនួន ៣.៩៦៥ ខ្នងទៀត។[១៦៧] ក្រសួងនេះ បានរាយការណ៍ផងដែរអំពីដំណើរការនៃការផ្តល់សម្បទានដីដល់អតីតយុទ្ធជន យុទ្ធជនពិការ និងគ្រួសារយុទ្ធជនពលី។

៨៥. វិស័យឧស្សាហកម្មនិស្សារណកម្មរបស់កម្ពុជា (រាប់ទាំងការទាញយកប្រេងឆៅ ឧស្ម័នធម្មជាតិ និងរ៉ែ) និងវិស័យថាមពល ដែលបច្ចុប្បន្នកំពុងដំណើរការពង្រីក។ វិស័យរ៉ែ ដែលបច្ចុប្បន្ន មានរាប់ទាំងប្រតិបត្តិការទាញយករ៉ែ និងការផលិតសម្ភារៈទ្រង់ទ្រាយតូច ជាពិសេសប្រតិបត្តិការទាំងឡាយដែលទាក់ទងនឹងឧស្សាហកម្មសំណង់ ឧទាហរណ៍ គ្រួស ថ្មកំបោ និងខ្សាច់ ក៏ដូចជាការរុករករ៉ែបុកស៊ីត និងរ៉ែមាស។ បើតាមអង្គការ អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) និងបណ្តាញផលប៉ះពាល់បរិស្ថាន និងសង្គមដោយឧស្សាហកម្មនិស្សារណកម្ម (EISEI) មាន

[១៦៧] លិខិតពីឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជូនចំពោះលោក សុរិយា ស៊ូបេឌី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២។

ក្រុមហ៊ុនរ៉ែ ចំនួន ១៦៧ បានទទួលអាជ្ញាប័ណ្ណស្វែងរុករកធនធានរ៉ែ គិតត្រឹមខែឧសភា ឆ្នាំ២០១០។[១៦៨] ចំណែកវិស័យប្រេងវិញ បច្ចុប្បន្នកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលស្វែងរុករក ហើយគេហទំព័ររបស់អាជ្ញាធរប្រេងកាតជាតិកម្ពុជា រាយបញ្ជីឈ្មោះប្រតិបត្តិការនៅក្នុងដែនទឹក និងដែនគោក ដែលកំពុងស្ថិតក្នុងការសិក្សា។[១៦៩]

៨៦. ចំណែកឯវិស័យវារីអគ្គីនីវិញ នាបច្ចុប្បន្ននេះ មានទំនប់វារីអគ្គីសនីចំនួនបី កំពុងតែប្រតិបត្តិការនៅកម្ពុជា គឺ វារីអគ្គីសនីគីរីរម្យ ១ (កម្លាំង១២ មេកាវ៉ាត់) ក្នុងខេត្តកំពង់ស្ពឺ, វារីអគ្គីសនីអូជុំ ២ (កម្លាំង១ មេកាវ៉ាត់) ក្នុងខេត្តរតនគីរី និងទំនប់វារីអគ្គីសនីកំចាយ ដែលទើបបើកថ្មីៗនេះ (កម្លាំង១៩៣ មេកាវ៉ាត់) ក្នុងខេត្តកំពត។ មានគម្រោងទំនប់វារីអគ្គីសនីទ្រង់ទ្រាយធំចំនួន ៥ ទៀត កំពុងដំណើរការបង្កើត រាប់ទាំង គីរីរម្យ ៣ (កម្លាំង១៨ មេកាវ៉ាត់), ឫស្សីជ្រុំក្រោម (កម្លាំង៣៣៨ មេកាវ៉ាត់), ស្ទឹងតាតៃ (កម្លាំង២៤៦ មេកាវ៉ាត់) ដែលទំនប់វារីអគ្គីសនីទាំងនេះស្ថិតនៅក្នុងខេត្តកោះកុង ហើយនិងទំនប់វារីអគ្គីសនីស្ទឹងអាតៃ (កម្លាំង ១២០ មេកាវ៉ាត់) ក្នុងខេត្តពោធិសាត់។ លើសពីនេះទៀត យ៉ាងហោចណាស់ក៏មានគម្រោងចំនួន ៩ ទៀតដែរ ដែលជាកម្មវត្ថុនៃការព្រមព្រៀងធ្វើការសិក្សាអំពីសមិទ្ធិលទ្ធភាព។ មានសេចក្តីរាយការណ៍ថា មានរោងចក្រធ្យូងថ្មមួយកន្លែងកំពុងតែដំណើរការបង្កើត។[១៧០]

## ខ. លទ្ធភាពទទួលបានព័ត៌មាន និងឯកសារ

៨៧. ដូចបានពិភាក្សាខាងដើម ទោះបីជាមានការខិតខំប្រឹងប្រែងកាលពីពេលថ្មីៗនេះ របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដើម្បីធ្វើបច្ចុប្បន្នភាពលើគេហទំព័ររបស់ខ្លួនក្តី ក៏ទិន្នន័យស្តីពីសម្បទានដីសេដ្ឋកិច្ច នៅតែមិនបានពេញលេញដែរ រាប់ទាំងព័ត៌មានពិស្តារមួយចំនួនអំពីក្រុមហ៊ុន ឈ្មោះ និងសញ្ជាតិរបស់នាយកក្រុមហ៊ុន ប៉ុន្តែ មិនមែនម្ចាស់ភាគហ៊ុន និងសម្ព័ន្ធភាពរបស់ក្រុមហ៊ុន។[១៧១] ម្យ៉ាងវិញទៀត ព័ត៌មានដែលបានផ្តល់នោះ មិនបានបញ្ចូលសម្បទានដីដែលមានទំហំ ១.០០០ ហិកតា ឬ ទំហំក្រោម១.០០០ហិកតាទេ។ ដូចបានរៀបរាប់ខាងលើ វាទំនងជាថា សម្បទានដី ឬ ការជួលដីរដ្ឋរយៈពេលវែងមួយចំនួនត្រូវបានផ្តល់ ឬ បានអនុម័តយល់ព្រមដោយក្រសួងដទៃផ្សេងទៀត ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ប៉ុន្តែទិន្នន័យអំពីប្រភេទសម្បទានដីទាំងនេះ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទាំងស្រុងទេ។ លទ្ធភាពទទួលបានព័ត៌មានស្តីពីសម្បទានដី និងក្រុមហ៊ុនទាំងនោះ អាចធ្វើបានតែតាមរយៈការពិនិត្យមើលទាំងស្រុងលើអនុក្រឹត្យពាក់ព័ន្ធនីមួយៗ ដែលបានចុះផ្សាយក្នុងព្រះរាជកិច្ច ដោយទីស្តីការគណៈរដ្ឋមន្ត្រីតែប៉ុណ្ណោះ ហើយពុំមានប្រព័ន្ធទិន្នន័យនៃសម្បទានដីទាំងនេះដែលអាចឲ្យសាធារណៈជនងាយស្រួលរក

---

[១៦៨] DPA-EISEI៖ *ផលប៉ះពាល់បរិស្ថាន និងសង្គម ដែលកើតចេញពីការរីកលូតលាស់នៃ*ឧស្សាហកម្មនិស្សារណកម្ម*នៅកម្ពុជា* ឯកសារគោលជំហរ ឆ្នាំ២០១២។ ចំនួននៃប្រតិបត្តិការរុករករ៉ែ ដែលត្រូវបានចុះបញ្ជីដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មិនអាចទៅរកមើលបានទេ នៅពេលសរសេររបាយការណ៍នេះទេ។ នៅលើគេហទំព័រ Open Development Initiative បានរាយបញ្ជីឈ្មោះ និងពត៌មានរបស់ក្រុមហ៊ុនសម្បទានរុករករ៉ែ ចំនួន ៨៧។

[១៦៩] អាជ្ញាធរប្រេងកាតជាតិកម្ពុជា (អ.ប.ជ.ក.) ឬ CNPA "ការរុករក និងការអភិវឌ្ឍន៍" មាននៅគេហទំព័រ៖ http://www.cnpa.gov.kh/index.php?option=com_content&view=article&id=50&Itemid=125.

[១៧០] ក្រសួងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME), អគ្គនាយកដ្ឋានថាមពល, នាយកដ្ឋានវារីអគ្គីសនី បទបង្ហាញអំពី "ការអភិវឌ្ឍវិស័យថាមពលនៅកម្ពុជា" ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១ អាចរកបាននៅគេហទំព័រ Open Development website (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។

[១៧១] ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ស្ថានភាពទូទៅនៃសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា គេហទំព័រ៖ http://www.elc.maff.gov.kh/en/news/12-elc-status.html ចូលមើលចុងក្រោយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ។ ព័ត៌មានខ្លះៗអំពី ក្រុមហ៊ុនទទួលបានដីសម្បទានសេដ្ឋកិច្ច ក៏អាចស្រាវជ្រាវរកបានពីគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម ផងដែរ។

ឬ ស្រាវជ្រាវរកបាននោះទេ។[១៧២] ក្នុងចំណោមអនុក្រឹត្យទាំងនេះ មានសេចក្តីសម្រេចស្តីពីការធ្វើអនុបយោគតំបន់មួយចំនួនទៅជាដីឯកជនរបស់រដ្ឋ ឬ ការចាត់ថ្នាក់ដីនៅក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដើម្បីសម្រួល និងធ្វើឲ្យការអភិវឌ្ឍនៅតំបន់នោះប្រព្រឹត្តទៅដោយស្របច្បាប់។ កង្វះតម្លាភាព និងព័ត៌មានជុំវិញសម្បទានដីដែលបានផ្តល់ នៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន គឺជាកង្វល់យ៉ាងខ្លាំង ហើយវាមិនច្បាស់លាស់ទេថា តើមានការបំពេញគ្រប់លក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងនីតិវិធីសម្រាប់ការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ និងការផ្តល់សម្បទានដីហើយឬយ៉ាងណា មុនការចាប់ផ្តើមសកម្មភាពសម្បទានដីទាំងនោះ។

៨៨. ទោះបីជា ខ្វះនូវព័ត៌មានដែលអាចរកបានជាសាធារណៈក្តី ក៏រាជរដ្ឋាភិបាល បានសន្យានៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ អំពី "ការចូលរួមរបស់សាធារណៈជនប្រកបដោយសមធម៌ និងភាពត្រឹមត្រូវក្នុងគ្រប់បញ្ហាទាំងអស់ តាមបែបប្រជាធិបតេយ្យ និងសន្តិវិធី ដើម្បីធានាថា ឆន្ទៈសេរី និងការសម្រេចចិត្ត ដែលផ្អែកលើការទទួលបានព័ត៌មានគ្រប់គ្រាន់នៃប្រជាជនភាគច្រើន ត្រូវបានអនុម័តទទួលយកមកអនុវត្ត និងទន្ទឹមគ្នានោះការពារសិទ្ធិ និងសុខមាលភាពរបស់ក្រុមប្រជាជនជនភាគតិច"។[១៧៣] ពិតណាស់ថា សមាសធាតុស្នូលមួយនៃយុទ្ធសាស្រ្តចតុកោណ គឺដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព "ការប្រកាន់ខ្ជាប់នូវវិធានការច្បាប់ តម្លាភាព ភាពអាចដឹងជាមុនបាន និងគណនេយ្យភាពនៃស្ថាប័នសាធារណៈ" ក្នុងគ្រប់បញ្ហាទាំងអស់របស់រដ្ឋាភិបាល។[១៧៤]

៨៩. ដោយសារគោលបំណងសំខាន់មួយក្នុងចំណោមគោលបំណងសំខាន់ៗដទៃទៀតនៃរបាយការណ៍នេះ គឺដើម្បីលើកកម្ពស់តម្លាភាព និងផ្តល់ការវិភាគដែលរួមបញ្ចូលទស្សនទាន និងព័ត៌មានរបស់ក្រសួង-មន្ទីរពាក់ព័ន្ធ ទើបនៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១២ ខ្ញុំបានធ្វើសំណើជាលាយលក្ខណ៍អក្សរសុំព័ត៌មានលម្អិត ស្តីពីការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ[១៧៥] ក្រសួងរៀបចំដែនដី នគរូប

[១៧២] ព្រះរាជកិច្ច មាននិងអាចរកបាន តែតាមរយៈការជាវប៉ុណ្ណោះ ដោយផ្តល់មកដល់អ្នកជាវជាឯកសារបោះពុម្ពផ្សាយ ពីទីស្តីការគណៈរដ្ឋមន្ត្រី។ សមាគមច្បាប់ខ្មែរ បានបង្កើតទិន្នន័យតាមប្រព័ន្ធកំព្យូទ័រ ដោយចងក្រងជាបណ្តុំនូវច្បាប់ចម្លងនៃឯកសាច្បាប់ និងអនុក្រឹត្យផ្សេងៗផង ដែលអាចទាក់ទងរកជាវបាន។

[១៧៣] រាជរដ្ឋាភិបាលកម្ពុជា ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣៖ ការរីកលូតលាស់ ឱកាសការងារ សមភាព និងប្រសិទ្ធភាព ដើម្បីទៅសម្រេចបានបានគោលដៅអភិវឌ្ឍន៍សហវត្សរ៍របស់កម្ពុជា ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ (ដំណាក់កាលទី២ នៃយុត្តិសាស្រ្តចតុកោណ សម្រាប់ការរីកលូតលាស់ ឱកាសការងារ សមភាព និងប្រសិទ្ធភាព) ទំព័រទី១១ កថាខណ្ឌទី ២៩ ។

[១៧៤] ដូចគ្នាខាងលើ។

[១៧៥] ជាពិសេស ខ្ញុំបានស្នើសុំនូវព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពទាក់ទងនឹង ស្ថានភាព និង ប្រវត្តិរបស់ក្រុមហ៊ុននានាដែលទទួលបានសម្បទានដីសេដ្ឋកិច្ច នៅកម្ពុជា រហូតមកទល់ខែមេសា ឆ្នាំ២០១២ និងវិស័យធុរកិច្ចដែលពាក់ព័ន្ធ ដោយសារពត៌មានទាំងអស់នោះ មិនមានដើម្បីរកបាននៅលើគេហទំព័ររបស់ក្រសួង។ ខ្ញុំបានស្នើសុំទិន្នន័យផងដែរ អំពីទំហំ និងការប្រើប្រាស់ដីសម្បទាន, កិច្ចសន្យា និងព័ត៌មានលំអិតមួយចំនួនអំពីម្ចាស់ក្រុមហ៊ុន, ផែនទី និង ចំណុចទីតាំងភូមិសាស្រ្ត, និងព័ត៌មានដែលចាំបាច់ដើម្បីផ្តល់ដីសម្បទានផ្សេងៗ ដូចជា ការធ្វើអត្តសញ្ញាណកម្មដី ការចុះបញ្ជីដីធ្លី ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកំណត់ហេតុនៃការពិគ្រោះយោបល់ជាសាធារណៈ ព្រមទាំងសេចក្តីពិស្តារទាក់ទងនឹងដំណោះស្រាយចំពោះទំនាស់ដីធ្លីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច។ ខ្ញុំបានស្នើសុំព័ត៌មានផងដែរ អំពីការវិវឌ្ឍន៍រីកចម្រើននៃសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច និង ការងារនៃលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច។ ជាចុងក្រោយ ខ្ញុំបានស្នើសុំព័ត៌មានអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក្នុងកិច្ចការពារបរិស្ថាន និងការលើកកម្ពស់ការអនុវត្តសកម្មភាពអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅពេលផ្តល់សម្បទានដីសេដ្ឋកិច្ច ឬសម្បទានផ្សេងៗទៀត។

នីយកម្ម និងសំណង់[១៧៦] និងក្រសួងបរិស្ថាន។[១៧៧] ខ្ញុំមានការសោកស្តាយ ដែលខ្ញុំមិនបានទទួលការឆ្លើយតបពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។[១៧៨] ក្រសួងបរិស្ថាន បានផ្តល់ព័ត៌មានដ៏មានសារៈប្រយោជន៍ នៅអំឡុងជំនួបប្រជុំរបស់ខ្ញុំជាមួយរដ្ឋមន្ត្រីក្រសួងនេះនៅក្នុងខែឧសភា ឆ្នាំ២០១២ ប៉ុន្តែព័ត៌មានទាំងនោះ មិនបានពេញលេញទេ ហើយក៏មិនបានទទួលព័ត៌មានបន្ថែមដែរ នៅពេលក្រោយមកទៀត។ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ខ្ញុំបានទទួលការឆ្លើយតបពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការចុះបញ្ជីដីធ្លី និងសម្បទានដីសង្គមកិច្ច។

៩០. បច្ចុប្បន្នព័ត៌មានទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត និងសហគ្រាសពាណិជ្ជកម្មពាក់ព័ន្ធនានា ដែលអាចរកបានជាសាធារណៈភាគច្រើន ដោយទោះបីជាទិន្នន័យទាំងនោះមិនទាន់ពេញលេញក្តី គឺប្រភពព័ត៌មានបើកចំហរ វិបផត់ថលស៍(web portals) ដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល មានដូចជា គំម្រោងទិន្នន័យបើកចំហរកម្ពុជា (គំរោងអភិវឌ្ឍន៍កម្ពុជាបើកចំហរ Open Development Cambodia) និងគម្រោងសិទ្ធិរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជាបន្ថែមពីលើការសិក្សាស្រាវជ្រាវ និងការឃ្លាំមើលល្អិតល្អន់ដោយអង្គការមិនមែនរដ្ឋាភិបាលផ្នែកអភិវឌ្ឍន៍ ផ្នែកបរិស្ថាន និងផ្នែកសិទ្ធិមនុស្ស។[១៧៩] ការកំណត់ផែនទីនៃទីតាំងសម្បទានដីនៅកម្ពុជា តាមរយៈ

[១៧៦] ដោយឡែក ខ្ញុំបានស្នើសុំព័ត៌មានទាក់ទងនឹងតួនាទីរបស់ក្រសួង ក្នុងដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត ជាពិសេសទាក់ទងនឹងការចុះបញ្ជីដីសម្បទាន ស្របតាមមាត្រា ៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១។ ពិសេសជាងនេះទៀត ខ្ញុំចាប់អារម្មណ៍លើព័ត៌មានអំពី ការគូសផែនទីជាប្រព័ន្ធ ការធ្វើអត្តសញ្ញាណកម្ម និងការចុះបញ្ជី ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ នៅកម្ពុជា ការបង្កើតនិងការរក្សាទិន្នន័យដីរដ្ឋ ការបែងចែក ការគ្រប់គ្រង និងការវិនិយោគដីធ្លី ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ឆ្នាំ២០០៥។ ជាងនេះទៅទៀត ខ្ញុំបានស្នើសុំព័ត៌មានទាក់ទងនឹងសកម្មភាពការងាររបស់គណៈកម្មការសុរិយាដី និងភាពរីកចម្រើននៃគណៈកម្មការនេះដែលមានមកដល់ពេលបច្ចុប្បន្នក្នុងបេសកកម្មដោះស្រាយទំនាស់ដីធ្លី ទាក់ទងនឹងដីមិនទាន់ចុះបញ្ជី ដែលប្រជាពលរដ្ឋអះអាងអំពីសិទ្ធិភោគៈលើដី នោះ (មានន័យថា ទំនាស់ដីធ្លីដែលកើតឡើងនៅក្រៅតំបន់វិនិច្ឆ័យ ឫទំនាស់ដែលកើតឡើងនៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយ ដោយគណៈកម្មការរដ្ឋបាលបាន) ហើយខ្ញុំ ក៏បានស្នើសុំផងដែរនូវព័ត៌មានទាក់ទងនឹងសម្បទានដីសង្គមកិច្ច។ ជាចុងក្រោយ ខ្ញុំបានស្នើសុំព័ត៌មានអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក្នុងកិច្ចការពារបរិស្ថាន និង ការលើកកំពស់ការអនុវត្តសកម្មភាពអភិវឌ្ឍប្រកបដោយនិរន្តរភាព ក្នុងបរិបទនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត។

[១៧៧] ជាពិសេស ខ្ញុំបានស្នើសុំព័ត៌អំពី ដីសម្បទាននានា ដែលអាចត្រូវបានផ្តល់ឲ្យទៅក្រុមហ៊ុន នៅក្នុងតំបន់ការពារធម្មជាតិ និងព័ត៌មានអំពីស្ថានភាព និងប្រវត្តិរបស់សហគ្រាសពាណិជ្ជកម្មនានា ដែលទទួលបានដីសម្បទានក្នុងតំបន់ការពារធម្មជាតិ រហូតមកដល់ខែ មេសា ឆ្នាំ២០១២ ។ ខ្ញុំបានស្នើសុំផងដែរនូវព័ត៌មានទាក់ទងនឹង គោលបំណងនៃដីសម្បទាន ទំហំដី និងការប្រើប្រាស់ដីសម្បទានទាំងនោះ, កិច្ចសន្យា និងព័ត៌មានលំអិតពីម្ចាស់កម្មសិទ្ធិ, ផែនទី និងចំនុចទីតាំងភូមិសាស្ត្រ និងព័ត៌មានត្រូវការចាំបាច់សម្រាប់ការផ្តល់សម្បទានដី (អត្តសញ្ញាណកម្ម និងការចុះបញ្ជីដីធ្លី ការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម និងរបាយការណ៍ស្តីពីការពិគ្រោះយោបល់ជាសាធារណៈ)។ ចំពោះស្ថានភាពផ្លូវច្បាប់នៃតំបន់ការពារធម្មជាតិនានា ខ្ញុំបានស្នើសុំព័ត៌មានអំពីការវិវត្តន៍រីកចម្រើន តាំងតែពីការអនុម័តច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ មកក្នុងនោះមាន៖ ការបង្កើត និងការកែប្រែ តំបន់ការពារ និងអនុក្រឹត្យកំណត់តំបន់ទាំងនោះ, ស្ថានភាពនៃតំបន់គ្រប់គ្រងក្នុងទមបន់ការពារ ឬ ការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រង ផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ សិទ្ធិក្នុងការចូលរួម និងប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងតំបន់ និងជនជាតិដើមភាគតិច ដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់, ការបង្កើតគណៈកម្មការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារ (NCRPAM) ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ ហើយខ្ញុំបាន ស្នើសុំព័ត៌មានអំពីដំណើរការនៃការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងគម្រោងវិនិយោគនៅក្នុងតំបន់ការពារ។ ជាចុងក្រោយ ខ្ញុំបានសាកសួរអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក្នុងកិច្ចការពារបរិស្ថាន និងការលើកម្ពស់ការអនុវត្តសកម្មភាពអភិវឌ្ឍប្រកបដោយនិរន្តរភាព ក្នុងបរិបទនៃ សម្បទានដីសេដ្ឋកិច្ច និង សម្បទានដីផ្សេងៗទៀត។

[១៧៨] ខ្ញុំមិនត្រូវបានផ្តល់ឲ្យមានជំនួបជាមួយក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ នៅក្នុងពេលនៃការបំពេញបេសកម្មរបស់ខ្ញុំ ក្នុងខែឧសភា ឆ្នាំ២០១២។

[១៧៩] ជាឧទាហរណ៍ អង្គការមួយចំនួន ក្នុងចំនោមអង្គការជាច្រើន ដែលតាមឃ្លាំមើលសម្បទានដី ដូចជា៖ អង្គការលីកាដូ (LICADHO), អាដហុក (ADHOC), អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum), បណ្តាញផលប៉ះពាល់បរិស្ថាន និងសង្គម ដោយឧស្សាហកម្មនិស្សារណកម្ម/អង្គការ អភិវឌ្ឍន៍ និងដៃគូក្នុងសកម្មភាព, អង្គការអុកស្វាម (Oxfam), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR),

ទិន្នន័យនៃប្រព័ន្ធកំណត់ទីតាំងពិភពលោក (GPS) បានរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីរបាយការណ៍តំណាងពិសេស (SRSG) ឆ្នាំ២០០៧ មក។ ក្នុងចំណោមអង្គការជាច្រើនទៀត អង្គការលីកាដូ បានរួមវិភាគទានយ៉ាងច្រើនដល់កំណត់ផែនទីទីតាំងសម្បទានដីនៅទូទាំងប្រទេស។ ក្នុងខែមិថុនា ឆ្នាំ២០១២ គេហទំព័រនៃគម្រោងអភិវឌ្ឍន៍កម្ពុជាបើកចំហរ (ODC) បានរាយបញ្ជីឈ្មោះសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៣២០ នៅក្នុងខេត្តចំនួន ២១ រាប់ទាំងរាជធានីភ្នំពេញផងដែរ ដែលបានផ្តល់ទៅឲ្យក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុក, សម្បទានរ៉ែចំនួន ៨៧ (ជាពិសេសសម្រាប់ការស្វែងរុករក) ក្នុងខេត្តចំនួន ១៩ និង តំបន់សេដ្ឋកិច្ចពិសេសចំនួន ២៣ នៅក្នុងខេត្តចំនួន ៨ ។[១៨០] គម្រោងសិទ្ធិ (Sithi) បានបោះពុម្ពផ្សាយផែនទីស្តីពីទំនាស់ដីធ្លីដោយរៀបចំករណីទំនាស់តាមខេត្តនីមួយៗ ហើយដែលសរសេរចងក្រងជាឯកសារនូវករណីចំនួន ២២៣ ដែលត្រូវបានរាយការណ៍ជាសាធារណៈចាប់ពីឆ្នាំ២០០៧ ដល់ ឆ្នាំ២០១១ រាប់ទាំងទំនាស់លើកម្មសិទ្ធិ ការដណ្តើមយកដីធ្លី និងការបណ្តេញចេញពីដីធ្លីផងដែរ ប៉ុន្តែមិនបានបំបែក ចេញពីគ្នានូវករណីទំនាស់ដែលទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតឡើយ។[១៨១]

៩១. ការអនុវត្តបទបញ្ជាស្តីពីសម្បទានដីសេដ្ឋកិច្ច ខែឧសភា ឆ្នាំ២០១២ លើការចេញប័ណ្ណកម្មសិទ្ធិដីធ្លី សម្រាប់សហគមន៍ដែលគ្មានដី គឺមានបញ្ហាផងដែរ ជាពិសេសលើបញ្ហានៃការទទួលបានព័ត៌មាន។ ដោយមិនមានការផ្តល់ព័ត៌មានលំអិតច្បាស់លាស់ពីដំបូងអំពីការអនុវត្តគោលនយោបាយថ្មីនេះដល់ ក្រសួងពាក់ព័ន្ធ សហគមន៍ អាជ្ញាធរមូលដ្ឋាន អាជ្ញាធរខេត្ត សម្បទានិកនៃក្រុមហ៊ុនសម្បទានដីនានា ម្ចាស់ជំនួយដែលពាក់ព័ន្ធក្នុងវិស័យដីធ្លី ឬ អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញសហគមន៍ទាំងឡាយ ស្រាប់តែមានការជ្រើសរើសក្រុមយុវជនជាច្រើន និងបានបញ្ជូនពួកគេទៅវាស់វែងដីធ្លីនៅចុងខែមិថុនា ឆ្នាំ២០១២។ ឯកសារគោលនយោបាយផ្សេងៗជាច្រើន និងការណែនាំផ្សេងៗ ត្រូវបានចេញ និងផ្សព្វផ្សាយជាបន្តបន្ទាប់ នៅបន្ទាប់ការវាស់វែងដីធ្លីបានចាប់ផ្តើមហើយ។[១៨២] ទោះបីជាយ៉ាងណាក៏ដោយ ឯកសារទាំងអស់នេះ មិនបានបញ្ជាក់ច្បាស់ថា សម្បទានដីណាខ្លះដែលនឹងត្រូវជាគោលដៅនៃការកាត់ផ្ទៃដី ដើម្បីចេញប័ណ្ណកម្មសិទ្ធិតាម "គោលនយោបាយស្បែកខ្លា"។ ក្រៅពីផែនការវាស់វែងដីធ្លី ដើម្បីចេញប័ណ្ណកម្មសិទ្ធិដល់ប្រជាពលរដ្ឋក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច មានសេចក្តីរាយការណ៍ថាមានសម្បទានិកជាច្រើនមិនបានដឹងថា ដីដែលខ្លួនកំពុងធ្វើការអភិវឌ្ឍន៍នោះ គឺជាផ្នែកមួយនៃគោលដៅរបស់គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិថ្មីនោះទេ លុះត្រាតែដល់ពេលដែលក្រុមយុវជនចុះទៅកាន់ទីតាំងដីសម្បទានរបស់ពួកគេ។

៩២. ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញលិខិតមួយចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ ផ្ញើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយជូនដំណឹងដល់ក្រសួងនេះអំពីការអនុវត្តបទបញ្ជាសម្បទានដីសេដ្ឋកិច្ច ខែឧសភា ឆ្នាំ

គណៈកម្មការប្រព្រឹត្តកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្ស (CHRAC), មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC), វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម (EWMI), ក្រុមការពារធនធានធម្មជាតិ (Natural Resources Protection Group), អង្គការសមធម៌កម្ពុជា (Equitable Cambodia), អង្គការគាំទ្រជនជាតិដើមភាគតិច (ICSO), សមាគមជាងត្នោត (STT), អង្គការ Welthungerhilfe, អង្គការ Flora and Fauna International, បណ្តាញការពារសហគមន៍, និង អង្គការសម្ព័ន្ធភាពសម្រាប់សត្វព្រៃ (Wildlife Alliance) រួមទាំងដៃគូរសម្ព័ន្ធភាពផ្សេងៗរបស់ពួកគេនៅទូទាំងប្រទេស។

១៨០ គម្រោងOpen Data Cambodia Project (ODC), សារពើភាពក្រុមហ៊ុនផ្សេងៗ៖ http://www.opendevelopmentcambodia.net/concessions/

១៨១ គេហទំព័រសិទ្ធិមនុស្សកម្ពុជា (Cambodia Human Rights Portal) របាយការណ៍ស្តីពីករណីវិវាទដីធ្លី ឆ្នាំ២០០៧ -២០១១៖ http://sithi.org/temp.php?url=land_case.php&. ដែលរកបាននៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២។

១៨២ គំនិតផ្តួចផ្តើមនេះ ដែលគេរាយការណ៍ថា បានការឧបត្ថម្ភថវិការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការឧបត្ថម្ភបន្ថែមទៀតជាថវិការផ្ទាល់ខ្លួនពីលោកនាយករដ្ឋមន្ត្រី ផ្អែកតាមការប្រកាសរបស់លោកនាយករដ្ឋមន្ត្រីក្នុងពេលដែលលោកថ្លែងសន្ទរកថានៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២។

២០១២។[១៨៣] នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានចេញសេចក្តីណែនាំបន្ថែមទៀត ដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ នៅគ្រប់ខេត្តទាំងអស់ អំពីការអនុវត្តបទបញ្ជាពាក់ព័ន្ធនឹងដីជនជាតិដើមភាគតិច តំបន់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃឡង់ ក៏ដូចជាមូលដ្ឋានការពារជាតិ និងតំបន់បេតិកភ័ណ្ឌ វប្បធម៌នានា។[១៨៤] នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ក្រុមប្រឹក្សាគោលនយោបាយ ដីធ្លី បានចេញសេចក្តីណែនាំបន្ថែមទៀត ស្តីពីការធ្វើអត្តសញ្ញាណកម្មដីធ្លី អត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិបឋម នៅក្នុងការអនុវត្តបទបញ្ជានេះ។[១៨៥] ពិតណាស់ ការចេញសេចក្តីណែនាំ និងការជូនដំណឹងជាហូរហែ បន្ទាប់ពីការដាក់ពង្រាយយុវជនស្ម័គ្រចិត្តដើម្បីវាស់វែងដីធ្លី ស្តែងឲ្យឃើញអំពីកង្វះនៃការរៀបចំផែនការឲ្យបានគ្រប់ជ្រុងជ្រោយ និងការធ្វើសុខដុមនីយកម្មជាមួយក្របខ័ណ្ឌគតិយុត្ត និងប្រព័ន្ធផ្តល់កម្មសិទ្ធិដីធ្លីដែលមានស្រាប់។

## គ. ចំនួនសម្បទានដីសេដ្ឋកិច្ច និងសម្បទានផ្សេងទៀត ដែលត្រូវបានផ្តល់ នៅក្នុងតំបន់ការពារធម្មជាតិ និង នៅលើដីជនជាតិដើមភាគតិច

៩៣. សម្បទានជាច្រើន ត្រូវបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិនានា នាប៉ុន្មានឆ្នាំកន្លងមកនេះ។ រាជរដ្ឋាភិបាលបានផ្តល់សម្បទានដីឲ្យទៅក្រុមហ៊ុនយ៉ាងហោចណាស់ចំនួន ១០៩ ក្រុមហ៊ុន នៅក្នុងតំបន់ការពារធម្មជាតិ ចំនួន ១៦ នៃតំបន់ការពារចំនួន ២៣ កន្លែង ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ហើយដែលភាគច្រើននៃសម្បទានដីទាំងនេះ ត្រូវបានអនុក្រឹត្យចេញផ្តល់ឲ្យសម្រាប់គោលបំណងកសិឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិ (សូមមើលឧបសម្ព័ន្ធទី I តារាងស្តីពីសម្បទានដី ដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិ)។ ក្រសួងបរិស្ថាន បានបញ្ជាក់ថា សម្បទានដីមួយចំនួន ត្រូវបានផ្តល់ឲ្យនៅក្នុងតំបន់ការពារដែលស្ថិតក្រោមរដ្ឋបាល និងការគ្រប់គ្រងរបស់

[១៨៣] លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៦៦៦ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ ជូនចំពោះរដ្ឋមន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការសំរេចរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើការចុះបញ្ជីដីធ្លីឲ្យបានឆាប់រហ័ស នៅតំបន់គោលដៅនៃការអនុវត្តបទបញ្ជាលេខ ០១ របស់លោកនាយករដ្ឋមន្ត្រី។ បទបញ្ជានេះ បានបញ្ជាក់ថា តំបន់ដែលត្រូវអនុវត្ត រួមមាន ដីដែលបានកាត់ចេញពី តំបន់ព្រៃសម្បទាន សម្បទានដីសេដ្ឋកិច្ច ដីដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ហើយនិងដីរដ្ឋដែលមានដីការដកហូតដោយអាជ្ញាធរខេត្ត-ក្រុង។ បណ្ណកម្មសិទ្ធិដី នឹងត្រូវចេញផ្តល់ឲ្យ អ្នកកាន់កាប់ដីដែលមានទំហំមិនលើសពី ៥ ហិកតា នៅតំបន់ទាំងអស់នោះ ដោយធ្វើឡើងតាមពីរដំណាក់កាលគឺ ដំណាលទី ១ គឺត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋម និងដំណាក់កាលទី២ គឺការចេញប័ណ្ណកម្មសិទ្ធិស្ថាពរ។ ចំពោះដីដែលមានទំហំលើសពី ៥ ហិកតា គឺ អាចផ្តល់កម្មសិទ្ធបានតែលើចំណែកដីដែលបានធ្វើការដាំដុះជាក់ស្តែង ចំណែកឯដីដែលមិនបានដាំដុះ នឹងត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ហើយបន្ទាប់មកផ្តល់ជាសម្បទានដីសេដ្ឋកិច្ចខ្នាតតូចទៅឲ្យអ្នកដែលកាន់កាប់សម្រាប់រយៈពេល ៩៩ ឆ្នាំ។ ចំពោះប្រជាពលរដ្ឋដែលទទួលបានដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល នឹងត្រូវចេញប័ណ្ណសម្គាល់សម្បទានដីសង្គមកិច្ចអំឡុងពេលអន្តរកាលនេះ។

[១៨៤] ក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានចេញសេចក្តីណែនាំលេខ ០១៥ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២ ណែនាំពីការអនុវត្តបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ របស់លោកនាយករដ្ឋមន្ត្រី ស្តីពីការពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច និងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ដែលបានចុះហត្ថលេខាដោយទេសរដ្ឋមន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ សេចក្តីណែនាំនេះ ផ្តល់ឲ្យជនជាតិដើមភាគតិច ជ្រើសរើសរស់នៅជាឯកជន ដោយមិនចូលជាសមាជិកសហគមន៍ជន ដោយទទួលបានដីជាកម្មសិទ្ធិឯកជនលើចំណែកដី ដែលពួកគេបាននិងកំពុងកាន់កាប់និងដាំដុះជាក់ស្តែង និងតម្រូវឲ្យគណៈកម្មការគ្រប់គ្រងដីរដ្ឋខេត្ត លើកសំណើសុំធ្វើអនុបយោគ បើសិនជាដីនោះជាដីសាធារណៈរបស់រដ្ឋ។ សេចក្តីណែនាំនេះ ក៏បានប្រាប់អំពី ដំណើរការនៃការកំណត់អត្តសញ្ញាណកម្ម ប្រសិនបើមានប្រជាពលរដ្ឋមកអះអាង និងឬស្នើសុំសិទ្ធិលើចំណែកដីដែលស្ថិតក្នុងតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស តំបន់បេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ការអះអាងនិងទាមទារទាំងនោះមិនត្រូវយកមកពិនិត្យឡើយ។

[១៨៥] សេចក្តីណែនាំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី លេខ ០១៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការធ្វើអត្តសញ្ញាណកម្មដីធ្លី អត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិបឋម អនុវត្តតាមបទបញ្ជាលេខ ០១ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ របស់រដ្ឋាភិបាល។

ក្រសួង ប៉ុន្តែមានតែនៅក្នុងតំបន់ទ្រនាប់នៃតំបន់ការពារប៉ុណ្ណោះ (ឬនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព) ដើម្បីទប់ស្កាត់ការបំផ្លិចបំផ្លាញព្រៃ និងធនធានធម្មជាតិជាបន្ត នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។ យោងតាមព័ត៌មានដែលផ្តល់ឲ្យដោយក្រសួងបរិស្ថាន ផ្ទៃដីសរុបដែលត្រូវបានធ្វើអាជីវកម្មនៅក្នុងតំបន់ការពារធម្មជាតិ តាមទិន្នន័យ ឆ្នាំ២០១១ បង្ហាញថា ក្នុងចំណោមផ្ទៃដីតំបន់ការពារធម្មជាតិសរុបទំហំ ៣.១៤៣.៧៦៣ ហិកតា មានផ្ទៃដីទំហំ ៣២២.១១៣ ហិកតា ត្រូវបានប្រើប្រាស់សម្រាប់ដំណាំកៅស៊ូ, ផ្ទៃដីទំហំ ១៧២.៧៣១ ហិកតា ត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិឧស្សាហកម្មផ្សេងៗ, ផ្ទៃដីទំហំ ៣៨.៨៣១ ហិកតា ត្រូវបានប្រើប្រាស់ សម្រាប់ការស្វែងរុករក និងជីកយករ៉ែ, ផ្ទៃដីទំហំ ៤.៥៩៣ ហិកតា ត្រូវបានប្រើប្រាស់សម្រាប់ទំនប់វារីអគ្គីសនី និងផ្ទៃដីទំហំ ៨៩.៣៥៩ ហិកតា ត្រូវបានប្រើប្រាស់សម្រាប់ទេសចរណ៍ធម្មជាតិ។[១៨៦] សរុបផ្ទៃដីដែលត្រូវបានប្រើប្រាស់នេះមានទំហំ ៦២៧.៦២៧ ហិកតា ឬ ជិត ២០ភាគរយនៃផ្ទៃដីតំបន់ការពារធម្មជាតិសរុប។

៩៤. ដោយសារក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំបានផ្តល់ព័ត៌មានលំអិតផ្លូវការតាមការស្នើសុំ វាពិបាកនឹងបញ្ជាក់ពីចំនួនជាក់ស្តែងនាបច្ចុប្បន្ននៃសម្បទានដី និងគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតនៅក្នុងតំបន់ការពារធម្មជាតិ។ យោងតាមរបាយការណ៍ដែលត្រូវបានបញ្ចេញកាលពីខែមិនា ឆ្នាំ២០១២ ដោយអង្គការអាដហុក នៅក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន ១២៣ ផ្តល់សម្បទានដីឲ្យដល់ក្រុមហ៊ុនឯកជនដែលមានផ្ទៃដីទំហំ ៧៥១.៨៨២ ហិកតា ហើយភាគច្រើននៃដីនោះ ត្រូវបានឆ្វៀលចេញពីតំបន់ការពារធម្មជាតិ រួមមានដែនជម្រកសត្វព្រៃ និង ឧទ្យានជាតិនានា។[១៨៧] សម្បទាននានា ដែលត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឯកជន គ្របដណ្តប់លើផ្ទៃដីទំហំ ៥០០.០០០ ហិកតា នៅក្នុងតំបន់ការពារធម្មជាតិ។

៩៥. សម្បទានដីជាច្រើន ត្រូវបានផ្តល់នៅលើដីរបស់ជនជាតិដើមភាគតិច ទោះបីជាមានការការពារក្រោមច្បាប់ភូមិបាល ឆ្នាំ ២០០១ និងអនុក្រឹត្យចុះខែមេសា ឆ្នាំ២០០៩ ស្តីពីការចុះបញ្ជីដីជនជាតិដើមភាគតិចក្តី។ របាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ បានរាយបញ្ជីឈ្មោះសម្បទានដីសេដ្ឋកិច្ចយ៉ាងហោចណាស់ចំនួន ២៥ ដែលត្រូវបានគេដឹងថា បានប៉ះពាល់លើដីជនជាតិដើមភាគតិច នៅក្នុងខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្ត ឧត្តរមានជ័យ ខេត្តរតនៈគីរី និងខេត្តស្ទឹងត្រែង និងសម្បទានដីសម្រាប់គោលបំណងដទៃទៀត នៅលើដីជនជាតិដើម ភាគតិច នៅខេត្តកំពង់ស្ពឺ (ស្រុកឱរ៉ាល់) ខេត្តមណ្ឌលគិរី (ឃុំប៊ូស្រា) ខេត្តពោធិសាត់ និងខេត្តព្រះវិហារ។ អំឡុងពេលនៃការធ្វើរបាយការណ៍នេះ មានសម្បទានដីយ៉ាងហោចណាស់ចំនួន ៩៨ ដែលត្រូវបានផ្តល់នៅលើដីរបស់ជនជាតិដើមភាគតិច (សូមមើលឧបសម្ព័ន្ធ២ តារាងស្តីពីសម្បទានដី ដែលត្រូវបានផ្តល់ក្នុងតំបន់ដែលរស់នៅ និងប្រើប្រាស់ជាប្រពៃណីដោយសហគមន៍ជនជាតិដើមភាគតិច)។

## VI. ច្បាប់ និងការអនុវត្តជាក់ស្តែង៖ សម្បទានដី និងការអនុវត្តតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងនីតិវិធី

៩៦. ដោយហេតុថា ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយគ្រប់គ្រងលើការផ្តល់ និងការចាត់ចែងសម្បទានដីសេដ្ឋកិច្ច មានលក្ខណៈល្អប្រសើរច្រើន ដូចដែលបានលើកឡើងនៅក្នុងផ្នែកទី III ប៉ុន្តែការដាក់ឲ្យអនុវត្តត្រឹមត្រូវតាមក្របខ័ណ្ឌច្បាប់ទាំងនេះនាពេលបច្ចុប្បន្ន គឺជាបញ្ហាដ៏លំបាកទៅវិញ។ ការលើកកម្ពស់ការវិនិយោគវិស័យឯកជន ហាក់

---

[១៨៦] ទិន្នន័យដែលបានផ្តល់ឲ្យក្នុងជំនួបប្រជុំរវាងឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង លោក សុរិយា ស៊ូប៊ែឌី តំណាងពិសេសរបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២។

[១៨៧] របាយការណ៍ស្តីពី សិទ្ធិដីធ្លី និងលំនៅដ្ឋាន របស់អង្គការអាដហុក (ADHOC) ឆ្នាំ២០១១ ខែមីនា ឆ្នាំ២០១២។

ដូចជា យកតាមបទដ្ឋានមួយដែលនៅពីលើការគោរពតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ ហើយជាលទ្ធផល គឺការផ្តល់សម្បទានដីដ៏ច្រើនសម្បើម នៅក្នុងតំបន់ការពារធម្មជាតិ នៅលើដីរបស់ជនជាតិដើមភាគតិច និងនៅក្នុងតំបន់ព្រៃស្រោងនានា។ លើសពីនេះទៀតគឺ ការខ្វះតម្លាភាព ខ្វះការត្រួតពិនិត្យមើល និងការតាមដានមើលជាសាធារណៈ និងការធ្វើរបាយការណ៍ទាក់ទិននឹងសម្បទានដី ដែលត្រូវបានផ្តល់។ ដោយសារតែព័ត៌មានមានតិចតួច និងទិន្នន័យពេញលេញ ពិបាកនឹងទទួលបានទាក់ទងនឹងសម្បទានរ៉ែ គម្រោងវារីអគ្គីសនី និង ប្រភេទផ្សេងៗទៀតនៃសម្បទានដី ដូច្នេះក្នុងផ្នែកនេះនៃរបាយការណ៍ គឺផ្តោតភាគច្រើនតែលើការគោរពតាមលក្ខខណ្ឌគតិយុត្តនៃសម្បទានដីសេដ្ឋកិច្ច។

## ក. ទំហំផ្ទៃដីសម្បទាន និងកម្មសិទ្ធិ

៩៧. មានភស្តុតាងដែលចង្អុលបង្ហាញថា សម្បទានិកជាច្រើន ត្រូវបានអនុញ្ញាតឲ្យទទួលបានផ្ទៃដីលើសពីទំហំកំណត់ ១០.០០០ ហិកតា សម្រាប់បុគ្គលម្នាក់ ដែលមានចែងក្នុងមាត្រា៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដោយទទួលបានសម្បទានដីផ្សេងៗគ្នា ប៉ុន្តែសម្បទានទាំងនោះនៅជាប់ៗគ្នា ឬ ក្បែរៗគ្នា និងការប្រើប្រាស់សម្បទានដីទាំងនោះសម្រាប់គោលបំណងដូចគ្នាៗ (សូមមើលផែនទីនៅក្នុងឧបសម្ព័ន្ធទី V)។[១៨៨] នៅក្នុងករណីខ្លះ ក្រុមហ៊ុនដដែលបានចុះបញ្ជីសម្បទានដីជាប់ៗគ្នារបស់ខ្លួនដាច់ដោយឡែកពីគ្នា ប៉ុន្តែការចុះបញ្ជីសម្បទានដីទាំងនោះដោយប្រើប្រាស់ឈ្មោះនៃសមាជិកគ្រួសារខ្លួន ឬ អ្នកដែលជាប់សម្ព័ន្ធភាពគ្នា (ជាក្រុមហ៊ុនដែលនឹងត្រូវចាត់ចូលជា នីតិបុគ្គលដែលគ្រប់គ្រងដោយរូបវន្តបុគ្គលដដែល)។ ខណៈដែលសម្បទានដីភាគច្រើន ដែលត្រូវបានផ្តល់ចាប់តាំងពីការប្រកាសឲ្យប្រើច្បាប់ភូមិបាល ឆ្នាំ ២០០១ មក មានទំហំមិនលើសពីទំហំកម្រិត ១០.០០០ ហិកតា ប៉ុន្តែរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ បានស្រង់សម្បទានដីសេដ្ឋកិច្ចចំនួនប្រាំបួន ដែលមានទំហំលើសពីការកំណត់របស់ច្បាប់។[១៨៩] បើយោងតាមស្ថិតិថ្មីបំផុតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃើញថា ពុំមានសម្បទានដីសេដ្ឋកិច្ចមានទំហំលើសពី ១០.០០០ ហិកតា ត្រូវបានផ្តល់ឲ្យទេចាប់តាំងពីរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ មក។

៩៨. ទោះបីជាពិបាកក្នុងការតាមដានមើលលើបញ្ហានេះក្តី តែទោះជាយ៉ាងណាក៏ដោយ ក៏មានករណីរំលោភបំពានថ្មីៗមួយចំនួនដែលអាចកើតមាន។ ឧទាហរណ៍ សម្បទានដីពីរកន្លែង ដែលត្រូវបានអនុម័តយល់ព្រមដោយរដ្ឋាភិបាលកាលពីខែកុម្ភៈ ឆ្នាំ២០១០ សម្រាប់ដំណាំអំពៅ ត្រូវបានផ្តល់ឲ្យឧកញ៉ា លី យ៉ុងផាត់ សមាជិកព្រឹទ្ធសភាកម្ពុជា និងភរិយារបស់លោក គឺលោកស្រី គឹម ហ៊ាង នៅខេត្តកំពង់ស្ពឺ។ សម្បទានដីទាំងនោះ ត្រូវបានផ្តល់ឲ្យក្រុមហ៊ុនស៊ូហ្គើរ

[១៨៨] ផែនទីដែលបានផលិតដោយអង្គការលីកាដូ (LICADHO) បង្ហាញថា ក្នុងខេត្តកំពង់ស្ពឺ ក្រុមហ៊ុន ភ្នំពេញស៊ូហ្គើរ (៨.៥០៦ ហាត) និង ក្រុមហ៊ុនកំពង់ស្ពឺស៊ូហ្គើរ (៨.២៤៥ ហាត) ដោយបានពង្រីកយកផ្ទៃដីបន្ថែមផង, ហើយ ក្រុមហ៊ុន អង្គរស៊ូហ្គើរ (៦.៥២៣ ហាត) ក្រុមហ៊ុន ទន្លេស៊ូហ្គើរ (៦.៦១៨ ហាត) និង ក្រុមហ៊ុន ខេន និងវ៉េលីស៊ូហ្គើរ (៦.៥៩៥ ហាត) ត្រូវបានគេរាយការណ៍ថា មានសម្ព័ន្ធភាពទៅនឹង សម្បទានិកដូចគ្នាក្នុងខេត្តឧត្តរមានជ័យ។ នៅក្នុងខេត្តព្រះវិហារ ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធឺណេសិនណល ខមភេនី លីមីធីត (៦.៤៨៨ ហាត) ក្រុមហ៊ុន ហេងយូ (ខេមបូឌា) អ៊ិនធឺណេសិនណល ខមភេនី លីមីធីត (៨.៩៥៩ ហាត), ក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធឺណេសិនណល ខមភេនី លីមីធីត (៩.១១៩ ហាត), ក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អ៊ិនធឺណេសិនណល ខមភេនី លីមីធីត (៩.០១៥ ហាត) និងក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធឺណេសិនណល ខមភេនី លីមីធីត (៨.៨៤១ ហាត)។ ក្នុងខេត្តមណ្ឌលគីរី ក្រុមហ៊ុន ផេស៊ីហ្វិក ប្រេ្តន យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.៦៥៦ ហាត), ក្រុមហ៊ុន ផេស៊ីហ្វិក ភើល យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.៦១៤ ហាត), ក្រុមហ៊ុន ផេស៊ីហ្វិក ឡូធើស យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.០១៤ ហាត), និងក្រុមហ៊ុនផេស៊ីហ្វិក ប្រាយដ៍ យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.៧៧៣ ហាត)។

[១៨៩] របាយការណ៍របស់តំណាងពិសេស ឆ្នាំ២០០៧ កថាខ័ណ្ឌទី១១។

ភ្នំពេញ (ទំហំ ៨.៥០៦ ហិកតា) និងក្រុមហ៊ុន ស៊ូហ្គើរកំពង់ស្ពឺ (ទំហំ ៨.២៤៥ ហិកតា)។[១៩០] លើសពីនេះ សម្បទានដីចំនួន ៣ ទៀត ត្រូវបានផ្តល់នៅក្នុងខែមករា ឆ្នាំ ២០០៨ សម្រាប់ដំណាំអំពៅនៅខេត្តឧត្តរមានជ័យ ទៅឲ្យក្រុមហ៊ុនចំនួន ៣ ដែលមានសម្ព័ន្ធភាពជាមួយសមាជិកព្រឹទ្ធសភា ឧកញ៉ា លី យ៉ុងផាត់ គឺ ក្រុមហ៊ុន អង្គរស៊ូហ្គើរ (៦.៥២៣ ហិកតា) ក្រុមហ៊ុន ទន្លេស៊ូហ្គើរ (៦.៦១៨ ហិកតា) និងក្រុមហ៊ុនវើលីស៊ូហ្គើរ (៦.៥៩៥ ហិកតា)។ ក្រុមហ៊ុនទាំង ៣ នេះ ត្រូវបានចុះបញ្ជី ក្រោមឈ្មោះនាយកប្រតិបត្តិនានា មកពីក្រុមហ៊ុនស្ករសរបស់ថៃដដែលៗ ប៉ុន្តែ ជាទូទៅសហគមន៍មូលដ្ឋានជឿជាក់ថា គម្រោងទាំងនោះមានជាប់ទាក់ទិននឹងសមាជិកព្រឹទ្ធសភា ឧកញ៉ា លី យ៉ុងផាត់។[១៩១]

៩៩. នៅខេត្តព្រះវិហារ មានសម្បទានដីសេដ្ឋកិច្ច ដែលត្រូវបានផ្តល់នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១១ នៅក្នុងស្រុកឆែប ស្រុកជ័យសែន និងស្រុកត្បែងមានជ័យ ដែលជាប់ព្រំប្រទល់គ្នាសម្រាប់ ដាំអាកាស្យា និងអំពៅ ឲ្យទៅក្រុមហ៊ុនចំនួនប្រាំ ដែលមានសម្ព័ន្ធភាពជាមួយគ្នា គឺ ក្រុមហ៊ុន ហេងណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធិត (៦.៤៨៨ ហិកតា) ក្រុមហ៊ុនហេងយូ (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធិត (៨.៩៥៩ ហិកតា) ក្រុមហ៊ុនហេងរួយ (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធិត (៩.១១៩ ហិកតា) ក្រុមហ៊ុនឡានហ្សេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធិត (៩.០១៥ ហិកតា) និងក្រុមហ៊ុនរួយហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធិត (៨.៨៤១ ហិកតា)។[១៩២]

១០០. នៅខេត្តមណ្ឌលគិរី សម្បទានដីសេដ្ឋកិច្ចជាប់ព្រំប្រទល់គ្នាត្រូវបានផ្តល់នៅក្នុងខែកញ្ញា ឆ្នាំ២០១១ ក្នុងឃុំ រយ៉ ស្រុកកោះញ៉ែក សម្រាប់ធ្វើចំការកៅស៊ូ ឲ្យទៅក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នាចំនួនបួន គឺ ក្រុមហ៊ុនប៉ាស៊ីហ្វិក ហ្គ្រេន យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.៦៥៦ ហិកតា) ក្រុមហ៊ុន ប៉ាស៊ីហ្វិក ភើលយ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.៦១៤ ហិកតា) ក្រុមហ៊ុនប៉ាស៊ីហ្វិក ឡូធើស យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.០១៤ ហិកតា) និងក្រុមហ៊ុនប៉ាស៊ីហ្វិក

[១៩០] លិខិតលេខ ០០២/២០០៩ ករ របស់ក្រុមហ៊ុនស៊ូហ្គើរកំពង់ស្ពឺ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ ជូនចំពោះលោកនាយករដ្ឋមន្ត្រី ស្នើសុំការយល់ព្រមផ្តល់ដីទំហំ ១០.០០០ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សម្រាប់ដាំអំពៅ និងដំណាំផ្សេងៗទៀត និងធ្វើរោងចក្រកែច្នៃ ដោយបានចុះហត្ថលេខាស្នើសុំដោយលោកស្រី គឹម ហ៊ាង ជានាយកក្រុមហ៊ុន។ តាមលិខិតលេខ ០០២/២០០៩ ផស របស់ក្រុមហ៊ុន ស៊ូហ្គើរ ភ្នំពេញ ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០០៩ ជូនចំពោះលោកនាយករដ្ឋមន្ត្រី ស្នើសុំការយល់ព្រមផ្តល់ដីទំហំ ១០.០០០ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សម្រាប់ដាំអំពៅ និង ដំណាំផ្សេងៗទៀត និងធ្វើរោងចក្រកែច្នៃ ដោយបានចុះហត្ថលេខាស្នើសុំដោយលោកឧកញ៉ា លី យ៉ុងផាត់ ជានាយកក្រុមហ៊ុន។ សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៧៥ សជណ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ផ្ញើជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដើម្បីយល់ព្រមផ្តល់ដីសម្បទានទំហំលើសពី ៩.០៥២ ហិកតា ឲ្យទៅក្រុមហ៊ុនស៊ូហ្គើរកំពង់ស្ពឺ។ លិខិតរបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និង នេសាទ លេខ ២២២៨ កសក/ណជផក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ផ្ញើជូននាយកក្រុមហ៊ុនស៊ូហ្គើរភ្នំពេញ ទាក់ទងនឹងស្ថានភាពនៃដីសម្បទាន និងការអនុញ្ញាតិឲ្យក្រុមហ៊ុន ដំណើរការក្នុងការដាំដុះអំពៅលើផ្ទៃដីទំហំ ៨.៣៤៣ ហិកតា។ (គួរកត់សំគាល់ថា ក្រុមហ៊ុនសម្បទានទាំងពីរនេះ មិនបានចុះឈ្មោះនៅក្នុងបញ្ជីសម្បទានដីសេដ្ឋកិច្ច ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទទេ)។

[១៩១] អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា (BABC) *ផ្អែមជូរចត់, របាយការណ៍សង្ខេបអំពី ផលិតកម្មឧស្សាហកម្មស្ករ, វិស័យជំនួញ និង សិទ្ធិមនុស្សនៅកម្ពុជា ខែកញ្ញា ឆ្នាំ២០១០។ គេហទំព័រ៖* http://babcambodia.org/developmentwatch/cleansugarcampaign/bittersweet.pdf.

[១៩២] ក្រុមហ៊ុនទាំងប្រាំ បានចុះហត្ថលេខា នៅក្នុងថ្ងៃតែមួយ (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១១) យោងតាមតារាងស្ថិតិដីសម្បទានរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ខែមិថុនា ឆ្នាំ២០១២។ បើយោងតាមគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនទាំងនេះ បានចុះបញ្ជីដោយដាក់អាស័យដ្ឋានក្រុមហ៊ុនដូចគ្នា នៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសចិន ទោះបីជាមានឈ្មោះនាយកក្រុមហ៊ុនខុសគ្នាក៏ដោយ។

ប្រាយដ៍ យ៉ាញ-ស្តុក ខមភេនី លីមីធីត (៩.៧៧៣ ហិកតា)។[១៩៣]

## ខ. ការពិនិត្យមើលឡើងវិញ ការតាមដានត្រួតពិនិត្យ និងការលុបចោលសម្បទានដី

១០១. បាតុភូតមួយទៀតគឺ ការប្រើប្រាស់ដោយខុសច្បាប់ ឬការមិនធ្វើអាជីវកម្មលើដីធ្លី បន្ទាប់ពីក្រុមហ៊ុនទទួលបានសម្បទានដី។ ជំពូកទី២ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ថ្លែងថា "ការប្រមូលផ្តុំដីធ្លី និង ប្រជាជនដែលគ្មានដី គឺស្ថិតក្នុងនិន្នាការមួយ ដែលកំពុងមានការកើនឡើង ដោយបង្កើតជាផលប៉ះពាល់អវិជ្ជមានមកលើ សមធម៌ និង ប្រសិទ្ធិភាព នៃការប្រើប្រាស់ដីធ្លី។ ជាមួយគ្នានេះ ផ្ទៃដីដ៏ធំនៃតំបន់ដីសម្បទានសេដ្ឋកិច្ច ពុំទាន់ត្រូវបានប្រើប្រាស់ឲ្យមានប្រសិទ្ធិភាពទៅតាមគោលដៅដោយតម្រូវឲ្យមានវិធានការដ៏តឹងរឹងរបស់រដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាទាំងនេះ។"[១៩៤] ទោះជាមន្ត្រីមួយចំនួននៅក្នុងជួររដ្ឋាភិបាល បានដឹងអំពីបញ្ហាទាំងអស់នេះ និងបានខិតខំប្រឹងប្រែងដោះស្រាយដោយបាននាំទៅដល់ការរំលាយកិច្ចសន្យាសម្បទានដីនៅក្នុងករណីមួយចំនួនក៏ដោយ ក៏នៅមានបញ្ហាមិនប្រក្រតីនៃការតាមដានត្រួតពិនិត្យលើការប្រើប្រាស់ដីដែលបានផ្តល់ឲ្យតាមរយៈសម្បទាន ដោយរួមមានទាំង ការខ្វះប្រសិទ្ធិភាពខាងការគ្រប់គ្រង និងការឃ្លាំមើល ។

១០២. របាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ សរសេរថា នៅក្នុងខែធ្នូ ឆ្នាំ២០០៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្តល់ព័ត៌មានថា មានសម្បទានដីដែលមានសកម្មភាពចំនួន ១០ ត្រូវបានទទួលការពិនិត្យមើលឡើងវិញ ហើយថា ក្រៅពីការលប់ចោលនូវសម្បទានដីមួយចំនួន គេមិនដឹងប្រាកដទេថា តើមានការចាប់ផ្តើមពិនិត្យមើលឡើងវិញជាទូទៅលើសម្បទានដីដែលមានស្រាប់ទាំងអស់ឬទេ។ សម្បទានដីទំហំធំៗរួមមាន សម្បទានដីរបស់ក្រុមហ៊ុនភាពីម៉ិច នៅក្នុងខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំង និងសម្បទានដីរបស់ក្រុមហ៊ុន ហ្គ្រីនស៊ី (Green Sea) ដែលគ្របដណ្តប់លើផ្ទៃដីទំហំ ១០០.៨៥២ ហិកតា ក្នុងខេត្តស្ទឹងត្រែង មិនត្រូវបានកាត់បន្ថយផ្ទៃដីទេ។ ព័ត៌មានថ្មីៗ ដែលនៅតែជាព័ត៌មានមិនទាន់ធ្វើបច្ចុប្បន្នភាព ដែលរកបាននៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ បានរាយការណ៍ថា ចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០០៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានរៀបចំឡើងនូវក្រុមការងារចំនួន ៥ សម្រាប់ឲ្យធ្វើការពិនិត្យមើលឡើងវិញ និងវាយតំលៃលើគ្រប់សម្បទានដីសេដ្ឋកិច្ច ដែលមានស្រាប់ទាំងអស់។ ជាលទ្ធផល មានសម្បទានដីសេដ្ឋកិច្ចចំនួន ៥ ត្រូវបានលុបចោល។[១៩៥]

---

[១៩៣] យោងតាមក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រុមហ៊ុនទាំងអស់ ដែលបានចុះកិច្ចសន្យា នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ និងយោងតាមគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនទាំងនេះ បានចុះឈ្មោះ និងបានដាក់អាស័យដ្ឋានក្រុមហ៊ុនដូចគ្នា ក្នុងប្រទេសកម្ពុជា និង អាស័យដ្ឋានផ្សេងគ្នា ក្នុងប្រទេសវៀតណាម។

[១៩៤] ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ទំព័រទី ១០។

[១៩៥] យោងតាម ព័ត៌មានទូទៅស្តីពីសម្បទានដីសេដ្ឋកិច្ច ចុះផ្សាយនៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ គិតមកទល់ ខែមេសា ឆ្នាំ២០១០ មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ៩ ដែលបានទទួលដីសម្បទានលើផ្ទៃដីទំហំធំជាង១០.០០០ ហិកតា តែត្រូវបានចរចា ដើម្បីកាត់បន្ថយទំហំផ្ទៃដីទាំងនោះឲ្យមកនៅត្រឹម ១០.០០០ ហិកតា វិញ។ រវាងពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០០៩ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបង្កើតក្រុមការងារ ៥ ដើម្បី ពិនិត្យមើលឡើងវិញ និងវាយតំលៃលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ នៅ ១៦ ខេត្ត ។ នៅខែកក្កដា ឆ្នាំ២០០៩ ក្រុមការងារនេះបានដាក់របាយការណ៍របស់ខ្លួនទៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ហើយបន្ទាប់មកក្រសួងក៏បានធ្វើការវាយតម្លៃ និងចេញសេចក្តីណែនាំទៅដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ៣៨ ក្រុមហ៊ុន ដែលអភិវឌ្ឍន៍ដោយភាពយឺតយ៉ាវ ឬ មិនចាប់ផ្តើមដំណើរការសកម្មភាពលើដីសម្បទានរបស់ខ្លួន។ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក៏បានស្នើសុំផងដែរឲ្យរដ្ឋាភិបាលលុបចោលសម្បទានដីមួយចំនួន ដែលជាយថាហេតុ មានការលុបចោលសម្បទានសេដ្ឋកិច្ចចំនួន ៥ ដែលមានផ្ទៃដីស្មើនឹង ៤០.១៧១ ហិកតា។

១០៣. ថ្មីៗនេះ យោងតាមរបាយការណ៍មួយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងនេះបានបង្កើតក្រុមការងារចម្រុះមួយ ដែលរួមមានលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច សម្រាប់ធ្វើការពិនិត្យមើលឡើងវិញ និងវាយតំលៃលើសម្បទានដីនៅទូទាំងប្រទេស នៅក្នុងខែមករា ឆ្នាំ២០១១។[១៩៦] ជាលទ្ធផលនៃការងារនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់សំណើមួយជូននាយករដ្ឋមន្ត្រី ដើម្បីសុំគោលការណ៍លុបចោលកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចំនួន ១២ ដោយសារតែក្រុមហ៊ុនទាំងនោះមិនមានសកម្មភាព និងមិនគោរពតាមកាតព្វកិច្ចនៃកិច្ចសន្យាសម្បទាន និងផែនការមេរបស់ខ្លួន និងដោយអនុញ្ញាតិឲ្យមានការកាប់ឈើខុសច្បាប់ និងការបំពានកាន់កាប់ដីធ្លីក្នុងតំបន់សម្បទានដី។[១៩៧] ការពិនិត្យមើលឡើងវិញនោះ ក៏បានរកឃើញផងដែរថា មានក្រុមហ៊ុនចំនួន ៥១ បានធ្វើសកម្មភាពស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា និងផែនការមេរបស់ពួកគេ ហើយក្រុមហ៊ុន ចំនួន ៧៥ ផ្សេងទៀត ត្រូវបានទទួលការព្រមាន ឬ ណែនាំឲ្យកែតម្រូវភាពមិនប្រក្រតីនានា។[១៩៨]

១០៤. យោងតាមតារាងស្ថិតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២ សម្បទានិកនៃសម្បទានដីសេដ្ឋកិច្ចធំបំផុតគឺ ក្រុមហ៊ុនភាពីម៉ិច ដែលជាកម្មសិទ្ធិរបស់ឧកញ៉ា ឡៅ ម៉េងឃិន បានបន្តកាន់កាប់ដីសម្បទានទំហំ ៣១៥.០២៨ ហិកតាដដែល ខណៈដែលក្រុមហ៊ុន ហ្គ្រីន ស៊ី (Green Sea) ដែលជាកម្មសិទ្ធិរបស់សមាជិកព្រឹទ្ធសភា ឧកញ៉ា ម៉ុង ឫទ្ធី នៅក្នុងខេត្តស្ទឹងត្រែង នៅតែមានឈ្មោះក្នុងបញ្ជីកាន់កាប់ដីសម្បទានសេដ្ឋកិច្ចទំហំ ១០០.៨៥២ ហិកតា ឬ "ប្រមាណជា" ៧០.០០០ ហិកតា ប៉ុន្តែទំហំផ្ទៃដីបច្ចុប្បន្នពុំច្បាស់លាស់។[១៩៩] លើសពីនេះទៀត ក្រុមហ៊ុនមានសម្ព័ន្ធភាពជាមួយគ្នាចំនួន ២ គឺ ក្រុមហ៊ុន ហ្វឹស បាយអូ-តិច អាគ្រីខលឆើរ៉ល (ខេមបូឌា) (First Bio-Tech Agricultural (Cambodia)) និងក្រុមហ៊ុនវើល ទ្រីស្តា អេនធីថេនមិន (ខេមបូឌា) (World Tristar Entertainment

១៩៦ លិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ លេខ ២៤៨៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ ពីលោករដ្ឋមន្ត្រីក្រសួងនេះផ្ញើជូនលោកនាយករដ្ឋមន្ត្រី ទាក់ទងនឹងសំណើសុំលុបចោល គោលការណ៍សម្បទាន និងកិច្ចសន្យាសម្បទានរបស់ក្រុមហ៊ុនចំនួន ១២ ដែលមានដីសម្បទាន នៅក្នុងស្រុកឈូក ខេត្តកំពត នៅស្រុកកែវសីមា និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី នៅស្រុកអណ្តូងមាស និងស្រុក អូរយ៉ាដាវ ខេត្តមណ្ឌលគិរី នៅស្រុកសន្ទុក ខេត្តកំពង់ធំ នៅស្រុកស្នួល និងស្រុកសំបូរ ខេត្តក្រចេះ។

១៩៧ មាន ១២ ក្រុមហ៊ុន ដូចជា៖ វើល ទ្រីស្តា អេនធីថេនមិន (ខេមបូឌា) នូវផ្ទៃដីទំហំ ៩.៨០០ ហិកតា ក្នុងស្រុកឈូក ខេត្តកំពត, ក្រុមហ៊ុន ហ្វឹស បាយអូ-តិច អាគ្រីខលឆើរ៉ល (ខេមបូឌា) ទំហំ ១.០០០ ហិកតា ក្នុងស្រុកឈូក ខេត្តកំពត, អាគ្រោ ហ្វរេសទ្រី រីសឹច (Agro Forestry Research Co., Ltd) ទំហំ ៧០០០ ហិកតា ក្នុងឃុំចុងភ្លាស ស្រុកកែវសីមា និងឃុំពូជ្រី ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី, ហេង អភិវឌ្ឍន៍ (Heng Development Co.,Ltd) ទំហំដី ៨.៦៥៥ ហិកតា ក្នុងស្រុកអណ្តូងមាស ខេត្តរតនៈគិរី, ក្រុមហ៊ុន ហេង ហ៊ាប (Heng Heap Investment Co.,Ltd) ទំហំដី ៧.០០០ ហិកតា ក្នុងស្រុកអូរយ៉ាដា ខេត្តរតនៈគិរី, ក្រុមហ៊ុន ហេង មាន (Heng Mean Investment Co.,Ltd) ទំហំដី ៩១៧ ហិកតា នៅស្រុកសន្ទុក ឃុំក្រយ៉ា ខេត្តកំពង់ធំ; ក្រុមហ៊ុន ក្រចេះ ស៊ីធី ផៅវើ (Kratie City Power Ltd) ទំហំដី ៨០០ ហិកតា នៅស្រុកសំបូរ ខេត្តក្រចេះ; ក្រុមហ៊ុន ហ្គោល មេនថូល (Gold Menthol II Co., Ltd) ទំហំដី ៨២៤ ហិកតា នៅស្រុកក្រចេះ ខេត្តក្រចេះ; ក្រុមហ៊ុន មេគង្គ អេស ស៊ី ឌីវេឡុបមិន (Mekong S.C Development Co.,Ltd) ទំហំដី ៨៣៤ ហិកតា នៅខេត្តក្រចេះ; ក្រុមហ៊ុន ភីអេសវ៉ាយ (PSY Co.,Ltd) ទំហំ ៩៥០ ហិកតា នៅស្រុកសំបូរ ខេត្តក្រចេះ; ក្រុមហ៊ុន ស៊ីល ឌីវេឡុបមិន (Seal Development Co.,Ltd) ទំហំដី ៩៥០ ហិកតា នៅស្រុកសំបូរ ខេត្តក្រចេះ; ក្រុមហ៊ុន ធីធីវ៉ាយ (TTY Cooperation Co.,Ltd) ទំហំដី ៩២៨ ហិកតា នៅស្រុកស្នួល ខេត្តក្រចេះ។

១៩៨ ឆ្លើយតបនឹងសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ ទីស្តីការគណៈរដ្ឋមន្ត្រី បានប្រាប់ទៅក្រសួងវិញថា រដ្ឋាភិបាលបាន យល់ព្រមតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខប្រម៉ាញ់ និងនេសាទ ដើម្បីលុបចោល គោលការណ៍សម្បទាន និងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ចំនួន ១២ នឹងត្រូវផ្ទេរដីនោះទៅជាទ្រព្យសម្បត្តិរបស់រដ្ឋវិញ។ សូមមើលលិខិតជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤៣៧ សជណ កស ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ពីឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជូនចំពោះ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។

១៩៩ តារាងស្ថិតិក្រុមហ៊ុន ដែលបានចុះកិច្ចសន្យាសម្បទាដីសេដ្ឋកិច្ច ជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២ ដែលមានបង្ហោះនៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (មានតែជាភាសាខ្មែរប៉ុណ្ណោះ)។

(Cambodia)) នៅក្នុងស្រុកឈូក ខេត្តកំពត ក៏ដូចជាក្រុមហ៊ុនហេង ប្រាឌ័រ (Heng Brother) និង ក្រុមហ៊ុន ហេង ហ៊ាប (Heng Heap) ដែលមានទីតាំងក្នុងខេត្តរតនគិរី ដែលក្រុមហ៊ុនទាំងអស់នេះ ត្រូវបានគេគិតថា កិច្ចសន្យាសម្បទានដី ត្រូវបានលុបចោលហើយនោះ ប៉ុន្តែផ្ទុយទៅវិញឈ្មោះក្រុមហ៊ុនទាំងអស់នេះ នៅតែឃើញមានកត់ត្រានៅក្នុងស្ថិតិសម្បទានដីសេដ្ឋកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ ២០១២។

១០៥. ទោះបីជារដ្ឋាភិបាល បានប្រឹងប្រែងដោះស្រាយបញ្ហាអសកម្ម ឬ ការអភិវឌ្ឍន៍មិនត្រឹមត្រូវដោយក្រុមហ៊ុនសម្បទានដីនានា ស្ថិតិបង្ហាញថាការពិនិត្យមើលឡើងវិញ ការតាមដានត្រួតពិនិត្យ និងការលុបចោលកិច្ចសន្យាសម្បទានដី ដែលបានធ្វើកន្លងមក ពុំមានភាពស៊ីសង្វាក់គ្នាទេ។ បទបញ្ជាចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពី សម្បទានដីសេដ្ឋកិច្ច មានគោលដៅច្បាស់លាស់ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ចំពោះក្រុមហ៊ុន ដែលទទួលបានសិទ្ធិប្រើប្រាស់ដីក្រោមលក្ខខ័ណ្ឌសម្បទានដីសេដ្ឋកិច្ចរួចហើយ ប៉ុន្តែខកខានក្នុងការអនុវត្តតាមនីតិវិធីជាធរមាន និងតាមកិច្ចសន្យាសម្បទាន រដ្ឋាភិបាល បានសន្យាដកហូតសម្បទានដីសេដ្ឋកិច្ចនោះមកវិញ និងទុកដីទាំងនោះ ក្រោមការគ្រប់គ្រងរបស់រដ្ឋដោយផ្ទាល់។ ទោះបីជាពុំមានការសិក្សាជាសាធារណៈ បានស្តែងចេញឲ្យឃើញក៏ដោយ ក៏នៅអំឡុងពេលសរសេររបាយការណ៍នេះ មានព័ត៌មានថា មានកិច្ចខិតខំប្រឹងប្រែងពិនិត្យមើលឡើងវិញជាលក្ខណៈបណ្តោះអាសន្នកំពុងតែដំណើរការនៅថ្នាក់ខេត្ត ក៏ដូចជាមានសារព័ត៌មានមួយចំនួនបានរាយការណ៍ថា សម្បទានដីមួយចំនួន ត្រូវបានលុបចោល តាមរយៈការការអនុវត្តបទបញ្ជានេះ។

## គ. ការអនុវត្តន៍ស្របតាមក្របខ័ណ្ឌនៃការអភិរក្សចំពោះតំបន់ការពារធម្មជាតិ និងព្រៃឈើ

១០៦. ក្រោមច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ ក្រសួងបរិស្ថានត្រូវបានផ្តល់អំណាចឲ្យបង្កើត ឬ រៀបចំកែប្រែតំបន់ការពារធម្មជាតិ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ និងគោរពតាមការពិនិត្យយ៉ាងហ្មត់ចត់នូវការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លី។ ការចាត់ថ្នាក់ ឬ ការធ្វើអនុបយោគនៃតំបន់ការពារ ត្រូវតែធ្វើឡើងដោយអនុក្រឹត្យ។[២០០] អំឡុងពេលនៃការសរសេររបាយការណ៍នេះ មិនព័ត៌មានអំពីការបង្កើត ឬ កែប្រែព្រំប្រទល់ជាផ្លូវការនូវតំបន់ការពារណាមួយដោយក្រសួងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ ប៉ុន្តែចំនួនសម្បទានដីមានការកើនឡើង រួមមានទាំងសម្បទានដីសេដ្ឋកិច្ច អាជ្ញាប័ណ្ណស្វែងរុករក និងជីកយករ៉ែ និងគម្រោងអភិវឌ្ឍន៍ខ្នាតធំៗ ដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារនានា។

១០៧. ទោះបីជាយ៉ាងណាក៏ដោយ គេសង្កេតឃើញថា តាមការជាក់ស្តែង ការកំណត់ជាប្រព័ន្ធនូវតំបន់គ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិភាគច្រើន តែងតែមិនត្រូវបានកំណត់ជាផ្លូវការទេ នៅមុនពេលដែលផ្ទៃដី ត្រូវបានពិចារណាសម្រាប់សម្បទាន ឬ គម្រោងអភិវឌ្ឍន៍ ។ ប៉ុន្តែវាបានបង្ហាញឲ្យឃើញថា ក្នុងករណីជាច្រើន ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ត្រូវបានសម្រេច បន្ទាប់ពីមានការផ្តល់សម្បទានដី ឬ គម្រោងអភិវឌ្ឍន៍។ នៅក្នុងករណីមួយចំនួន ដំណើរការនៃការកំណត់តំបន់មួយទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ត្រូវបានសម្រេច បន្ទាប់ពីក្រុមហ៊ុនឯកជនដាក់សំណើទៅក្រសួងពាក់ព័ន្ធសុំសម្បទានដី ឬ គម្រោងអភិវឌ្ឍន៍តែប៉ុណ្ណោះ ហើយដែលបន្ទាប់មកទៀត ធ្វើការស្នើសុំទៅក្រសួងបរិស្ថាន ដើម្បីរៀបចំឯកសារចាំបាច់នានា ដើម្បីធ្វើចំណាត់ថ្នាក់ដីនោះទៅជាតំបន់ប្រើ

[២០០] ព្រះរាជក្រឹត្យស្តីពី តំបន់ការពារធម្មជាតិ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ មាត្រា ៣ អនុញ្ញាតឲ្យធ្វើការកែប្រែព្រំប្រទល់តំបន់ការពារធម្មជាតិ ដែលអាចធ្វើទៅបានដោយ "ផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រ ពាក់ព័ន្ធនឹងការអភិរក្សអេកូឡូស៊ី និងការថែរក្សាផ្ទៃដីតំបន់ទាំងនោះ នៅព្រះរាជាណាចក្រកម្ពុជា"។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ មាត្រា ៨ និង មាត្រា ១៣ ក៏បានអនុញ្ញាតិនូវការកែសម្រួលព្រំប្រទល់តំបន់ការពារ បន្ទាប់ពីមានការសិក្សាវាយតម្លៃពេញលេញលើសំណើសុំកែប្រែព្រំប្រទល់ទាំងនោះ។

ប្រាស់ដោយចីរភាព និង ធ្វើអនុបយោគតំបន់ប្រើប្រាស់ដោយចីរភាពនោះទៅជាដីឯកជនរបស់រដ្ឋ។ ជាឧទាហរណ៍ គឺសម្បទានដីដែលផ្តល់ឲ្យក្រុមហ៊ុន ជីងហ្សុងរី (Jing Zhong Ri) នៅក្នុងដែនជម្រកសត្វព្រៃលំផាត់ (សូមមើល ឧបសម្ព័ន្ធទី IV សម្រាប់ការវិភាគបន្ថែម)។

១០៨. អនុក្រឹត្យរបស់រដ្ឋាភិបាលភាគច្រើន ដែលប្រើប្រាស់សម្រាប់ធ្វើចំណាត់ថ្នាក់ដីនៃតំបន់ ដែលស្នើសុំសម្រាប់សម្បទាននៅក្នុងតំបន់ការពារធម្មជាតិ គ្រាន់តែចែងថា "ផ្ទៃដីត្រូវបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាព" ប៉ុន្តែ ពុំបានចែងអំពីប្រភេទនៃតំបន់គ្រប់គ្រងនោះ មុនការកំណត់នេះទេ (សូមមើលឧបសម្ព័ន្ធ I)។ ដូច្នោះហើយ វាពុំមានភាពច្បាស់លាស់ទេថា តើតំបន់ស្នូល ឬ ក៏តំបន់អភិរក្ស ដែលត្រូវបានធ្វើចំណាត់ថ្នាក់បែបនេះ ឬ ថាតើតំបន់ដែលចោទជាសំណួរនេះ មិនត្រូវបានគេវាស់វែងកំណត់ពីមុនមកទេ តាមប្រព័ន្ធគ្រប់គ្រង នៃតំបន់ការពារធម្មជាតិ។

១០៩. ទោះបីជា មានព័ត៌មានតិចតួចដែលអាចរកបានជាសាធារណៈអំពី តំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ គេយល់ឃើញថា មានតំបន់ស្នូល និងតំបន់អភិរក្ស ចំនួនតិចតួចប៉ុណ្ណោះ ដែលត្រូវបានវាស់វែង កំណត់ព្រំប្រទល់ជាផ្លូវការ។ ដូចដែលកត់សំគាល់ពីខាងដើមនៅក្នុងរបាយការណ៍នេះ ច្បាប់ហាមឃាត់ការឈូសឆាយ ឬ សាងសង់ ក្នុងតំបន់ស្នូល ឬ តំបន់អភិរក្ស ហើយការអភិវឌ្ឍន៍ណាមួយនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ឬ តំបន់សហគមន៍ ដែលអាចធ្វើទៅបាន លុះត្រាតែមានការឯកភាពយល់ព្រមដ៏ត្រឹមត្រូវពីរដ្ឋាភិបាល តាមសំណើរបស់ក្រសួងបរិស្ថានតែប៉ុណ្ណោះ។ ការអភិវឌ្ឍន៍ណាមួយនៅក្នុងតំបន់ទាំងនេះ ឬ នៅតំបន់ជាប់គ្នានឹងតំបន់ការពារធម្មជាតិ ដំបូងបំផុតត្រូវតែដាក់ឲ្យមានការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គមជាមុនសិន។ ខណៈដែលវាមានសេចក្តីត្រូវការនូវការបកស្រាយបន្ថែមទៀតពីក្រសួងបរិស្ថាន ទាក់ទងនឹងការកំណត់តំបន់គ្រប់គ្រងជាប្រព័ន្ធ មានរបាយការណ៍ថា សម្បទានដីជាច្រើនកំពុងតែដំណើរការយ៉ាងសកម្មនៅក្នុងតំបន់ភាគកណ្តាលៗនៃតំបន់ការពារ ជាទីកន្លែងដែលមានព្រៃឈើក្រាស់ៗ។ ឧទាហរណ៍ អង្គការលីកាដូ បានបោះពុម្ពផ្សាយទិន្នន័យ ដែលបង្ហាញថា ២២ ភាគរយ នៃដែនជម្រកសត្វព្រៃបឹងពែរ ត្រូវបានគ្របដណ្តប់ដោយចំការកៅស៊ូ។[២០១]

១១០. ក្រសួងបរិស្ថាន ដែលបានផ្តល់កិច្ចសហការយ៉ាងល្អ នៅអំឡុងពេលនៃទស្សនកិច្ចរបស់ខ្ញុំកាលពី ខែឧសភា ឆ្នាំ ២០១២ បានពន្យល់ខ្ញុំអំពីគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការផ្តល់សម្បទានដីនៅតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ សម្រាប់ធ្វើទំនប់វារីអគ្គីសនី គម្រោងទេសចរណ៍ធម្មជាតិ ស្វែងរុករកនិងជីកយករ៉ែ និងផលិតកម្មកសិ-ឧស្សាហកម្ម ថាជាការចាំបាច់ក្នុងការបង្កើតជាខ្សែក្រវ៉ាត់ការពារ មួយដើម្បីបង្ការ និងទប់ស្កាត់ការចូលទន្រ្ទានកាន់កាប់ដោយបំពានជាបន្តទៀតលើដីព្រៃក្នុងតំបន់ការពារធម្មជាតិ ជាពិសេសតំបន់ស្នូល និងតំបន់អភិរក្ស ហើយក្រសួងនេះ ក៏បន្តអះអាងផងដែរថា ខ្លួនអនុវត្ត "គោលនយោបាយស្បែកខ្លា" ក្នុងគោលបំណងបញ្ចៀស ការប៉ះពាល់ដីសហគមន៍។

១១១. ដោយសារតែការអនុវត្តទាំងអស់នេះ នាំឲ្យមានកង្វល់ថា អនុក្រឹត្យកំពុងត្រូវបានប្រើប្រាស់បែប ឱកាសនិយមជាមធ្យោបាយមួយសម្រាប់រដ្ឋាភិបាលធ្វើការកំណត់ផ្ទៃដីក្នុងតំបន់ការពារធម្មជាតិ និងផ្តល់សម្បទានដីនោះឲ្យទៅក្រុមហ៊ុននានា។ បន្ទាប់ពីការពិនិត្យមើលលើអនុក្រឹត្យនានា ដែលត្រូវបានបោះពុម្ពផ្សាយតាមព្រះរាជកិច្ច វាស្តែងឲ្យឃើញថា អនុក្រឹត្យទាំងអស់នោះ ត្រូវបានប្រើប្រាស់ជាទូទៅដើម្បីកំណត់ផ្ទៃដីនៅក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើ

[២០១] ផែនទីរបស់អង្គការលីកាដូ (LICADHO) បានចុះផ្សាយក្នុង*កាសែត ខេមបូឌា ដេលី* (លេខ ៧៣០ នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ទី១០ និងទី១១ ខែមីនា ឆ្នាំ២០១២)។

ប្រាស់ដោយចីរភាព ដោយពុំមានផ្តល់ព័ត៌មានថា តើមានការធ្វើឡើងជាមុន និងយ៉ាងពេញលេញនូវ ការវាយតម្លៃ និង ការពិគ្រោះយោបល់នោះទេ។

១១២. លើសពីនេះទៀត ដោយសារឈ្មោះរបស់ក្រុមហ៊ុនជានិច្ចកាល ត្រូវបានសរសេរនៅក្នុងអនុក្រឹត្យ (ជាញឹកញាប់ មាននិយាយយោងដល់លិខិតឆ្លើយឆ្លងជាលាយលក្សណ៍អក្សរពីមុនៗផង) អ្នកសង្កេតការណ៍ប្រកបដោយហេតុផល ម្នាក់ អាចសន្និដ្ឋានបានថា មានការរៀបចំទុកមុនរួចជាស្រេចហើយជាមួយក្រុមហ៊ុនដែលទំនងជា ទទួលបានសម្បទាន ដី ដើម្បីនឹងដំណើរការទៅមុខជាមួយនឹងការអភិវឌ្ឍនៅក្នុងតំបន់នោះ។ មានករណីមួយចំនួន ដែលក្នុងរយៈពេលតែ ប៉ុន្មានសប្តាហ៍ ឬ ប៉ុន្មានខែ បន្ទាប់ពីការចេញនូវអនុក្រឹត្យលើកដំបូងមួយរួចមក មានការចេញនូវអនុក្រឹត្យបន្ទាប់មួយ ទៀត ដើម្បីធ្វើអនុបយោគទៅជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីដែលបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាពនោះ ដូច្នេះ ដើម្បីធានាបានអំពីភាពស្របច្បាប់នៃដីនេះក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ឬ សម្បទានដីផ្សេងៗទៀត។ ការណ៍នេះ បានចោទឡើងជាសំណួរថា តើការអនុវត្តបែបនេះ ស្របតាមក្របខ័ណ្ឌគតិយុត្តជាធរមានយ៉ាងពេញលេញ សម្រាប់រដ្ឋា ភិបាល ក្នុងការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋ ដោយពុំឆ្លងកាត់ការពិនិត្យរបស់រដ្ឋសភា។

១១៣. ឧទាហរណ៍បន្ថែមទៀតត្រូវបានផ្តល់ ក្នុងករណីនៃតំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម និងគម្រោងរមណីយដ្ឋាន ទេសចរណ៍ ដែលកំពុងត្រូវបានអភិវឌ្ឍន៍នៅខេត្តកោះកុង ដោយក្រុមហ៊ុន យូញៀន ឌីវេឡុបមិន គ្រុប (Union Development Group) (សូមមើលឧបសម្ព័ន្ធ៣)។ មុនពេលរដ្ឋាភិបាលចុះកិច្ចសន្យាជួលរយៈពេលវែង ៩៩ឆ្នាំ ដើម្បី ផ្តល់ដីទំហំ ៣៦.០០០ ហិកតា នៅក្នុងឧទ្យានជាតិបុទុមសាគរឲ្យទៅក្រុមហ៊ុន មានព្រះរាជក្រឹត្យមួយ ត្រូវបានចេញ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៨ ដើម្បីធ្វើវិសោធនកម្មព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលបានទទួល ស្គាល់តំបន់នេះ ជាឧទ្យានជាតិដែលត្រូវការពារ។ ព្រះរាជក្រឹត្យថ្មីនេះ បានកាត់ផ្ទៃដីទំហំ ៣៦.០០០ ហិកតា ចេញពី ឧទ្យានជាតិបុទុមសាគរដែលមានផ្ទៃដី ទំហំសរុប ១៧១.២៥០ ហិកតា និងបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវ ផ្ទៃដីដែលត្រូវបានកាត់ចេញនេះ។ ការណ៍នេះ អាចអនុញ្ញាតិឲ្យរដ្ឋាភិបាល ចុះកិច្ចសន្យាជួលរយៈពេលវែង ជាមួយក្រុម ហ៊ុន នៅខែឧសភា ឆ្នាំ២០០៨ ដោយពុំបានឆ្លងកាត់ការពិនិត្យពីរដ្ឋសភា។ គួររំលឹកថា ក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ ដីសាធារណៈរបស់រដ្ឋ អាចត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋបាន តែតាមរយៈការធ្វើអនុបយោគ ដោយច្បាប់ ដែលអនុម័តដោយរដ្ឋសភាប៉ុណ្ណោះ។[២០២]

## ឃ. ការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

១១៤. ដូចបានពិពណ៌នាយ៉ាងលំអិតនៅក្នុងផ្នែកទី III ក្រោមក្របខ័ណ្ឌច្បាប់កម្ពុជា លក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ ការផ្តល់សម្បទានដីនានាគឺ ការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ការ វាយតម្លៃទាំងអស់ ត្រូវតែបានប្រព្រឹត្តិទៅ និងត្រូវបានពិនិត្យមើលឡើងវិញ និងលទ្ធផលនៃការវាយតម្លៃ ត្រូវបានចែក ផ្សាយមុនពេលនៃការផ្តល់សម្បទានដី។

១១៥. ដូចបានលើកឡើងនៅក្នុងរបាយការណ៍តំណាងពិសេស ឆ្នាំ២០០៧ នៅក្នុងករណីភាគច្រើន មានភស្តុតាង តិចតួចណាស់ នៃការពិគ្រោះយោបល់ជាសាធារណៈគ្រប់ជ្រុងជ្រោយ (ដែលមាននូវកិច្ចខិតខំប្រឹងប្រែងដោយសុទ្ធចិត្ត ដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នករងការប៉ះពាល់ទាំងអស់ និងដើម្បីសម្រេចយកដំណោះស្រាយនានា ដែលមានការ ព្រមព្រៀងទៅវិញទៅមក) ត្រូវបានធ្វើឡើងមុនការផ្តល់សម្បទានដី។ ផ្ទុយទៅវិញ សេចក្តីសម្រេចចិត្តនានា ដែលប៉ះ

[២០២] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ១៦ និង មាត្រា ១៧។

ពាល់ដល់ដីធ្លីដែលសហគមន៍កំពុងរស់នៅ ជានិច្ចកាលត្រូវបានធ្វើឡើង ដោយពុំមានការចូលរួមរបស់ពួកគេទេ។ ដូចគ្នាផងដែរ នៅក្នុងករណីភាគច្រើន ការវាយតម្លៃដ៏ពិតប្រាកដអំពីការប៉ះពាល់ខាងបរិស្ថាន និងសង្គម ជាទូទៅ ពុំត្រូវបានធ្វើនៅមុនពេលនៃការផ្តល់សម្បទានដីសម្រាប់ការវិនិយោគឡើយ ឬ ក៏ត្រូវបានធ្វើឡើងនៅក្នុងករណីមួយចំនួន ប៉ុន្តែពុំមានការផ្សព្វផ្សាយដល់ ឬ ចែករំលែកការរកឃើញអំពីការប៉ះពាល់នោះ ជាមួយសហគមន៍ដែលរងផលប៉ះពាល់នោះទេ។

១១៦. សម្បទាននានាដែលត្រូវបានផ្តល់ចាប់តាំងពីឆ្នាំ២០០៧មក ហាក់ដូចជាឆ្លុះបញ្ចាំងអំពីនិន្នាការនេះ។ ស្ថិតិចុងក្រោយនៃសម្បទានដីសេដ្ឋកិច្ច ដែលបានបង្ហោះលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្ហាញថា ការវាយតម្លៃអំពីផលប៉ះពាល់ ត្រូវបានធ្វើឡើងចំពោះសម្បទានដីចំនួន ៣ ក្នុងចំណោមសម្បទានដីចំនួន១១៧ ដែលត្រូវបានផ្តល់ បន្ទាប់ពីមានការឯកភាពជាផ្លូវការលើគម្រោងវិនិយោគរបស់ក្រុមហ៊ុន (បន្ទាប់ពីក្រុមហ៊ុនទាំងនោះ បានចុះកិច្ចសន្យាសម្បទានរួចរាល់ហើយជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។[២០៣] កត្តានេះ បន្សល់មកនូវភាពមិនច្បាស់លាស់ ថាតើមានការវាយតម្លៃអំពីផលប៉ះពាល់ត្រូវបានធ្វើឡើងឬទេ ចំពោះសម្បទានដីសេដ្ឋកិច្ចនានា ដែលបានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១២ ហើយ បើសិនជាបានធ្វើឡើង ថាតើលទ្ធផលនៃការវាយតំលៃទាំងនោះ ត្រូវបានឯកភាពយល់ព្រមដោយក្រសួងពាក់ព័ន្ធ មុនពេលដែលក្រុមហ៊ុនចាប់ផ្តើមសកម្មភាពរបស់ពួកគេឬយ៉ាងណា។

១១៧. យោងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាព នៅក្នុងឆ្នាំ២០០៨ ក្រសួងបរិស្ថាន បានពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើរបាយការណ៍នៃការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់គម្រោង សាធារណៈ និងឯកជនចំនួន ៣៧ ដែលជាចំនួនដ៏តិចតួចស្តួចស្តើង នៃចំនួនសម្បទានដីសរុបដែលត្រូវបានផ្តល់។ មានរបាយការណ៍វាយតម្លៃចំនួន ១៥ ប៉ុណ្ណោះ លើវិស័យកសិកម្ម ឧស្សាហកម្ម ថាមពល ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានអនុម័ត ហើយពុំមានរបាយការណ៍ណាមួយនៃរបាយការណ៍ទាំងនេះ អាចរកបានជាសាធារណៈនោះទេ។ ក្រសួងបរិស្ថាន ក៏បានចុះកិច្ចព្រមព្រៀងស្តីពីការការពារបរិស្ថាន ជាមួយវិនិយោគិនចំនួន ៦១ ផងដែរ ប៉ុន្តែ ពុំមានព័ត៌មានអំពីការអនុវត្តកិច្ចព្រមព្រៀងទាំងនោះ ដែលអាចរកបានទេ។[២០៤]

## ង. ការអនុវត្តតាមក្របខ័ណ្ឌការពារតាមផ្លូវច្បាប់ សម្រាប់ដីធ្លីរបស់ជនជាតិដើមភាគតិច

[២០៣] តារាងស្ថិតិក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ គិតត្រឹមថ្ងៃទី៨ ខែមិថុនា ឆ្នាំ ២០១២ មាននៅគេហទំព័រៈ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf. ស្ថិតិនេះបង្ហាញថា ក្រុមហ៊ុន Asia World Agricultural Development (Cambodia) Co. Ltd) និងក្រុមហ៊ុន Green Island Agricultural Development (Cambodia) Co. Ltd ស្ថិតនៅស្រុកសំបូរ ខេត្តក្រចេះ បានចុះកិច្ចសន្យាសម្បទាន ជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ លើផ្ទៃដីទំហំ ១០.០០០ ហិកតា និង ដីទំហំ ៩.៥៨៣ ហិកតា រៀងៗខ្លួន។ ក្រុមហ៊ុនទាំងនេះ មានឯកភាពយល់ព្រមអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ តាមរយៈលិខិតចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ ចំពោះ Asia World Agricultural Development (Cambodia) Co. Ltd និងលិខិតចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ចំពោះក្រុមហ៊ុន Green Island Agricultural Development (Cambodia) Co. Ltd ។ ក្រុមហ៊ុន (ខេមបូឌា) តុងមិនគ្រុប អ៊ិនជីនារីង ((Cambodia) Tong Min Group Engineering) នៅស្រុកក្រចេះ ខេត្តក្រចេះ បានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជាមួយ ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨ លើផ្ទៃដីទំហំ ៧.៤៦៥ ហិកតា និងបានរៀបចំធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ប៉ុន្តែមិនទាន់មានការឯកភាពនៅឡើយ។

[២០៤] ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ទំព័រ ៣៨ កថាខ័ណ្ឌទី១២៥ ។

១១៨. ច្បាប់ភូមិបាល ឆ្នាំ ២០០១ ចែងអំពី សិទ្ធិរបស់ជនជាតិដើមភាគតិចលើដីធ្លី ហើយការអនុម័តអនុក្រឹត្យ ស្តីពីការចុះបញ្ជីដីជនជាតិដើមភាគតិចនៅខែមេសា ឆ្នាំ២០០៩ បានបង្កើតឲ្យមានឡើងនូវការផ្តួចផ្តើមផ្សេងៗ ដោយក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ម្ចាស់ជំនួយទ្វេភាគី អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីជួយដល់សហគមន៍ជនជាតិដើមភាគតិច ចុះបញ្ជីជានីតិបុគ្គល និងដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ គម្រោងសាកល្បងមួយ ត្រូវបានដាក់ឲ្យដំណើរការ នៅឆ្នាំ២០០៩ ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដល់សហគមន៍ជនជាតិភាគតិចចំនួន ៣ សហគមន៍ នៅក្នុងខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី។ នៅក្នុងខែធ្នូ ឆ្នាំ២០១១ សហគមន៍ទាំងនេះបាន ទទួលកម្មសិទ្ធិដីសមូហភាពដំបូងគេបំផុតនៅកម្ពុជា ដែលជាសមិទ្ធិផលដ៏សំខាន់មួយ។[២០៥]

១១៩. នៅអំឡុងពេលសរសេររបាយការណ៍នេះ យោងតាមអង្គការពលកម្មអន្តរជាតិ (ILO) មានជនជាតិដើមភាគតិចចំនួន ៦០ សហគមន៍ នៅក្នុងខេត្តចំនួន ៤ (មណ្ឌលគិរី រតនៈគិរី ក្រចេះ និងកំពង់ស្ពឺ) ត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ ថាជាជនជាតិដើមភាគតិច ដែលផ្អែកលើការធ្វើស្វ័យអត្តសញ្ញាណរបស់ខ្លួន, មានសហគមន៍ជនជាតិដើមភាគតិចចំនួន ៤៣ ត្រូវបានទទួលស្គាល់ថាជានីតិបុគ្គល ដោយក្រសួងមហាផ្ទៃ និងមានសហគមន៍ជនជាតិដើមភាគតិចយ៉ាងណាស់ចំនួន ២៤ បានតាក់តែងបង្កើតបទបញ្ជាផ្ទៃក្នុង ឬ កំពុងដំណើរការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[២០៦]

១២០. ទោះបីជាតួលេខនេះតំណាងឲ្យជំហានវិជ្ជមាន សម្រាប់ការការពារដីធ្លី វប្បធម៌ ភាសា និងប្រពៃណី នៃសហគមន៍ទាំងនេះ ក៏នៅមានជនជាតិដើមភាគតិចជាច្រើនសហគមន៍ទៀត នៅក្នុងខេត្តចំនួន ១៥ ដែលកំពុងតែត្រូវការកិច្ចគាំទ្រ ដើម្បីការការពារដីធ្លីដែលបានកាន់កាប់ជាប្រពៃណីរបស់ពួកគេ នៅចំពោះមុខនៃការអភិវឌ្ឍន៍ប្រកបដោយភាពខ្វះការគ្រប់គ្រងត្រឹមត្រូវតាមច្បាប់។ ការផ្តល់សម្បទានដីនៅលើដីរបស់ជនជាតិដើមភាគតិច ប៉ះពាល់ដល់ភាពរួបរួមគ្នារបស់សហគមន៍ ហើយហេតុនេះ ក៏មានការប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេក្នុងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដែលជាលទ្ធផលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ និងលទ្ធភាពរបស់ពួកគេក្នុងការរកអាហារ ទទួលទាន និងអនុផលព្រៃឈើ និងក្នុងការអនុវត្តសិទ្ធិខាងវប្បធម៌របស់ពួកគេ។ ជាឧទាហរណ៍មួយគឺ ក្រុមហ៊ុនចំការកៅស៊ូ ជីង ហ្សុងវី ដែលទទួលបានសម្បទានដីនៅលើដីរបស់ជនជាតិដើមភាគតិចទំពួន នៅក្នុងស្រុកលំផាត់ ខេត្តរតនៈគិរី ដែលខ្ញុំបានទៅធ្វើទស្សនៈកិច្ច (សូមមើលឧបសម្ព័ន្ធ IV)។

១២១. លើសពីនេះទៀត ទោះបីជាមានច្បាប់ និងគោលនយោបាយនានាមានលក្ខណៈរឹងមាំជាទូទៅនៅថ្នាក់ជាតិ ក៏ដំណើរការទាំងអស់នេះ ត្រូវពឹងផ្អែកទាំងស្រុងលើជំនួយមកពីក្រៅនៃប្រទេសអ្នកផ្តល់ជំនួយ និង ឆន្ទៈនយោបាយមិនប្រាកដប្រជាដែលបានអនុវត្តតាមមួយករណីៗ។ វាក៏តម្រូវឲ្យមាននូវអង្គការសង្គមស៊ីវិល នៅតាមមូលដ្ឋានក្នុងបណ្តា

---

[២០៥] សហគមន៍ទាំងបី មាន៖ ១)-ភូមិឡាអឺន ឃុំគីន ស្រុកកូនមុំ ខេត្តរតនៈគិរី មាន ១២១ គ្រួសារ (៤៩១នាក់) ជាជាតិដើមភាគតិចគ្រឹង និង ទំពួន ដែលបានទទួលប័ណ្ណកម្មសិទ្ធិសមូហភាពលើផ្ទៃដីទំហំ ១.៤៥៤ ហិកតា ២)-ភូមិឡាអឺនក្រែន ឃុំអូជុំ ស្រុកអូជុំ ខេត្តរតនៈគិរី មាន ៩៤ គ្រួសារ (៤៥៦នាក់) ជាជនជាតិដើមភាគតិចទំពួន ដែលបានទទួលប័ណ្ណកម្មសិទ្ធិសមូហភាពលើផ្ទៃដីទំហំ ៩២០ ហិកតា និង ៣)-ភូមិអណ្តូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្ត មណ្ឌលគិរី មាន ១១៤ គ្រួសារ (៤៦៦ នាក់) ជាជនជាតិដើមភាគតិចពួង បានទទួលប័ណ្ណកម្មសិទ្ធិសមូហភាព លើផ្ទៃដីទំហំ ១.៤២៥ ហិកតា។ សូមមើលផងដែរ សេចក្តីថ្លែងការណ៍រួមរបស់ការិយាល័យ OHCHR/ILO "សហគមន៍ ៣ ទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព" នៅគេហទំព័រ http://cambodia.ohchr.org/WebDOCs/DocNewsIndex/ 2011/122011/3_indigenous_communities_to_receive_communal_land_titles_Eng.pdf

[២០៦] អង្គការ ILO "ស្ថានភាពនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា" ឯកសារបច្ចុប្បន្នភាព បានដាក់ជូនដៃគូរអភិវឌ្ឍន៍ ថ្ងៃទី១ ខែសីហា ឆ្នាំ២០១២។

ខេត្តនានា សម្រាប់អនុវត្តផងដែរ។ យោងតាមព័ត៌មានអំពីគម្រោងនានា ដែលកំពុងតែមានដំណើរការដែលផ្តល់ដោយអង្គការ ILO ដែលជាអ្នកសម្របសម្រួលការផ្តួចផ្តើមទាំងនោះថា ខណៈតំបន់ដែលមានចំនួនប្រជាជនជនជាតិដើមភាគតិចច្រើន ដូចជាខេត្តមណ្ឌលគិរី ខេត្តរតនៈគិរី និងខេត្តព្រះវិហារ បានទទួលការយកចិត្តទុកដាក់បំផុត និង ទទួលបានជំនួយហិរញ្ញវត្ថុទ្វេភាគី និងពហុភាគី ពីអង្គការ GIZ អង្គការ Danida អង្គការ CIDA ការិយាល័យ OHCHR ក៏ដូចជាអង្គការសង្គមស៊ីវិលនានា ដែលទទួលមូលនិធិពីសហភាពអឺរ៉ុប ការផ្តួចផ្តើមបែបនោះ មានភាពយឺតយ៉ាវក្នុងការពង្រីកទៅកាន់ខេត្តផ្សេងៗ ទៀត ដោយសារតែកត្តាសមត្ថភាព និងធនធានមានកម្រិត។[២០៧]

១២២. មានបញ្ហាប្រឈមជាច្រើនត្រូវបានរាយការណ៍ ជាមួយនឹងលក្ខខណ្ឌតម្រូវខាងនីតិវិធី សម្រាប់ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដែលត្រូវការពេលវេលាយូរ និងជាដំណើរការដែលពោរពេញដោយបន្ទុកការិយាធិបតេយ្យ។ ខណៈដែលគោលនយោបាយពាក់ព័ន្ធ មានទៅដោយដំណើរការមួយដែល "សាមញ្ញ ទាំងលើ ទិដ្ឋភាពរដ្ឋបាល និង បច្ចេកទេស"[២០៨] ការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ន មាននិតិវិធីចំនួន ១១ ជំហាន សម្រាប់ចុះបញ្ជីជានីតិបុគ្គល និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។ នេះរួមមាន នីតិវិធីផ្សេងៗពាក់ព័ន្ធនឹងអាជ្ញាធរជាតិ អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ក្នុងការទទួលស្គាល់សហគមន៍ជាផ្លូវការថា ជាជនជាតិដើមភាគតិចដោយផ្អែកលើស្វ័យអត្តសញ្ញាណកម្ម និងការវាយតំលៃផ្លូវការ ព្រមទាំងការបង្កើតលក្ខន្តិកៈសហគមន៍ និងការចុះបញ្ជីជានីតិបុគ្គល។ កិច្ចការនេះ ត្រូវបន្តដោយការបង្កើតបទបញ្ជាផ្ទៃក្នុង ការវាស់វែងដីធ្លីការគូសផែនទី និងការបង្ហាញលទ្ធផលនោះជាសាធារណៈ។ ម្យ៉ាងវិញទៀត ទិដ្ឋភាពវិជ្ជមានមួយនៃដំណើរការទាំងនោះគឺថា នីតិវិធីទាំងនោះកំពុងប្រព្រឹត្តទៅជាមួយនឹងការចូលរួមនៃអ្នកពាក់ព័ន្ធនានា និងជាមួយនឹងការចូលរួមយ៉ាងពេញលេញពីសហគមន៍នានា ដែលនេះជាកិច្ចការដែលសូមចូលរួមកោតសរសើរ។

១២៣. ដោយសារតែនីតិវិធីដ៏អូសបន្លាយនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដូច្នេះសារាចរអន្តរក្រសួងចេញក្នុងខែឧសភា ឆ្នាំ២០១១ ដែលផ្តល់នូវវិធានការការពារជាបណ្តោះអាសន្នដល់ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ គឺជាការបោះជំហានគួរជាទីស្វាគមន៍មួយ ។ ជាលទ្ធផល វាគួរតែបានបញ្ឈប់នូវការផ្តល់សម្បទានដីនានាលើដីដែលកាន់កាប់ជាប្រពៃណីដោយជនជាតិដើមភាគតិច ។ ឧទាហរណ៍ យ៉ាងហោចណាស់ មានជនជាតិព្នង មកពីភូមិចំនួន ២ នៅក្នុងស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី ត្រូវបានផ្តល់នូវការការពារ ដោយអភិបាលខេត្តមណ្ឌលគិរី នៅក្នុងឆ្នាំ២០១១ និង ២០១២ នៅខណៈពេលដែលពួកគេកំពុងតែដំណើការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ។ ទោះបីជាលក្ខខណ្ឌតម្រូវសម្រាប់ការទទួលស្គាល់ដល់ជនជាតិដើមភាគតិច ដោយក្រសួងមហាផ្ទៃ មានតែចំពោះសហគមន៍ដែលទទួលបានអត្ថប្រយោជន៍ពីការជួយឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍ក៏ដោយ តែទោះជាដូច្នេះក្តី ក៏បច្ចុប្បន្ននេះមានសហគមន៍ ចំនួន ៣៥ ដែលមានសិទ្ធិនឹងទទួលបានការការពារនេះ។ មិនតែប៉ុណ្ណោះ មានការកំណត់តម្រូវឲ្យសហគមន៍ ផ្តល់ផែនទីលំអិតនៃដីសមូហភាពដែលស្នើសុំ ដាក់ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយបើសិនជាមិនមានផែនទីលំអិតទេ នោះគឺជាមូលដ្ឋាននៃការបដិសេធផងដែរ។ វាក៏អាស្រ័យលើឆន្ទៈរបស់អភិបាលខេត្តនីមួយៗផងដែរ ។ មានតែសហគមន៍មួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឲ្យនូវការការពារបែបនេះ។

១២៤. លើសពីនេះទៀត មានបញ្ហាចន្លោះប្រហោងជាអកុសលមួយក្នុងសារាចរនេះ ដែលជួយបន្ថែមមិនឲ្យសារាចរនោះអនុវត្តបានទូលំទូលាយ នៅក្នុងការអនុវត្តជាក់ស្តែង។ វិធានការការពារជាបណ្តោះអាសន្ន មិនរាប់បញ្ចូលផ្ទៃដីដែល

[២០៧] គម្រោងមួយចំនួនតូច មាននៅក្នុងខេត្តកំពង់ស្ពឺ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ដោយមានសំណើសុំពង្រីកគម្រោងបែបនេះបន្ថែមទៀត។

[២០៨] គោលនយោបាយស្តីពី ការចុះបញ្ជី និងសិទ្ធិក្នុងការប្រើប្រាស់ដី របស់សហគមន៍ជនជាតិដើមភាគតិច នៅកម្ពុជា មាត្រា ៤ ។

រដ្ឋាភិបាលបានព្រមព្រៀង*ជាគោលការណ៍* សម្រាប់ការវិនិយោគ ឬ ការអភិវឌ្ឍន៍ មុនពេលដែលសារាចរនេះ ចូលជាធរមាននៅខែឧសភា ឆ្នាំ២០១១ (យោងតាមសារាចរនេះ ដើម្បីបញ្ចៀសផលប៉ះពាល់ពាល់ណាមួយលើកម្មសិទ្ធិដីឯកជន និងសាធារណៈស្របច្បាប់ ដែលត្រូវបានកាន់កាប់ដោយស្របច្បាប់ និងមានការឯកភាព ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន)។ ដោយសារភាពមិនប្រក្រតីនៃការផ្តល់សម្បទានដី និងការប្រឹងប្រែងដោយជោគជ័យក្នុងការកេងចំណេញពីលើក្របខ័ណ្ឌច្បាប់ ដូច្នេះ ធ្វើឲ្យសារាចរនេះ មានប្រសិទ្ធិភាពតិចតួចប៉ុណ្ណោះ។

១២៥. ចំពោះការគាំទ្រដែលកំពុងតែប្រព្រឹត្តទៅពីសំណាក់ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលនានា ដើម្បីជួយចងក្រងសហគមន៍ជនជាតិដើមភាគតិចវិញ គឺការផ្តួចផ្តើមទាំងនេះជាច្រើន កំពុងប្រឈមនឹងហានិភ័យនៃការខូចខាត ទោះបីជាមិនត្រូវបានបោះបង់ចោលទាំងស្រុងក្តី ដោយសារការអនុវត្តមិនស៊ីសង្វាក់គ្នា ពាក់ព័ន្ធនឹងគម្រោងការណ៍ថ្មីនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី តាមបទបញ្ជាស្តីពីសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២។

១២៦. សេចក្តីណែនាំជាបន្តបន្ទាប់មួយត្រូវបានចេញនៅ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២ ដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដោយបំភ្លឺថា ដំណើរការដែលកំពុងតែអនុវត្តទាំងអស់ ត្រូវជាធ្វើបន្ត ។[២០៩] សេចក្តីណែនាំជាបន្តទៀត ដែលបានចេញនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ បង្គាប់ដល់អាជ្ញាធរខេត្តនានាថា ជាផ្នែកមួយនៃគម្រោងការណ៍ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី សូមកុំឲ្យវាស់វែងដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ។[២១០] លើសពីនេះទៀត ជនជាតិដើមភាគតិច ដែលពួកគេភាគច្រើនពុំបានយល់ដឹងអំពីសិទ្ធិលើដីសហគមន៍របស់ខ្លួន ហើយដែលនៅក្នុងករណីមួយចំនួនមានសេចក្តីរាយការណ៍ថា ពួកគេត្រូវបានលើកទឹកចិត្តឲ្យទទួលយកដីឯកជន ដោយអាជ្ញាធរដែលពាក់ព័ន្ធ នៅក្នុងគម្រោងការណ៍ថ្មីនេះ។ ពិតប្រាកដណាស់ បុគ្គលឯកជនទាំងអស់ រួមទាំងជនជាតិដើមភាគតិចផង មានសិទ្ធិទទួលបានដីឯកជន យោងតាមមាត្រា៥ នៃច្បាប់ភូមិបាល (ហើយមានសិទ្ធិទទួលបានភាគខ្លះនៃដីសហគមន៍ នៅពេលចាកចេញពីសហគមន៍នោះ យោងតាមមាត្រា ២៧) ប៉ុន្តែបញ្ហានាពេលបច្ចុប្បន្ននេះ គឺការខ្វះព័ត៌មានពេញលេញ ដើម្បីធ្វើការសម្រេចចិត្ត ផ្អែកលើព័ត៌មានគ្រប់គ្រាន់។ ចំពោះសហគមន៍ដែលមិនទាន់បានចងក្រង ការផ្តល់ព័ត៌មានអំពីសិទ្ធិរបស់ពួកគេលើកម្មសិទ្ធិដីសមូហភាព និងការទទួលបានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និង អាជ្ញាធរខេត្ត/មូលដ្ឋាន ដើម្បីដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពវិញ នោះគម្រោងការណ៍ថ្មីនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីអាចនឹងមានដំណើរការទៅលឿនលុបលើដំណើរការនៃកម្មវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ការពុះចែកដីដែលប្រើប្រាស់ជាប្រពៃណីដោយជនជាតិដើមភាគតិច ទៅជាបំណែកនៃដីឯកជន អាចនឹងធ្វើឲ្យអន្តរាយដល់ការបង្កើតនិងការថែរក្សានៃដីសហគមន៍ (ដែលជាការចាំបាច់សម្រាប់ការការពារតំបន់ដីសមូហភាព ដូចជាទីបញ្ចុះសព និងព្រៃអារក្សជាដើម) ហើយក៏អាចនឹងបណ្តាលឲ្យមានការលក់ដីជនជាតិដើមភាគតិច ជាដីឡូត៍តូចៗផងដែរ។

## VII. ផលប្រយោជន៍ និងផលប៉ះពាល់អវិជ្ជមាននៃសម្បទានដីនានា

[២០៩] ក្រុមប្រឹក្សាគោលនយោបាយដីធ្លី សេចក្តីណែនាំលេខ ១៥ ចុះថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ២០១២ ស្តីពី ការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០១ បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច តំបន់ព្រៃស្រោង និងពាក់កណ្តាលស្រោង ព្រៃឡង់ មូលដ្ឋានការពារប្រទេស និងតំបន់បេតិកភ័ណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ។

[២១០] ក្រុមប្រឹក្សាគោលនយោបាយដីធ្លី សេចក្តីណែនាំ លេខ ២០ ចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១២ ស្តីពី ការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០១ បប ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងតំបន់សហគមន៍ជនជាតិដើមភាគតិច។

១២៧. ក្នុងឋានៈជាទីផ្សារដែលកំពុងងើបឡើង ប្រទេសកម្ពុជាមានវត្ថុបំណងច្បាស់លាស់ ក្នុងការបង្កើនការនាំចេញ និងធ្វើអាជីវកម្មលើធនធានធម្មជាតិរបស់ខ្លួន ដើម្បីគោលបំណងនៃការអភិវឌ្ឍជាតិ។ ជាពិសេស ចំពោះសម្បទានដីសេដ្ឋកិច្ច ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាព ដាក់អាទិភាពលើការបង្កើនផលិតភាព និង ពិពិធកម្មវិស័យកសិកម្ម។[២១១] គម្រោងវារីអគ្គិសនីរបស់កម្ពុជា នឹងមិនគ្រាន់តែផលិតអគ្គិសនីប៉ុណ្ណោះទេ ប៉ុន្តែនឹងជួយរកចំណូលផងដែរ ហើយថាមពលដែលផលិតបាននោះនឹងត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងស្រុក និងក៏ដូចជាអាចសម្រាប់ការនាំចេញផងដែរ។ សម្បទានដី បាននាំមកឲ្យកម្ពុជា ទាំងអត្ថប្រយោជន៍ខាងសេដ្ឋកិច្ច និងខាងសង្គម ដូចជា ការបង្កើតការងារធ្វើ (ហេតុដូច្នេះ មានការកើនឡើងទីផ្សារក្នុងស្រុក ដែលកាន់តែមានសក្តានុពល) ចំណូលពន្ធ ផ្លូវថ្មីៗ និងការធ្វើឲ្យប្រសើរឡើងដល់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ក្រុមហ៊ុនសម្បទានដីមួយចំនួន បានចូលរួមក្នុងកម្មវិធីអប់រំអំពីការអភិរក្ស និងថែរក្សាបរិស្ថាន។ អត្ថប្រយោជន៍ពាក់ព័ន្ធផ្សេងទៀតសម្រាប់សហគមន៍នានា នៅក្នុងតំបន់សម្បទានដី រួមមាន មណ្ឌលសុខភាព និងសាលារៀន។

១២៨. ទោះជាដូច្នោះក្តី ក៏ពុំមានរបាយការណ៍ដែលផ្អែកលើភស្តុតាងទូលំទូលាយ ត្រូវបានបោះផ្សាយជាផ្លូវការ អំពីអត្ថប្រយោជន៍នៃសម្បទានដីនោះដែរ។ ចំនួននៃអ្នកមានការងារធ្វើថ្មី និងការវិនិយោគរូបវន្ត ជាទូទៅអាចទាបជាងការរំពឹងទុក។ លើសពីនេះទៀត ពុំមានភស្តុតាងបង្ហាញថា ចំណូលដែលបានមកពីសម្បទានដី ត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច នៅក្នុងតំបន់មានដីសម្បទាន ដូចជាលើ វិស័យសុខាភិបាល និងវិស័យអប់រំ ឬក៏ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនោះទេ។ ដូចគ្នានេះផងដែរ វាពិបាកនឹងធ្វើការវាយតំលៃថា តើសម្បទានដីនានា បានរួមចំណែកកាត់បន្ថយភាពក្រីក្រដែរឬទេ។ ផ្ទុយទៅវិញ រដ្ឋាភិបាល នៅតែបន្តពឹងផ្អែកយ៉ាងខ្លាំងលើជំនួយបរទេស។ ទិន្នន័យ និងការវិភាគលើចំណូលដែលបានមកពីសម្បទានដី និង អត្ថប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ គឺជាអ្វីដែលត្រូវការជាបន្ទាន់ទៀតនូវការសិក្សា និងការបង្ហាញជាសាធារណៈ ។ ផ្ទុយទៅវិញ ផលប៉ះពាល់អវិជ្ជមាន ត្រូវបានចងក្រងជាឯកសារយ៉ាងច្បាស់លាស់។

## ក. ផលប៉ះពាល់ទូទៅលើសិទ្ធិមនុស្ស

១២៩. គួរឲ្យសោកស្តាយ ផលប៉ះពាល់នៃសម្បទានដី ជាពិសេស សម្បទានដីសេដ្ឋកិច្ចលើសិទ្ធិមនុស្ស នៅតែបន្តកើតមានដូចនិន្នាការដែលបានលើកឡើងនៅក្នុងរបាយការណ៍តំណាងពិសេស ឆ្នាំ ២០០៤ និងឆ្នាំ ២០០៧ ។ ផលប៉ះពាល់មានច្រើន ក្នុងនោះផលប៉ះពាល់ភាគច្រើនដែលខ្ញុំបានឃើញដោយខ្លួនឯង ក្នុងដំណើរបេសកកម្មរបស់ខ្ញុំ នៅកម្ពុជា មានដូចជា ការបំផ្លាញបរិស្ថាន ដោយសារការឈូសរុញដីដោយគ្រឿងចក្រ ការកាប់ឆ្ការព្រៃយកដី និងការ ដាំដំណាំ និងដើមឈើដែលមិនមែនជាពូជក្នុងស្រុក កង្វះការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ដែលរួមចំណែកធ្វើឲ្យសហគមន៍ទាំងនោះ យល់ថាខ្លួនរស់នៅដាច់ឆ្ងាយតែឯង និងគ្មានសារៈសំខាន់ចំពោះសង្គម និងបង្កឲ្យមានទំនាស់ជាមួយនឹងក្រុមហ៊ុន និងអាជ្ញាធរដែនដី ការធ្វើឲ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងចុះបញ្ជីអត្រានុកូលដ្ឋាន ជនជាតិដើមភាគតិចជានីតិបុគ្គល ដើម្បីឲ្យពួកគេមានលទ្ធភាពការពារវប្បធម៌ ភាសា និងរបៀបរបបធ្វើកសិកម្ម បែប បុរាណរបស់ខ្លួន និងដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ការរំលោភយកដីស្រែចំការ និងតំបន់ដីដែលមានសារៈ សំខាន់ផ្នែកវប្បធម៌ និងការគោរពបូជា ការបាត់បង់របរចិញ្ចឹមជីវិតជាប្រពៃណី និងការការពារកុំឲ្យមានភាពខុសគ្នានៃ ចំណូលសរុប (ជនក្រីក្រនៅជនបទ ដោយប្រៀបធៀបទៅនឹងសម្បទានិកជាអ្នកមាន និងអ្នកដែលទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីសម្បទានដី) កង្វះលទ្ធភាពទទួលបានទឹកស្អាត និងមូលដ្ឋានសម្ភារៈអនាម័យ ការបណ្តេញចេញដោយបំពាន ការផ្លាស់

[២១១] ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម កថាខ័ណ្ឌទី ៤ ទំព័រ ១២១។

ទីកន្លែង និងការផ្លាស់ប្តូរទីលំនៅ ដោយប្រជាជនត្រូវចាកចេញពីផ្ទះ និងដីស្រែចំការរបស់ពួកគេ ការបង្កឲ្យមានការលំបាកក្នុងការស្វែងរក ឬ រក្សាស្ថិរភាពការងារ/ការរកប្រាក់ចំណូល និងលទ្ធភាពទទួលបាន សេវាកម្មជាមូលដ្ឋាន លក្ខខណ្ឌការងារមានកម្រិតតស្តង់ដារទាប ការធ្វើឃោធូនីយកម្មដីសម្បទាន ដែលរួមចំណែក ធ្វើឲ្យមានការបំភិតបំភ័យ និងអំពើហិង្សាដែលបង្កឡើងដោយកម្លាំងសន្តិសុខប្រដាប់ដោយអាវុធ ជួនកាល ទាហាននៃកងយោធពលខេមរភូមិន្ទ និង ពេលខ្លះទៀត កងកម្លាំងសន្តិសុខឯកជន និងកង្វះដំណោះស្រាយតាមឧបាស្រ័យ ឬ បណ្តឹងសើរើប្រកបដោយប្រសិទ្ធភាពសម្រាប់សហគមន៍រងគ្រោះ ។ បញ្ហាខ្លះ ត្រូវបានពិភាក្សាស៊ីជម្រៅជាងនេះ នៅខាងក្រោម ។

## ខ. បញ្ហាអស្ថិរភាព និងការគ្រប់គ្រងទន់ខ្សោយ

១៣០. សេចក្តីសន្និដ្ឋានដ៏លើសលប់ដែលត្រូវបានធ្វើឡើងដោយផ្អែកលើ ញត្តិនានា លិខិតផ្សេងៗ ការសិក្សាស្រាវជ្រាវ ការតវ៉ាដោយសន្តិវិធី បាតុកម្មដោយហិង្សា បណ្តឹងតាមផ្លូវច្បាប់ ស្ថិតិទំនាស់ដីធ្លី[២១២] និងការសង្កេត ផ្ទាល់របស់ខ្ញុំ គឺថា សម្បទានដី ផ្តល់ផលប្រយោជន៍ដល់តែជនមួយក្រុមតូចប៉ុណ្ណោះ ។ បរិយាកាសវិនិយោគនៅកម្ពុជា នាពេលបច្ចុប្បន្ននេះ មានលក្ខណៈខ្វះតម្លាភាព ដោយហេតុនេះ មិនមានបញ្ជីផ្លូវការពេញលេញស្តីពីសម្បទានដី និងប្រតិបត្តិការរបស់សហគ្រាសពាណិជ្ជកម្ម ហើយការវាយតម្លៃលើផលប៉ះពាល់ទៀតសោត ក៏មិនត្រូវបានគេធ្វើឡើង និងមិនមានការផ្សព្វផ្សាយជាសាធារណៈដែរ ឬ ត្រូវបានធ្វើឡើងដែរតែនៅពេលបន្ទាប់ពីសម្បទានដីត្រូវបានផ្តល់ ឬ ក៏បន្ទាប់ពីពេលដែលក្រុមហ៊ុន បានចាប់ផ្តើមដំណើរការសកម្មភាពការងាររួចហើយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ជារឿយៗ មិនមានការបញ្ជាក់ច្បាស់លាស់ថា នរណាជាអ្នកទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីដី ដែលបានប្រើប្រាស់ សម្រាប់ការអភិវឌ្ឍក្រុង សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត និងគម្រោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំនោះទេ ។

១៣១. ស្ថានភាពនេះ ផ្តល់នូវមូលដ្ឋានដ៏ងាយស្រួលបំផុតមួយសម្រាប់សហគ្រាសពាណិជ្ជកម្ម គេចវេះពី "ការយកចិត្តទុកដាក់ត្រឹមត្រូវ" លើសិទ្ធិមនុស្ស ឬ ការបង្ការ-ទប់ស្កាត់ និងការដោះស្រាយផលប៉ះពាល់លើសិទ្ធិមនុស្ស ។ លទ្ធផលដ៏អាក្រក់នៃកង្វះតម្លាភាព និងកង្វះការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួមពីសហគមន៍ដែលរស់នៅក្នុង ឬ នៅជិតតំបន់សម្បទានដី ជារឿយៗ គឺការប្រើប្រាស់មិនមានលក្ខណៈចីរភាពនូវធនធានធម្មជាតិ និងការតវ៉ា និងការធ្វើបាតុកម្មជាបន្តតស្រាលស្រាន្ត ។

១៣២. តាមការពិត ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរបំផុតនៃ ការផ្តល់សម្បទានដីមិនប្រក្រតី និងការគ្រប់គ្រងមិនបានល្អនូវសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត ទៅលើប្រទេសជាតិ គឺប្រហែលជាបញ្ហាស្ថិរភាពរបស់ប្រទេសនេះ ។ ទោះបីជាបាតុកម្មជាច្រើន ត្រូវបានធ្វើឡើងដោយសន្តិវិធី និងអាចត្រូវបានចាត់ទុកថា ជាការរួមចំណែកជាវិជ្ជមានដល់សង្គមដ៏រស់រវើកនេះក៏ដោយ ក៏និន្នាការនៃការតវ៉ា និងទំនាស់ដីធ្លីដោយហិង្សា បង្ហាញឲ្យឃើញពីប្រជាជន ដែលមានការអស់សង្ឃឹម និង មិនសប្បាយចិត្តកាន់តែច្រើនឡើងៗ និងសហគមន៍ដែលបានបាត់បង់ជំនឿទៅលើរដ្ឋាភិបាលរបស់ពួកគេ ក្នុងការគ្រប់គ្រង និងការពិនិត្យតាមដានត្រឹមត្រូវលើការចាប់យកដីធ្លី និងធនធានរបស់ខ្លួន ។ ម្យ៉ាងទៀត ការធ្វើអាជីវកម្មដែលមិនមានកិច្ចការពារតាមផ្លូវច្បាប់ និងនីតិវិធីសមស្របជាស្រេចនោះ ត្រូវប្រឈមមុខនឹងហានិភ័យចម្បងៗ ដែលអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឋានៈផ្លូវច្បាប់ និងផលចំណេញ និងចុងក្រោយបង្អស់ អាចរារាំងដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាទៀតផង ។

[២១២] យោងតាមរបាយការណ៍របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលសំរាប់កម្ពុជា (NGO Forum) ទិន្នន័យឆ្នាំ២០១០ បានបង្ហាញថា នៅក្នុងករណីនៃវិវាទដីធ្លីចំនួន ២៨២ ករណី មាន ១៤ ភាគរយ ឬ ៣៩ ករណី គឺបញ្ហាចម្បងកើតចេញមកពីគម្រោងអភិវឌ្ឍន៍ ជាពិសេស បញ្ហានៃការផ្តល់សម្បទានដីសេដ្ឋកិច្ច។ NGO Forum *របាយការណ៍ការវិភាគស្ថិតិនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច* ឆ្នាំ២០១០។

១៣៣. វាអាចមានតម្លៃខាងផលចំណេញ ចំពោះការអភិវឌ្ឍន៍ប្រកបដោយផែនការពេញលេញ សម្រាប់ទាំងអស់គ្នា និងការបង្ការ-ទប់ស្កាត់ជម្លោះ។[២១៣] រដ្ឋាភិបាល មិនគួរសន្មត់ជាមុនថា ខ្លួនកំពុងតែជួយដល់ធុរកិច្ចនានា ដោយការមិនដាក់ឲ្យពួកគេទទួលខុសត្រូវនោះទេ។ ផ្ទុយទៅវិញ ធុរកិច្ចដែលមិនគោរពសិទ្ធិមនុស្ស ឬ ផ្តល់ឲ្យមាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នៅពេលដែលធុរកិច្ចទាំងនេះ រួមចំណែកធ្វើឲ្យមានផលប៉ះពាល់ជាអវិជ្ជមាននោះ ត្រូវប្រឈមមុខនឹងហានិភ័យកាន់តែច្រើនឡើង ដូចជា ការប្រឈមមុខនឹងបណ្តឹងវិវាទផ្នែកសិទ្ធិមនុស្ស ការបង្អាក់ដំណើរការប្រតិបត្តិការ ដោយសារជម្លោះ ឬ ការផ្សព្វផ្សាយព័ត៌មានអវិជ្ជមានជាសាធារណៈ ដោយសារតែការជាប់ពាក់ព័ន្ធជាមួយនឹងការរំលោភបំពាន។ កាលៈទេសៈបែបនេះ អាចប៉ះពាល់ដល់ផលចំណេញ និងគម្រាមកំហែងដល់ចីរភាពនៃអាជីវកម្ម ហើយអត្រាចំណូលវិនិយោគកាន់តែទាប នាំឲ្យចំណូលពន្ធរបស់រដ្ឋាភិបាលថយចុះ។

១៣៤. តាំងតែពីពេលចាប់ផ្តើមអាណត្តិរបស់ខ្ញុំនៅឆ្នាំ ២០០៩ មក ខ្ញុំទទួលបានរបាយការណ៍ច្រើនរាប់មិនអស់ ស្តីពីការតវ៉ា ដែលត្រូវបានធ្វើឡើងដោយសហគមន៍នៅមូលដ្ឋាន ជាពិសេស ប្រឆាំងទៅនឹងសកម្មភាពរបស់ក្រុមហ៊ុនសម្បទានដី។ ក្រុមហ៊ុនជាច្រើន ហាក់ដូចជាធ្វើប្រតិបត្តិការ នៅក្នុងសភាពបិទបាំងស្ទើរតែទាំងស្រុង ហើយមិនអាចតាមដានបានលើប្រតិបត្តិការរបស់ក្រុមហ៊ុនទាំងនោះទេ ដោយសារក្រុមហ៊ុនទាំងនោះ មិនមានការិយាល័យដែលអាចទាក់ទងបាន។ សូម្បីតែក្រុមហ៊ុនដែលអាចទាក់ទងបាន ក៏មិនបានឆ្លើយតបទៅនឹងលិខិតរបស់ខ្ញុំ ដែលបានស្នើសុំព័ត៌មានពីខាងក្រុមហ៊ុននោះដែរ។ ការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមហ៊ុនអាជីវកម្មបរទេស ដែលមានទឹកចិត្តក្នុងការទាក់ទងនោះ បានបង្ហាញឲ្យឃើញថា សម្បទានិកជាច្រើន មិនបានចាត់ទុកតួនាទីរបស់ខ្លួននៅកម្ពុជា ថាមានលក្ខណៈចាំបាច់ដែលត្រូវពិគ្រោះយោបល់ ឬ ចូលរួមពាក់ព័ន្ធច្រើនជាមួយនឹងសហគមន៍ទេ ដោយពួកគេចូលចិត្តប្រើប្រាស់អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ ធ្វើជាអ្នកកណ្តាលជាង ដើម្បីដោះស្រាយបញ្ហានៃការចេញសំណង និងការផ្លាស់ប្តូរទីលំនៅ ។ ជាលទ្ធផលនៃសកម្មភាពទាំងនេះ គឺការមិនទុកចិត្តលើនិយោជិតរបស់ក្រុមហ៊ុន និងការមានអារម្មណ៍ទោមនស្សកាន់តែច្រើនឡើងជាប់ជាប្រចាំ ចំពោះក្រុមហ៊ុនអាជីវកម្មបរទេស ។

១៣៥. ជារឿយៗ ក៏មានការពន្យារពេលដំណើរការនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលបណ្តាលមកពីទំនាស់ផងដែរ ។ ឧទាហរណ៍៖ ចំពោះទំនាស់ដែលកំពុងតែកើតមានឡើងរវាង សាលារាជធានីភ្នំពេញ ក្រុមហ៊ុនស៊ូកាគូអ៊ីន (ជាមួយនឹងក្រុមហ៊ុនវិនិយោគ Inner Mongolia Erdos Hungjun Investment Company, Ltd.) និង សហគមន៍បឹងកក់ ដែលគិតមកត្រឹមថ្ងៃសរសេររបាយការណ៍នេះ ក្រៅតែពីការចាក់ដីបំពេញបឹងនេះ ការអភិវឌ្ឍមិនទាន់បានដំណើរការនៅឡើយទេ ចាប់តាំងពីកិច្ចសន្យាត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៧ មក ពោលគឺរយៈពេល ៥ ឆ្នាំមុន។ គ្មានអ្វីដែលគួរឲ្យសង្ស័យទេ ការបង្អាក់ដំណើរការនេះ គឺមានទំនាក់ទំនងទៅនឹងទំនាស់ដែលមានបន្តឥតឈប់ឈរ ដែលរួមចំណែកធ្វើឲ្យមានពន្យាពេលដល់ការទទួលបានផលវិញនៃការធ្វើវិនិយោគនេះ និងភាពអាម៉ាស់ចំពោះសាលារាជធានី។ មានឧទាហរណ៍ផ្សេងទៀតស្តីពីការពន្យារពេល ឬ ការខាតបង់ ដោយសារកង្វះការធ្វើផែនការ និងការពិគ្រោះយោបល់ ដែលជាហេតុបណ្តាលឲ្យចំណូលពន្ធថយចុះ និងការខូចកេរ្តិ៍ឈ្មោះក្រុមហ៊ុន និងអាជ្ញាធរ ។ តម្លៃនៃការខាតបង់ ផ្នែកហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការ ដោយសារទំនាស់នៅកម្ពុជា តម្រូវឲ្យមានការពិនិត្យមើល និងការវិភាគបន្ថែមទៀត ។

១៣៦. លើសពីនេះទៀត មានហានិភ័យទាក់ទងនឹងការធ្វើឲ្យខូចកេរ្តិ៍ឈ្មោះកាន់តែខ្លាំងក្លាថែមទៀត ដែលទីផ្សារដែលកំពុងតែងើបឡើង ដូចជា ប្រទេសកម្ពុជានេះត្រូវប្រឈមមុខ ពោលគឺ ការងាកចេញរបស់អ្នកវិនិយោគទុន

[២១៣] សូមមើល ឧទាហរណ៍ ឯកសារ Rachel Davis និង David M. Franks" តម្លៃខាតបង់ពាក់ព័ន្ធនឹងទំនាស់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម"។ នៅកិច្ចប្រជុំសិក្ខាសាលាអន្តរជាតិលើកទីមួយ ស្តីពីការទទួលខុសត្រូវខាងសង្គម ក្នុងវិស័យរ៉ែ នៅទីក្រុងសាតាយហ្គូ ប្រទេសឈីលី ខែតុលា ឆ្នាំ២០១១។

ដោយសារក្រុមហ៊ុនបរទេស ស្វែងរកបរិយាកាសអាជីវកម្មដែលមានស្ថិរភាព និងអាចព្យាករណ៍បានដោយផ្អែកលើ "ហានិភ័យសង្គម" ដែលអាចដឹងបាន។ តាមពិត អំពើហិង្សាទាក់ទងនឹងទំនាស់ដីធ្លីនៅកម្ពុជា ត្រូវបានចងក្រងជាឯកសារផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ លទ្ធភាពទទួលបានព័ត៌មានស្តីពីឧប្បត្តិហេតុបាញ់ប្រហារ និងការបណ្តេញចេញដោយបំពាន តាមរយៈវីដេអូក្នុងប្រព័ន្ធអ៊ិនធើណិត មានការកើនឡើង ចាប់តាំងពីពេលចេញផ្សាយរបាយការណ៍ឆ្នាំ ២០០៧ របស់តំណាងពិសេស ដោយសារការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងសមត្ថភាពចងក្រងឯកសារ ស្តីពីឧប្បត្តិហេតុនានា និងការផ្សព្វផ្សាយអំពីឧប្បត្តិហេតុទាំងនេះនៅលើប្រព័ន្ធអ៊ិនធើណិតបានទាន់ពេលវេលា មានភាពរីកចម្រើនឡើង ។[២១៤] តាមប្រសាសន៍របស់ប្រធានប្រតិបត្តិជាន់ខ្ពស់នៃសម្បទានដីសេដ្ឋកិច្ចមួយនៅកម្ពុជា បានឲ្យដឹងថា "មិនដូចហានិភ័យអាជីវកម្មជាប្រពៃណីទេ ដែលដរាបណាហានិភ័យកាន់តែខ្ពស់ អត្រាចំណូលដែលជា សេចក្តីត្រូវការចាំបាច់ក៏កាន់តែខ្ពស់ដែរ ចំណែកឯហានិភ័យសង្គមវិញ មានទំនោរទៅរកផលប៉ះពាល់ពីរយ៉ាង ដែលក្នុងនោះក្រុមហ៊ុនគ្រាន់តែចាត់ទុកថា ទីផ្សារមានហានិភ័យខ្ពស់ពេក រហូតដល់មិនអាចធ្វើវិនិយោគបាន ទោះបីអត្រាចំណូលផ្នែកហិរញ្ញវត្ថុមានកម្រិតខ្ពស់ក៏ដោយ។ ការធ្វើវិនិយោគ និងប្រតិបត្តិការនៅក្នុងទីផ្សារដែលកំពុងតែងើបឡើង មានហានិភ័យប៉ះពាល់កេរ្តិ៍ឈ្មោះកាន់តែខ្ពស់ ចំពោះក្រុមហ៊ុន និងឈ្មោះរបស់ក្រុមហ៊ុន" ។[២១៥]

១៣៧. លើសពីនេះទៀត ការផ្តល់សម្បទានដីដោយគ្មានការព្យាករណ៍ទុកជាមុនបាន នៅទីកន្លែងដែលមានគម្រោងនានាដែលកំពុងតែអនុវត្តដោយ អង្គការសង្គមស៊ីវិល ក្រុមសហគមន៍មូលដ្ឋាន និងម្ចាស់ជំនួយបរទេសនោះ បានរារាំងដល់ក្តីសង្ឃឹមក្នុងការអភិវឌ្ឍ និងភាពរីកចម្រើន។ អង្គការខ្លះ រាយការណ៍អំពី ការបង្អាក់សកម្មភាពការងារ ដែលមានយូរណាស់មកហើយទាក់ទងនឹងការប្រកបរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀង ជាឧទាហរណ៍ ក៏ដូចជា ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាដើម។ ដោយហេតុថា បរិយាកាសសហប្រតិបត្តិការជាមួយរដ្ឋាភិបាល មានលក្ខណៈមិនល្អប្រសើរដូច្នេះ ម្ចាស់ជំនួយខ្លះកំពុងតែពិចារណាអំពីការបង្វែរមូលនិធិរបស់ខ្លួនចេញពីកម្ពុជា។

## គ. ការបណ្តេញចេញដោយបំពាន និងការផ្លាស់ប្តូរទីលំនៅថ្មី

១៣៨. ក្នុងគ្រាដែលមានការផ្តល់សម្បទានដី សហគមន៍ដែលរស់នៅលើដីនោះ ជារឿយៗ អាចប្រឈមមុខនឹងការបណ្តេញចេញដោយបំពាន ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ឬ ការផ្លាស់ប្តូរទីលំនៅថ្មីដែលមិនមានការរៀបចំត្រឹមត្រូវ ឬ មិនមានការធ្វើផែនការជាមុនសោះ ។ ការបណ្តេញចេញ និងការផ្លាស់ប្តូរទីលំនៅ ទោះបីជា ដោយបំពាន ឬ មិនបំពានក៏ដោយ ជារឿយៗ អាចធ្វើឲ្យភាពក្រីក្រកើនឡើងកាន់តែខ្ពស់ និងធ្វើឲ្យមានលទ្ធភាពតិចតួចក្នុងការរកប្រាក់ចំណូល និងជាប់ជំពាក់បំណុលគេ, កង្វះលទ្ធភាពទទួលបានទឹកស្អាត អនាម័យ អគ្គិសនី សេវាសុខភាព និងការអប់រំ, បញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត, ឧបសគ្គក្នុងការទទួលបានពេញលេញសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ដូចជា

---

[២១៤] សូមមើលនូវឧទាហរណ៍នៃការប្រើប្រាស់កំលាំង ដែលបានចងក្រងឡើងទាក់ទងនឹងការបណ្តេញចេញដោយហិង្សានៃសហគមន៍បុរីកីឡា (សម្បទានដីសង្គមកិច្ច) និងសហគមន៍បឹងកក់ (ការអភិវឌ្ឍន៍អចលនៈទ្រព្យ) ដោយបានថតជាឯកសារដោយវិទ្យុអាស៊ីសេរី និងដោយអ្នកឃ្លាំមើលការបណ្តេញចេញមកពីស្ថាប័នក្រៅរដ្ឋាភិបាល និងបានបង្ហោះផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណែត YouTube (មានការពន្យល់លំអិត បន្ថែមទៀតនៅផ្នែក VII (គ))។ ចូរកត់សំគាល់ផងដែរ ករណីទាក់ទងនឹង ក្រុមហ៊ុន ធីធីវ៉ាយ (TTY) (សម្បទានដីសេដ្ឋកិច្ច) ដែលនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១២ មានកងកម្លាំងសន្តិសុខរបស់ក្រុមហ៊ុនបាញ់រះមកលើ ក្រុមអ្នកភូមិ ដែលបានប្រមូលផ្តុំគ្នាតវ៉ាប្រឆាំងនឹងការឈូសឆាយរបស់ក្រុមហ៊ុនលើដីស្រែចំការរបស់ពួកគេ នៅស្រុកស្នួល ខេត្តក្រចេះ។ សូមមើល វីដេអូឃ្លីបរបស់អង្គការលីកាដូ (LICADHO) "ទាហានបាញ់រះមកលើអ្នកតវ៉ាដីធ្លីនៅភាគឥសាន្តនៃប្រទេសកម្ពុជា" នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ http://licadho-cambodia.org/video.php? perm=29.

[២១៥] កាសែតភ្នំពេញប៉ុស្តិ៍ Daniel Mitchell នាយកប្រតិបត្តិនៃក្រុមហ៊ុន Grandis Timber, Ltd. សម្បទានដីសេដ្ឋកិច្ច សម្រាប់ចំការឈើម៉ៃសាក់នៅក្នុងខេត្តកំពង់ស្ពឺ "ការទទួលខុសត្រូវរបស់សាជីវកម្មនៅកម្ពុជា" ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ គេហទំព័រ៖ http://www.phnompenhpost.com/ index.php/2012051156099/Business/corporate-social-responsibility-in-cambodia.html.

ការបោះឆ្នោត លទ្ធភាពទទួលបានដំណោះស្រាយ) ការទទួលការមាក់ងាយពីសង្គម និងការបង្អាក់ដល់ភាពចុះសម្រុងគ្នារបស់សហគមន៍ និងគ្រួសារ ។ គោលនយោបាយ នីតិវិធី និងកិច្ចការពារ ដែលបង្ការ-ទប់ស្កាត់ការបណ្តេញចេញដោយបំពាននោះ នៅមានការខ្វះខាត ឬ មិនត្រូវបានអនុវត្ត ចំណែកឯគម្រោងការណ៍ ផ្តល់សំណង គឺមានការគ្រប់គ្រងមិនបានត្រឹមត្រូវល្អ ឬ មិនភាពគ្រប់គ្រាន់ ហើយការខិតខំប្រឹងប្រែងក្នុងការផ្លាស់ប្តូរទីលំនៅវិញ កម្រនឹងគ្រោងឡើងពេញលេញដោយមានធនធានគ្រប់គ្រាន់ និងការត្រួតពិនិត្យមើលណាស់ ។

១៣៩. ច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិ ដាក់កម្រិតទៅលើការផ្លាស់ប្តូរទីកន្លែង និងការផ្លាស់ប្តូរទីលំនៅ ហើយផ្តល់នូវការណែនាំ ប្រសិនបើការផ្លាស់ប្តូរទីលំនៅមិនអាចចៀសវាងបាន។[២១៦] ទោះជាយ៉ាងណាក៏ដោយ ការបណ្តេញចេញដោយបំពាន និងការតាំងទីលំនៅថ្មីរបស់សហគមន៍នៅមូលដ្ឋាន ដោយសារសម្បទានដី ឬ គម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ ជារឿយៗ ត្រូវបានអនុវត្ត ដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់ និងកិច្ចការពារសិទ្ធិទទួលបានដីធ្លី និងជម្រកស្នាក់នៅរបស់ប្រជាជនមូលដ្ឋាន។ ក្នុងករណីខ្លះ ការប្រើប្រាស់កម្លាំង ត្រូវបានធ្វើឡើងដើម្បីបណ្តេញចេញ ឬ ផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន ដោយមានការបញ្ជាពីក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស។ ម្យ៉ាងទៀត ជារឿយៗ មិនមានភាពច្បាស់លាស់ថា នរណាជាអ្នកផ្តល់ហិរញ្ញប្បទានដល់ការបណ្តេញប្រជាជនចេញនេះទេ ។

១៤០. ករណីដែលទាក់ទាញការផ្តោតការយកចិត្តទុកដាក់ខ្លាំងបំផុតពីសំណាក់សហគមន៍ជាតិ និងអន្តរជាតិ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ គឺការអភិវឌ្ឍបឹងកក់នៅរាជធានីភ្នំពេញ ដែលសាលារាជធានីភ្នំពេញ បានចុះកិច្ចសន្យារយៈពេល ៩៩ ឆ្នាំ ជួលដីទំហំ ១៣៣ ហិកតា ឲ្យទៅក្រុមហ៊ុនស៊ូកាគូអ៊ីន ដែលមានទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនវិនិយោគ Inner Mongolia Erdos Hungjun Investment Company សម្រាប់សាងសង់លំនៅដ្ឋាន។[២១៧] ក្រុមហ៊ុនស៊ូកាគូអ៊ីន ត្រូវបានដឹកនាំដោយសមាជិកព្រឹទ្ធសភាកម្ពុជា ឡៅ ម៉េងឃីន ដែលជាអ្នកដឹកនាំក្រុមហ៊ុន ភាពីម៉ិច គ្រុប (Pheapimex Group) និង ក្រុមហ៊ុន អ៊ូជីសាន អិលអេស គ្រុប (Wuzhishan LS Group) ផងដែរ។[២១៨] គម្រោងនេះប៉ះពាល់ដល់ប្រជាជនចំនួនជាង ៤.០០០ គ្រួសារ ដែលភាគច្រើន ត្រូវបានបណ្តេញដោយបំពាន ផ្លាស់ប្តូរទីលំនៅដោយមិនមានការស្ម័គ្រចិត្ត ឬ ទទួលបានគោលនយោបាយដោះដូរដែលមានកម្រិតស្តង់ដារទាប ដោយមានការបង្ខិតបង្ខំ។ នៅខែ សីហា ឆ្នាំ ២០១១ អនុក្រឹត្យមួយ ត្រូវបានដាក់ចេញឲ្យអនុវត្ត ដើម្បីកែសម្រួលផ្ទៃក្រឡាដីតំបន់អភិវឌ្ឍបឹងកក់[២១៩] ដោយកាត់ផ្ទៃដីទំហំ ១២,៤៤ ហិកតា និង ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនដល់សហគមន៍ដែលរស់នៅលើដីនេះ ហើយនេះគឺជាការវិវឌ្ឍជាវិជ្ជមានចំពោះទំនាស់ដែលមានជាយូរមកហើយនេះ។ ទោះជាយ៉ាងណាក៏ដោយ ការណ៍

[២១៦] រដ្ឋធម្មនុញ្ញ (មាត្រា ៤៤) ច្បាប់ភូមិបាល (មាត្រា ៤ និងមាត្រា ៥) និងច្បាប់អស្សាមិករណ៍ ឆ្នាំ២០១០ (មាត្រា១-៧) កំណត់ពីការធ្វើអស្សាមិករណ៍ដី និងការគ្រប់គ្រងលក្ខខណ្ឌរបស់វា។ អាស្សាមិករណ៍ដី/អស្សាមិករណ៍អាចធ្វើទៅបានសម្រាប់បំរើផលប្រយោជន៍សាធារណៈ ហើយក៏តម្រូវឲ្យមានការផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុន។ សម្រាប់បទដ្ឋានអន្តរជាតិវិញ សូមមើលគោលការណ៍ណែនាំជាមូលដ្ឋានសម្រាប់ ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីដោយគម្រោងអភិវឌ្ឍន៍ ឧបសម្ព័ន្ធ ១ នៃរបាយការណ៍របស់តំណាងពិសេសស្តីពី សិទ្ធិមានលំនៅដ្ឋានសមរម្យ ដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពសមរម្យ(A/HRC/4/18) និងគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់ទូទៅលេខ ៧ ស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ (ការបណ្តេញចេញដោយបំពាន) ឆ្នាំ១៩៩៧។

[២១៧] កិច្ចសន្យាជួលដីបឹងកក់ក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីអភិវឌ្ឍន៍ជាតំបន់ពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ លំនៅដ្ឋាន និង មជ្ឈមណ្ឌលកំសាន្ត ដែលបានចុះហត្ថលេខាដោយលោកឧកញ៉ា ឡៅ ម៉េងឃីន សមាជិកព្រឹទ្ធសភាកម្ពុជា និង លោក កែប ជុតិម៉ា អភិបាលសាលារាជធានីភ្នំពេញ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៧។

[២១៨] កិច្ចព្រមព្រៀងវិនិយោគរវាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រុមហ៊ុន ភាពីម៉ិច ដែលបានចុះហត្ថលេខាដោយ លោក ឧកញ៉ា ឡៅ ម៉េងឃីន សមាជិកព្រឹទ្ធសភាកម្ពុជា នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០០ សម្រាប់សម្បទានដីទំហំ ១៧៦.០៦៥ ហិកតា ក្នុងខេត្តកំពង់ឆ្នាំង និង ១៣៨.៩៦៣ ហិកតា ក្នុងខេត្តពោធិសាត់។ យោងលិខិតលេខ ៧២១ ពីក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ លោកឧកញ៉ា ឡៅ ម៉េងឃីន ត្រូវបានចុះបញ្ជីជានាយកមួយរូប នៃក្រុមហ៊ុន Wuzhishan LS Group ។

[២១៩] អនុក្រឹត្យ លេខ ១៨៣ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ។

នេះ មិនមានលក្ខណៈទូលំទូលាយ សម្រាប់ប្រជាជនទាំងអស់នៅក្នុងតំបន់បឹងកក់នេះទេ ហើយគ្រួសារខ្លះ ត្រូវបានបណ្ដេញចេញជាបន្តបន្ទាប់ និងពួកគេបន្តធ្វើការតវ៉ាជំទាស់នឹងការបណ្ដេញចេញ និងការផ្លាស់ប្តូរទីលំនៅ។ ឧទាហរណ៍ការបណ្ដេញចេញដោយហិង្សា ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១១ នៅលើដីដែលមានព្រំប្រទល់ជាប់នឹងបឹងនេះ ហើយដែលត្រូវបានកាត់ចេញពីផ្ទៃដីទំហំ ១២,៤៤ ហិកតា នេះ ។[២២០]

១៤១. តាមដែលខ្ញុំបានដឹង នាពេលថ្មីៗនេះ ករណីពីរ (២) ទៀត ដែលក្នុងនោះ ប្រជាជនរាប់ពាន់គ្រួសារ កំពុងតែត្រូវបានគេផ្លាស់ប្តូរទីលំនៅ ដោយសារសម្បទានដីនោះ គឺគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុមហ៊ុន យូនៀនដេវីលបមេន គ្រុប (Union Development Group) នៅក្នុងខេត្តកោះកុង និងគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោមទី ២ (Lower Sesan 2)[២២១] ដែលបានស្នើឡើងនៅក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានប្រវែង ១,៥ គីឡូម៉ែត្រ នៅផ្នែកខាងដើមទឹកដែលហូរចាក់ចូលក្នុងទន្លេស្រែពក និងទន្លេសេសាន។ សម្បទានដីរបស់ក្រុមហ៊ុន យូនៀនដេវីលប្បមេនគ្រុប បានបណ្ដេញប្រជាជនចំនួនជាង ១.០០០ គ្រួសារពីភូមិចាស់របស់ខ្លួន ហើយគ្រួសារដែលនៅសេសសល់ ត្រូវស្ថិតនៅក្រោមការគំរាមកំហែងនៃការផ្លាស់ប្តូរទីលំនៅ (សូមមើលឧបសម្ព័ន្ធ ៣)។ តាមលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន គម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោមទី ២ ដែលបានស្នើឡើង ប៉ះពាល់ដល់ប្រជាជនចំនួន ៤.៧៨៥ នាក់ (ត្រូវជា ១.០៥៩ គ្រួសារ) នៅក្នុងភូមិចំនួនប្រាំពីរ ដែលស្ថិតនៅក្នុងឃុំចំនួនបួន ដោយសារការកសាងអាងស្តុកទឹក ហើយតំបន់តាំងទីលំនៅថ្មីចំនួនប្រាំមួយកន្លែង ត្រូវបានស្នើឡើងសម្រាប់ប្រជាជន ដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅ ដោយសារតែការសាងសង់អាងស្តុកទឹក និងការសាងសង់ទំនប់វារីអគ្គិសនីនេះ។[២២២] ទិន្នន័យរបស់រដ្ឋាភិបាល បង្ហាញថា មានផលប៉ះពាល់ទាបបន្តិច ពោលគឺ ប្រជាជនដែលទទួលរងផលប៉ះពាល់ មានចំនួនតែ ៤.៦២០ នាក់ប៉ុណ្ណោះ ហើយប្រមើលទុកជាមុនថា ទឹកនឹងត្រូវរក្សាទុកក្នុងអាងស្តុក ដែលមានទំហំជាង ៣៤.៣០៧

[២២០] នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ នៅភូមិ ២២ តំបន់បឹងកក់ រាជធានីភ្នំពេញ មានផ្ទះចំនួន ៥ ខ្នង (មានប្រជាពលរដ្ឋចំនួន ៨ គ្រួសារ) ដែលត្រូវបានគេផាត់ចេញពីផ្ទៃដីទំហំ ១២,៤៤ ហិកតា ដែលផ្ទះទាំង ៥ ខ្នងនោះ ត្រូវបានឈូសបំផ្លាញចោលដោយគ្រឿងចក្រ (អាអ៊ិច)។ ការចរចាសំណង មិនត្រូវបានគេលើកឡើងទេ។ ការបណ្ដេញចេញនេះ បានធ្វើឡើងដោយមន្ត្រីនគរបាលជាង ១០០ នាក់ ដែលបានវាយមកលើប្រជាពលរដ្ឋ។ ការវាយតប់មកលើប្រជាពលរដ្ឋ និងការបណ្ដេញចេញនេះ ត្រូវបានអង្គការលីកាដូ(LICADHO) ថតជាខ្សែវីដេអូ ដោយដាក់ចំណងជើងថា សកម្មជនបឹងកក់រងការវាយប្រហារធ្ងន់ធ្ងរពីហ្វូងនគរបាល ក្នុងអំឡុងពេលបណ្ដេញចេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ មាននៅគេហទំព័រ៖ http://licadho-cambodia.org/ video. php?perm=28.

[២២១] គម្រោងទំនប់វារីអគ្គីសនីដែលបានយល់ព្រមក្នុងខែមករា ឆ្នាំ២០១១ គ្រោងនឹងចាប់ផ្តើមក្នុងឆ្នាំ ២០១២ ហើយគ្រោងនឹងបញ្ចប់នៅក្នុងឆ្នាំ ២០១៦។ គម្រោងទំនប់វារីអគ្គីសនីនេះនឹងដាក់ឲ្យដំណើរការនៅឆ្នាំ២០១៧។ ទំនប់វារីអគ្គីសនីនេះមានសមត្ថភាពផ្គត់ផ្គង់អគ្គីសនី ៤០០ មេហ្គាវ៉ាត់ ដែលមានកំពស់ ៧៥ ម៉ែត្រ និងមានបណ្ដោយ ៦ គីឡូម៉ែត្រ និងមានទំហំអាងគ្របដណ្ដប់លើផ្ទៃដីទំហំ ៣៤០ គីឡូម៉ែត្រការ៉េ។ តំលៃប៉ាន់ស្មានសម្រាប់គម្រោងនេះ គឺ ៨១៦ លានដុល្លារសហរដ្ឋអាមេរិក និងអាចផ្គត់ផ្គង់អគ្គីសនីក្នុងប្រទេសកម្ពុជា និងលក់ចេញទៅប្រទេសវៀតណាម។ យោងតាមការសិក្សាស្រាវជ្រាវរបស់ Mark Grimsditch លើរបាយការណ៍ *ទន្លេទាំងបីស្ថិតក្រោមការគម្រាមកំហែង៖ ការយល់ដឹងពី ការគម្រាមកំហែងថ្មី និងបញ្ហាប្រឈម បណ្ដាលមកពីការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី ទៅលើជីវចំរុះ និងសិទ្ធិរបស់សហគមន៍រស់នៅតាមអាងទន្លេទាំង៣៖* បណ្ដាញការពារទន្លេ ៣ និងបណ្ដាញទន្លេអន្តរជាតិ ខែមេសា ឆ្នាំ២០១២។

[២២២] ដូចខាងលើ ទំព័រ ២៨-២៩ របាយការណ៍នៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន(EIA) ដែលបានធ្វើឡើងដោយក្រុមហ៊ុន Key Consultants Cambodia (KCC) បានបញ្ជាក់ថា តំបន់នៃការតាំងទីលំនៅថ្មីជាច្រើនដែលបានស្នើឡើង ស្ថិតនៅក្នុងតំបន់សម្បទានព្រៃ/ សម្បទានដីដែលមានការអនុញ្ញាតិរួចហើយ ហើយហេតុដូច្នេះវាអាចជាប្រធានបទនៃការរំខានដ៏ខ្លាំងបំផុតមួយ ទាំងនៅពេលបច្ចុប្បន្ន និងនៅថ្ងៃអនាគត។ យោងតាមកំណត់ត្រាដែលរៀបចំដោយ KCC ផ្ទៃដីសរុបទំហំជាង ៤.០០០ ហិកតា ដែលត្រូវស្នើឡើងសម្រាប់ការអភិវឌ្ឍន៍កន្លែងតាំងលំនៅថ្មី គឺមានទីតាំងស្ថិតនៅក្នុងព្រំប្រទល់នៃព្រៃសម្បទាន និងដីអភិរក្ស។ អាងស្តុកទឹក នឹងធ្វើឲ្យលិចលង់លើផ្ទៃដីទំហំ ១.២០០ ហិកតា ដែលជាដីកសិកម្ម ដែលស្មើនឹង២៤% នៃផ្ទៃដីកសិកម្មសរុប នៅស្រុកសេសាន ហើយទោះបីជាដីដែលរងការលិចលង់នេះ នឹងត្រូវផ្តល់ជំនួសមកវិញនូវដី នៅកន្លែងតាំងទីលំនៅថ្មីក៏ដោយ ក៏មានការទទួលស្គាល់ថា ការណ៍នេះនឹងត្រូវតម្រូវនូវការឈូសឆាយរានដីព្រៃ។

ហិកតា។[២២៣] ខ្ញុំបានជួបទំនាក់ទំនងផ្ទាល់ជាមួយនឹងសហគមន៍ ដែលអាចទទួលរងផលប៉ះពាល់ ហើយសហគមន៍ទាំងនោះ បានរាយការណ៍ថា គេមិនបានពិគ្រោះយោបល់ជាមួយនឹងសហគមន៍ពួកគាត់ឲ្យបានពេញលេញ អំពីផលប៉ះពាល់នៃគម្រោងនេះ និងអំពីផែនការតាំងទីលំនៅថ្មីនេះទេ ទោះបីជាសហគមន៍ពួកគាត់ ពិតជាបានដឹងថា ការសាងសង់ទំនប់នេះនឹងត្រូវដំណើរការទៅមុខ ហើយសហគមន៍ពួកគាត់នឹងត្រូវគេផ្លាស់ប្តូរទីលំនៅទៅកាន់កន្លែងមួយ ដែលមានចំងាយ ១០ គីឡូម៉ែត្រ ពីភូមិដែលសហគមន៍ពួកគាត់កំពុងតែរស់នៅនាពេលបច្ចុប្បន្ននេះក៏ដោយ។

១៤២. ការបណ្តេញចេញពីលំនៅដ្ឋាន និងការផ្លាស់ប្តូរទីលំនៅ ដ៏គួរឲ្យព្រួយបារម្ភមួយទៀតនោះ គឺទាក់ទងនឹងសហគមន៍បុរីកីឡា ជាសហគមន៍ដែលត្រូវបានផ្តល់សម្បទានដីសង្គមកិច្ច នៅរាជធានីភ្នំពេញ។[២២៤] ការបណ្តេញចេញពីលំនៅដ្ឋាន ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១២ មានការប្រើប្រាស់កម្លាំង និងមានការតាំងទីលំនៅថ្មីដែលមិនមានផែនការល្អត្រឹមត្រូវ ហើយជាលទ្ធផលបណ្តាលឲ្យមានស្ថានភាពមួយ ដែលត្រូវការជំនួយមនុស្សធម៌ជាបន្ទាន់។[២២៥] បន្ទាប់ពីការបំផ្លាញលំនៅដ្ឋានទាំងនេះ ដែលតាមសេចក្តីរាយការណ៍ថា ត្រូវបានធ្វើឡើងដោយមានការប្រើប្រាស់កម្លាំងដ៏ច្រើនហួសប្រមាណនោះ សហគមន៍ដែលត្រូវបានបណ្តេញចេញ ត្រូវបានបញ្ជូនទៅកាន់តំបន់តាំងទីលំនៅថ្មី ដែលមានចំងាយឆ្ងាយគួរសមពីរាជធានីភ្នំពេញ ដោយមិនមានការរៀបចំត្រៀមលក្ខណៈឲ្យបានពេញលេញជាមុនសម្រាប់ការមកដល់របស់គ្រួសារ ដែលត្រូវបណ្តេញចេញនេះទេ។ តាមការរាយការណ៍បានឲ្យដឹងថា នៅកន្លែងតាំងទីលំនៅថ្មីក្នុងភូមិស្រះពោធិ៍ និងភូមិទួលសំបូរ មានការខ្វះខាតទឹកសម្រាប់បរិភោគ (ក្រៅពីអណ្តូងទាំងពីរ) ខ្វះសេវាអនាម័យ និងមិនមានជំរកស្នាក់នៅគ្រប់គ្រាន់។ ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនេះ ជាមូលហេតុបណ្តាលឲ្យគ្រួសារដែលទទួលរងផលប៉ះពាល់ កាន់តែក្រីក្រថែមទៀត។

១៤៣. កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់របស់ម្ចាស់ជំនួយបរទេស ក្នុងការគាំទ្រដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរផ្សេងទៀត នៅក្នុងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិតាមការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ ជាកម្មវិធី ដែលមានគោលបំណងផ្តល់នូវសុវត្ថិភាពខាងការកាន់កាប់ដី និងសម្រាប់រយៈពេលវែង គឺការបង្ការទប់ស្កាត់ការបណ្តេញចេញ។ ទោះជាយ៉ាងណាក៏ដោយ មានការរិះគន់ចំពោះប្រសិទ្ធភាពនៃកម្មវិធីទាំងនេះ ដោយ

---

[២២៣] ដូចខាងលើ ទំព័រ ៣១ ក្នុងខែមិថុនា ឆ្នាំ២០១១ រដ្ឋាភិបាល បានបញ្ជាក់ច្បាស់ថា ទំនប់វារីអគ្គិសនីនឹងធ្វើឲ្យផ្ទៃដីទំហំ ៣៤.៣០៧ ហិកតារងការលិចលង់ ដែលដីទំហំ ៨៣ ហិកតា ជាដីលំនៅដ្ឋាន ៩១០ ហិកតា ជាដីស្រែ ៣០៧ ហិកតា ជាដីវាល និង ១៧.៨០៦ ហិកតា ជាដីព្រៃរបស់រដ្ឋ និង ១០.៥៦៤ ហិកតា ជាដីដែលបានផ្តល់សម្បទានទៅឲ្យក្រុមហ៊ុនឯកជន និង ដីទំហំ ៤.៦៣៨ ហិកតា ជាបឹង និងទន្លេ។ គម្រោងនេះនឹងប៉ះពាល់ដល់ប្រជាពលរដ្ឋ ៤.៦២០ នាក់ ហើយកន្លែងតាំងទីលំនៅថ្មី នឹងមានការផ្គត់ផ្គង់ភ្លើងអគ្គិសនី និងការស្តារជីវភាពរបស់ពួកគេ បើធៀបទៅនឹងការរស់នៅរបស់ពួកគេពីពេលមុន។

[២២៤] នៅដើម ឆ្នាំ២០០៣ ការរៀបចំមួយស្តីពីការចែកដីគ្នា ត្រូវបានស្នើឡើងសម្រាប់សហគមន៍បុរីកីឡា ដែលបានអនុញ្ញាតិឲ្យក្រុមហ៊ុន ផានអ៊ីមិច ធ្វើការអភិវឌ្ឍន៍លើផ្នែកខ្លះនៃដីសម្រាប់គោលដៅពាណិជ្ជកម្ម ទន្ទឹមនឹងនេះក្រុមហ៊ុន ត្រូវសាងសង់ផ្ទះ ឲ្យប្រជាពលរដ្ឋរស់នៅលើចំណែកដីដែលនៅសេសសល់។ កិច្ចសន្យាសាងសង់ តម្រូវឲ្យក្រុមហ៊ុនផានអ៊ីមិច សាងសង់ផ្ទះចំនួន ១០ អាគារ សម្រាប់ផ្តល់ឲ្យប្រជាពលរដ្ឋចំនួន ១.៧៧៦ គ្រួសារ នៅលើផ្ទៃដី ទំហំ ២ ហិកតា ជាការតបស្នងចំពោះការដែលក្រុមហ៊ុនទទួលបានកម្មសិទ្ធិលើដីទំហំ ២.៦ ហិកតា សម្រាប់ការអភិវឌ្ឍន៍លក្ខណៈពាណិជ្ជកម្ម។ បន្ទាប់ពីសាងសង់បានអាគារចំនួន ៨ ខ្នង រួចរាល់ នៅខែមេសា ឆ្នាំ២០១០ ក្រុមហ៊ុន ផានអ៊ីមិច បានកែប្រែកិច្ចសន្យារបស់ខ្លួន ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាលផង បណ្តាលឲ្យមានការផាត់ចោលគ្រួសារប្រជាពលរដ្ឋសហគមន៍ បុរីកីឡាចំនួន ៣៨៤ គ្រួសារ ពីគម្រោងដើម។ ហើយក្រុមប្រជាពលរដ្ឋទាំងនោះ កំពុងរស់នៅមិនផ្លូវការលើតំបន់នោះ និងស្ថិតក្រោមការគំរាមកំហែងនៃការបណ្តេញចេញ ខណៈនេះដែរ ពួកគេទាំងនោះស្នើសុំការជួយអន្តរាគមន៍ពីភ្នាក់ងារនានារបស់រដ្ឋាភិបាលផងដែរ។

[២២៥] ក្នុងពេលមានឧប្បត្តិហេតុ មានកងកំលាំងចម្រុះជាង ២០០ នាក់ (នគរបាល ទាហាន និងអាជ្ញាធរខណ្ឌ) បានវាយកំទេចលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងបានដឹកជញ្ជូនពួកគេទៅកាន់កន្លែងតាំងទីលំនៅថ្មី។ ការបណ្តេញចេញនេះ ត្រូវបានគេថតជាវីដេអូ។ សូមមើលវីដេអូរបស់អង្គការលីកាដូ "បុរីកីឡាៈ រំលោភកិច្ចសន្យានៅកម្ពុជា" ថ្ងៃទី៣ ខែមករា ឆ្នាំ២០១២ មាននៅគេហទំព័រៈ http://licadho-cambodia.org/video.php?perm=28.។ មានប្រជាពលរដ្ឋជាង ១០០ គ្រួសារ ដែលមិនព្រមធ្វើការការផ្លាស់ប្តូរទៅកន្លែងតាំងទីលំនៅថ្មីត្រូវបានគេរាយការណ៍ថា កំពុងតែបន្តរស់នៅយ៉ាងលំបាកនៅលើទីតាំងដើមរបស់ពួកគេ។

សារគ្រួសារមួយចំនួន មិនត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីនេះ។ ឧទាហរណ៍៖ ចំពោះគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) អង្គការសង្គមស៊ីវិលដែលបានពិនិត្យតាមដានកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិនេះ អះអាងថា ថ្វីបើកម្មវិធីនេះ ទទួលបានជោគជ័យដ៏សំខាន់នៅតាមតំបន់ខ្លះក៏ដោយ ក៏កម្មវិធីនេះ មិនបានពង្រឹងសុវត្ថិភាពខាងការកាន់កាប់ដីធ្លីដល់ប្រជាជនមួយផ្នែកដែលងាយរងគ្រោះដោយការបណ្តេញចេញនោះទេ ពីព្រោះថា តំបន់ជាច្រើនដែលគេចង់បានរួមមានទាំងដីរបស់ជនជាតិដើមភាគតិចផង មិនត្រូវបានដាក់បញ្ចូលជាប្រព័ន្ធទៅក្នុងកម្មវិធីនេះទេ។[២២៦] អង្គការទាំងនោះចង្អុលបង្ហាញថា បញ្ហាគន្លឹះទាក់ទងនឹងការរៀបចំកម្មវិធី LMAP នេះ គឺ តំបន់ "ដែលទំនងជាមានទំនាស់" និងតំបន់ "ដែលមានស្ថានភាពមិនច្បាស់លាស់" មិនត្រូវបានកំណត់ជាគោលដៅសម្រាប់ប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិនេះទេ ដែលតាមការអនុវត្តជាក់ស្តែង បណ្តាលឲ្យមិនអាចទៅប្រើប្រាស់បាន នូវប្រព័ន្ធផ្តល់កម្មសិទ្ធិនេះនៃក្រុមគ្រួសារ និងសហគមន៍ដែលរស់នៅក្នុងតំបន់ដែលបានគ្រោងទុកសម្រាប់ការអភិវឌ្ឍន៍ (ជាពិសេស នៅក្នុងរាជធានីភ្នំពេញ) តំបន់ដីសម្បទាន ឬ ដីដែលអ្នកមានអំណាច ឬ ក្រុមហ៊ុនដែលមានខ្នងបង្អែកបានកំណត់ទុកជាគោលដៅ។[២២៧]

១៤៤. មានកង្វល់ប្រហាក់ប្រហែលគ្នានេះ ចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិ តាមកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលអនុញ្ញាតឲ្យអ្នកកាន់កាប់ដីមានសិទ្ធិភោគៈ ដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិស្ថាពរ តាមករណីពិសេស។ មានសេចក្តីរាយការណ៍ថា ការផ្តល់ប័ណ្ណកម្មសិទ្ធិតាមកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ ដោយដុំត្រូវបានញាំញីដោយអំពើពុករលួយ ហើយជារឿយៗ ពិបាកនឹងទៅប្រើប្រាស់បាន ដោយសារតែកម្រៃសេវាផ្លូវការ និងមិនផ្លូវការ ដែលតម្រូវឲ្យបង់នោះ គឺខ្ពស់គួរសម។ ហេតុដូច្នេះហើយទើបមានកង្វល់ថា គ្រួសារ និងសហគមន៍ ដែលមានសិទ្ធិស្របច្បាប់លើដីធ្លីត្រូវបានបដិសេធ "ម្តងហើយម្តងទៀត និងដោយបំពាន មិនឲ្យទទួលបានលទ្ធភាពប្រើប្រាស់យន្តការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនេះ និងយន្តការដោះស្រាយជម្លោះ" ដែលជាការធ្វើឲ្យអន្តរាយដល់គោលបំណងនៃកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុវត្ថិភាពខាងការកាន់កាប់ដីធ្លី ។[២២៨]

១៤៥. គំលាតដ៏ធំ ដែលបានបន្សល់ទុកពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ តាមការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំនេះ[២២៩] គឺការបង្កើនការផ្តល់សម្បទានដី លើដីដែលមិនទាន់ចុះបញ្ជី ឬ ដីមានទំនាស់ ហើយជាមួយនឹងគ្រួសារ ដែលភាគច្រើនមិនអាចទៅប្រើប្រាស់បាននូវយន្តការដោះស្រាយជម្លោះ (តាមប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ) បានបង្កើតឲ្យមានបរិយាកាសមួយ ដែលអំណោយផលដល់ការបណ្តេញចេញជាបន្ត។ ជាញឹកញាប់ ការបណ្តេញចេញដោយបំពាន ត្រូវបានផ្តល់ហេតុផលសំអាងតាមរយៈការអះអាងរបស់រដ្ឋាភិបាលថា គ្រួសារដែលត្រូវបានបណ្តេញចេញនេះ ខ្វះឯកសារ ឬ ប័ណ្ណកម្មសិទ្ធិ និងកំពុងតែកាន់កាប់ដីធ្លីដោយខុសច្បាប់ ឬ "ការតាំងទីលំនៅដោយមិនរៀបរយ" ឬ ក៏ទើបតែមករស់នៅលើដីនាពេលថ្មីៗ (ត្រូវបានចាត់ទុកជា "អ្នកចំណូលថ្មី" ឬ "ជនឱកាសនិយម")។ តាមពិត ទោះបីជាការចេញប័ណ្ណកម្មសិទ្ធិដីធ្លី មានភាពរីកចម្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះក៏ដោយ ដោយសារកេរ្តិ៍ដំណែលនៃប្រវត្តិសាស្ត្ររបស់កម្ពុជា ក៏នៅតែមានប្រជាពលរដ្ឋជាច្រើន នៅខ្វះឯកសារ និងប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយ។ ចំណាកស្រុកក្នុងប្រទេស បានធ្វើឲ្យមានភាពស្មុគ្រស្មាញដល់ដំណើរការនៃការផ្ទៀងផ្ទាត់បញ្ជាក់អំពីអ្នក

---

[២២៦] Mark Grimsditch & Nicholas Henderson, គ្មានកម្មសិទ្ធិ៖ *សុវត្ថិភាពដីធ្លី និងវិសមភាពក្នុងវិស័យដីធ្លីនៅកម្ពុជា* អង្គការស្ពានទៅកាន់សន្តិភាព (BABC) និងមជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ (COHRE), អង្គការ Jesuit Refugee Service ឆ្នាំ២០០៩។

[២២៧] ដូចគ្នាខាងលើ ទំព័រ ៣។

[២២៨] "បញ្ហាសិទ្ធិដីធ្លី និងផ្ទះសម្បែង" របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួននៅកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយបណ្តាញសហគមន៍ បានដាក់ជូន ជារបាយការណ៍ឧបសម្ព័ន្ធនៃរបាយការណ៍ស្របស្តីពីបញ្ហាសិទ្ធិដីធ្លី និងលំនៅដ្ឋាន ទៅគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (CESCR) របស់អង្គការសហប្រជាជាតិ ក្នុងការពិនិត្យលើរបាយការណ៍របស់កម្ពុជា នៅសម័យប្រជុំលើកទី៤២ ពីថ្ងៃទី៤ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩។

[២២៩] ដូចគ្នាខាងលើ ទំព័រ ១។

ដែលមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី និងដំណើរការនៃការផ្តល់សំណងសម្រាប់សហគមន៍ ដែលពិតជាទទួលរងការប៉ះពាល់ ឬ ដែលត្រូវបានផ្លាស់ប្តូរទីលំនៅ ដោយសារតែសកម្មភាពសម្បទានដី។ យ៉ាងណាក៏ដោយ ការបន្តនូវការបណ្តេញចេញ ដែលភាគច្រើនមានអំពើហិង្សាផងនោះ មិនត្រូវបានយកភាពស្មុគ្រស្មាញទាំងនេះ មកធ្វើជាហេតុផលសំអាងទេ ។

## ឃ. ការបំផ្លាញបរិស្ថាន និងផលប៉ះពាល់លើលើជីវភាពរស់នៅ

១៤៦. ការបំផ្លាញបរិស្ថាន គឺជាបញ្ហារាលដាលទូទៅនៅកម្ពុជា ហើយមិនមែនមានតែនៅលើតំបន់ដីសម្បទាននោះទេ។ ការកំណត់បង្កើតតំបន់ការពារធម្មជាតិត្រូវបានផ្តួចផ្តើមឡើង ដើម្បីប្រយុទ្ធទប់ទល់នឹងបញ្ហានេះ ជាពិសេស ដោយសារតំបន់ដីព្រៃ ត្រូវបានគេទទួលស្គាល់ថាមានជីវៈចម្រុះរបស់វា និងជាផ្នែកដ៏សំខាន់មួយ នៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែ នៅក្នុងការអភិវឌ្ឍកសិ-ឧស្សាហកម្ម ផលប៉ះពាល់ផ្នែកបរិស្ថានចម្បងបំផុតនៅចំពោះមុខ និងដែលអាចមើលឃើញ គឺការកាប់បំផ្លាញព្រៃឈើលើផ្ទៃដីធំៗ ដូចជា ការកាប់ឆ្ការព្រៃស្តុក ដើម្បីធ្វើជាចំការកៅស៊ូ ចំការអំពៅ ចំការអាកាស្យា ចំការដំឡូងមី និងចំការស្វាយចន្ទី។

១៤៧. មានផលប៉ះពាល់ធ្ងន់ធ្ងរលើជីវៈចម្រុះនៃតំបន់ដីព្រៃ។ ព្រៃស្តុកទាក់ទាញទឹកភ្លៀងតំបន់ត្រូពិច ផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនទាក់ទងនឹងប្រព័ន្ធអេកូឡូស៊ី ដែលប្រព័ន្ធនេះនឹងប្រែប្រួលទាំងស្រុង ដោយសារការកាប់បំផ្លាញព្រៃឈើ ។ តំបន់ដែលត្រូវបានកាប់ឆ្ការព្រៃ មិនផ្តល់នូវឱកាសខាងការរស់នៅ ដូចជាព្រៃស្តុកនោះទេ និងស្តែងឲ្យឃើញពីការបំផ្លិចបំផ្លាញយ៉ាងខ្លាំងដល់លក្ខខ័ណ្ឌជម្រកសម្រាប់ពពួកសត្វព្រៃ។ ឧទាហរណ៍ៈ តំបន់ព្រៃឡង់ (ព្រៃស្រោង-ស្តុកធំជាងគេបំផុតក្នុងតំបន់ទំនាបកណ្តាល ដែលនៅសេសសល់នៅកម្ពុជា) ឥឡូវនេះត្រូវបានចាត់ចូលជាតំបន់ព្រៃ ដែលកំពុងទទួលរងគ្រោះថ្នាក់។ តម្លៃខាងជីវៈចម្រុះរបស់ព្រៃឡង់ ត្រូវបានគេរាយការណ៍ថា មានកម្រិតខ្ពស់ដោយមានប្រភេទឈើជិតផុតពូជចំនួនជាង ២០ ប្រភេទ និងមានសត្វព្រៃកម្រចំនួនដល់ទៅ ២៧ ប្រភេទ ។[២៣០]

១៤៨. ការកាប់ឈើខុសច្បាប់នៅតែបន្ត មិនត្រឹមតែដោយសារតែការផ្តល់សម្បទានដីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារការប្រែប្រួលលំនាំនៃទេសន្តរប្រវេសន៍ ថ្វីបើមានច្បាប់ និងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្រុមល្បាតរបស់សហគមន៍ និងដៃគូអភិវឌ្ឍន៍ ក្នុងការតាមដានឃ្លាំមើល និងធ្វើនិយតកម្មលើការកាប់ឈើខុសច្បាប់នេះក៏ដោយ។[២៣១] នៅក្នុងតំបន់ព្រៃឡង់ ការកសាងផ្លូវថ្នល់ថ្មីៗ បានបំផ្លាញដល់ផ្ទៃដីព្រៃឈើ ហើយផ្លូវថ្នល់នេះ ក៏សម្រួលដល់ការហូរចូលនូវអ្នកកាប់ឈើខុសច្បាប់ និងជនអន្តោប្រវេសន៍ក្នុងស្រុក ដែលកំពុងតែកាប់ឈើខុសច្បាប់ កាប់ឆ្ការព្រៃយកដី និងបរបាញ់សត្វព្រៃផងដែរ។ ឈើដែលមានតម្លៃខ្ពស់ៗ ភាគច្រើនឈើដែលជាប្រភេទជិតផុតពូជ ដូចជា ប្រភេទឈើក្រញូង បានបាត់បង់ផុតពូជពីតំបន់ខ្លះទៅហើយ។

១៤៩. សូម្បីតែកម្មវិធីជាក់លាក់សម្រាប់ប្រយុទ្ធទប់ទល់នឹងការកាប់ឈើ តាមរយៈការលើកកម្ពស់គម្រោងឥណទានកាបូន ដូចជា កម្មវិធីកាត់បន្ថយការបំភាយចេញឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការថយចុះព្រៃឈើក្រោម ជំនួយរបស់អង្គការសហប្រជាជាតិ (កម្មវិធី REDD) ក៏ត្រូវប្រឈមមុខនឹងការកាប់ឈើនៅក្នុងតំបន់ ដែលបានជ្រើសរើសសម្រាប់ការអភិរក្សនេះដែរ។ ផ្នែកមួយនៃបញ្ហានេះ ទាក់ទងទៅនឹងវត្តមានកងកម្លាំងយោធានៅតាមតំបន់ព្រៃសហគមន៍

---

[២៣០] ព្រៃឡង់ "ការគំរាមកំហែង" គេហទំព័រ៖ http://preylang.com/threats/.

[២៣១] មានការចោទប្រកាន់ផងដែរថា ដៃគូអភិវឌ្ឍន៍អន្តរជាតិមួយ ដែលបានធ្វើការអស់រយៈពេលជាយូរនៅកម្ពុជា ជាប់ពាក់ព័ន្ធនឹងសកម្មភាពកាប់ឈើខុសច្បាប់ នៅតំបន់ជួរភ្នំក្រវ៉ាញកណ្តាល ដែលជាតំបន់ព្រៃការពារ។ សូមមើល David Boyle and May Tittihara, "មើលមិនឃើញពីបញ្ហាព្រៃឈើ (Blind Eye to Forest's Plight)" កាសែតភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ។

ដោយហេតុនេះ ការបង្កើនមូលដ្ឋានយោធា នាំឲ្យមានការកាប់ឆ្ការព្រៃយកដីសម្រាប់សាងសង់រចនាសម្ព័ន្ធថ្មីៗ ដែលក្នុងករណីខ្លះ បានធ្វើឲ្យមានការកាប់ឈើខុសច្បាប់កាន់តែច្រើនឡើងថែមទៀត ពីសំណាក់ទាហានទុច្ចរិត និងជនស៊ីវិលដែលភាគច្រើនប្រដាប់ដោយអាវុធ និង បំភិតបំភ័យដល់ក្រុមល្បាតសហគមន៍។

១៥០. ការអភិវឌ្ឍទំនប់វារីអគ្គិសនីធំៗ ស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ប៉ុន្តែវាច្បាស់ណាស់ថា តំបន់ទាំងនោះនឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើបរិស្ថាន។ ដូចនៅក្នុងករណីសម្បទានដីផ្សេងទៀតដែរ ដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) សម្រាប់សំណើរគម្រោងទំនប់វារីអគ្គីសនី និងការសាងសង់ទំនប់វារីអគ្គិសនីធំៗ ជាក់ស្តែងមិនបានប្រព្រឹត្តិទៅដោយគ្រប់គ្រាន់ពេញលេញទេ។ ដោយផ្អែកលើការវាយតម្លៃដំបូងៗ វាច្បាស់ណាស់ថា គម្រោងវារីអគ្គិសនីធំៗជាច្រើន នឹងធ្វើឲ្យផ្ទៃដីដ៏ធំត្រូវលិចទឹក ដែលវានឹងប៉ះពាល់ដល់ដីកសិកម្ម និងដីលំនៅដ្ឋាន ហើយភាគច្រើននៃទីតាំងដែលបានស្នើឡើងសម្រាប់គម្រោងនេះ ស្ថិតនៅក្នុងតំបន់ដីព្រៃដែលងាយរងគ្រោះ ដែលជាតំបន់ពោរពេញទៅដោយជីវៈចំរុះសម្បូណ៌បែប និងប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់។ ផលប៉ះពាល់លើការផ្លាស់ទីកន្លែងរបស់ត្រី និងលទ្ធភាពទៅប្រើប្រាស់ផលនិងអនុផលព្រៃឈើ គំរាមកំហែងធ្វើឲ្យអន្តរាយដល់របរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ តាមពិត រដ្ឋាភិបាលកម្ពុជា បានអំពាវនាវឲ្យមានការផ្អាកជាបណ្តោះអាសន្ននូវការអភិវឌ្ឍទំនប់កាត់ទន្លេសាយ៉ាប៊ូរី (Xayaburi) នៅប្រទេសឡាវ ដោយសារផលប៉ះពាល់ជាសក្តានុពលនៃទំនប់នេះទៅលើប្រព័ន្ធទន្លេមេគង្គ ។[២៣២]

១៥១. ទឹកជំនន់ ក៏ជាកង្វល់ដ៏ខ្លាំងមួយនៅតំបន់ទីក្រុង ដូចជា រាជធានីភ្នំពេញ ជាដើម ដែលមិនមានផែនការទីក្រុងបានល្អ ការអភិវឌ្ឍសំណង់អាគារនានាដែលមិនបានគិតគូរដោយប្រយ័ត្នប្រយែង និងប្រព័ន្ធលូទឹកស្អុយមិនគ្រប់គ្រាន់បានរួមចំណែកធ្វើឲ្យប្រព័ន្ធបង្ហូរទឹកក្នុទីក្រុង មានភាពរអាក់រអួលជាខ្លាំង។ ឧទាហរណ៍ បន្ទាប់ពីមានការអនុម័តលើគម្រោងសាងសង់អចលនទ្រព្យរបស់ក្រុមហ៊ុនស៊ូកាគូអ៊ីន នៅឆ្នាំ ២០០៧ (ដែលក្រោយមកដាក់ទុនរួមគ្នាជាមួយនឹងក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យ អេដូស ហុងជុន (Erdos Hongjun)) ដើម្បីអភិវឌ្ឍបឹងកក់ឲ្យក្លាយទៅជាតំបន់មួយ ដែលមានអគារលំនៅដ្ឋាន អគារពាណិជ្ជកម្ម និងមជ្ឈមណ្ឌលទេសចរណ៍ដែលមានលក្ខណៈជឿនលឿនបំផុត ក្រុមហ៊ុនដោយមានកិច្ចសហការពីសាលារាជធានីភ្នំពេញ បានចាប់ផ្តើមចាក់ដីខ្សាច់បំពេញបឹងនេះ នៅខែសីហា ឆ្នាំ២០០៨។ ការចាក់ដីបំពេញបឹងនេះ ធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធបង្ហូរទឹក និងបណ្តាលឲ្យមានទឹកជំនន់ធ្ងន់ធ្ងរនៅតាមភូមិ ដែលស្ថិតនៅជុំវិញតំបន់អភិវឌ្ឍនេះ ដោយគេហដ្ឋានត្រូវលិចទៅក្នុងទឹកភក់ និងទឹកស្អុយ និងធ្វើឲ្យគ្រួសារជាច្រើនត្រូវបង្ខំចិត្តចាកចេញ ដោយសារគេហដ្ឋានរបស់ពួកគេរស់នៅលែងបានតទៅទៀត។ កម្ពស់ទឹកដក់ដែលមានកម្រិតខ្ពស់ បន្ទាប់ពីមានភ្លៀងធំ ក៏ជាកង្វល់ចំពោះសុខភាពសាធារណៈ និងអាចរួមចំណែកធ្វើឲ្យមានការរីករាលដាលនៃជំងឺនានាដែលកើតឡើងដោយសារទឹក ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម។

១៥២. ផលប្រយោជន៍ពាក់ព័ន្ធមួយនៃសម្បទានដី គឺការកសាងផ្លូវថ្នល់ដោយសម្បទានិកបរទេស ដែលជួយសម្រួលដល់ការធ្វើដំណើរ ជាពិសេស នៅតំបន់ដាច់ស្រយាលមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ ការកសាងផ្លូវ ថ្នល់ ជារឿយៗ តម្រូវឲ្យមានការកាប់ឆ្ការព្រៃយកដី និងការកាប់រំលំដើមឈើ។ ជាបន្ថែមទៀត ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនេះ មិនមានលក្ខណៈសមធម៌ទេ ដោយសារសហគមន៍ជាច្រើនរស់នៅក្នុង ឬ ក្បែរដីសម្បទាន បានរាយការណ៍ថា មានការបដិសេធមិនឲ្យប្រើប្រាស់ផ្លូវថ្នល់នៅក្នុងដីសម្បទាន និងបង្ខំឲ្យប្រើប្រាស់ផ្លូវផ្សេងទៀត។

[២៣២] ទស្សនាវដ្តីសេដ្ឋកិច្ច(The Economist) "ទន្លេមេគង្គ៖ ការភូតកុហក អំពីទំនប់វារីអគ្គីសនី និងស្ថិតិ" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ មាននៅគេហទំព័រ៖ http://www.economist.com/blogs/banyan/2012/07/mekong-river

១៥៣. កង្វល់អំពីការបាត់បង់គំរបព្រៃឈើ ដោយសារការចូលទន្ទ្រានយកដីតាមរយៈសម្បទានដី នៅក្នុងព្រៃការពារ និងជាលទ្ធផលនាំឲ្យមានការបាត់បង់លទ្ធភាពទៅអាស្រ័យផល និងអនុផលព្រៃឈើរបស់សហគមន៍ ដែលនេះគឺជាកង្វល់ ដែលមានជាបន្តតតជាប់។ របាយការណ៍ឆ្នាំ ២០០៧ របស់តំណាងពិសេស SRSG បានលើកឡើងថា ការទន្ទ្រានចូលយកដីក្នុងតំបន់ព្រៃឈើពីសំណាក់សម្បទាន និងការបាត់បង់លទ្ធភាពទៅអាស្រ័យផល និងអនុផលព្រៃឈើរបស់សហគមន៍ មានពាក់ព័ន្ធនឹងក្រុមហ៊ុនសម្បទានដីចំនួនជាង ២២ នៅក្នុងខេត្តចំនួនប្រាំបី។ ចាប់តាំងពីឆ្នាំ ២០០៧ មក សម្បទានដីកាន់តែច្រើនថែមទៀត ត្រូវបានផ្តល់ជូនទៅក្រុមហ៊ុនឯកជន នៅក្នុងតំបន់ដែលសហគមន៍ជនបទ បានប្រើប្រាស់ និងប្រមូលជាប្រពៃណីនូវផលនិងអានុផលព្រៃឈើ។ ឧទាហរណ៍ ក្រុមហ៊ុនអភិវឌ្ឍន៍ចំការកៅស៊ូ CRCK (៦.១៥៥ ហិកតា) ក្រុមហ៊ុន PNT (៧.៩០០ ហិកតា) និងក្រុមហ៊ុនអភិវឌ្ឍន៍ និងវិនិយោគ ធី ង៉ា (៦.០៦០ ហិកតា) បានទទួលបានសម្បទានដី ដើម្បីអភិវឌ្ឍចំការកៅស៊ូនៅក្នុងតំបន់ព្រៃឡង់ និងបើតាមការរាយការណ៍ថា ក្រុមហ៊ុនទាំងនេះបានកាប់ឆ្ការព្រៃឈើយកដីនៅក្នុងតំបន់ដែលជនជាតិដើមភាគតិច បានប្រមូលជ័រឈើសម្រាប់ប្រើប្រាស់តាមទំនៀមទំលាប់។ ហេតុដូច្នេះហើយ សហគមន៍ដែលទទួលរងផលប៉ះពាល់ពីសម្បទានដី កំពុងតែខិតខំយ៉ាងលំបាកបំផុត ដើម្បីចិញ្ចឹមជីវិត និងរកស្បៀងឲ្យបានគ្រប់គ្រាន់ ។

## ង. បញ្ហាជុំវិញលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់

១៥៤. ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ មានកង្វល់កាន់តែកើនច្រើនឡើងៗ ទាក់ទងនឹងលទ្ធភាពទទួលបានទឹកស្អាតគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងគ្រួសារ (ដែលមានន័យថា ទឹកសម្រាប់ បរិភោគ អនាម័យសាធារណៈ បោកគក់សំលៀកបំពាក់ ដណ្តាំស្ល និង អនាម័យផ្ទាល់ខ្លួន និងគ្រួសារ) ក្នុងចំណោមសហគមន៍ដែលទទួលផលប៉ះពាល់ដោយសារសម្បទានដី អ្នកការពារបរិស្ថាន តំណាងរដ្ឋាភិបាល អ្នកការពារសិទ្ធិមនុស្ស និងដៃគូអភិវឌ្ឍន៍ដទៃទៀត។[២៣៣] កង្វល់នេះមានទាំងលើបញ្ហាកង្វះទឹក និងភាពកខ្វក់នៃទឹក និងមានកង្វល់ផ្សេងទៀតថា បញ្ហាទាំងនេះនឹងក្លាយជាកម្មវត្ថុនៃជម្លោះនៅក្នុង និងនៅជុំវិញតំបន់សម្បទានដី ដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិ នៅលើដីរបស់ជនជាតិដើមភាគតិច និងនៅក្នុងតំបន់ព្រៃស្តុក ដើម្បីប្រើប្រាស់សម្រាប់ដំណាំកសិ-ឧស្សាហកម្ម ការជីកយករ៉ែ ទំនប់វារីអគ្គិសនី និង ចំពោះគម្រោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំផ្សេងៗទៀត ។

១៥៥. ច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងថា សម្បទានដី មិនអាចប៉ះពាល់ផ្លូវគមនាគមន៍ រួមមានផ្លូវទឹក និង ដែនទឹកបម្រុងដែលត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេឡើយ។[២៣៤] របាយការណ៍តំណាងពិសេសឆ្នាំ ២០០៧ បានកត់សំគាល់អំពីដីសម្បទានមួយចំនួនដែលបិទច្រកផ្លូវ និង ផ្លូវថ្នល់ផ្សេងទៀតៗដែលអ្នកភូមិប្រើប្រាស់សម្រាប់ធ្វើដំណើរចេញចូលតំបន់ព្រៃ និងទៅកាន់ប្រភពទឹក ។ ការរំលោភបំពានបែបនេះ បានបន្តកើតមានជារហូតមក ហើយមានការកើនឡើងនូវការព្រួយបារម្ភណ៍កាន់តែច្រើនឡើងៗក្នុងចំណោមសហគមន៍ដែលរងការប៉ះពាល់ អំពីកង្វះទឹកនាពេលបច្ចុប្បន្ន និងទៅអនាគត និងការបំពុលទឹក ដែលបណ្តាល មកពីសកម្មភាពសម្បទានដី។

១៥៦. កង្វល់អំពីទឹកនៅតំបន់មានដីសម្បទានសេដ្ឋកិច្ច ដែលបានចងក្រងជាឯកសារ រួមមាន ចំការអំពៅរបស់ក្រុមហ៊ុនកោះកុងផ្លេនថេសិន ខមភេនី (Koh Kong Plantation Company) និងក្រុមហ៊ុនកោះកុងស៊ូហ្គើរខមភេនី (Koh Kong

[២៣៣] សិទ្ធិទទួលបានទឹកស្អាត ត្រូវបានកំណត់ថាជា សិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការទទួលបានទឹកគ្រប់គ្រាន់ មានសុវត្ថិភាព អាចទទួលយកបាន និងអាចទៅយកមកប្រើប្រាស់បាន អាចលៃលករកបាន សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងក្រុមគ្រួសារ មានចែងរៀបរាប់ នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ១៥ របស់គណៈកម្មាធិការសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅខែវិច្ឆិកា ឆ្នាំ២០០២។

[២៣៤] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៥៨។

Sugar Company) នៅស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ខេត្តកោះកុង។[២៣៥] ឧទាហរណ៍ ទាក់ទងនឹងក្រុមហ៊ុនកោះកុងស៊ូហ្គើរ ខមភេនី សហគមន៍ដែលរងការប៉ះពាល់ បានអះអាងថា កាកសំណល់គីមីពីចំការអំពៅ បានបំពុលប្រភពទឹកនៅក្នុងមូលដ្ឋាន និងសម្លាប់ត្រីដែលជាប្រភពសំខាន់នៃប្រូតេអ៊ីន សម្រាប់សហគមន៍រស់នៅនៅជុំវិញតំបន់នោះ ហើយប្រជាជនរស់នៅក្នុងមូលដ្ឋាននោះ បានឆ្លើយតបចំពោះបញ្ហានេះ ដោយការដាក់ពាក្យបណ្ដឹងតាមផ្លូវច្បាប់។ កង្វល់បន្ថែមទៀតអំពីបញ្ហាកង្វះទឹក បានស្ដែងឲ្យឃើញទាក់ទងនឹងសកម្មភាពរបស់ក្រុមហ៊ុន យូនៀន ដេវើលប្បមេន គ្រុប (Union Development Group) ស្ថិតក្នុងឧទ្យានជាតិបុទុមសាគរ នៃខេត្តកោះកុង និងចំការអំពៅរបស់ក្រុមហ៊ុន ភ្នំពេញស៊ូហ្គើរ ខមភេនី និងក្រុមហ៊ុនកំពង់ស្ពឺស៊ូហ្គើរ ខមភេនី។

១៥៧. លើសពីនេះទៀត នៅខែ មករា ឆ្នាំ ២០១០ នៅលើដីសម្បទានទំហំ ៩.៩៨៥ ហិកតា របស់ក្រុមហ៊ុន HLH នៅក្នុងដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលផលិត និងកែច្នៃ ពោតបង្កាត់ពូជថ្មីនោះ ក្រុមហ៊ុននេះបានបង្វែរទឹក ដើម្បីសាងសង់ប្រព័ន្ធស្រោចស្រពរបស់ខ្លួន។ តំបន់នេះ គឺជាទឹកដីកំណើតរបស់ជនជាតិដើមភាគតិចសួយ ដែលនៅសេសសល់នៅកម្ពុជា។ ជនជាតិដើមភាគតិចសួយ អះអាងថា ក្រុមហ៊ុន HLH បានបន្តបង្វែរទឹក ដោយការចាក់ដីទប់អូរនៅក្នុងមូលដ្ឋាន ដែលបានបណ្ដាលឲ្យជន់លិចដីស្រែចំការ។ បន្ទាប់ពីមានការធ្វើបាតុកម្មតវ៉ារបស់សហគមន៍ ក្រុមហ៊ុន HLH បានធ្វើការកែប្រែការអនុវត្តនេះរបស់ខ្លួនវិញ ប៉ុន្តែជនជាតិដើមភាគតិចសួយភាគច្រើន បានឈប់ប្រើប្រាស់ទឹកនោះ ដោយមានការភ័យខ្លាចថា ជាតិគីមីពុលដែលហូរមកពីចំការរបស់ក្រុមហ៊ុន HLH នោះធ្វើឲ្យបំពុលទឹក ដោយសារពួកគេបានឃើញទឹកប្រែទៅជាមានពណ៌ផ្សេងៗ។ ពួកគេក៏បានរាយការណ៍ថា បសុសត្វខ្លះ បានឈឺ ហើយងាប់ ដែលពួកគេជឿថា មានជាប់ទាក់ទងទៅនឹងការបំពុលទឹកនេះ។

## ច. កង្វល់អំពីសន្តិសុខ៖ ការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ និងបុគ្គលិកសន្តិសុខឯកជន

១៥៨. ការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ដើម្បីការពារផលប្រយោជន៍របស់ក្រុមហ៊ុនសម្បទានដី ត្រូវបានគេរាយការណ៍ថា មានច្រើនករណី។ នៅពេលចាប់ផ្ដើមដំណើរការ ជារឿយៗ ក្រុមហ៊ុន បានដាក់ពង្រាយកងកម្លាំងយោធារបស់ជាតិ ឬ កងកម្លាំងសន្តិសុខឯកជន ដើម្បីការពារតំបន់នោះ ដែលកងកម្លាំងទាំងនេះភាគច្រើន បានធ្វើការបំភិតបំភ័យដល់សហគមន៍នៅមូលដ្ឋាន ហើយពួកគេមួយចំនួននៃកងកម្លាំងទាំងនេះ គឺជាអ្នកទទួលខុសត្រូវចំពោះអំពើហិង្សាដែលពួកគេបានប្រព្រឹត្តិលើសហគមន៍ ការជម្រិតទារប្រាក់ ឬ បិទផ្លូវដោយដាក់កន្លែងត្រួតពិនិត្យ ។

១៥៩. មានករណីកាន់តែច្រើនឡើងៗ ដែលកងកម្លាំងប្រដាប់អាវុធ បានប្រើប្រាស់អាវុធជាតិផ្ទុះ នៅពេលមានការប្រឈមមុខដាក់គ្នាជាមួយនឹងអ្នកភូមិ ដែលតវ៉ាប្រឆាំងនឹងសកម្មភាពរបស់ក្រុមហ៊ុនសម្បទានដី ដែលរំលោភយកដីស្រែចំការ ព្រៃ ឬ តំបន់ដែលមានសារៈសំខាន់ផ្នែកវប្បធម៌ ឬ ជំនឿរបស់ពួកគេ។ ករណីមួយចំនួនពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធជាតិផ្ទុះ ត្រូវបានចងក្រងជាឯកសារ ក្នុងនោះមានករណីខ្លះ បណ្ដាលឲ្យស្លាប់បាត់បង់ជីវិត ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរ មានដូចជា ករណីក្រុមហ៊ុន ឌីធីវ៉ាយ នៅខេត្តក្រចេះ, ក្រុមហ៊ុន ជីងហ្សុងវី និងក្រុមហ៊ុនចំការកៅស៊ូ ហេង ប្រាឌ័រ នៅខេត្តរតនគីរី, ក្រុមហ៊ុន ភ្នំពេញស៊ូហ្គើរ និងក្រុមហ៊ុន កំពង់ស្ពឺស៊ូហ្គើរ នៅខេត្តកំពង់ស្ពឺ, ក្រុមហ៊ុន ជាតិអភិវឌ្ឍន៍ នៅខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ, និងក្រុមហ៊ុន មានសម្បត្តិ នៅខេត្តបាត់ដំបង។[២៣៦] លើសពីនេះទៀត កងកម្លាំងប្រដាប់អាវុធចម្រុះ រួមមានទាំង កងរាជអាវុធហត្ថផង ត្រូវបានប្រើប្រាស់ នៅខេត្តមណ្ឌលគីរី នៅខែឧសភា ឆ្នាំ

[២៣៥] APRODEV *លួចដីធ្លី លួចអនាគត របាយការណ៍រំលោភដីធ្លីនៅកម្ពុជា* ខែធ្នូ ឆ្នាំ២០១១។

[២៣៦] សូមមើល ជាឧទាហរណ៍ រឺដេអូខ្លីបរបស់អង្គការលីកាដូ(LICADHO) "ឧប្បត្តិហេតុនៃការបាញ់ ៥ គ្រាប់ មកលើអ្នកតវ៉ាក្នុងទំនាស់ដីធ្លី កាលពីពីរខែមុន បង្ហាញពីការកើនឡើងគួរឲ្យបារម្ភនៃការប្រើប្រាស់កំលាំងដែលបង្កឲ្យមានរបួស និងស្លាប់" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២។ គេហទំព័រ៖ http://www.licadho-cambodia.org/pressrelease.php?perm=269.

២០១២ ប្រឆាំងនឹងអ្នកភូមិ ដែលអាជ្ញាធរបានអះអាងថា បានចាប់យកដីដែលជារបស់ក្រុមហ៊ុន ចំការកៅស៊ូ គឺក្រុមហ៊ុន ប៉ាស៊ីហ្វិក ហ្គ្រេន យ៉ាញ-ស៊ុក និង ក្រុមហ៊ុន ប៉ាស៊ីហ្វិក អើលយ៉ាញ-ស៊ុក។ ក្នុងករណីសម្បទានដីនៅខេត្តឧត្តរមានជ័យ ក្រុមហ៊ុន អង្គរស៊ូហ្គើរ ក្រុមហ៊ុន ទន្លេ ស៊ូហ្គើរខេន និងក្រុមហ៊ុន ខេន និងស៊ូហ្គើរ វ៉ែលី បានដាក់ពង្រាយកម្លាំងនៃកង

វរសេនាតូចលេខ ៤២ ដើម្បីដាក់របាំងបិទផ្លូវ និងបានជួយដល់ការដុតបំផ្លាញ និងឈូសឆាយកម្ទេចភូមិ។

១៦០. មានករណីបាញ់ប្រហារសម្លាប់ផងដែរ ជាករណីដែលទទួលនូវការចាប់អារម្មណ៍យ៉ាងខ្លាំង ដែលកើតឡើងនាពេលថ្មីៗនេះ ដូចជា ការបាញ់ប្រហារ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ ទៅលើលោក ឈុត វុទ្ធី ជាសកម្មជនការពារបរិស្ថានដែលនិយាយតតសំថៃ និងដែលជាអ្នកការពារសិទ្ធិមនុស្ស នៅខណៈពេលដែលលោកប្រមូលភស្តុតាង ស្តីពីការកាប់ឈើខុសច្បាប់នៅក្នុងព្រៃនៃតំបន់ភ្នំក្រវ៉ាញភាគកណ្តាល នៅខេត្តកោះកុង និងការបាញ់ប្រហារទៅលើ កុមារី អាយុ ១៤ ឆ្នាំ អំឡុងពេលនៃការបណ្តេញចេញដោយបង្ខំ និងបង្ក្រាបលើក្រុម ប្រជាពលរដ្ឋដែលត្រូវបានចោទប្រកាន់ថា ជា "ចលនាអបគមន៍" នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២ នៅភូមិប្រម៉ា ក្នុងស្រុកឆ្លូង ខេត្តក្រចេះ។

១៦១. លើសពីនេះទៀត ដូចដែលបានលើកឡើងពីខាងដើម ក្រុមហ៊ុនសម្បទានដី ក៏បានជួលកងកម្លាំងប្រដាប់អាវុធ និងបុគ្គលិកសន្តិសុខ ដើម្បីបង្កើតកន្លែងត្រួតពិនិត្យ និងដាក់កម្រិតលើការប្រើប្រាស់ផ្លូវថ្នល់។ ឧទាហរណ៍ កាលពីឆ្នាំទៅ ឆ្មាំការពារបម្រើការឲ្យក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប នៅខេត្តកោះកុង បានហាមឃាត់ការធ្វើដំណើរចូលទៅកាន់ភូមិចំនួនពីរ ស្ថិតនៅក្នុងតំបន់ដីសម្បទានទំហំ ៣៦.០០០ ហិកតា នៅឧទ្យានជាតិបូទុមសាគរ ដោយសមាជិកសហគមន៍ និងតំណាងអង្គការសង្គមស៊ីវិល។ លើសពីនេះទៀត ទោះបីជាសកម្មភាពស៊ីវិលក្តី ក៏ការអនុវត្តគម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី បន្ទាប់ពីការចេញបទបញ្ជាស្តីពីសម្បទានដីសេដ្ឋកិច្ច នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១២ ត្រូវបានប្រតិបត្តិដោយក្រុមយុវជនស្លៀកពាក់ឯកសណ្ឋានយោធា ដែលជាធម្មតាស្លៀកពាក់ដោយកងកម្លាំងប្រដាប់អាវុធ(ដោយគ្មានស្លាកសញ្ញាសំគាល់កងកម្លាំងប្រដាប់អាវុធ) និង យានយន្តយោធា ត្រូវបានផ្តល់ជូនសម្រាប់ ដឹកជញ្ជូនអ្នកដែលត្រូវបានជ្រើសរើសទៅធ្វើការវាស់វែងដីធ្លី។ យោងតាមរបាយការណ៍ដែលទទួលបានពីសហគមន៍ នៅតាមតំបន់ជនបទ ការប្រតិបត្តិនេះបានបង្កើនឲ្យមាននូវការយល់ច្រឡំ និង នាំឲ្យមានការយល់ឃើញថា យុវជនដែល បានជ្រើសរើសយកមកវាស់វែងដីធ្លី គឺជាផ្នែកមួយនៃកងកម្លាំងយោធា។ ការបំភិតបំភ័យនៅក្នុងករណីមួយចំនួនត្រូវ បានគេរាយការណ៍។ មានកង្វល់ផងដែរថា ក្រុមយុវជនទទួលបានការបណ្តុះបណ្តាលដ៏មានកម្រិតនិងតិចតួច គឺក្នុងករណីខ្លះ ការបណ្តុះបណ្តាលនោះមានរយៈពេលតែពីរថ្ងៃប៉ុណ្ណោះ។

## ឆ. ផលប៉ះពាល់លើជនជាតិដើមភាគតិច

១៦២. សម្បទានដី និងគម្រោងអភិវឌ្ឍន៍ទ្រង់ទ្រាយធំ មានផលប៉ះពាល់ធ្ងន់ធ្ងរដូចគ្នាទៅលើ សហគមន៍មិនមែនជាជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែដោយឡែកសហគមន៍ជនជាតិដើមភាគតិច ដែលសិទ្ធិកម្មសិទ្ធិសមូហភាពរបស់ពួកគេលើដីធ្លី ត្រូវបានការពារដោយច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិនោះ ងាយនឹងទទួលរងគ្រោះណាស់។ ការរំលោភយកដីរបស់ពួកគេ កំពុងតែធ្វើឲ្យអន្តរាយដល់លទ្ធភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការចុះបញ្ជីដីសមូហភាពជាដីជាប្រពៃណីរបស់ពួកគេ និងការអនុវត្តសិទ្ធិរបស់ពួកគេដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយអនុលោមតាមច្បាប់ភូមិបាលឆ្នាំ ២០០១។

១៦៣. ខណៈដែល មានសេចក្តីរាយការណ៍ថា មានជនជាតិដើមភាគតិចរស់នៅក្នុងខេត្តចំនួន ១៥ ក៏ដោយ ក៏ពីរភាគបីនៃប្រជាពលរដ្ឋជនជាតិដើមភាគតិចទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេប្រទះឃើញនៅក្នុងខេត្តភាគឦសាន គឺខេត្តរតនគីរី និង ខេត្តមណ្ឌលគីរី ដែលជនជាតិដើមភាគតិច គឺជាចំនួនប្រជាពលរដ្ឋភាគច្រើន នៅក្នុងខេត្តទាំងពីរនេះ។

មានករណីជាច្រើនហើយដែលសម្បទានដីបានអភិវឌ្ឍដោយផ្ទាល់នៅលើដីរបស់ជនជាតិដើម ភាគតិច ហើយជារឿយៗ ដីជនជាតិដើមភាគតិចមាននៅសល់តិចតួច ឬ មិនមាននៅសេសសល់សោះ សម្រាប់ពួកគេអាចចុះ បញ្ជីដីបាន។[២៣៧] ការអភិវឌ្ឍកសិ-ឧស្សាហកម្ម កំពុងតែគម្រាមកំហែងដល់ប្រព័ន្ធកសិកម្មជាប្រពៃណីរបស់ជនជាតិដើមភាគតិច ហើយហេតុដូច្នេះ គម្រាមកំហែងដល់សន្តិសុខស្បៀងរបស់ពួកគេផងដែរ។ បច្ចេកទេសខាងកសិកម្មថ្មី ត្រូវបានយកមកអនុវត្តនៅលើដីរបស់ជនជាត់ដើមភាគតិច ដោយគ្មានការពិគ្រោះយោបល់ជាមួយនឹងសហគមន៍ ដែលជាអ្នកស្គាល់តំបន់ទាំងនោះច្បាស់។ ខណៈដែល ចំការថ្មីៗតែងតែផ្តល់ឲ្យមាននូវការងារធ្វើ ដែលតាមពិតទៅ និងជាញឹកញាប់ គឺមានបញ្ហាខ្វះកម្លាំងពលកម្មនៅតាមតំបន់ដាច់ស្រយាល ដោយសហគមន៍ជនជាតិដើមភាគតិចជាច្រើន ត្រូវបានរាយការណ៍ថា មិនអាចបន្សាំខ្លួនជាមួយនឹងបច្ចេកទេសខាងកសិកម្មថ្មីនេះបានទេ ហើយមិនអាចប្រាស្រ័យទាក់ទងជាភាសាខ្មែរ ឬជាភាសាប្រើប្រាស់ដោយក្រុមហ៊ុនបរទេសនោះបាន ហើយភាពតានតឹងនៅក្នុងមូលដ្ឋាន បានកើតមានឡើងទាក់ទងនឹងការចាប់យកដីធ្វើជារបស់ខ្លួន និងការគ្រប់គ្រងចាត់ចែងចំការរបស់ក្រុមហ៊ុន។ លក្ខខណ្ឌការងារ មិនត្រូវបានពិនិត្យតាមដានមើលយ៉ាងត្រឹមត្រូវទេ និងត្រូវបានរាយការណ៍ថា មានកម្រិតទាបក្រោមស្តង់ដារជាតិ និងអន្តរជាតិ ។

១៦៤. ដូចដែលបានលើកឡើងពីខាងដើម ការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត ក៏បានធ្វើឲ្យប៉ះពាល់ដល់ការងាររបស់ដៃគូអភិវឌ្ឍន៍ មិនត្រឹមតែដៃគូដែលកំពុងតែធ្វើការងារជួយសហគមន៍ក្នុងការចុះបញ្ជីដីធ្លី និងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងអង្គការអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ដែលបាននិងកំពុងតែព្យាយាមជួយលើកកម្ពស់របរចិញ្ចឹមជីវិតរបស់សហគមន៍នៅទីជនបទ និងសហគមន៍ជនជាតិដើមភាគតិចផងដែរ។[២៣៨]

## ជ. ផលប៉ះពាល់លើតំបន់ដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ និងខាងជំនឿ

១៦៥. របាយការណ៍ឆ្នាំ ២០០៤ របស់តំណាងពិសេស បានរៀបរាប់អំពីសារៈសំខាន់របស់ដីនៅតំបន់ជនបទ នៃប្រទេសកម្ពុជា ដោយសារដី គឺជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំសង្គម និងវប្បធម៌ និងរបរចិញ្ចឹមជីវិត[២៣៩] ហើយរបាយការណ៍ឆ្នាំ ២០០៧ របស់តំណាងពិសេស បានលើកឡើងនូវកង្វល់អំពីការរំលោភយកដីប្រើប្រាស់ជាប្រពៃណី ឬដីជាទីកន្លែងគោរពសក្ការៈបូជា ដែលបានប៉ះពាល់ទាំងសហគមន៍មិនមែនជនជាតិដើមភាគតិច និង សហគមន៍ជនជាតិដើមភាគតិច។ ដោយឡែក របាយការណ៍ឆ្នាំ ២០០៧ របស់តំណាងពិសេស បានកត់សំគាល់អំពីផលប៉ះពាល់ ដែល

---

[២៣៧] ឧទាហរណ៍ ក្នុងករណីសហគមន៍ជនជាតិដើមភាគតិចភ្នង ក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគិរី ដែលរងផលប៉ះពាល់ដោយការផ្តល់សម្បទានដីសេដ្ឋកិច្ចឲ្យក្រុមហ៊ុន Socfin-KCD (លុចសំបួរ-កម្ពុជា) និងក្រុមហ៊ុនដាំកៅស៊ូ ដាក់ឡាក់ (ប្រទេសវៀតណាម)។ សូមមើលរបាយការណ៍អង្គការ FIDH ផ្នែក ៣.៣.២. ។ នៅខេត្តរតនគីរីផងដែរ បើយោងតាមរបាយការណ៍ដែលផ្តោតលើសម្បទានដីនៅក្នុងស្រុកតាវែង (ក្រុមហ៊ុន ក្រុង បុក) និងក្នុងស្រុក អណ្តូងមាស (ក្រុមហ៊ុន ហេង ប្រាឌ័រ ក្រុមហ៊ុន ស៊ី អ ឌី C.R.D និង ក្រុមហ៊ុនវាសនា អ៊ិនវេសមេន នៅផ្នែកខាងលិចនៃទន្លេ និងក្រុមហ៊ុន ហ៊ាងអានអូយ៉ាដាវ និងក្រុមហ៊ុន ៧ មករា ប៉ារីស នៅផ្នែកខាងកើតនៃទន្លេ) ។ សហគមន៍ភូមិចាន់ រាយការណ៍ថា ដីស្រែចំការរបស់ប្រជាពលរដ្ឋ ៤៧ គ្រួសារ ស្ថិតនៅក្នុងតំបន់សម្បទាន ហើយសហគមន៍កាណាគធំ រាយការណ៍ថា មានប្រជាពលរដ្ឋ ៣០ គ្រួសារ និងសហគមន៍ញ៉ាង បានរាយការណ៍ថា មានប្រជាពលរដ្ឋ ១៦ គ្រួសារ ដែលរងផលប៉ះពាល់។ សហគមន៍ដាលវាលលេង បានបញ្ជាក់ថា ដីភាគច្រើនរបស់សហគមន៍ខ្លួនស្ថិតនៅក្នុងតំបន់ដីសម្បទានមានទំហំ ១.៩០០ ហិកតា។ អ្នកភូមិ បានរាយការណ៍ថា ការវាស់វែងដីសម្បទានជាទូទៅ គឺគ្របដណ្តប់លើដីស្រែចំការរបស់ពួកគេ និងដីព្រៃ រួមទាំង ដីសម្រាប់ដាំដំណាំចម្រុះ មានដាំស្រូវ បន្លែ និងដើមស្វាយចន្ទី។ សូមមើលរបាយការណ៍ Andrea Bues, ការកើនឡើងសម្ពាធនៃសេចក្តីត្រូវការសម្រាប់ដីធ្លី– *ភាពសុក្រិតស្មាញចំពោះជីវភាពរស់នៅ របស់អ្នកភូមិជនបទនៅក្នុងប្រទេសកំពុងអភិវឌ្ឍៈ ករណីប្រទេសកម្ពុជា* ខែតុលា ឆ្នាំ២០១១ ដែលអាច រកបានតាមរយៈគេហទំព័រៈ http://www.welthungerhilfe.de/fileadmin/media/pdf/Studien/Cambodia_Increasing_Pressure_final_Nov11.pdf.

[២៣៨] ដូចគ្នាខាងលើ។ ការសិក្សាបានបង្ហាញថា អសន្តិសុខស្បៀង និងការបាត់បង់ប្រពៃណី គឺជាលទ្ធផលដែលបណ្តាលមកពីសម្បទានទាំងនោះ។

[២៣៩] របាយការណ៍តំណាងពិសេស ឆ្នាំ២០០៤ ទំព័រ ២៧។

សម្បទានដីរបស់ក្រុមហ៊ុនអ៊ូជីសាន (Wuzhishan) នៅខេត្តមណ្ឌលគីរី ទៅលើដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចព្នង, ផលប៉ះពាល់នៃសម្បទានដីសម្រាប់ទេសចរណ៍ធម្មជាតិ ដែលត្រូវបានផ្តល់ជូន ក្រុមហ៊ុន ញូវ កូសម៉ូ ឌីវេឡុបមេន (New Cosmos Development (Cambodia)) ទៅលើដីជាប្រពៃណី និងលើតំបន់ដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ និងការគោរពបូជារបស់សហគមន៍ជនជាតិដើមភាគតិចសួយ នៅស្រុក ឱរ៉ាល់ ខេត្តកំពង់ស្ពឺ, និងការដាក់កំហិតលើព្រះសង្ឃ ក្នុងការរៀបចំពិធីសាសនាតាមបែបប្រពៃណី ដោយសារសកម្មភាពរបស់ក្រុមហ៊ុន ភាពីម៉ិច នៅខេត្តពោធិសាត់។[២៤០] សម្បទានដីទាំងនេះ នៅមានសកម្មភាពនៅឡើយ (លើកលែងតែសម្បទានដីរបស់ក្រុមហ៊ុន ញូវ កូសម៉ូ ឌីវេឡុបមេន នៅស្រុកឱរ៉ាល់ដែលបានបញ្ឈប់ដំណើរការ)។

១៦៦. នៅខែ ឧសភា ឆ្នាំ ២០១១ សម្បទានដី ត្រូវបានផ្តល់ជូនក្រុមហ៊ុន យីះចៀ ធួរីហ្ស៊ឹម ឌីវេឡុបមេន (ខេមបូឌា) (Yeejia Tourism Development (Cambodia)) សម្រាប់កសិ-ទេសចរណ៍ និងតំបន់ទេសចរណ៍ធម្មជាតិ តេទឹកពុះ នៅលើដីរបស់ជនជាតិដើមភាគតិចសួយ នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលជាន់គ្នាជាមួយនឹងសម្បទានដីរបស់ក្រុមហ៊ុន ញូវ កូសម៉ូ ឌីវេឡុបមេន។[២៤១] តេទឹកពុះ មានសារៈសំខាន់ផ្នែកវប្បធម៌ និងជំនឿរបស់ជនជាតិដើមភាគតិចសួយ។ របាយការណ៍ខែ តុលា ឆ្នាំ ២០១១ របស់សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) បានសរសេរចងក្រងជាឯកសារអំពីការបំផ្លិចបំផ្លាញព្រៃអារក្ស និងទីកន្លែងបញ្ចុះសពរបស់ជនជាតិដើមភាគតិចព្នង នៅប៊ូស្រា ដោយរថយន្តប៊ូលដូហ្ស័រកាន់កាប់ដោយជនជាតិខ្មែរ ដែលបានចុះកិច្ចសន្យាបន្តពីក្រុមហ៊ុន សូហ្វីន ខេស៊ីឌី (Socfin-KCD) (ជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នារវាង ក្រុមហ៊ុនដែលចុះបញ្ជីនៅប្រទេសលុចសំបួរ (Luxembourg-registered Socfinasia) និងក្រុមហ៊ុនក្នុងស្រុកឈ្មោះ ខូវ ជីលី សម្រាប់ដីសម្បទានចំការកៅស៊ូ)។[២៤២] ក្រុមហ៊ុន ជីង ហ្សុងរី នៅខេត្តរតនគីរី ក៏បានឈូសឆាយផ្នែកខ្លះនៃព្រៃអារក្សរបស់សហគមន៍ជនជាតិដើមភាគតិចទំពួន នៅស្រុកលំផាត់។ ក្រុមហ៊ុននោះបានបញ្ឈប់សកម្មភាពរបស់ខ្លួន បន្ទាប់ពីមានបាតុកម្មតវ៉ាចំនួន បី ឬ បួនលើក ពីសំណាក់សហគមន៍ជនជាតិដើមភាគតិច ដែលទទួលរងការប៉ះពាល់ ។

១៦៧. លើសពីនេះទៀត ដីសម្បទានទំហំ ៦.០០០ ហិកតា ដែលត្រូវបានផ្តល់ជូនទៅក្រុមហ៊ុនជាតិអភិវឌ្ឍន៍ នៅក្នុងតំបន់ការពារទេសភាពបន្ទាយឆ្មា ក៏គ្របដណ្តប់លើទួលប្រាសាទបុរាណចំនួនប្រាំមួយ[២៤៣] ហើយដីសម្បទាននេះ បានធ្វើឲ្យប៉ះពាល់ និងរំលោភចូលដីស្រែចំការដែលជារបស់ប្រជាជនចំនួនជាង ៩០០ គ្រួសារ នៅក្នុងភូមិចំនួន ប្រាំ ក្នុងឃុំបន្ទាយឆ្មា ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងភូមិចំនួនបី នៅក្នុងឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ទួលចំនួនពីរ ក្នុងចំណោមទួលប្រាសាទចំនួនប្រាំមួយ ឈ្មោះ ដានមង និង អន្លង់ព្រិច ត្រូវបានក្រុមហ៊ុនឈូសឆាយអស់ហើយ ថ្វីបើមានការតវ៉ាពីសហគមន៍នៅមូលដ្ឋានក៏ដោយ។ ទួលដានមង គឺជាទីកន្លែងដែលសហគមន៍មូលដ្ឋាន ទៅបន់ស្រន់សុំសេចក្តីសុខ ភាពរីកចម្រើនរុងរឿង និងសុំទឹកភ្លៀង ដល់ភូមិរបស់ពួកគេជារៀងរាល់ឆ្នាំ ជាពិសេស នៅពេលចូលឆ្នាំប្រពៃណីខ្មែរ ។

## ឈ.ផលប៉ះពាល់លើស្ត្រី និងក្មេងស្រី

[២៤០] របាយការណ៍តំណាងពិសេស ឆ្នាំ២០០៤ ទំព័រ ១៤។

[២៤១] អនុក្រឹត្យ លេខ ៧៧ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១។

[២៤២] FIDH *ដីធ្លីនៅកម្ពុជា ត្រូវបានគេកាប់ឆ្ការសំរាប់សិទ្ធិដាំដំណាំកៅស៊ូ ៖ ផលវិបាកនៃការដាំដំណាំកៅស៊ូដោយ Socfin-KCD មកលើសហគមន៍ជនជាតិដើមភាគតិច នៅស្រុកប៊ូស្រា ខេត្តមណ្ឌលគិរី* ខែតុលាឆ្នាំ២០១១ ផ្នែក ៥.៤.៣។

[២៤៣] ទួលបុរាណទាំងនោះគឺ ១) ទួលគោកវត្ត ២) ទួលស្រែរូង ៣) ទួលតាណាក់ ៤) ទួលគ្រឹះមមាំង ៥) ទួលពង្រ ៦) ទួលដំរីស៊ីកន្ទេល។

១៦៨. ការផ្តល់សម្បទានដី បានធ្វើឲ្យប៉ះពាល់ជាពិសេសទៅលើស្ត្រី និងក្មេងស្រី ឧទាហរណ៍ នៅក្នុងផ្នែកទាក់ទងនឹងការងារ ជីវភាពរស់នៅ សន្តិសុខ និង រចនាសម្ព័ន្ធនិងតួនាទីរបស់គ្រួសារ។ សម្បទានដី រួមចំណែកធ្វើឲ្យមានការថយចុះដី និង ព្រៃឈើសម្រាប់ការរស់នៅ ដោយបណ្តាលឲ្យមានការផ្លាស់ប្តូរចំពោះឱកាសសម្រាប់របរចិញ្ចឹមជីវិត និងការប្រែប្រួលដល់លំនាំនៃកម្លាំងពលកម្ម និងការធ្វើអន្តោប្រវេសន៍។ កង្វះធនធាន បានធ្វើឲ្យសហគមន៍ ប្រឈមមុខនឹងបញ្ហាទាក់ទងនឹងសន្តិសុខស្បៀង ហើយសហគមន៍ជាច្រើនត្រូវបង្ខំចិត្តចាកចេញពីតំបន់ដែលពួកគេរស់នៅ ដើម្បីទៅស្វែងរកការងារធ្វើ ឬ ស្បៀងអាហារ។ ឧទាហរណ៍ នៅខេត្តក្រចេះ ជាខេត្តដែលសម្បទានដីសេដ្ឋកិច្ច ភាគច្រើនត្រូវបានផ្តល់នោះ មានសេចក្តីរាយការណ៍ថា បុរស បានចាកចេញទៅកាន់ខេត្តផ្សេងៗ ដើម្បីស្វែងរកផលអនុផលព្រៃឈើដែលលែងមាននៅក្នុងតំបន់របស់ខ្លួន។ ស្ត្រី ត្រូវបានរាយការណ៍ថា បានចាកចេញទៅតំបន់ជិតៗនោះ ក៏ដូចជាធ្វើដំណើរទៅក្រៅប្រទេសកម្ពុជា ដើម្បីធ្វើការងារនៅតាមចំការ ឬ ធ្វើជាអ្នកធ្វើការតាមផ្ទះ។[២៤៤] ជាញឹកញាប់ មានតែសហគមន៍ប្រុសៗប៉ុណ្ណោះ ដែលនឹងទទួលបានឱកាសការងារជាកម្មករនៅតាមចំការ ដោយសារហេតុផលខាងវប្បធម៌ ដែលនាំទៅដល់ការធ្វើឲ្យមានការផាត់ស្ត្រីចេញកាន់តែខ្លាំងឡើងថែមទៀត ដែលស្ត្រី ជាទូទៅប្រឈមខ្លាំងរួចទៅហើយទៅនឹងភាពក្រីក្រ និងកង្វះអាហារដែលមានជីវជាតិគ្រប់គ្រាន់។

១៦៩. ចំពោះស្ត្រី និងក្មេងស្រីទាំងជាជនជាតិដើមភាគតិច និងមិនមែនជនជាតិដើមភាគតិច នៅតាមតំបន់ជនបទដាច់ស្រយាល វត្តមានថ្មីនៃ "អ្នកមកពីខាងក្រៅ" (ជនជាតិខ្មែរដែលមិនមែនជាអ្នកនៅតំបន់នេះ និងជនបរទេស ដែលកំពុងបម្រើការងារឲ្យក្រុមហ៊ុនសម្បទានដី) គឺកង្វល់បន្ថែមទៀតទាក់ទងនឹងសុវត្ថិភាពដែលអាចកើតឡើង ដូចជា អំពើប្លន់ ចោរកម្ម និងអំពើហិង្សាលើរូបរាងកាយ រួមទាំង ការរំលោភសេពសន្ថវៈផងដែរ។ ការណ៍នេះមានសារៈសំខាន់ ជាពិសេសចំពោះស្ត្រី ដែលជាប្រពៃណី ត្រូវធ្វើដំណើរទៅព្រៃដើម្បីទៅរកស្បៀងអាហារ និង ផលអនុផលព្រៃឈើ។ មានសេចក្តីរាយការណ៍ថា ឥឡូវនេះ ស្ត្រីមួយចំនួនជ្រើសរើសធ្វើដំណើរជាក្រុម។ កង្វល់ចំពោះសន្តិសុខ ក៏មានចំពោះស្ត្រីដែលត្រូវបានបណ្តេញចេញ និងផ្លាស់ប្តូរទីលំនៅទៅកន្លែងថ្មី ដែលជារឿយៗ ស្ថិតនៅឆ្ងាយពីទីក្រុង ដែលនាំមកនូវភាពអវត្តមានរបស់ ប្តី និងសាច់ញាតិ ដែលពួកគេត្រូវវិលត្រឡប់ទៅធ្វើការនៅក្នុងទីក្រុងវិញ

១៧០. ស្ត្រី និងមនុស្សចាស់ ក៏ដូចជា កុមារ ជារឿយៗ ស្ថិតនៅជួរមុខ នៅពេលធ្វើបាតុកម្ម។ ស្ត្រីដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី នៅតំបន់បឹងកក់ មានសកម្មភាពក្លៀវក្លាណាស់។[២៤៥] កាលពីមុន សហគមន៍ បានសន្មត់ថា ស្ត្រី និងកុមារ មិនសូវចំជាទិសដៅនៃការវាយប្រហាររបស់អជ្ញាធរទេ ហើយហេតុដូច្នេះ ពួកគេ ជាអ្នកដឹកនាំបាតុកម្ម ប៉ុន្តែជាក់ស្តែង មានករណីអំពើហិង្សាលើស្ត្រី នៅក្នុងបរិបទបាតុកម្មកាន់តែច្រើនឡើងៗ ហើយមានការឃុំខ្លួនដោយបំពានចំពោះបាតុករជាស្ត្រីភេទ។ ក្នុងរយៈពេលប៉ុន្មានខែកន្លងទៅថ្មីៗនេះ ស្ត្រីបានអនុវត្តសកម្មភាពសាធារណៈកាន់តែខ្លាំងក្លាឡើង ក្នុងការការពារខ្លួនទប់ទល់នឹង ការប្រើប្រាស់កម្លាំងដែលធ្វើឡើងដោយកងកម្លាំងប្រដាប់អាវុធ។ នៅក្នុងឧប្បត្តិហេតុមួយ កាលពីខែ មីនា ឆ្នាំ ២០១២ តំណាងស្ត្រី នៃសហគមន៍បឹងកក់ បានដោះអាវបង្ហាញសុដន់របស់ខ្លួនជាសាធារណៈ ដើម្បី

[២៤៤] Margherita Maffii ឧបត្ថម្ភដោយ Heinrich Böll Foundation *ភាពជាអ្នកដឹកនាំរបស់ស្ត្រី ៖ ករណីសិក្សាមួយនៅកម្ពុជា* ខែកក្កដា ឆ្នាំ២០១១ ដែលអាចរកបានលើគេហទំព័រ៖ http://www.kh.boell.org/ downloads/Women_leadership_case_study_report_July_2011_1_FINAL. pdf

[២៤៥] អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) *ការបណ្តេញចេញ និងការតស៊ូតទល់នៅកម្ពុជា៖ ស្ត្រី ៥ រូប និយាយពីរឿងរ៉ាវរបស់ខ្លួន* ខែវិច្ឆិកា ឆ្នាំ២០១១។

ចៀសវាងការចាប់ខ្លួនពីសំណាក់នគរបាល ដែលនេះជាការបង្ហាញឲ្យឃើញពីភាពអស់សង្ឃឹម ដែលមិនធ្លាប់មានពីមុនមក។[២៤៦]

១៧១. សកម្មជនជាស្ត្រីដែលពាក់ព័ន្ធនឹងជម្លោះដីធ្លី បានរាយការណ៍អំពី ការគម្រាមគំហែង និងការបំភិតបំភ័យលើខ្លួនពួកគេ និងក្រុមគ្រួសាររបស់ពួកគេ ដែលជាការធ្វើឲ្យខូចខាតដល់ទំនាក់ទំនងគ្រួសាររបស់ពួកគេ និងសុខភាពផ្លូវចិត្ត។ ស្ត្រីជាច្រើន រាយការណ៍អំពី អារម្មណ៍អស់សង្ឃឹម និងការធ្លាក់ទឹកចិត្ត អារម្មណ៍ចង់ធ្វើអត្តឃាត និងជួបប្រទះស្ថានភាពនៃការលែងលះគ្នា និងការរស់នៅបែកគ្នា ទាក់ទងទៅនឹងទំនាស់ដីធ្លីរបស់ពួកគេ និងការពាក់ព័ន្ធក្នុងបណ្តឹងតវ៉ាអំពីដីធ្លី។

១៧២. ស្ត្រី បន្តការឈឺចាប់ប្រកបដោយភាពមិនសមាមាត្រ នៅក្នុងដំណើរការបណ្តេញចេញ និងការផ្លាស់ប្តូរទីលំនៅដោយសារពួកគេមានការទទួលខុសត្រូវទាំងចំពោះការរកប្រាក់ចំណូល និងក៏ដូចជាការថែទាំគ្រួសារ និង គេហដ្ឋានផងដែរ។[២៤៧] នៅពេលមានបញ្ហាកើតឡើងទាក់ទងនឹងការប្រើប្រាស់សេវាជាមូលដ្ឋាននៅតំបន់តាំងទីលំនៅថ្មី ដូចជា ទឹក និងអនាម័យ ស្ត្រី និង កុមារ ជារឿយៗ ទទួលរងផលប៉ះពាល់ប្រកបដោយភាពវិសមាមាត្រ ដោយសារពួកគេ គឺជាអ្នកដែលមានវត្តមានច្រើននៅលើតំបន់តាំងទីលំនៅថ្មី។ ក្នុងករណីសម្បទានដីនៅក្នុងតំបន់ទីក្រុង ដែលនាំមកនូវការបណ្តេញចេញ ស្ត្រីបានបាត់បង់ការងារ និងប្រភពរបរចិញ្ចឹមជីវិត ក្នុងករណីខ្លះ តាមរបាយការណ៍បានឲ្យដឹងថា ស្ត្រីបាត់បង់ច្រើនជាងបុរស ជាពិសេស ប្រសិនបើពួកគេត្រូវបានផ្លាស់ប្តូរទៅទីកន្លែងតាំងទីលំនៅថ្មីស្ថិតនៅឆ្ងាយពីទីក្រុង។ ការងារដូចគ្នាដែលមាននៅតាមតំបន់តាំងទីលំនៅថ្មី ជារឿយៗ មិនអាចជួយឲ្យពួកគេរក្សាកម្រិតជីវភាពរស់នៅស្មើគ្នានឹងកម្រិតជីវភាពនៅក្នុងទីក្រុងដែលមានដង់ស៊ីតេប្រជាជនខ្ពស់នោះទេ។ ដោយមានការបាត់បង់ប្រាក់ចំណូល និងការលំបាកទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅ នោះការទទួលទានស្រា ត្រូវបានគេរាយការណ៍ថា បានកើតមានជាទូទៅ ហើយដែលវាទាក់ទងទៅនឹងភាពតានតឹងនៅក្នុងគ្រួសារកាន់តែច្រើនឡើងៗ និងអំពើហិង្សានៅក្នុងករណីជាច្រើន។ ការមានផ្ទៃពោះដោយមិនបានគ្រោងទុកជាមុននៃស្ត្រី នៅតាមតំបន់តាំងទីលំនៅថ្មី ត្រូវបានគេរាយការណ៍ថា មានលក្ខណៈរីករាលដាល ដោយសារកង្វះលទ្ធភាពទទួលបានសេវាខាងការធ្វើផែនការគ្រួសារ (សេវាពន្យារកំណើត)។

១៧៣. ស្ត្រី ក៏ប្រឈមមុខនឹងការលំបាកទាក់ទងនឹងការចុះបញ្ជីទ្រព្យសម្បត្តិ និងប័ណ្ណកម្មសិទ្ធិដីធ្លី ដែលជាការធ្វើឲ្យចុះខ្សោយដល់សុវត្ថិភាពខាងការកាន់កាប់របស់ពួកគេ និងធ្វើឲ្យពួកគេងាយទទួលរងគ្រោះ ពីសម្បទានដី ដែលត្រូវបានផ្តល់នៅលើដីដែលពួកគេកំពុងរស់នៅ។ ក្នុងចំណោមប័ណ្ណកម្មសិទ្ធិដីធ្លីសរុប ដែលត្រូវបានចេញរហូតមកដល់ ត្រឹមខែមិថុនា ឆ្នាំ ២០១០ មានប័ណ្ណកម្មសិទ្ធិដីប្រមាណជា ៧០ ភាគរយ ត្រូវបានរាយការណ៍ថា ជាទ្រព្យសម្បត្តិរួមរបស់គូស្វាមីភរិយា មាន ២០ ភាគរយ ជាកម្មសិទ្ធិរបស់ស្ត្រី មាន ៥ ភាគរយ ជាកម្មសិទ្ធិរបស់បុរស និង ៥ ភាគរយទៀត ជាកម្មសិទ្ធិរបស់វត្ត។[២៤៨] តាមរបាយការណ៍បានឲ្យដឹងថា ដោយការធ្វើសហប្រតិបត្តិការជាមួយនឹង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មានកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីធ្វើឲ្យប្រសើរឡើងដល់ការចុះបញ្ជីទ្រព្យសម្បត្តិ ដែលមានស្ត្រីជាម្ចាស់កម្មសិទ្ធិ ដែលកិច្ចការនេះអាចទទួលរងផលប៉ះពាល់ ពីកម្រិតទាបនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ជាផ្លូវ

[២៤៦] អង្គការលើកលែងទោសអន្តរជាតិ *កម្ពុជា៖ ដាក់ពន្ធនាគារដោយសារតែការបញ្ចេញមតិ បច្ចុប្បន្នភាពនៃតំបន់បឹងកក់របស់ទីក្រុងភ្នំពេញ* ឆ្នាំ ២០១២ ផ្នែក ៣.៤ អាចរកបានលើគេហទំព័រ៖ https://doc.es.amnesty.org/cgi-bin/ai/BRSCGI/asa230102012en? CMD= VEROBJ&MLKOB=31770732121

[២៤៧] សូមមើលរបាយការណ៍របស់ COHRE *ការស្ទាបស្ទង់ពីផលប៉ះពាល់នៃការបណ្តេញចេញទៅលើស្ត្រី នៅរាជធានីភ្នំពេញ* ខែវិច្ឆិកា ឆ្នាំ២០១១។

[២៤៨] ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ផ្នែកទី២ ទំព័រ ៣៤ កថាខ័ណ្ឌទី១១១។ សូមមើលផងដែរ នូវគម្រោង គ្រប់គ្រងរដ្ឋបាល និង ដីធ្លីនៅកម្ពុជា ៖ *សមភាពយេនឌ័រ ក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ* របាយការណ៍ស្ទាបស្ទង់មតិ ខែមេសា ឆ្នាំ២០១០។

ការ។[២៤៩] ទោះបីជាប័ណ្ណកម្មសិទ្ធិ កាន់តែច្រើនឡើងៗ ត្រូវបានចុះបញ្ជីដោយដាក់ឈ្មោះរបស់ស្ត្រីក៏ដោយ ក៏ស្ត្រីដែលជាសហកម្មសិទ្ធិទ្រព្យរួម រាយការណ៍ថា ពួកគេមានបញ្ហាទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិនោះ នៅពេលស្ថិតក្នុងស្ថានភាពនៃការបែកបាក់គ្នា ការបោះបង់ចោល អំពើហិង្សាក្នុងគ្រួសារ ការរៀបអាពាហ៍ពិពាហ៍ច្រើន ដង និងការលែងលះគ្នា ។[២៥០] នៅក្នុងទិដ្ឋភាពណាមួយ នៃទិដ្ឋភាពដែលបានលើកឡើងខាងលើនេះ ស្ត្រីដែលមានចំណូលទាប (និងកូនៗរបស់ពួកគេ) ត្រូវស្ថិតនៅក្នុងស្ថានភាពមិនទៀងទាត់ទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ។

## ញ. ផលប៉ះពាល់លើកុមារ

១៧៤. ផលប៉ះពាល់ដ៏ច្រើនលើសលុបលើកុមារ គឺទាក់ទងទៅនឹងភាពយ៉ាប់យ៉ឺននៃជីវភាពរស់នៅ ដែលវាពាក់ព័ន្ធជាមួយនឹងសុវត្ថិភាពខាងការកាន់កាប់ដីធ្លី ការបំផ្លាញបរិស្ថាន និងការរំលោភយកដី ព្រមទាំងការបណ្តេញចេញដោយបំពាន និង ការតាំងទីលំនៅថ្មី។ បញ្ហាប្រឈមទាំងនេះ ប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេដើម្បីទទួលបានសេវាជាមូលដ្ឋានដូចជា សុខភាព និង ទឹកស្អាត និងអនាម័យ គ្រប់គ្រាន់ ក៏ដូចជាឱកាសទទួលបានការអប់រំរបស់ពួកគេ។ ក្នុងករណីមានការផ្លាស់ប្តូរទីលំនៅ កុមារ នៅពេលនោះ ត្រូវបោះបង់ចោលការសិក្សា ឬ ក៏ក្រុមគ្រួសារត្រូវរស់នៅបែកគ្នាដោយទុកកូនឲ្យរស់នៅជិតទីតាំងដែលត្រូវបានបណ្តេញចេញ ដើម្បីឲ្យពួកគេបានរៀនបញ្ចប់ឆ្នាំសិក្សា។ ក្នុងករណីខ្លះគ្រួសារ ត្រូវបង់កម្រៃមិនផ្លូវការ ដើម្បីផ្លាស់ប្តូរកូនរបស់ខ្លួនពីសាលារៀនមួយ ទៅសាលារៀនមួយទៀត ហើយកម្រៃមិនផ្លូវការប្រចាំថ្ងៃ ដែលត្រូវបានទារដោយលោកគ្រូ-អ្នកគ្រូ គឺជាកាដាក់បន្ទុកបន្ថែមលើចំណូលដ៏តិចតួចរបស់គ្រួសារ។

១៧៥. មានបញ្ហាទាក់ទងនឹងពលកម្មកុមារផងដែរ។ ឧទាហរណ៍ ការសិក្សាស្រាវជ្រាវមួយ បានរកឃើញថា កុមារត្រូវបានបានឲ្យឈប់ទៅសាលារៀន ដើម្បីមកជួយធ្វើការ និងរកប្រាក់ចំណូលទ្រទ្រង់គ្រួសាររបស់ពួកគេ ដែលកំពុងតែខំប្រឹងតស៊ូពុះពារ ដោយសារតែផលប៉ះពាល់ដែលបណ្តាលមកពីសម្បទានដី។[២៥១] ដូចគ្នានឹងផលប៉ះពាល់លើស្ត្រី និងក្មេងស្រីដូចដែលបានរៀបរាប់ខាងលើដែរ តម្រូវការខាងមុខរបរចិញ្ចឹមជីវិត អាចបណ្តាលឲ្យមានការប៉ះពាល់ដល់រចនាសម្ព័ន្ធគ្រួសារ ដោយសារឪពុក-ម្តាយ ត្រូវចាកចេញដើម្បីទៅរកការងារធ្វើ ដែលអាចបង្កើនឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ។ ការមានផ្ទៃពោះដែលមិនបានគ្រោងទុកជាមុន បណ្តាលឲ្យគ្រួសារជាច្រើន មានកូនច្រើន ដែលមិនអាចមានលទ្ធភាពចិញ្ចឹម ឬ ឲ្យចូលរៀនបាន។ ជារួម ផលប៉ះពាល់នៃការផ្លាស់ប្តូរទីកន្លែង និងការផ្លាស់ប្តូរទីលំនៅថ្មី អាចនាំឲ្យមានការប៉ះទង្គិចខ្លាំងណាស់ចំពោះកុមារ។

១៧៦. ក្រុមហ៊ុនសម្បទានដីខ្លះ បានចូលរួមក្នុងកិច្ចផ្តួចផ្តើមពិសេស និងដោយស្ម័គ្រចិត្ត ជាកាយវិការមួយដែលចូលទៅក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម ហើយដែលវាអាចមានឥទ្ធិពលវិជ្ជមានលើសុខុមាលភាពរបស់កុមារ ដូចជា ការបង្កើតមណ្ឌលសុខភាព និងថ្នាក់រៀន នៅតាមតំបន់ជនបទដាច់ស្រយាល។ ឧទាហរណ៍ៈ ក្រុមហ៊ុន Socfin-KCD បានវិនិយោគទៅលើគម្រោងខាងសង្គម ដោយការរៀបចំកែលំអរជាថ្មីនូវសាលាបឋមសិក្សាចំនួនពីរខ្នង នៅប៊ូស្រា ដែលផ្តល់ការអប់រំជាភាសាខ្មែរ (ប៉ុន្តែមិនមែនជាភាសាប្រើប្រាស់នៅក្នុងមូលដ្ឋានទេ -ភាសាជន

---

[២៤៩] គូស្វាមីភរិយាដែលទើបរៀបការថ្មីៗ ជាធម្មតា មិនបានចុះលិខិតអាពាហ៍ពិពាហ៍ឲ្យបានត្រឹមត្រូវទេ។ ចំពោះស្វាមីភរិយា ដែលបានចុះលិខិតអាពាហ៍ពិពាហ៍ត្រឹមត្រូវវិញ នៅពេលមានការលែងលះ គឺតែងជួបនូវនីតិវិធីលំបាកស្មុគស្មាញ (ចំណាយថវិកា) ខណៈដែលគូស្វាមីភរិយាដែលមិនបានចុះលិខិតអាពាហ៍ពិពាហ៍ត្រឹមត្រូវ ការលែងលះគឺគ្រាន់តែទៅការិយាល័យឃុំ-សង្កាត់ ដើម្បីប្រកាសពីការលែងលះជាការស្រេច។

[២៥០] Mehrak Mehrvar, ឆាយ គីមស័រ និង មី សម្បត្តិ *ទស្សនៈទានរបស់ស្ត្រី ៖ករណីសិក្សាពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅកម្ពុជា* ខែកក្កដា ឆ្នាំ ២០០៨ គាំទ្រដោយអង្គការ យេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា និងអង្គការ Heinrich Böll Stiftung Cambodia។

[២៥១] ឧទាហរណ៍ ករណីនៃការដាំដំណាំអំពៅ នៅខេត្តកោះកុង សូមមើល APRODEV *របាយការណ៍រំលោភដីធ្លីនៅកម្ពុជា៖ លួចដីធ្លី លួចអនាគត* ចេញ នៅខែធ្នូ ឆ្នាំ២០១១។

ជាតិពួង) និងដោយបានផ្តល់ប្រាក់ខែជូនលោកគ្រូ-អ្នកគ្រូ និងការរួមវិភាគទានចំពោះហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈសាលារៀន។[២៥២] ក្រុមហ៊ុន ហ្គ្រេនឌីស ធីមបឺ (Grandis Timber) នៅខេត្តកំពង់ស្ពឺ បានបង្កើតគិលានដ្ឋានសម្រាប់ពលករ និងមជ្ឈមណ្ឌលថែទាំកុមារសម្រាប់កូនរបស់ពលករ។

# VIII. លទ្ធភាពទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព

## ក. ភាពមាន និងលទ្ធភាពប្រើប្រាស់ នៃយន្តការក្រៅប្រព័ន្ធតុលាការដែលមានស្រាប់

១៧៧. ដូចដែលបានរៀបរាប់ខាងលើ មានយន្តការក្រៅប្រព័ន្ធតុលាការមួយចំនួន សម្រាប់ ដោះស្រាយទំនាស់ រួមទាំងយន្តការនៃប្រព័ន្ធសុរិយោដីនៅតាមកម្រិតផ្សេងៗផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏បន្ទុកខាងរដ្ឋបាល និង ខាងនីតិវិធី ដែលត្រូវការនូវពេលវេលាយូរ ការចំណាយខាងហិរញ្ញវត្ថុពាក់ព័ន្ធនឹងការដាក់ពាក្យបណ្តឹង (មិនមានការបង់កម្រៃផ្លូវការ ដូចជាករណីដែលដាក់ទៅតុលាការក៏ពិតមែន ប៉ុន្តែចំណាយលើការធ្វើដំណើរ ការខាតបង់ប្រាក់ឈ្នួល និងការស្វែងរកជំនួយផ្នែកច្បាប់ ពិតជាមានតម្លៃខ្ពស់សម្រាប់បុគ្គលនានា) និងកង្វះជំនឿលើប្រព័ន្ធនេះ បានធ្វើឲ្យយន្តការទាំងនេះ ត្រូវបានប្រើប្រាស់ដោយមិនមានលក្ខណៈស៊ីសង្វាក់គ្នា។ អ្នកដាក់ពាក្យបណ្តឹងតវ៉ា រាយការណ៍ថា សេចក្តីសម្រេចរបស់ស្ថាប័នទាំងនេះ មិនមានភាពស្របគ្នា មិនប្រក្រតី និងរងការជ្រៀតជ្រែកខាងនយោបាយ។

១៧៨. មានការខិតខំប្រឹងប្រែងខ្លះ ក្នុងការកាត់បន្ថយចំនួនរឿងក្តីដែលកំពង់តែរង់ចាំនូវការដោះស្រាយ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរាយការណ៍ថា ចាប់ពីឆ្នាំ ២០០៣ រហូតដល់ខែ មេសា ឆ្នាំ ២០១២ គណៈកម្មការសុរិយោដី បានដោះស្រាយទំនាស់ដីធ្លីមានផ្ទៃដីទំហំដី ៣.៦០៨ ហិកតា (ទាក់ទងនឹង ១០.៨៨១ គ្រួសារ) ហើយបានព្យាយាមដោះស្រាយករណីទំនាស់ដីធ្លីដ៏ច្រើនដែលទទួលជាយូរមកហើយ ដោយក្រុមចល័ត ដែលក្រុមនេះ បានដោះស្រាយរឿងក្តីចំនួន ៤.៦២៣ ករណី នៅក្នុងអំឡុងពេលនោះ។[២៥៣] ក្រសួងនេះ ក៏បានរាយការណ៍ថា ខ្លួនបានបើកវគ្គបណ្តុះបណ្តាលអំពី ច្បាប់ភូមិបាលឆ្នាំ ២០០១ និងនីតិវិធីសម្រាប់ដោះស្រាយទំនាស់ដីធ្លី និងការសម្រុះសម្រួល ដល់មន្ត្រីសុរិយោដី និងមន្ត្រីឃុំ/សង្កាត់ និងដៃគូមកពីអង្គការសង្គមស៊ីវិល។ ទោះជាយ៉ាងណាក៏ដោយ ក៏គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីនៅលើតំបន់សម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ និងដីរដ្ឋ កំពុងតែជៀសវាងការវាស់វែងដីធ្លី ដែលមានទំនាស់ អាស្រ័យហេតុនេះវាមិនអាចដោះស្រាយចំណុចសំខាន់នៃបញ្ហានោះទេ។ ទោះបីជាគ្មានក្បាលដីណាមួយអាចត្រូវបានចុះបញ្ជី ប្រសិនបើដីនោះមានការតវ៉ាទាក់ទងនឹងម្ចាស់កម្មសិទ្ធ នោះការជៀសវាងទីកន្លែងមានបញ្ហាទាំងនេះ មានន័យថា ទំនាស់ដីធ្លីនៅតែមានបន្ត ហើយភាគីទន់ខ្សោយជាង ត្រូវចាញ់ជានិច្ច។

១៧៩. ប្រទេសកម្ពុជា មិនមានស្ថាប័នសិទ្ធិមនុស្សឯករាជ្យនៅថ្នាក់ជាតិទេ ទោះបីជាមានគណៈកម្មាធិការអន្តរក្រសួងមួយ ដែលទទួលបន្ទុកសម្របសម្រួលសកម្មភាពសិទ្ធិមនុស្សសម្រាប់រដ្ឋាភិបាលក្តី ពោលគឺគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ អាណត្តិរបស់គណៈកម្មាធិការនេះ ក្នុងការពិនិត្យតាមដាន និងស៊ើបអង្កេតបណ្តឹងជាលក្ខណៈបុគ្គល និងបណ្តឹងជាក្រុម ដែលទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស រួមទាំង ការរំលោភសិទ្ធិមនុស្សទាក់ទងនឹងសម្បទានដីផង នៅកំពុងរង់ចាំការសម្រេចនៅឡើយ។[២៥៤] សមត្ថភាពរបស់គណៈកម្មាធិការនេះ នៅមានកម្រិត ហើយនៅពេលដែលគណៈ

[២៥២] របាយការណ៍របស់ FIDH ផ្នែក ៥.៤.៤។

[២៥៣] លិខិតពីឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ញើជូន លោក សុរិយា ស៊ូប៊ែឌី នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២។

[២៥៤] អនុក្រឹត្យ កំណត់ពីអាណត្តិរបស់គណកម្មាធិការនេះ ស្ថិតនៅក្នុងការរង់ចាំនៅឡើយ ហើយនាពេលបច្ចុប្បន្ននេះ ភាគច្រើននៃសកម្មភាពរបស់គណៈកម្មាធិការនេះ គឺលើការកសាងសមត្ថភាពខាងវិស័យសិទ្ធិមនុស្សទូទៅនៅថ្នាក់ខេត្ត។

កម្មាធិការនេះ ត្រួតពិនិត្យលើរឿងក្តី ជាញឹកញាប់គឺ មិនធ្វើការស៊ើបអង្កេតរឿងក្តីទំនាស់ដីធ្លីដល់កន្លែងកើតហេតុទេ ។ ការវិភាគរឿងក្តីដល់ទីកន្លែងកើតហេតុ លើករណីទំនាស់ដីធ្លី ដោយធ្វើការសហការជាមួយអាជ្ញាធររដ្ឋាភិបាល និង

អង្គការផ្តល់ជំនួយផ្នែកច្បាប់ ត្រូវបានកំណត់ជាផ្នែកមួយនៃគោលដៅនៃការអភិវឌ្ឍជាបន្ត ។[២៥៥]

១៨០. ជាជម្រើសផ្សេង អ្នកប្តឹងតវ៉ា ជារឿយៗ ស្វែងរកជំនួយពីបុគ្គល ឧទាហរណ៍ បុគ្គលជាអាជ្ញាធរមូលដ្ឋាន និង អាជ្ញាធរខេត្ត (ដូចជា មេឃុំ និងអភិបាលស្រុក) ឧកញ៉ា (ឬ អ្នកជំនួញ) និងអ្នកមានអំណាច និងអាជ្ញាធរជាតិ ដែលត្រូវបានគេចាត់ទុកថា ជាអ្នកមានឥទ្ធិពល។ ជាញឹកញាប់ សហគមន៍តែងតែបានធ្វើការសុំអង្វរករជាសាធារណៈចំពោះព្រះមហាក្សត្រ និងនាយករដ្ឋមន្ត្រី និង ភរិយារបស់លោក ឲ្យជួយដោះស្រាយទំនាស់របស់ពួកគេ ក្នុងនោះរួមមាន ការដាក់ជូននូវញ្ញត្តិនានា និងការធ្វើបាតុកម្មនៅខាងមុខព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី និងលំនៅដ្ឋានឯកជនរបស់នាយកដ្ឋមន្ត្រី។ បន្ទាប់ពីប្រើអស់វិធីសាស្ត្រផ្សេងៗ ដោយគ្មានទទួលនូវការឆ្លើយតប ឬ មានការឆ្លើយតបដែរមិនគួរជាទីពេញចិត្ត ក៏មាននូវនិន្នាការនៃការចូលរួមក្នុងពិធីបែបប្រពៃណី និងការធ្វើពិធីបន់ស្រន់។ ប្រជាជនជាច្រើនដែលរងការប៉ះពាល់ ក៏បានដាក់ជូនខ្ញុំនូវ លិខិត ឬ ញត្តិជាឯកជន និងជាក្រុម ឬ មកជួបខ្ញុំផ្ទាល់ នៅអំឡុងពេលដែលខ្ញុំមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសនេះ ដោយសុំឲ្យខ្ញុំជួយធ្វើអន្តរាគមន៍។

## ខ. ការប្រើប្រាស់ប្រព័ន្ធតុលាការ និងការចោទប្រកាន់បទព្រហ្មទណ្ឌចំពោះ បុគ្គលដែលប្តឹងតវ៉ាទាមទារដីរបស់ខ្លួន និងសកម្មជនខាងដីធ្លី

១៨១. ប្រព័ន្ធតុលាការ គឺជាប្រធានបទនៃរបាយការណ៍ឆ្នាំ ២០១០ របស់ខ្ញុំ ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ហើយខ្ញុំបានបញ្ជាក់អំពីបញ្ហាប្រឈមចម្បងៗមួយចំនួន ទាក់ទងនឹងឯករាជ្យភាពរបស់តុលាការ និង កង្វះសមត្ថភាពក្នុងការដោះស្រាយចំពោះបន្ទុករឿងក្តី ជាពិសេស ចំពោះទំនាស់ដីធ្លី។ ខ្ញុំបានកត់សំគាល់ឃើញថា ទោះបីជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ផ្តល់ឲ្យមាននូវការបែងចែកអំណាចដាច់ពីគ្នារវាងស្ថាប័នសំខាន់ៗទាំងបីរបស់រដ្ឋ ប៉ុន្តែជាក់ស្តែង ការបែងចែកអំណាចរវាងស្ថាប័នទាំងនេះ មានភាពស្រពិចស្រពិល ហើយស្ថាប័នអង្គនីតិប្រតិបត្តិ គ្របសង្កត់លើស្ថាប័នតុលាការ មិនត្រឹមតែតាមរយៈការផ្តល់ធនធានដល់តុលាការ ឬ ការតែងតាំងនូវមុខតំណែងនានាតាមតុលាការនោះទេ តែក៏តាមមធ្យោបាយផ្សេងៗទៀតផងដែរ។[២៥៦] កត្តានេះនៅតែ ជាបញ្ហាប្រឈមជាចម្បងសម្រាប់ប្រទេសនេះក្នុងការអនុវត្តនីតិរដ្ឋ និង ការលើកកម្ពស់ និង ការការពារសិទ្ធិរបស់ប្រជាជន។ ដោយសារតែផលប្រយោជន៍ដែលរដ្ឋាភិបាលទទួលបាន ទាក់ទងនឹងការផ្តល់ និងការគ្រប់គ្រងសម្បទានដី សេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត តុលាការត្រូវរងនូវរាំងរាំងជាពិសេសពីការកាត់សេចក្តីលើករណីទំនាស់ដីធ្លី។ លើសពីនេះទៀត នៅពេលដែលប្រឈមមុខទល់នឹង បុគ្គល ឬ ក្រុមហ៊ុនមានអំណាចដែលកាន់កាប់ដីសហគមន៍ របាយការណ៍អំពីអារម្មណ៍ដែលត្រូវបានប្រព័ន្ធនេះផាត់ពួកគេចេញ ដោយសារតែមានការស៊ីសំណូក និងការជ្រៀតជ្រែកផ្នែកនយោបាយ ហើយដែលការណ៍នេះបណ្តាលឲ្យសហគមន៍បាត់បង់ជំនឿទាំងស្រុងលើប្រព័ន្ធនេះ។

១៨២. ប្រព័ន្ធតុលាការ ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង ដើម្បីចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើបុគ្គល និង សហគមន៍ ដែលអនុវត្តសិទ្ធិរបស់ខ្លួន ដើម្បីប្តឹងតវ៉ាទាមទារដីរបស់ខ្លួនមកវិញ។ អ្នកការពារសិទ្ធិមនុស្ស ត្រូវបានកំណត់

---

[២៥៥] ចូរកត់សំគាល់ថា នៅក្នុងជំនួបប្រជុំមួយនាខែមិថុនា ឆ្នាំ២០១២ លោកប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានស្នើសុំបង្កើតឲ្យមានក្រុមការងារពិសេសក្រៅផ្លូវការមួយ ដើម្បីពិនិត្យករណីទំនាស់ដីធ្លីមួយចំនួនដែលនៅមិនទាន់ដោះស្រាយ សូមមើល A/HRC/15/46, កថាខ័ណ្ឌ ៣២។

[២៥៦] របាយការណ៍តំណាងពិសេសស្តីពី ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា A/HRC/15/46 ខែកញ្ញា ឆ្នាំ២០១០ កថាខ័ណ្ឌទី ៤១។

ជាគោលដៅស្រដៀងគ្នានេះផងដែរ ដែលវាគឺជាការរំលោភលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំគ្នា។ ក្នុងករណីមួយចំនួន ការចោទប្រកាន់បទព្រហ្មទណ្ឌ ត្រូវបានធ្វើឡើងចំពោះសមាជិកសហគមន៍ និងបុគ្គលផ្សេងទៀត ដែលត្រូវបានគេសង្ស័យថា ជាប់ពាក់ព័ន្ធនឹងការប្ដឹងតវ៉ាប្រឆាំងនឹងសម្បទានដី។ អង្គការអាដហុក ដែលជាអង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍អំពីរឿងក្ដីប្រឆាំងនឹងសហគមន៍ចំនួន ៤២៧ ករណី នៅឆ្នាំ ២០១១ ជាករណីពាក់ព័ន្ធនឹងជម្លោះដីធ្លី ដែលមានការកើនឡើងខ្ពស់ជាងឆ្នាំ ២០១០ ដែលមានរឿងក្ដីចំនួនតែ ៣១៩ ប៉ុណ្ណោះ។ ក្នុងចំណោមបុគ្គលទាំងនេះ មានអ្នកការពារសិទ្ធិមនុស្ស ឬ សកម្មជនការពារសិទ្ធិមនុស្ស តំណាងរាស្ត្រ អ្នកសារព័ត៌មាន មេធាវី សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងអនុប្រធានភូមិ។[២៥៧] នៅក្នុងរបាយការណ៍ប្រចាំឆ្នាំជាសាធារណៈរបស់ខ្លួន ទាក់ទងនឹងសកម្មភាពពីខែ មិថុនា ឆ្នាំ ២០១១ ដល់ខែ មិថុនា ឆ្នាំ ២០១២ ការិយាល័យ OHCHR បានកត់សំគាល់អំពីករណីទាក់ទងនឹងប្រជាជនចំនួន១៨២ នាក់ ដែលត្រូវបានចោទសួរដោយតុលាការ អំពីបណ្ដឹងទាមទារពាក់ព័ន្ធនឹងដីធ្លី (ករណីខ្លះ គឺជាបញ្ហាទំនាស់ដីធ្លីដែលកើតមានជាយូរណាស់មកហើយ) ហើយដែលពួកគេភាគច្រើន រងនូវការចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត រារាំងមន្ត្រីសាធារណៈដោយមានស្ថានទម្ងន់ទោស កាន់កាប់អចលនទ្រព្យ (ដី) ដែលជារបស់នីតិបុគ្គលសាធារណៈ (រដ្ឋ) ដោយខុសច្បាប់ បំផ្លាញទ្រព្យសម្បត្តិ និងទន្ទ្រានកាន់កាប់ដីព្រៃ។ ក្នុងករណីមួយចំនួន បទចោទប្រកាន់នេះ នៅបង្អង់ទុកក្នុងតុលាការ ហើយសំណុំរឿងនឹងត្រូវដាក់ឲ្យដំណើរការឡើងវិញ នៅគ្រប់ពេលវេលាបាន ខណៈដែលអ្នកផ្សេងទៀតត្រូវបានជាប់ឃុំឃាំង។[២៥៨]

១៨៣. ឧទាហរណ៍៖ ក្នុងអំឡុងពេលនៃការបំពេញទស្សនកិច្ចរបស់ខ្ញុំកាលពីខែ ឧសភា ឆ្នាំ ២០១២ ទៅកាន់ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ខ្ញុំបានទទួលព័ត៌មានថា សមាជិកសហគមន៍ចំនួនបួន (៤) នាក់ ដែលរងការប៉ះពាល់ពីសម្បទានដីរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ចំការកៅស៊ូ ដូវទៀងកម្ពុជា (Dau Thieng (Cambodia) Rubber Development Company) និងក្រុមហ៊ុនអភិវឌ្ឍន៍ចំការកៅស៊ូ ដូវទៀងក្រចេះ (Dau Thieng (Kratie) Rubber Development Company) ត្រូវបានកោះហៅឲ្យចូលខ្លួនទៅកាន់តុលាការខេត្តក្រចេះ កាលពីខែ កញ្ញា ឆ្នាំ ២០១១។ ពួកគេត្រូវបានកោះហៅ ដើម្បីទៅសាកសួរទាក់ទងទៅនឹងករណីនៃការបំផ្លិចបំផ្លាញដោយចេតនាដែលប្រព្រឹត្តឡើងកាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ជាកាលបរិច្ឆេទដែលសមាជិកសហគមន៍ បានបិទផ្លូវថ្នល់ ដើម្បីធ្វើការតវ៉ាប្រឆាំងនឹងការឈូសឆាយដី ស្រែចំការរបស់ពួកគេ។[២៥៩]

១៨៤. ទាក់ទងនឹងទំនាស់ដីធ្លីរ៉ាំរ៉ៃ រវាង សហគមន៍បឹងកក់ និងក្រុមហ៊ុនស៊ូកាគូអ៊ីន សាលាដំបូងរាជធានីភ្នំពេញ នៅក្នុងអំឡុងពេលសវនាការរយៈពេលបីម៉ោងកន្លះ នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២ បានរកឃើញថា ស្ត្រីចំនួន ១៣ នាក់ មកពីសហគមន៍បឹងកក់ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ នៅពេលប្រមូលផ្ដុំគ្នាដោយសន្តិវិធី មានពិរុទ្ធភាពទាក់ទងនឹងការរារាំងមន្ត្រីសាធារណៈដោយមានស្ថានទម្ងន់ទោស និងការកាន់កាប់ដោយខុសច្បាប់នូវអចលនទ្រព្យរបស់នីតិបុគ្គលសាធារណៈ។[២៦០] ពួកគេ ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរ (២)

---

[២៥៧] អង្គការអាដហុក(ADHOC)៖ *របាយការណ៍ស្ដីពី សិទ្ធិដីធ្លី និងលំនៅដ្ឋាន ឆ្នាំ២០១១* សេចក្ដីសង្ខេប ខែមីនា ឆ្នាំ ២០១២។

[២៥៨] របាយការណ៍ប្រចាំឆ្នាំរបស់ការិយាល័យ OHCHR ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅខែកញ្ញា ឆ្នាំ២០១២ កម្មវិធីសិទ្ធិដីធ្លី និងលំនៅដ្ឋាន។ របាយការណ៍ទាំងនោះមាននៅលើគេហទំព័រ http://cambodia.ohchr.org/EN/PagesFiles/Reports/SG-RA-Reports.htm.

[២៥៩] ក្រុមហ៊ុន ដូវទៀងកម្ពុជា (Dau Thieng (Cambodia) Rubber Development Co., Ltd) បានទទួលសម្បទានដីទំហំ ៧.៩៧២ ហិកតា និង ក្រុមហ៊ុន ដូវទៀងក្រចេះ (Dau Thieng (Kratie) Rubber Development Co., Ltd.) បានទទួលដីសម្បទានទំហំ ៦.៥៩២ ហិកតា។ សម្បទានដីសេដ្ឋកិច្ចទាំងនេះ បានផ្ដល់សម្រាប់គោលដៅវិនិយោគលើដំណាំកៅស៊ូ ហើយដីទាំងនេះត្រូវបានកំណត់ជាដីឯកជនរបស់រដ្ឋ តាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១០។

[២៦០] ក្រោមមាត្រា ៥០៤ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៤ និងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ឆ្នាំ២០០១។ មានសកម្មជនពីរនាក់ ត្រូវបានចាប់ខ្លួនក្នុងវិវាទដីធ្លីនេះដែរ។

ឆ្នាំកន្លះ ដែលក្រោយមក គឺនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ ត្រូវបានសាលាឧទ្ធរណ៍កាត់សេចក្តីដោយបន្ថយមកនៅត្រឹមមួយខែ និងបីថ្ងៃវិញ (ពោលគឺជារយៈពេល ដែលពួកគេបានជាប់ឃុំឃាំងរួចហើយ)។

## គ. បរិយាកាសសម្រាប់សង្គមស៊ីវិល និងសកម្មភាពរបស់សហគមន៍

១៨៥. ដោយហេតុថា ការអនុវត្តមិនបានត្រឹមត្រូវ នូវក្របខ័ណ្ឌច្បាប់ល្អៗដែលគ្រប់គ្រងលើសិទ្ធិដីធ្លី ការជ្រៀតជ្រែកផ្នែកនយោបាយ និងលទ្ធភាពមិនពេញលេញក្នុងការទទួលបានដំណោះស្រាយ សហគមន៍មានអារម្មណ៍ខឹងសម្បារ និងស្រងាកចិត្តកាន់តែខ្លាំងឡើងៗ ចំពោះដំណើរការនីតិវិធីតុលាការ និងរដ្ឋបាល។ ការធ្វើបាតុកម្ម និង ការតវ៉ារបស់សហគមន៍ដែលទទួលរងការប៉ះពាល់ នៅរាជធានី និងបណ្តាខេត្តផ្សេងៗ កំពុងតែមានការកើនឡើង និងមានអំពើហិង្សាកាន់តែច្រើនឡើង។ សហគមន៍ដែលរងការប៉ះពាល់ពីសម្បទានដី បានបញ្ចេញយោបល់តតសំចៃកាន់តែច្រើនឡើងៗទាក់ទងនឹងការប្តឹងតវ៉ារបស់ពួកគេ បានដាក់ញត្តិ និងបានស្វែងរកដំណោះស្រាយតាមផ្លូវតុលាការ នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ មានការរៀបចំបាតុកម្មនៅតាមខេត្ត/ក្រុង និងរាជធានីភ្នំពេញ មានការបិទផ្លូវជាតិ និងពេលខ្លះមានការចូលរួមពាក់ព័ន្ធនឹងអំពើហិង្សា។ ឧទាហរណ៍ ដោយសារតែ ដីសម្បទានមានចំនួនច្រើនឡើងៗត្រូវបានផ្តល់ឲ្យក្រុមហ៊ុននៅក្នុងស្រុកស្នួល ខេត្តក្រចេះ នោះនាំមកនូវការតវ៉ាជាបន្តតតដាច់ ជាពិសេស នៅតាមដងផ្លូវជាតិលេខ ៧៦អា។[២៦១] មានការតវ៉ាមួយចំនួនផងដែរ ពាក់ព័ន្ធនឹងចំការអំពៅនៅក្នុងខេត្តកោះកុង។

១៨៦. កាលពីឆ្នាំមុន ហាក់ដូចជាមានកំណើនសហគមន៍ជនជាតិដើមភាគតិច គេណ្តាប់មកធ្វើបាតុកម្មប្រឆាំងនឹងសកម្មភាពរបស់ធុរកិច្ច។ ឧទាហរណ៍៖ ចលនាបណ្តាញព្រៃឡង់ បាននិងកំពុងតែធ្វើយុទ្ធនាការ ដើម្បីការពារព្រៃឈើដែលមាននៅសេសសល់ ដែលវាជាប្រភពស្បៀងអាហារសម្រាប់អ្នកស្រុករាប់ពាន់នាក់រស់នៅក្នុងបណ្តាខេត្តមួយចំនួន (ដូចជា ខេត្តព្រះវិហារ កំពង់ធំ ក្រចេះ និងស្ទឹងត្រែង)។ ការខិតខំប្រឹងប្រែងរបស់ពួកគេ រួមមាន ការល្បាតព្រៃ ដោយសមាជិកសហគមន៍ ការធ្វើដំណើរដោយថ្មើរជើង ឬ ម៉ូតូ កាត់តំបន់ព្រៃដ៏ដាច់ស្រយាលធំល្វឹងល្វើយ ដើម្បីរកមើល និងទប់ស្កាត់សកម្មភាពកាប់ឈើខុសច្បាប់ជាបន្តទៀត។ ពួកគេ ក៏ចូលពាក់ព័ន្ធនៅក្នុងការលើកកម្ពស់ការយល់ដឹង នៅរាជធានីភ្នំពេញ និងនៅខេត្តសៀមរាប រួមទាំង ការរៀបចំការដើរដង្ហែក្បួនដោយសន្តិភាព ពិធីបួងសួង (ឧទាហរណ៍៖ នៅព្រះអង្គដងកើ ទល់មុខព្រះបរមរាជវាំង) ការធ្វើបាតុកម្ម និងការចែកខិត្តប័ណ្ណនានា ដើម្បីលើក កម្ពស់ការយល់ដឹងអំពីការគម្រាមកំហែងចំពោះធនធានធម្មជាតិព្រៃឈើ និងរបបចិញ្ចឹមជីវិតរបស់សហគមន៍។ ឧទាហរណ៍មួយទៀត នៅខែកុម្ភៈ ឆ្នាំ ២០១២ សហគមន៍ជនជាតិដើមភាគតិចទំពួន នៅក្នុងដែនជំរកសត្វព្រៃលំផាត់ បានចាប់អ្នកបម្រើការក្រុមហ៊ុនធ្វើជាចំណាប់ខ្មាំងអស់រយៈពេលបួនប្រាំម៉ោង ជាការតវ៉ាប្រឆាំងនឹងការឈូសឆាយ ដីស្រែចំការរបស់ពួកគេ (សូមមើលឧបសម្ព័ន្ធទី IV)។

១៨៧. ក្នុងករណីខ្លះ ការឆ្លើយតបរបស់អាជ្ញាធរ គឺជាការចាត់វិធានការបង្ក្រាបទៅលើបាតុកម្មដោយសន្តិវិធី ភាពសកម្មរបស់សហគមន៍ និងបង្ក្រាបលើកិច្ចផ្តួចផ្តើមខាងការអប់រំរបស់សង្គមស៊ីវិល។ បន្ថែមពីនេះ ក្រៅពីការរារាំង បង្អាក់ដល់ការប្រមូលផ្តុំដោយអហិង្សា ការធ្វើបាតុកម្ម ការរៀបចំពិធី និងការលើកកម្ពស់ការយល់ដឹង និងសកម្មភាពផ្សព្វផ្សាយផ្សេងទៀត ដែលវាជាការរំលោភលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំ ហើយអ្វីដែលជានិន្នាការដ៏គួររំខានចិត្តមួយទៀតនោះ គឺការរំខាន និងការបិទសិក្ខាសាលារបស់សង្គមស៊ីវិល និងកិច្ចប្រជុំរបស់សហគមន៍ ដែល

[២៦១] ព័ត៌មានជ្រើសសម្រាំងមួយចំនួន ទាក់ទងនឹងការតវ៉ាក្នុងបញ្ហាទំនាស់ដីធ្លី នៅស្រុកស្នួល ដែលអាចរកបានលើគេហទំព័រ៖ http://www.opendevelopmentcambodia.net/tag/snuol-district/.

ពេលខ្លះ ដោយមានការគម្រាមប្រើអំពើហិង្សាផង។[២៦២] ជាញឹកញាប់ កិច្ចប្រជុំ និងសិក្ខាសាលាទាំងនេះ គឺជាការអប់រំដែលត្រូវការចាំបាច់ជាខ្លាំង ស្តីពីក្របខ័ណ្ឌច្បាប់ក្នុងស្រុករបស់កម្ពុជាដែលគ្រប់គ្រងលើសិទ្ធិដីធ្លី និងព័ត៌មានស្តីពីរបៀបដាក់ពាក្យទាមទារតាមផ្លូវច្បាប់សុំប័ណ្ណកម្មសិទ្ធិដីធ្លី។ ជារឿយៗ ពួកគេចូលរួមពាក់ព័ន្ធនឹងការសហការ ជាមួយនឹងអាជ្ញាធរថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត និងបំពេញគំលាតនៃការកសាងសមត្ថភាព ដែលរដ្ឋាភិបាលមិនបានផ្តល់ជូន។ ម្យ៉ាងវិញទៀត រដ្ឋាភិបាល បានណែនាំដល់អង្គការមិនមែនរដ្ឋាភិបាល មិនឲ្យចូលពាក់ព័ន្ធនៅក្នុងការអនុវត្តគម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី លើសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ និងដីរដ្ឋនោះទេ។ មានសេចក្តីរាយការណ៍យ៉ាងទូលំទូលាយអំពី ការបំភិតបំភ័យ និងការគម្រាមកំហែងដល់បុគ្គលដែលពាក់ព័ន្ធ។ អវត្តមានរបស់អង្គការសង្គមស៊ីវិល បានទុកឲ្យសហគមន៍ គ្រួសារ និងបុគ្គលជាច្រើន មិនបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ជាពិសេស ប្រសិនបើពួកគេពាក់ព័ន្ធក្នុងទំនាស់ដីធ្លីដែលកំពុងតែកើតមានឡើង ឬ បានដាក់ពាក្យបណ្តឹងពាក់ព័ន្ធតាមយន្តការតុលាការ ឬ រដ្ឋបាលពីមុនមក។

## ឃ. យន្តការដោះស្រាយវិវាទកម្រិតប្រតិបត្តិការ

១៨៨. ការកើនឡើងនូវការបង្ហាញពីភាពទោមនស្សនៅជុំវិញប្រទេស ទាក់ទងនឹងទំនាស់ដីធ្លី សបញ្ជាក់ឲ្យឃើញពីភាពខ្វះខាតនៃការពិគ្រោះយោបល់ និងការចរចារជាមួយនឹងអ្នកដែលទទួលរងការប៉ះពាល់។ ជាការពិតណាស់ថា ការពិគ្រោះយោបល់ជាមួយ និង ការដាក់បញ្ចូលអ្នកដែលនឹងរងផលប៉ះពាល់តាំងពីដំណាក់កាលដំបូងៗ អាចដោះស្រាយភាពតានតឹងនានា មុនពេលដែលវារីករាលដាល និងអាចចូលរួមចំណែកបង្ការ-ទប់ស្កាត់ទំនាស់។ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស លើកកម្ពស់ការប្រើប្រាស់យន្តការដោះស្រាយវិវាទ "កម្រិតប្រតិបត្តិការ" ដើម្បីសម្របសម្រួលដល់ការដោះស្រាយវិវាទឲ្យបានទាន់ពេលវេលា និងដោយផ្ទាល់។[២៦៣] យន្តការបែបនេះជាធម្មតា ត្រូវបានគ្រប់គ្រងដោយសហគ្រាសពាណិជ្ជកម្មតែឯង ឬ ដោយមានការសហការ ជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល។ យន្តការនេះ គួរតែផ្តល់ឲ្យបុគ្គល និងសហគមន៍ ដែលអាចទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីសកម្មភាពធុរកិច្ច នូវលទ្ធភាពទៅប្រើប្រាស់វាបាន និងគួរធ្វើឲ្យមានការជឿទុកចិត្ត ពីក្រុមអ្នកពាក់ព័ន្ធដែលយន្តការនេះមានគោលបំណងឲ្យពួកគេប្រើប្រាស់។[២៦៤] ការយកចិត្តទុកដាក់ជាពិសេស គួរតែត្រូវបានធ្វើឡើង ដើម្បីដោះស្រាយឧបសគ្គខាងភាសាទំនាក់ទំនង (ជាពិសេស ជាមួយនឹងវិសាលភាពនៃក្រុមហ៊ុនសម្បទានដី ដែលគ្រប់គ្រងដោយបរទេស និងដោយពិចារណាលើទម្លាប់ដែលជនជាតិដើមភាគតិចមួយចំនួន មិនប្រាស្រ័យទាក់ទងគ្នាដោយប្រើប្រាស់ភាសាខ្មែរទេ)។

១៨៩. ក្រុមហ៊ុនសម្បទានដីខ្លះ បានកំណត់នីតិវិធីដោះស្រាយទំនាស់ និងបណ្តឹងនៅថ្នាក់មូលដ្ឋាន ដែលអាចជា វិធីមួយប្រកបដោយប្រសិទ្ធភាព សម្រាប់ស្រាយបំភ្លឺការយល់ខុស និងព័ត៌មានមិនត្រឹមត្រូវ និងដោះស្រាយភាពតានតឹងមុនពេលដែលវារីករាលដាលខ្លាំងឡើង។ ឧទាហរណ៍ៈ ក្រុមហ៊ុន ហ្គ្រេនឌីស ធីមបឺ (Grandis Timber) រាយការណ៍ថា

---

[២៦២] ឧទាហរណ៍ថ្មីៗទាក់ទងនឹងកិច្ចប្រជុំដែលរៀបចំឡើងដោយអង្គការអាដហុក(ADHOC) និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) សូមមើលអត្ថបទដែលមានចំណងជើងថា "នគរបាលបង្រ្កាបការប្រជុំរបស់សកម្មជនសិទ្ធិដីធ្លី" ដោយ គុច ណារ៉ែន នៃកាសែតឌឹខែមបូឌាដេលី ថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០១២។

[២៦៣] សូមមើលគោលការណ៍ណែនាំលេខ ៣១ សម្រាប់បញ្ជីនៃលក្ខខណ្ឌអំពីប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ យោងគោលការណ៍លេខ ២១ ដើម្បីធានាឲ្យមានប្រសិទ្ធភាព យន្តការដោះស្រាយវិវាទកម្រិតប្រតិបត្តិការនានា គួរតែស្របច្បាប់ អាចទៅប្រើប្រាស់បាន អាចប្រមើលមើលបាន សមធម៌ តម្លាភាព ស្របនឹងសិទ្ធិដទៃទៀត ជាប្រភពនៃការសិក្សាស្រាវជ្រាវជាបន្ត និងដោយផ្អែកលើការចូលរួម និងការសន្ទនា។

[២៦៤] គោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច ទំព័រ ២៨-៣១ ។

បានធ្វើផែនទីផ្ទៃដីដែលកាន់កាប់ដោយសហគមន៍ តាំងតែពីពេលចាប់ផ្តើមសកម្មភាពសម្បទានដី ព្រមទាំងបានជ្រើសរើសបុគ្គលិកឲ្យធ្វើជាអ្នកគ្រប់គ្រងខាងទំនាក់ទំនងសហគមន៍ ដើម្បីដោះស្រាយទំនាស់ដីធ្លី និងទំនាស់ផ្នែកការងារ។[២៦៥] ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានភាពយឺតយ៉ាវក្នុងការរៀបចំវិធានការសម្រាប់ដោះស្រាយទំនាស់នេះ វិធានការនេះអាចនឹងបាត់បង់ប្រសិទ្ធភាពរបស់វា ជាពិសេសខណៈ ដែលការមិនទុកចិត្តបានកើតឡើងជាមុនរួចទៅហើយ។ ឧទាហរណ៍ៈ គណៈកម្មាធិការត្រីភាគី ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០០៩ ដោយ ក្រុមហ៊ុន សូហ្វីន ខេស៊ីឌី (Socfin-KCD) នៅក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគីរី។ កិច្ចផ្តួចផ្តើមដែលជាគោលការណ៍ គឺត្រូវទទួលបាននូវការស្វាគមន៍នោះ ត្រូវបានគេរិះគន់ទៅវិញថា យន្តការប្រាស្រ័យទាក់ទងគ្មានប្រសិទ្ធភាព ក្នុងការដោះស្រាយទំនាស់ដែលបានកើតមានឡើងជាយូរមកហើយ ហើយខណៈដែលភាពតានតឹងបានរីករាលដាលខ្លាំងរួចហើយនោះ។[២៦៦]

១៩០. លើសពីនេះទៀត ការខិតខំប្រឹងប្រែងដើម្បីសន្ទនាគ្នានៅថ្នាក់មូលដ្ឋាន ដែលមិនមានការចូលរួមដោយផ្ទាល់ពីតំណាងក្រុមហ៊ុន អាចរារាំងមិនឲ្យទទួលបានជោគជ័យដែលទំនងនឹងទទួលបាននោះ។ ក្រុមហ៊ុនបរទេសមួយចំនួនបានរាយការណ៍អំពី ការពឹងពាក់ទៅលើអាជ្ញាធរមូលដ្ឋាន ដោយជាញឹកញាប់ មានវត្តមានរបស់កងកម្លាំងប្រដាប់អាវុធផង ដើម្បីសន្ទនាចរចារលើការដោះដូរ និងការតាំងទីលំនៅថ្មី។ វត្តមានរបស់កងកម្លាំងប្រដាប់អាវុធ អំឡុងពេលចរចារ អាចជាការបំភិតបំភ័យចំពោះសហគមន៍ ហើយការជម្រិតយកប្រាក់ពីសំណាក់អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធក៏ត្រូវបានគេរាយការណ៍ផងដែរ។ ការចាត់ចែងមានលក្ខណៈទន់ខ្សោយលើកិច្ចចរចារ អាចនាំឲ្យមានការមិនទុកចិត្តពីសំណាក់សហគមន៍ ដែលមើលឃើញក្រុមហ៊ុនបរទេស ថាជាក្រុមហ៊ុនប្រកបដោយការកេងប្រវ័ញ្ច និងមិនមានឆន្ទៈក្នុងប្រាស្រ័យទាក់ទងគ្នាដោះស្រាយបញ្ហាឡើយ ឧទាហរណ៍ៈ ក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប នៅក្នុងខេត្តកោះកុង ជាដើម ។

## ង. ភាពមាន និងលទ្ធភាពទៅប្រើប្រាស់ យន្តការដោះស្រាយវិវាទកម្រិតអន្តរជាតិ

១៩១. ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានករណីប្តឹងតវ៉ាមួយចំនួន ដែលដឹកនាំធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងនាមសហគមន៍ជាមួយនឹងយន្តការដោះស្រាយវិវាទរបស់រដ្ឋជាលក្ខណៈអន្តរជាតិ រួមទាំងស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងយន្តការនីតិវិធីពិសេសនៃអង្គការសហប្រជាជាតិ។[២៦៧] មិនមានយន្តការដោះស្រាយវិវាទថ្នាក់តំបន់សម្រាប់ដោះស្រាយបណ្តឹងសិទ្ធិមនុស្ស ជាលក្ខណៈបុគ្គល ឬ ជាក្រុម ដែលជាផ្នែកមួយនៃអាស៊ានទេ ដោយសារគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (ASEAN Inter-governmental Commission on Human Rights)

[២៦៥] ក្រុមហ៊ុន ហ្គ្រេនឌីស ធីមបឺ (Grandis Timber) *សៀវភៅណែនាំនៃបទវិន័យនានាសម្រាប់ការបង្កើតចំការ*, "ការចុះបញ្ជីអ្នករស់នៅអចិន្ត្រៃយ៍ និងការកំណត់ផែនទីដីធ្លីដែលបានកាន់កាប់" ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩។

[២៦៦] របាយការណ៍របស់ FIDH ចំណុច ៥.៦ ។

[២៦៧] ចំពោះបញ្ជីនៃស្ថានភាពនៃការធ្វើរបាយការណ៍របស់ប្រទេសកម្ពុជា ជូនស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ សូមមើល OHCHR ស្ថាប័នសន្ធិសញ្ញា "ស្ថានភាពនៃការធ្វើរបាយការណ៍ដាក់ជូនស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស" មាននៅគេហទំព័រ៖ http://www.ohchr.org/EN/HRBodies/Pages/HumanRightsBodies.aspx.។ ការដាក់បណ្តឹងជាបុគ្គល ឬជាក្រុម ទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស គឺជាការសំងាត់។ បណ្តឹងជាបុគ្គល ឬ ជាក្រុម ទៅជូនទៅយន្តការនិតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ត្រូវបានដាក់ឲ្យសាធារណៈជនអាចរកបាន នៅក្នុងរបាយកាណ៍ប្រាស្រ័យទាក់ទងប្រចាំឆ្នាំ បើសិនជា អ្នកជំនាញការឯករាជ្យ/អ្នករាយការណ៍ពិសេស បានធ្វើកិច្ចអន្តរាគមន៍ជាលាយលក្ខអក្សរ។ ឧទាហរណ៍ មានលិខិតឆ្លើយឆ្លងជាលាយលក្ខអក្សរ ហើយដែលមានជាសាធារណៈ ទាក់ទងនឹងជនជាតិដើមភាគតិចរស់នៅ ក្នុងតំបន់ព្រៃឡង់ និងលើបញ្ហាជំលោះនៅបឹងកក់ បុរីកីឡា ក្នុងចំនោមជំលោះផ្សេងៗទៀត។ សូមមើលគេហទំព័រ ៖ http://www.ohchr.org/EN/HRBodies/SP/Pages/Communications.aspx.

មិនមានអាណត្តិច្បាស់លាស់ ដើម្បីពិនិត្យលើបណ្តឹងជាលក្ខណៈបុគ្គល ទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស[២៦៨] ហើយវិធាននីតិវិធីរបស់គណៈកម្មការនេះទៀតសោតន៍ មិនត្រូវបានពង្រឹងលើទិដ្ឋភាពនេះទេ។

១៩២. អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នៅកម្ពុជា មានចំណេះដឹងនៅមានកម្រិតអំពីការទៅប្រើប្រាស់ និងការប្រាស្រ័យទាក់ទងជាមួយយន្តការទទួលបណ្តឹងដែលជានិតិវិធីពិនិត្យតាមដានឃ្លាំមើលសកម្មភាពធុរកិច្ចជាពិសេស។ នេះគឺជាផ្នែកមួយ ដែលតម្រូវឲ្យមានការអភិវឌ្ឍបន្ថែមទៀត។ បណ្តឹងដែលចោទប្រកាន់ទៅលើការអនុវត្តដោយខ្វះការទទួលខុសត្រូវរបស់ធុរកិច្ច អាចត្រូវធ្វើឡើងជាសាធារណៈទាក់ទងទៅនឹងក្រុមហ៊ុនប្រភេទណាក៏បាន នៅក្នុងប្រទេសណាក៏បាន។[២៦៩] ស្ថាប័នពហុភាគីមួយចំនួន (ដូចជា ធនាគារពិភពលោក គណៈកម្មការសហគមន៍អឺរ៉ុប សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍[២៧០]) មាននីតិវិធីដោះស្រាយវិវាទជាលក្ខណៈស្ថាប័ន សម្រាប់ករណីដែលពាក់ព័ន្ធនឹងគម្រោង ដែលស្ថិតនៅក្រោមមូលនិធិរបស់ស្ថាប័នទាំងនោះ ប៉ុន្តែជម្រើសមានកម្រិត។ ខណៈដែលអវត្តមានយន្តការជាផ្លូវការសម្រាប់ដោះស្រាយបណ្តឹងនៅក្នុងតំបន់[២៧១] សហគមន៍ព្យាយាម ចូលទៅរកការជួយអន្តរាគមន៍ពី បេសកកម្មការទូត និងអង្គការអន្តរជាតិនានា នៅរាជធានីភ្នំពេញ ដូចជា គណៈប្រតិភូនៃសហភាពអឺរ៉ុប និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក៏ដូចជា ស្ថានឯកអគ្គរដ្ឋទូត/ស្ថានឯកអគ្គរាជទូតបរទេស ដើម្បីដាក់ញត្តិ និងរៀបចំឲ្យមានជាក្បួនបាតុកម្មជាដើម។

១៩៣. យ៉ាងណាក៏ដោយ មានឧទាហរណ៍គួរឲ្យកត់សំគាល់ខ្លះ ទាក់ទងនឹងការតស៊ូមតិជាលក្ខណៈអន្តរជាតិ ដោយប្រើនីតិវិធីដែលមានជាផ្លូវការ។ បន្ទាប់ពីមានបណ្តឹងតវ៉ា នៅខែ សីហា ឆ្នាំ ២០០៩ ដែលត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការបណ្តេញចេញ (COHRE) ជំនួសមុខឲ្យប្រជាជនប្រមាណជា ៤.២៥០ គ្រួសារ ដែលប្រឈមមុខនឹងការបណ្តេញចេញដោយបំពានពីគេហដ្ឋានរបស់ពួកគេ នៅជុំវិញបឹងកក់ គណៈកម្មការអធិការកិច្ចនៃធនាគារពិភពលោក បានរកឃើញថា ធនាគារនេះ បានប្រព្រឹត្តល្មើសនឹងគោលនយោបាយប្រតិបត្តិរបស់ខ្លួន ដោយ

[២៦៨] គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) លក្ខខណ្ឌយោងសម្រាប់កិច្ចការងារ មាននៅគេហទំព័រ៖ http://www.asean.org/DOC-TOR-AHRB.pdf.

[២៦៩] ក្រុម ឬ បុគ្គល អាចដាក់ជូន ព័ត៌មានអំពីផលប៉ះពាល់សិទ្ធិមនុស្សពីសកម្មភាពរបស់ធុរកិច្ច (វិជ្ជមាន និង អវិជ្ជមាន) នៅទូទាំងលើពិភពលោក ទៅកាន់គេហទំព័រនៃមជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស ហើយការឆ្លើយតបរបស់ក្រុមហ៊ុន ក៏ត្រូវបានគេដាក់នៅលើគេហទំព័រនោះផងដែរ។ សូមមើលគេហទំព័រ៖ http://www.business-humanrights.org/Home។ ជាឧទាហរណ៍ ទាក់ទងនឹងអង្គការសង្គមស៊ីវិលដែលដឹកនាំ "ការធ្វើយុទ្ធនាការស្ករសស្អាតស្អំ" នៅខេត្តកោះកុង នោះមានការឆ្លើយតបពី ក្រុមហ៊ុន Mitr Phol និង Ve Wong ដែលអាចរកបានជាសាធារណៈតាមគេហទំព័រ៖ http://www.business-humanrights.org/Documents/CambodiaCleanSugar2012។ ចំពោះបញ្ជីនៃយន្តការសម្រាប់ដាក់ពាក្យបណ្តឹង សូមមើល BASES Wiki, ធុរកិច្ច និង សង្គម វិរះរកដំណោះស្រាយ, សហគមន៍ដោះស្រាយជំលោះ "យន្តការនានា" មាននៅគេហទំព័រ៖ http://baseswiki.org/en/Category: Mechanism.

[២៧០] នៅក្នុងឆ្នាំ២០០០ ក្នុងដំណើរការពិនិត្យឡើងវិញ នៃ ក្រុមប្រឹក្សាអង្គការ OECD រដ្ឋាភិបាលបានប្តេជ្ញាចិត្ត បង្កើតស្ថាប័នទំនាក់ទំនងថ្នាក់ជាតិ ដើម្បីលើកកំពស់គោលការណ៍ណែនាំរបស់ OECD ស្តីពី ក្រុមហ៊ុនសហគ្រាសពហុជាតិ ដើម្បី ដោះស្រាយចំពោះ ការចោទសួរ និងពាក្យបណ្តឹងផ្សេងៗ (ត្រូវបានស្គាល់ថា ជា "ជំហានពិសេស") ហើយអាចជាវេទិកាសម្រាប់ពិភាក្សាលើគ្រប់បញ្ហាទាំងអស់ ទាក់ទងនឹងគោលការណ៍ណែនាំទាំងនោះ។ រដ្ឋាភិបាល មានភាពបត់បែនក្នុងរៀបចំស្ថាប័នទំនាក់ទំនងថ្នាក់ជាតិរបស់ខ្លួន និងអំពីវិធីដែលស្ថាប័ននេះដំណើរការ។ មិនមានស្ថាប័នទំនាក់ទំនងថ្នាក់ជាតិប្រចាំកម្ពុជានៅឡើយទេ ប៉ុន្តែមានស្ថាប័នទំនាក់ទំនងថ្នាក់ជាតិសម្រាប់ប្រទេសផ្សេងៗ ដែលមានក្រុមហ៊ុនរបស់ខ្លួនមកធ្វើសកម្មភាពធុរកិច្ចនៅកម្ពុជា (ឧទាហរណ៍ ប្រទេសបារាំង សាធារណៈរដ្ឋកូរ៉េ អូស្ត្រាលី ប៊ែលស៊ិក កាណាដា ជប៉ុន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងបណ្តាប្រទេសដទៃទៀត)។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ៖ BASES Wiki, OECD national contact points general information, http://baseswiki.org/en/OECD_National_Contact_Points,_General_Information.

[២៧១] គួរកត់សំគាល់ថា ធនាគារអភិវឌ្ឍន៍អាស៊ី មាន យន្តការទទួលខុសត្រូវរបស់ខ្លួន ប៉ុន្តែយន្តការនេះ អនុវត្តបានតែចំពោះ បណ្តឹងទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាដីសម្បទាននៅកម្ពុជា ហើយដែលបណ្តឹងនោះពាក់ពន្ធ័នឹងគម្រោងជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីប៉ុណ្ណោះ។ យន្តការនេះមិនរាប់បញ្ចូលបណ្តឹងទាំងឡាយណា ដែលមិនទាក់ទងនឹងសកម្មភាព ឬកំហុសឆ្គងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឡើយ។

ខកខានមិនបានរៀបចំ និងត្រួតពិនិត្យមើលឲ្យបានត្រឹមត្រូវលើគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី នៅក្នុងប្រទេសកម្ពុជា (LMAP)។ គណៈកម្មការអធិការកិច្ចនេះ បានរកឃើញថា ការខកខានទាំងនេះ បានរួមចំណែកធ្វើឲ្យមានការបណ្ដេញចេញដោយបំពាននូវប្រជាជនរស់នៅក្នុងតំបន់បឹងកក់ ដែលពួកគេត្រូវបានបដិសេធសិទ្ធិចុះបញ្ជីកម្មសិទ្ធិដីធ្លីរបស់ខ្លួនដោយភាពអយុត្តិធម៌ តាមរយៈគម្រោង LMAP មុនពេលដែលរដ្ឋាភិបាល ជួលតំបន់នេះឲ្យទៅក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន ហើយដោយនៅទីបំផុត នាំទៅដល់ការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត និង ការបណ្ដេញចេញដោយបំពាន។[២៧២] បន្ទាប់ពីរកឃើញបញ្ហាទាំងនេះ តាមរបាយការណ៍បានឲ្យដឹងថា ធនាគារពិភពលោក បានព្យាយាមកែតម្រូវជួសជុលបញ្ហាដែលជាកំហុសឆ្គងក្រោមគម្រោង LMAP នេះឡើងវិញ ប៉ុន្តែរដ្ឋាភិបាល បានបញ្ចប់គម្រោងរបស់ខ្លួនក្រោមកិច្ចព្រមព្រៀមកំចីនេះ។ ក្រោយមក ធនាគារពិភពលោក បានបញ្ឈប់ជាបណ្ដោះអាសន្ននូវការផ្ដល់មូលនិធិដល់គម្រោងថ្មីទាំងអស់នៅកម្ពុជា (ការផ្អាកនេះនៅកំពុងអនុវត្តនៅឡើយ រហូតមកដល់ពេលសរសេររបាយការណ៍នេះ)។[២៧៣]

១៩៤. លើសពីនេះទៀត ជាផ្នែកមួយនៃយុទ្ធនាការស្ករសស្អាតស្អំនៅកម្ពុជា មានបណ្ដឹងតវ៉ាមួយ ដាក់ជូនគណៈកម្មការទទួលបន្ទុកពាណិជ្ជកម្មរបស់សហគមន៍អឺរ៉ុប ទាក់ទងនឹងបញ្ហាជំពាក់ជំពិនខាងសិទ្ធិមនុស្សនៃកិច្ចផ្ដួចផ្ដើម ស្ដីពី "អ្វីៗទាំងអស់ លើកលែងតែសព្វាវុធ" (EBA) របស់គណៈកម្មការនេះ ពោលគឺជាគម្រោងពាណិជ្ជកម្មអនុគ្រោះពន្ធរបស់អឺរ៉ុប ដែលអនុញ្ញាតឲ្យក្រុមហ៊ុនដែលមានមូលដ្ឋាននៅកម្ពុជា នាំចេញស្ករ និង ផលិតផលផ្សេងទៀតទៅសហភាពអឺរ៉ុបដោយគ្មានបង់ពន្ធនាំចូល និងក្នុងតម្លៃធានាអប្បបរមាមួយ។ នៅក្នុងចំណោមអ្នកទទួលផលប្រយោជន៍ ពីគម្រោងអនុគ្រោះពន្ធពាណិជ្ជកម្មទាំងនេះ មានក្រុមហ៊ុនដែលជាប់ពាក់ព័ន្ធក្នុងការចាប់យកដីធ្លី និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀត។ តាមរបាយការណ៍បានឲ្យដឹងថា បណ្ដឹងនោះពាក់ព័ន្ធនឹងការអំពាវនាវដល់គណៈកម្មការទទួលបន្ទុកពាណិជ្ជកម្មរបស់សហគមន៍អឺរ៉ុប ឲ្យចាត់វិធានការដោយអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា ១៧ នៃប្រព័ន្ធជាទូទៅសម្រាប់បទប្បញ្ញត្តិអនុគ្រោះពន្ធ (Generalized System of Preference regulation)[២៧៤] ដោយស្នើសុំឲ្យមានការស៊ើបអង្កេតឲ្យបានល្អិតល្អន់លើការរំលោភបំពានសិទ្ធិមនុស្សដែលបានចោទប្រកាន់ ពាក់ព័ន្ធនឹង ឧស្សាហកម្មនេះ និងប្រសិនបើចាំបាច់ បញ្ឈប់ជាបណ្ដោះអាសន្ននូវផលប្រយោជន៍ខាង "អ្វីៗទាំងអស់ លើកលែងតែ សព្វាវុធ" (EBA)។ ការអនុគ្រោះពន្ធ អាចត្រូវដកចេញជាបណ្ដោះអាសន្ន ដើម្បីហេតុផលមួយចំនួន រួមទាំង "ការរំលោភធ្ងន់ធ្ងរ និងជាប្រព័ន្ធ" លើសិទ្ធិមនុស្សដែលមានចែងនៅក្នុងអនុសញ្ញាសំខាន់ៗស្ដីពី សិទ្ធិមនុស្ស និង អនុសញ្ញាស្ដីការងាររបស់អង្គការសហប្រជាជាតិ ដូចជា កតិកាសញ្ញាអន្តរជាតិស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌។ ការសម្រេចចិត្តនេះ ត្រូវធ្វើឡើងដោយគណៈកម្មការនេះ ដោយឈរលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានរបស់ "ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចខាងការពិនិត្យតាមដាន"។[២៧៥]

---

២៧២ សូមមើល COHRE ពាក្យបណ្ដឹងចំពោះ គម្រោងរៀបចំដែនដី និងរដ្ឋបាល, ក្រុមអធិការកិច្ចរបស់ធនាគារពិភពលោក ឆ្នាំ២០១២ មាននៅគេហទំព័រ៖ http://babcambodia.org/developmentwatch/lmap/ and Natalie Bugalski and David Pred, "Land Titling in Cambodia: Formalizing Inequality," 2009.

២៧៣ សេចក្ដីថ្លែងការណ៍របស់ Annette Dixon នាយកប្រចាំប្រទេសនៃធនាគារពិភពលោក ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១១ (កម្ចីចុងក្រោយ ត្រូវបានគេរាយការណ៍ថា មាននៅខែធ្នូ ឆ្នាំ២០១០) រាយការណ៍ដោយកាសែតរ៉យទឺ (Reuters) មាននៅគេហទំព័រ៖ http://www.reuters.com/article/2011/08/09/cambodia-worldbank-idUSL3E7J920D20110809.

២៧៤ មាត្រា១៧ (១) នៃប្រព័ន្ធជាទូទៅសម្រាប់ការអនុគ្រោះពន្ធ ថ្លែងថា "នៅពេលដែល គណៈកម្មាការ ឬរដ្ឋជាសមាជិកណាមួយ ទទួលព័ត៌មានដែលអាចធ្វើជាហេតុផលសំអាងសម្រាប់ការដកជាបណ្ដោះអាសន្ន ហើយដែល គណៈកម្មាការ ឬ រដ្ឋជាសមាជិកណាមួយ យល់ឃើញថា មានហេតុផលគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេត នោះគណៈកម្មការ ឬ រដ្ឋជាសមាជិកនោះ ត្រូវរាយការណ៍ប្រាប់ទៅ គណៈកម្មការនៃប្រពន្ធ័ជាទូទៅសម្រាប់ការអនុគ្រោះពន្ធ និងស្នើសុំធ្វើការពិគ្រោះយោបល់។ ការពិគ្រោះយោបល់នឹងធ្វើឡើង ក្នុងរយៈពេលមួយខែ ។

២៧៥ បទបញ្ជានៃក្រុមប្រឹក្សា លេខ ៧៣២/២០០៨ មាត្រា១៥ ។

១៩៥. ក៏មានការប្រើប្រាស់ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅបរទេស ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ (NHRI)[២៧៦] ទោះបីជាស្ថាប័នទាំងនោះខ្លះនៅមានកម្រិតនៅឡើយក៏ដោយ ដើម្បីដាក់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស ដែលកើតមានឡើងនៅកម្ពុជា។ ឧទាហរណ៍៖ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) បានដាក់ពាក្យបណ្តឹងជូន គណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិរបស់ប្រទេសថៃ (NHRC) កាលពីថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១០ ពាក់ព័ន្ធនឹងទំនាស់អស់រយៈពលដ៏យូរ រវាងប្រជាជននៅភូមិត្រពាំងកណ្តាល ភូមិឈូក និងភូមិជីខ ក្នុងឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ជាមួយនឹងក្រុមហ៊ុនឧស្សាហកម្មស្ករឃុនខែន (Khon Kaen Sugar Industry (ក្រុមហ៊ុនរបស់ថៃ)) ដែលជាម្ចាស់ភាគហ៊ុនដ៏ធំ នៃក្រុមហ៊ុនកោះកុងស៊ូហ្គើរអ៊ិនដាស្រ្ទី (Koh Kong Sugar Industry (KKS)) និងក្រុមហ៊ុនកោះកុងស៊ូហ្គើរផ្លេនថេសិន (Koh Kong Sugar Plantation (KKP))។[២៧៧] ពាក្យបណ្តឹងនេះ បានចោទប្រកាន់ថា ក្រុមហ៊ុន KSL តាមរយៈសាខាក្រុមហ៊ុននៅកម្ពុជា KKP និង KKS បានទទួលដីសម្បទាននៅខេត្តកោះកុង ដោយរំលោភលើច្បាប់របស់កម្ពុជា។ ភាគីអ្នកប្តឹង បានផ្អែកអំណះអំណាងរបស់ខ្លួនអំពីយុត្តាធិការ នៃគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិរបស់ប្រទេសថៃនេះ នៅលើភាពជាម្ចាស់របស់ KSL នៃ KKP និង KKS ការត្រួតត្រារបស់ KSL លើប្រតិបត្តិការនៅកម្ពុជា និងភារកិច្ចរបស់ KSL ក្នុងការគោរពសិទ្ធិមនុស្សនៅទីកន្លែងណា ក៏ដោយដែលខ្លួនមានប្រតិបត្តិការ។ វាតំណាងឲ្យភាពជោគជ័យនៃការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សឆ្លងដែន គណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិរបស់ប្រទេសថៃ បានទទួលយកពាក្យបណ្តឹងមកពិចារណា ហើយថ្មីៗនេះ បានបញ្ចេញនូវលទ្ធផលនៃការរកឃើញដំបូងៗរបស់ខ្លួន។[២៧៨] នេះគឺជារឿងក្តី ដ៏គួរឲ្យកត់សំគាល់ក្នុងប្រវត្តិសាស្រ្ត សម្រាប់ ការតស៊ូមតិជាលក្ខណៈអន្តរជាតិនៅកម្ពុជា ហើយនិងការប្រើប្រាស់ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ NHRI ដែលអាចត្រូវបានធ្វើការស្រាវជ្រាវជាបន្ថែមទៀត សម្រាប់រឿងក្តីសម្បទានដី។

## IX. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១៩៦. ជាបឋម គេគួរកត់សំគាល់ថា កាលៈទេសៈប្រវត្តិសាស្រ្ត រួមមានគោលនយោបាយនៃរបបខ្មែរក្រហម ព្រមទាំងវិនាសកម្ម និងការផ្លាស់ទីលំនៅទូទាំងប្រទេស ដែលបានបន្សល់ទុកពីសង្គ្រាមស៊ីវិល ដ៏រ៉ាំរ៉ៃនៅប្រទេសកម្ពុជា បាននាំឲ្យកើនឡើងទំនាស់ដីធ្លីដ៏រាលដាល ដែលរដ្ឋាភិបាលកំពុងតែព្យាយាមគ្រប់គ្រង។ លើសពីនេះទៀត ក៏គួរកត់សំគាល់ផងដែរថា ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសកម្ពុជា ប្រាថ្នាយកការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ខ្លួនធ្វើជាអាទិភាព ដើម្បីអភិវឌ្ឍប្រទេសឲ្យបានកាន់តែរុងរឿង។ ទោះបីជាដូច្នោះក៏ដោយ ខ្ញុំយល់ឃើញថា សម្បទានដី គួរត្រូវបានផ្តល់ និងគ្រប់គ្រងនៅក្នុងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដ៏សមប្រកបមួយ រួមមានការគិតគូដល់ និងពិគ្រោះយោបល់ជាមួយអ្នកដែលនឹងរងការប៉ះពាល់ និងគិតគូដល់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាពផង។

---

[២៧៦] សម្រាប់ បញ្ជីឈ្មោះនៃប្រទេសដែលមានស្ថាប័នសិទ្ធិមនុស្សជាតិ (NHRIs) ដែលមានការទទួលស្គាល់ដោយ គណៈកម្មាការសម្របសម្រួលអន្តរជាតិ សូមមើលសៀវភៅបញ្ជីស្ថាប័នសិទ្ធិមនុស្សជាតិនានា នៅគេហទំព័រ៖ http://www.nhri.net/default.asp_PID=237_AFD=0.html.

[២៧៧] ក្រុមហ៊ុន KSL មានភាគហ៊ុន ៧០ភាគរយ ជាមួយដៃគូពាណិជ្ជកម្មរបស់ខ្លួនដែលជាជនជាតិកម្ពុជា ដែលគ្រប់គ្រងទាំងស្រុងលើដំណើរការប្រតិបត្តិការរបស់ក្រុមហ៊ុននៅកម្ពុជា និងទទួលបាន ១០០ភាគរយនៃស្ករសដែលចម្រាញ់រួច ចេញមកពីដីសម្បទានកម្ពុជាទាំងពីរកន្លែង។ សូមអានសេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ "ក្រុមហ៊ុនស្ករសអន្តរជាតិ ជាប់ពាក់ព័ន្ធនឹងការដណ្តើមយកដីធ្លី នៅប្រទេសកម្ពុជា" ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២។

[២៧៨] សូមមើល "របាយការណ៍របស់អនុគណៈកម្មាធិការសិទ្ធិពលរដ្ឋ និងនយោបាយ នៃគណៈកម្មាធិការជាតិសិទ្ធិមនុស្សថៃឡង់ដ៍ ស្តីពីករណីក្រុមហ៊ុនកោះកុងស៊ូហ្គ័រផ្លេនថេស៊ិន នៅប្រទេសកម្ពុជា" នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ (ទាក់ទងនឹងសំណុំរឿង លេខ ៥៨/២៥៥៣) នៅគេហទំព័រ http://www.nhrc.or.th/2012/wb/en/news_detail.php?nid=662&parent_id=1&type=hot.

១៩៧. ភាគច្រើននៃការប្រឈម ដែលខ្ញុំបានរកឃើញនៅក្នុងរបាយការណ៍នេះ (បានវិភាគនៅក្នុងផ្នែកទី V ដល់ VIII) កើតចេញមកពីការខកខានមិនអនុវត្តក្របខ័ណ្ឌគតិយុត្តក្នុងស្រុក មានជាអាទិ៍ ច្បាប់ គោលនយោបាយ និង បទបញ្ញានានា ដែលរដ្ឋាភិបាលខ្លួនឯងបានបង្កើត (បានពន្យល់នៅក្នុងផ្នែកទី III)។ ការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀតនៅកម្ពុជា ខ្វះខាតយ៉ាងខ្លាំងនូវតម្លាភាព និងការគោរពច្បាប់ដែលមានស្រាប់។ ភាគច្រើននៃក្របខ័ណ្ឌគតិយុត្តលើវិស័យនេះ មានការតាក់តែងឡើងបានយ៉ាងល្អប្រសើរនៅលើក្រដាស ប៉ុន្តែបញ្ហាចោទគឺនៅលើការអនុវត្តជាក់ស្តែង។

១៩៨. លើសពីនេះទៀត បញ្ហាដ៏ធ្ងន់ធ្ងរដែលខ្ញុំបានជួបប្រទះ គឺភាពមិនប្រក្រតីនៃការទទួលបានព័ត៌មាន ដែលបានរួមចំណែកធ្វើឲ្យសម្បទាននានាផ្តល់ផលប្រយោជន៍ដល់តែក្រុមមនុស្សភាគតិចប៉ុណ្ណោះ និងកំណើននៃទំនាស់ ដែលទាក់ទងនឹងដីធ្លី ដែលមានសក្តានុពលរួមចំណែកដល់អស្ថេរភាពជាតិ។ រដ្ឋាភិបាល គួរតែមានភាពម៉ឺងម៉ាត់ និងមានតម្លាភាព ក្នុងការផ្តល់ និងគ្រប់គ្រងសម្បទានដី (ផ្នែកទី II និង VI) ជាពិសេស នៅពេលចរចាកិច្ចសន្យាសម្បទានជាមួយក្រុមហ៊ុនបរទេស និងក្នុងស្រុកនានា ដោយបញ្ចៀសឲ្យបាននូវទំនាស់ខាងផលប្រយោជន៍ ព្រមទាំងដាក់ក្រុមហ៊ុនដែលទទួលបានសម្បទានដី ឲ្យមានគណនេយ្យភាព ដោយអនុវត្តការត្រួតពិនិត្យលើសកម្មភាពនានារបស់ពួកគេ និងដោះស្រាយចំពោះទំនាស់ដីធ្លី។ ការខ្វះតម្លាភាពនៅក្នុងបញ្ហាទាំងនេះ បង្កឲ្យមានការសង្ស័យអំពី អំពើពុករលួយ នៅគ្រប់កម្រិតទាំងអស់នៃរដ្ឋាភិបាល និងធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាជាច្រើនមានការថ្នាំងថ្នាក់។ ទោះបីជាខ្ញុំ បានធ្វើទស្សនៈកិច្ចនៅកម្ពុជាតាំងពីឆ្នាំ ២០០៩ និងទទួលបានកិច្ចសហប្រតិបត្តិការល្អប្រសើរពីរដ្ឋាភិបាល នៅក្នុងវិស័យជាច្រើន ក្នុងរង្វង់អាណត្តិរបស់ខ្ញុំក្តី ក៏ខ្ញុំនៅមានការលំបាកក្នុងការទទួលបានព័ត៌មានផ្លូវការចាំបាច់នានា ក៏ដូចជាក្នុងការចូលទៅជួបក្រុមហ៊ុននានា ដែលទទួលបានសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត។ កង្វះការទទួលបានព័ត៌មានសំខាន់ៗទាំងនេះ ធ្វើឲ្យមានការលំបាកជាខ្លាំង ដើម្បីសរសេររបាយការណ៍ដ៏គ្រប់ជ្រុង ជ្រោយមួយស្តីពីបញ្ហាទាំងអស់នេះ។

១៩៩. ជាទីផ្សារដែលកំពុងងើបឡើង ប្រទេសកម្ពុជាមានហានិភ័យក្នុងការកសាងកេរ្តិ៍ឈ្មោះលើឆាក អន្តរជាតិ ចំពោះសុវត្ថិភាពនៃការធ្វើវិនិយោគនៅក្នុងវិស័យដីធ្លី និងវិស័យទូទៅផ្សេងទៀត។ បរិយាកាសនៃការអភិវឌ្ឍបច្ចុប្បន្ន ត្រូវបានកំណត់ចរិតលក្ខណៈដោយតម្លាភាពដែលមានកម្រិតទាប និងការទទួលបានព័ត៌មានមិនសមាមាត្រគ្នា ការពិគ្រោះយោបល់មិនគ្រប់គ្រាន់ និងការចូលរួមដែលមិនមានភាពពេញលេញ ហើយតាមការយល់ឃើញរបស់ខ្ញុំនេះ គឺជាការពុំមានចីរភាព និងទំនងជាធ្វើឲ្យរាំងស្ទះដល់ការរីកចំរើននៃសេដ្ឋកិច្ចជាតិនាពេលអនាគត។ ពិតណាស់ថា មានករណីសម្បទានដីខ្លះ ហាក់ដូចជាមានផលប៉ះពាល់វិជ្ជមានសម្រាប់ប្រជាជនកម្ពុជា ទាក់ទិននឹងការបង្កើតការងារធ្វើ បង្កើនសេដ្ឋកិច្ចពលរដ្ឋមូលដ្ឋាន ផ្តល់ចំណូលសម្រាប់ជួយផ្នែកហិរញ្ញវត្ថុដល់សេវាសាធារណៈ និងលើកកំពស់ដល់ការអភិវឌ្ឍជាតិទាំងមូល។ ទោះជាដូច្នោះក៏ដោយ តម្លៃនៃការខូចខាតចំពោះមនុស្សដោយសម្បទានដីជាច្រើនមានកម្រិតខ្ពស់ ហើយសិទ្ធិមនុស្ស គួរតែជាកត្តាស្នូលដែលត្រូវយកចិត្តទុកដាក់ខ្ពស់នៅចំពោះមុខនៃការផ្តល់ និង ការគ្រប់គ្រងនៃសម្បទានដីនានា ដើម្បីធ្វើឲ្យសម្បទានទាំងនោះមានផលប៉ះពាល់វិជ្ជមាន។ មានការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងធំធេង ដែលត្រូវបានកត់ត្រាទុកយ៉ាងច្បាស់លាស់ ពាក់ព័ន្ធនឹងសម្បទានដី ដែលត្រូវការលើកយកមកដោះស្រាយ និងកែតម្រូវវិញ។ ការចោទប្រកាន់សកម្មជនដីធ្លី និងអ្នកការពារ សិទ្ធិមនុស្សពីបទព្រហ្មទណ្ឌ គឺជាបញ្ហាកង្វល់ដ៏ធ្ងន់ធ្ងរ ខណៈដែលសេរីភាពខាងការបញ្ចេញមតិ និងខាងការប្រមូលផ្តុំ ជាកត្តាតម្រូវចាំបាច់សម្រាប់សង្គម ដែលប្រកាន់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

២០០. លើសពីនេះទៀត ក្នុងការវិភាគរបស់ខ្ញុំ ខ្ញុំបានមានការលំបាកក្នុងការយល់ច្បាស់ទាំងស្រុង នូវអត្ថប្រយោជន៍នៃសម្បទានដីជាច្រើន ដែលរដ្ឋាភិបាលបានផ្តល់។ ជាទូទៅ វាមិនច្បាស់លាស់ទេថា តើទំហំនៃអត្ថប្រយោជន៍ដែល

ប្រជាជនកម្ពុជាទទួលបានពីសម្បទានដីមានយ៉ាងណា។ ខ្ញុំមានក្តីបារម្ភថា ថ្វីបើរដ្ឋាភិបាលកម្ពុជា មានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏មានសម្បទានិកជាច្រើន បាននឹងកំពុងធ្វើប្រតិបត្តិការរបស់ខ្លួនដោយលាក់កំបាំង។ ចំណូលពីសម្បទានដីដែលមានស្រាប់ដែលរកបាន ត្រូវគន់គូរពីកម្រិតចំណូលទាំងអស់ និង ធ្វើឲ្យកាន់តែច្បាស់លាស់ឡើង។ ប្រសិនបើផលប្រយោជន៍ ដូចជាចំណូលបែបនេះ មិនបានស្តែងចេញឲ្យឃើញទេ នោះគោលនយោបាយ និងការអនុវត្តនានាជុំវិញការផ្តល់សម្បទានដី ត្រូវការកែតម្រូវ។ ផលប៉ះពាល់នានានៃសម្បទានដី គួរតែត្រូវបានវិភាគ ទាំងសម្រាប់កម្មវិបាករយៈពេលខ្លី និង រយៈពេលវែង។ ប្រាកដណាស់ថា ផលចំណូលគួរតែជាក់ស្តែង និងផ្តល់អត្ថប្រយោជន៍ដល់មនុស្សភាគច្រើន ដើម្បីអាចចាត់ទុកថាមានសារៈប្រយោជន៍ ។ ខ្ញុំយល់ឃើញថា ការអភិវឌ្ឍវិស័យដីធ្លី និងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា អាចនឹងមានផលប៉ះពាល់វិជ្ជមានលើជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ប្រសិនបើវាត្រូវបានអនុវត្តនៅក្នុងលក្ខណៈដែលមានចីរភាព និងសមធម៌ និងនៅក្នុងក្របខ័ណ្ឌនៃ កាតព្វកិច្ចខាងសិទ្ធិមនុស្សរបស់រដ្ឋាភិបាលកម្ពុជា។ នៅក្នុងស្មារតីស្ថាបនានេះ ដែលខ្ញុំសូមដាក់ជូននូវអនុសាសន៍ទាំងអស់នេះ។

## ក. ការទទួលបានព័ត៌មាន និងតម្លាភាព

២០១. រដ្ឋាភិបាលកម្ពុជា គួរតែបង្ហាញព័ត៌មានអំពីការវិនិយោគនានាលើដីធ្លី ប្រត្តិបត្តការដីធ្លី និងដំណើរការដេញថ្លៃការពិនិត្យលើសំណើរសុំសម្បទានដី (និងលក្ខណៈវិនិច្ឆ័យនៃការសម្រេចចិត្ត ចំពោះការយល់ព្រម ឬបដិសេធសំណើ) និងផែនការអនាគត (រួមមានការចាប់ផ្តើមដំណើរការសកម្មភាពសម្បទានដី) ដល់សាធារណជន រួមមាន តាមរយៈការបង្ហាញជាសាធារណៈនៅថ្នាក់ខេត្ត និងបង្ហោះព័ត៌មានទាំងអស់នោះនៅលើគេហទំព័រផ្លូវការនានារបស់រដ្ឋាភិបាល។

២០២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែធ្វើបច្ចុប្បន្នភាព និងបំពេញបញ្ជីសម្បទានដីសេដ្ឋកិច្ច និងសម្បទានព្រៃដែលមានស្រាប់របស់ខ្លួន នូវព័ត៌មានដ៏ពេញលេញ រួមមាន ការវិវត្តន៍រីកចម្រើននៃប្រតិបត្តិការសម្បទានដីទាំងនោះ និងបង្ហាញព័ត៌មាននោះជាសាធារណៈឲ្យបានទាន់ពេលវេលា។ បញ្ជីនោះ គួររួមបញ្ចូលពត៌មានអំពីក្រុមហ៊ុន ថ្នាក់ដឹកនាំ ម្ចាស់ភាគហ៊ុន ក្រុមហ៊ុនមេ និងព័ត៌មានទំនាក់ទំនង នៃការិយាល័យមូលដ្ឋានរបស់ក្រុមហ៊ុន (រួមទាំងការិយាល័យនានានៅក្នុងប្រទេសសាម៉ីបើមាន) ថ្លៃឈ្នួលដី សម្បទានដែលបានបង់ និងចំណូលនានា ដែលបានមកពីសម្បទានដីទាំងអស់នោះ។ ព័ត៌មាននេះគួរតែ មានជាភាសាអង់គ្លេស និងភាសាខ្មែរ។

២០៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរផ្សព្វផ្សាយព័ត៌មានស្តីពី ការកំណត់លើផែនទី ការធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជីដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ព្រមទាំងបង្កើត និងរក្សាប្រព័ន្ធទិន្នន័យដីធ្លីរដ្ឋ។ ព័ត៌មានស្តីពីការលែបម្រុង ការគ្រប់គ្រង និងការធ្វើអនុបយោគដីរដ្ឋ គួរតែផ្សព្វផ្សាយជាសាធារណៈ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ ២០០៥។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែធ្វើសហប្រតិបត្តិការនៅក្នុងដំណើរការនេះ និងចែករំលែកព័ត៌មានទាក់ទងនឹង ការធ្វើអនុបយោគទ្រព្យសម្បត្តិរបស់រដ្ឋ។

២០៤. ក្រសួងបរិស្ថាន គួរតែបង្ហាញឲ្យសាធារណជនបានដឹងពីបញ្ជីឈ្មោះបច្ចុប្បន្ន និងដែលបានធ្វើបច្ចុប្បន្នភាពនៃគ្រប់តំបន់ការពារទាំងអស់ រួមមានឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើន យ៉ាងតំបន់រ៉ាមសារ តំបន់ស្នូលនៃបឋនីយ៍ជីវមណ្ឌល តំបន់បេតិកភ័ណ្ឌធម្មជាតិ និងតំបន់ឧទ្យានជាតិសមុទ្រ ដែលរួមមានព័ត៌មានពិស្តារអំពីទំហំ ព្រំប្រទល់ តំបន់គ្រប់គ្រង និងការប្រើប្រាស់នៃតំបន់ទាំងនោះ ព្រមទាំងអំពីដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តចំពោះការកែប្រែ ឬការធ្វើអនុបយោគនូវតំបន់ការពារនានា។

២០៥. ដំណើរការនៃការធ្វើអនុបយោគដីរដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងការចាត់ថ្នាក់តំបន់គ្រប់គ្រងក្នុងតំបន់ការពារនានា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព គួរត្រូវបានធ្វើនៅក្នុងបរិយាកាសមួយ ប្រកបដោយតម្លាភាព និងបើកចំហ ដោយមានតួអង្គពាក់ព័ន្ធទាំងអស់ រួមមានក្រសួងបរិស្ថាន និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ខ. ការផ្តល់សម្បទានដី - ការពិគ្រោះយោបល់ និងការត្រួតពិនិត្យ

២០៦. ប្រព័ន្ធដែលកាន់តែមានការសម្របសម្រួល និងការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងការផ្តល់សម្បទានដីនានា គួរតែត្រូវបានយកទៅពិចារណាដោយរដ្ឋាភិបាល និងអនុវត្តដោយអាជ្ញាធរពាក់ព័ន្ធ រួមមាន ការពិចារណាលើដំណើរការធ្វើផែនការនៅថ្នាក់ជាតិ និងខេត្ត។ វិធីសាស្ត្រនេះគួរតែបើកឲ្យមានការចូលរួម និងដំណើរការអភិវឌ្ឍន៍ប្រកបដោយការចូលរួម ដោយអនុលោមតាមផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩ - ២០១៣។

២០៧. ស្ថាប័នរដ្ឋាភិបាល និងសហគ្រាសពាណិជ្ជកម្មដែលពាក់ព័ន្ធទាំងអស់ គួរតែប្រកាន់តាមលក្ខខណ្ឌដែលច្បាប់តម្រូវ សម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ ឧទាហរណ៍ អនុក្រឹត្យឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច។ ការពិគ្រោះយោបល់បែបនោះ គួរតែប្រកបដោយអត្ថន័យ មានការចូលរួមពីអ្នកពាក់ព័ន្ធ និងបើកចំហដល់អ្នករងការប៉ះពាល់នានា។ សហគមន៍នានាដែលស្ថិតនៅលើដី ដែលនឹងរងការប៉ះពាល់ដោយការផ្តល់សម្បទានដី គួរតែត្រូវបានពិគ្រោះយោបល់នៅដំណាក់កាលដំបូងបំផុតនៃ ផែនការប្រើប្រាស់ដី និងគួរត្រូវបានរួមបញ្ចូល នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ គួរមានការពិចារណាយ៉ាងហ្មត់ចត់ដល់សកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់សហគមន៍នោះ និងគិតគូរអំពីកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដែលត្រូវធ្វើឡើងដើម្បីបញ្ចៀសឲ្យបានការរំខានដល់ពួកគាត់។ ស្តង់ដារនៃការយល់ព្រមដោយសេរី ជាមុន និងមានការជូនដំណឹងគ្រប់គ្រាន់ គួរតែត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ នៅពេលពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចទាំងអស់។

២០៨. ការពិនិត្យពិច័យកាន់តែហ្មត់ចត់ឡើងលើប្រវត្តិ និងសាវតារបស់សហគ្រាសពាណិជ្ជកម្ម និង សមត្ថភាពធ្វើប្រតិបត្តិការនៃសំណើវិនិយោគរបស់ពួកគេ គួរតែត្រូវបានធ្វើឡើងដោយអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីត្រួតពិនិត្យមើលវិនិយោគិននានា មុនពេលផ្តល់សម្បទានដីណាមួយ។ ការពិនិត្យលើសំណើវិនិយោគ គួរតែត្រូវបានប្រព្រឹត្តទៅក្នុងលក្ខណៈតម្លាភាពមួយ ដោយថ្លឹងថ្លែងរវាងការចង់រក្សាការសម្ងាត់នៃព័ត៌មានរសើបរបស់ក្រុមហ៊ុន និង តំរូវការ សម្រាប់ការពិនិត្យជាសាធារណៈ។ កិច្ចការនេះរួមមាន ការផ្សព្វផ្សាយព័ត៌មាន ស្តីពីដំណើរការដេញថ្លៃជាសាធារណៈ និងបន្ទាត់ពេលវេលា អំពីសកម្មភាពសម្បទាននានាដែលបានព្រមព្រៀង។

២០៩. ការធ្វើអនុបយោគដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ គួរធ្វើតាមនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ និងនីតិវិធីដែលតំរូវឲ្យមានការអនុម័តច្បាប់ដោយរដ្ឋសភា។ រហូតដល់ច្បាប់បែបនោះ ត្រូវបានអនុម័តអនុបយោគណាមួយដែលបានកំណត់ គួរតែត្រូវបានធ្វើឡើងក្នុងលក្ខណៈបើកចំហ និងតម្លាភាពមួយ ដោយពិចារណាយ៉ាងល្អិតល្អន់អំពី ផលប៉ះពាល់ជាសក្តានុពលនានានៃការធ្វើអនុបយោគតំបន់ជាក់លាក់ណាមួយ ព្រមទាំងមានការពិគ្រោះយោបល់ត្រឹមត្រូវជាមួយទីភ្នាក់ងារបច្ចេកទេសដែលពាក់ព័ន្ធនានា និង ប្រជាពលរដ្ឋដែលរងការប៉ះពាល់។

២១០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត គួរតែធានាថា ដំណើរការដេញថ្លៃប្រកបដោយការប្រកួតប្រជែងមួយ សម្រាប់ការផ្តល់សម្បទានដី ត្រូវបានអនុវត្តកាន់តែ ម៉ឺងម៉ាត់ និង តម្លាភាព ឧទាហរណ៍ តាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០០៥។

២១១. បទបញ្ជាទាក់ទងនឹងការផ្អាកសម្បទានដីសេដ្ឋកិច្ច (ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២) ដែលផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី គឺជាចំណាត់ការគួរជាទីស្វាគមន៍ ប៉ុន្តែគួរត្រូវបានអនុវត្តយ៉ាងពេញលេញ និងរក្សាសុពលភាពរហូតដល់ប្រព័ន្ធពិនិត្យការផ្តល់សម្បទានមួយត្រូវបានបង្កើតចប់សព្វគ្រប់។ សម្បទាន នានាដែលត្រូវបានរកឃើញថាមានការកេងប្រវ័ញ្ច អសកម្ម ឬ ម្យ៉ាងវិញទៀតរំលោភលើលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងសម្បទាន គួរត្រូវបានមោឃភាព យោងតាមច្បាប់ពាក់ព័ន្ធនានា។ ការពិនិត្យមើលលើសម្បទាននាពេលបច្ចុប្បន្នឡើងវិញ រួមទាំង ការងាររបស់លេខាធិការដ្ឋានបច្ចេកទេសស្តីពីសម្បទានដីសេដ្ឋកិច្ច គួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈឲ្យបានទាន់ពេលវេលា។ បន្ទាប់ពីពិនិត្យរួចហើយ ព័ត៌មានលំអិតនៃសម្បទានទាំងឡាយដែលត្រូវបានមោឃភាព តាមរយៈដំណើរការនេះ ឬ ត្រូវបានមោឃភាពនាពេលកន្លងមក គួរតែត្រូវបានផ្សព្វផ្សាយជាសាធារណៈ រួមទាំងព័ត៌មានអំពីការគ្រប់គ្រងសម្បទានដីដែលត្រូវបានមោឃភាពផងដែរ។

## គ. ការផ្តល់សម្បទានដី - ការការពារបរិស្ថាន និងសង្គម

២១២. រដ្ឋាភិបាល គួរតែត្រូវបានធ្វើឲ្យប្រសើរឡើង នូវរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីអនុវត្តច្បាប់ គោលនយោបាយ និងបទបញ្ជានានា ដែលតំរូវឲ្យធ្វើការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម *មុនពេល* ផ្តល់សម្បទានដី រួមមាន ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ហើយការរកឃើញបានមកពីការវាយតម្លៃទាំងនោះត្រូវផ្សព្វផ្សាយជាសាធារណៈ។

២១៣. វិធាន និងនីតិវិធីនានាទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ និងការធ្វើអនុយោគដីក្នុងតំបន់ការពារនានា ជាពិសេសតំបន់ប្រើប្រាស់ដោយចីរភាព គួរតែត្រូវបានប្រកាន់ខ្ជាប់ (រួមមាន ដោយធ្វើការសិក្សាបែបវិទ្យាសាស្ត្រ ដូចមានចែងក្នុងច្បាប់ស្តីពីតំបន់ការពារឆ្នាំ ២០០៨)។ លទ្ធផលនានានៃការវាយតំលៃនោះ និងនីតិវិធីដែលទាក់ទងនឹងការចាត់ថ្នាក់ និងការធ្វើអនុប្រយោគ គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២១៤. លក្ខខណ្ឌនានាដែលត្រូវបានកំណត់សំរាប់ការផ្តល់សម្បទានដីនៅក្នុងតំបន់ការពារនានា យោងតាមច្បាប់ស្តីពីតំបន់ការពារឆ្នាំ ២០០៨ គួរត្រូវបានប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់។ លើសពីនេះទៀត ការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់នូវសម្បទានដី ដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារនានាត្រូវតែធ្វើឡើង ហើយការធ្វើមោឃភាពសម្បទានដី គួរត្រូវបានអនុវត្តឲ្យបានទាន់ពេលវេលា។ គួរធ្វើឲ្យសាធារណៈជនបាន ដឹងច្បាស់លាស់ផងដែរអំពីមូលដ្ឋានគតិយុត្តអ្វីខ្លះ ដែលមានសម្រាប់ស្ថាប័ននានា ក្រៅពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការផ្តល់សម្បទាន និងការធ្វើកិច្ចសន្យារយៈពេលវែងផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍលើដីរដ្ឋ។

២១៥. ដីដែលត្រូវបានកាន់កាប់ និងប្រើប្រាស់ជាប្រពៃណីដោយប្រជាជនជនជាតិដើមភាគតិច គួរត្រូវបានកំណត់ និងវាស់វែងឲ្យបានឆាប់រហ័សបំផុត។ ពុំមានសម្បទានដីណាគួរត្រូវបានផ្តល់លើ ឬ ក្បែរដីរបស់ប្រជាជនជនជាតិដើមភាគតិចនោះទេ *រហូតដល់*ដំណើរការទទួលស្គាល់ និងចុះបញ្ជីកម្មសិទ្ធិដីសមូហភាពបានចប់សព្វគ្រប់។ សារាចរអន្តរក្រសួងឆ្នាំ ២០១១ ស្តីពីវិធានការការពារជាបណ្តោះអាសន្ន គួរត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ សម្រាប់សហគមន៍ទាំងឡាយដែលត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ ហើយដំណើរការចុះបញ្ជីដីផ្តល់កម្មសិទ្ធិដីសមូហភាពនេះ គួរធ្វើឲ្យបានរួសរាន់ ដើម្បីបញ្ចៀសវិវាទនាពេលខាងមុខ។

២១៦. គួរតែពិចារណាលើសំណើវិនិយោគរបស់សម្បទានិកណា ដែលមានទៅដោយលក្ខខណ្ឌតំរូវតាមច្បាប់ និង បញ្ញតិច្បាប់រឹងមាំ ភ្ជាប់ជាមួយគម្រោងវិនិយោគរបស់ពួកគេ (ដូចជា គ្រោងការណ៍មានការទទួលស្គាល់ដោយភាគីទីបី និងក្រមប្រតិបត្តិដ៏ម៉ឺងម៉ាត់) ដែលរួមបញ្ចូល ស្តង់ដារអន្តរជាតិស្តីពីចីរភាព បរិស្ថាន និងសង្គម។

## ឃ. សកម្មភាពនៃសម្បទានដី

២១៧. ក្រុមហ៊ុនគ្រប់ទំហំ រចនាសម្ព័ន្ធ និងប្រភេទប្រតិបត្តិការទាំងអស់ ទាំងក្នុងស្រុក និងបរទេស និង បើទោះបីជា

គ្រប់គ្រងទាំងស្រុង ឬ មួយផ្នែកដោយរដ្ឋ គួរតែដោះស្រាយការប៉ះពាល់សិទ្ធិមនុស្សរបស់ពួកគេ ដោយអនុវត្តការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវ រួមមានការអនុវត្តវិធានការកំណត់ បង្ការនិងកាត់បន្ថយផល ប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និង មានគណនេយ្យភាពចំពោះសកម្មភាពពាណិជ្ជកម្មរបស់ពួកគេ។

២១៨. នៅក្នុងករណីនៃក្រុមហ៊ុនបរទេស រដ្ឋសាមីគួរតែធានាថា តំណាងនានានៃសហគ្រាសពាណិជ្ជកម្មឯកជនដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន នឹងពុំរួមចំណែកធ្វើឲ្យមានការប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សឡើយ ដោយធ្វើការឃ្លាំមើល និងត្រួតពិនិត្យជាទៀងទាត់។

២១៩. ការបណ្តេញចេញ និងការផ្លាស់ប្តូរទីលំនៅ គួរតែត្រូវបានប្រើប្រាស់ជាដំណោះស្រាយចុងក្រោយប៉ុណ្ណោះ ហើយគួរតែត្រូវអនុវត្តការផ្អាកការបណ្តេញចេញដោយបំពាន ដែលទាក់ទងនឹងសកម្មភាពសម្បទាននានា។ នៅក្នុងករណីនៃការរំលោភកន្លងមក កិច្ចខិតខំប្រឹងប្រែងនានាគួរត្រូវបានធ្វើ ដើម្បីធានាដល់ការកែតម្រូវហេតុការណ៍អាក្រក់។ នៅពេលដែលនីតិវិធីត្រឹមត្រូវត្រូវបានគោរព ហើយការបណ្តេញចេញ ត្រូវបានចាត់ទុកថាស្របច្បាប់ និង បម្រើផលប្រយោជន៍សាធារណៈ គ្រួសារដែលរងប៉ះពាល់នានា គួរត្រូវបានពិគ្រោះយោបល់អំពីរបៀប និងពេលវេលា ដែលត្រូវធ្វើការផ្លាស់ប្តូរលំនៅថ្មី ព្រមទាំងកិច្ចខិតខំប្រឹងប្រែងទាំងឡាយដែលត្រូវធ្វើ ដើម្បីធានាថា ការផ្លាស់ប្តូរលំនៅថ្មីនោះ នឹងប្រព្រឹត្តទៅក្រោមលក្ខខណ្ឌនានាដែលប្រកាន់ខ្ជាប់តាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ទាក់ទងនឹងលំនៅដ្ឋានសមរម្យ និងសំណងដែលត្រឹមត្រូវ និងយុត្តិធម៌។ កិច្ចខិតខំប្រឹងប្រែងជាបន្ថែមនានា គួរត្រូវបានធ្វើដើម្បីបង្កើតឡើងវិញនូវកាលានុវត្តភាពនៃការចិញ្ចឹមជីវិត។

២២០. កងយោធពលខេមរភូមិន្ទ ពុំគួរត្រូវបានប្រើប្រាស់ដើម្បីការពារផលប្រយោជន៍ឯកជន និងពុំគួរត្រូវបានដាក់ពង្រាយ ឬ ជួលដោយក្រុមហ៊ុនសម្បទានដីនានានោះទេ ទោះបីជាមានការឯកភាព ឬ មិនឯកភាពពីរដ្ឋាភិបាលក៏ដោយ។ កងនគរបាល កងរាជអាវុធហត្ថ និងអាជ្ញាធរពាក់ព័ន្ធផ្សេងៗទៀត គួរអត់ធ្មត់មិនប្រើប្រាស់កំលាំងលើសលប់ប្រឆាំងនឹងសហគមន៍ និងអ្នកតវ៉ានានាដែលរងការប៉ះពាល់ដោយសម្បទានដី។

២២១. រដ្ឋាភិបាលគួរធានាថា ក្រុមហ៊ុនសម្បទានដីនានាពុំប្រើប្រាស់ ឬ លើកទឹកចិត្តឲ្យភ្នាក់ងារសន្តិសុខឯកជន ចូលប្រឡូក ឬ ប្រើប្រាស់កំលាំងប្រឆាំងនឹងសហគមន៍ និងអ្នកតវ៉ាដែលរងការប៉ះពាល់ដោយសម្បទាននោះឡើយ។

២២២. ក្រុមហ៊ុនសម្បទានដីនានា គួរចាត់វិធានការទាំងអស់ ដើម្បីបញ្ចៀសការបំផ្លិចបំផ្លាញបរិស្ថាន នៅក្នុងប្រតិបត្តិការរបស់ពួកគេ រួមមាន ការបង្ការការបំពុលទឹក ការធ្វើឲ្យខូចគុណភាពដី និងការឆ្ការដីដោយមិនចាំបាច់ ឬ ការកាប់ឈើដោយខុសច្បាប់។ ពួកគេគួរធានាថា ហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្មីៗនៅលើសម្បទានរបស់ពួកគេ អាចប្រើប្រាស់បានដោយសហគមន៍នៅជុំវិញនោះទាំងអស់ និងគួរជៀសវាងការបិទផ្លូវចរាចរណ៍នៅក្នុងបរិវេណតំបន់សម្បទាននោះ។

២២៣. រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ គួរត្រូវបានធ្វើដោយអាជ្ញាធរនានា ដែលច្បាប់ប្រគល់សិទ្ធិឲ្យផ្តល់សម្បទាន ដើម្បីបង្ការសកម្មភាពនានានៅលើតំបន់ដែលមានតំលៃខាងវប្បធម៌ និងខាងសាសនា ក៏ដូចជាដោះស្រាយ (តាមរយៈការកែតម្រូវហេតុការណ៍អាក្រក់) ផលប៉ះពាល់អវិជ្ជមានដែលបានកើតឡើងរួចហើយ។ ក្រសួងនានារបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ ដូចជាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចធ្វើអន្តរគមន៍ដើម្បីកែតម្រូវផលប៉ះពាល់ទាំងនោះ។

២២៤. ក្រុមហ៊ុនសម្បទានដីនានា ជាមួយការប្រើប្រាស់ចំណូលពីសកម្មភាពសម្បទាន គួរបង្កើនការរួមចំណែកនានារបស់ពួកគេទៅដល់សហគមន៍មូលដ្ឋាននានា រួមមាន ការផ្តល់អត្ថប្រយោជន៍ខាងសង្គមកិច្ច ដូចជាសេវា សុខភាព ឱកាសទទួលបានការអប់រំ និងវិធានការការពារបរិស្ថាន។

## ង. ការឃ្លាំមើល ការស្រាវជ្រាវ និងការវិភាគ

២២៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូពាក់ព័ន្ធផ្សេងៗទៀត គួរស្វះស្វែងប្រមូលទិន្នន័យ និងធ្វើការវិភាគលើចំណូលដែលបានមកពីសម្បទានដីនានា និងបែងចែងអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ ដែលមានដូចជា ការងារដែលបង្កើតដោយក្រុមហ៊ុនសម្បទានដីនានា និងការរួមចំណែកដល់ទីផ្សារមូលដ្ឋាន ដែលកើតចេញមកពីកំណើនចំណូល ជាផ្នែកមួយនៃការសិក្សាលើបរិមាណផ្អែកលើភស្តុតាង ទៅក្នុងប្រព័ន្ធសម្បទាន។ ទិន្នន័យនេះ ក៏គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈផងដែរ។

២២៦. កាលានុវត្តភាពក្នុងការចិញ្ចឹមជីវិត និងរកចំណូលរបស់គ្រួសារនានា ដែលរងផលប៉ះពាល់ដោយសម្បទាននានា គួរតែត្រូវបានពិនិត្យ និងកំណត់ជាផ្នែកមួយនៃការសិក្សាលើបរិមាណ និងគុណភាព ដោយលើកសំណើដោះស្រាយផលប៉ះពាល់ខាងហិរញ្ញវត្ថុអវិជ្ជមាននានា នៅក្នុងកម្រិតគ្រួសារ និងសហគមន៍។

២២៧. អ្នកស្រាយជ្រាវនានា គួរពិនិត្យបន្ថែមលើការរៀបចំផែនការ និងការពិគ្រោះយោបល់មិនគ្រប់គ្រាន់ ដែលកំពុងរួមចំណែកធ្វើឲ្យមានវិវាទទាក់ទងនឹងសម្បទានដីនានា ក្នុងគោលដៅវាយតំលៃជាបរិមាណនៃ (ក្នុងន័យហិរញ្ញវត្ថុ) ការបាត់បង់ចំណូលនៅកម្រិតថ្នាក់ជាតិ។

២២៨. ការឃ្លាំមើលកាន់តែហ្មត់ចត់លើការប្រើប្រាស់ដីធ្លី គួរត្រូវបានធ្វើ ហើយការមោឃភាពសម្បទានដី គួរត្រូវបានអនុវត្តឲ្យបានទាន់ពេលវេលា ហើយប្រសិនបើអាចធ្វើទៅរួច ប្រគល់ដីនោះឲ្យអ្នកប្រើប្រាស់ផ្សេងៗទៀត។ សម្បទានដីដែលត្រូវបានមោឃភាព គួរត្រូវបានចុះបញ្ជីដោយក្រុមហ៊ុន ឬ អាជ្ញាធរខេត្ត និងផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័ររបស់ក្រសួងពាក់ព័ន្ធនានា ដោយភ្ជាប់ជាមួយមូលហេតុនៃមោឃភាព។

២២៩. ក្នុងករណីដែលសម្បទានដីត្រូវបានផ្តល់លើដីដែលកាន់កាប់ និងប្រើប្រាស់ជាប្រពៃណីដោយជនជាតិដើមភាគតិច ដីនោះគួរត្រូវប្រគល់ និង ស្តារស្ថានភាពសម្រាប់ឲ្យពួកគេឡើងវិញ រួមទាំងផ្តល់កាលានុវត្តភាពដល់សហគមន៍ទាំងនោះ ក្នុងការចុះបញ្ជីជានីតិបុគ្គល និងដាក់ពាក្យសុំចុះបញ្ជីដីកម្មសិទ្ធិសមូហភាពផងដែរ។

២៣០. បន្ទាប់ពីសម្បទាននានាត្រូវបានផ្តល់ និងដាក់ឲ្យដំណើរការរួចហើយ ការឃ្លាំមើលគួរបន្តធ្វើ និងវាយតំលៃលើការប៉ះពាល់បរិស្ថាន ការអនុវត្តច្បាប់ការងារ និងការប្រព្រឹត្តជាទូទៅរបស់សម្បទានិកជាទៀងទាត់ ដើម្បីធានាថា ការអនុវត្តន៍មិនពេញលេញអាចត្រូវបានដោះស្រាយ ឬ ដាក់ទណ្ឌកម្ម។

២៣១. រដ្ឋាភិបាល គួរពិនិត្យឡើងវិញលើការរំលោភលក្ខខណ្ឌតម្រូវ ដែលកម្រិតតទំហំដីសម្បទាន មិនឲ្យលើសពីទំហំ ១០.០០០ ហិកតា សម្រាប់បុគ្គលតែមួយ និង ការអនុវត្តន៍នៃការផ្តល់ដីជាប់ៗគ្នាឲ្យទៅក្រុមហ៊ុនឬអ្នកមានសម្ព័ន្ធភាព

ជាមួយគ្នា ឬ សមាជិកគ្រួសាររបស់សម្បទានិក។ រដ្ឋាភិបាល គួរអះអាងបញ្ជាក់ និងអនុវត្តការដាក់កំហិត តាមលក្ខខ័ណ្ឌតម្រូវដែលចែងក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលថា សម្បទានដីដែលមានទំហំច្រើនជាង ១០.០០០ ហិកតា មិនអាចត្រូវបានផ្តល់ជូនបុគ្គលតែម្នាក់ ឬ ឲ្យនីតិបុគ្គលច្រើនដែលគ្រប់គ្រងដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលដដែលៗនោះទេ។ ប្រសិនជាអាចអនុវត្តទៅរួច សម្បទានដីដែលល្មើសនឹងបទប្បញ្ញត្តិនេះ គួរតែត្រូវបានមោឃភាពចោល។

## ច. ការដោះស្រាយទំនាស់

២៣២. អាស្រ័យដោយស្ថានការណ៍ដែលហាក់ដូចជាមិនស្រាកស្រាននៃទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃ និង កំណើននៃទំនាស់ថ្មីៗ កិច្ចខិតខំប្រឹងប្រែងនានា គួរតែត្រូវបានធ្វើឡើង ដើម្បីបង្កើនប្រសិទ្ធិភាព និងធម្មានុរូបនៃយន្តការដោះស្រាយបណ្តឹងតវ៉ានៅកម្រិតប្រតិបត្តិការនានា ដោយផ្តល់ឲ្យសហគមន៍ និងតំណាងរបស់ពួកគេ (សហគមន៍ អាចធ្វើការសម្រេចថា តើគួរឲ្យអង្គការសង្គមស៊ីវិលចូលពាក់ព័ន្ធឬយ៉ាងណា) ចូលរួមតាំងពីនៅតំណាក់កាលដំបូងបំផុត នៃការផ្តល់សម្បទានដី ព្រមទាំងរួមបញ្ចូលពួកគេនៅក្នុងដំណើរការធ្វើផែនការផងដែរ។

២៣៣. តំណាងក្រុមហ៊ុននានាគួរមានវត្តមាន និងចូលរួមយ៉ាងពេញលេញនៅក្នុងយន្តការដោះស្រាយវិវាទថ្នាក់មូលដ្ឋាននានា ដើម្បីបន្ធូរបន្ថយសតិអារម្មណ៍ប្រឆាំងក្រុមហ៊ុន និងលើកទឹកចិត្តដល់សហគមន៍វិនិយោគឲ្យលើកយកមកដោះស្រាយដោយផ្ទាល់នូវផលប៉ះពាល់ខាងបរិស្ថាន និងសង្គម ដែលបណ្តាលមកពីសកម្មភាពវិនិយោគរបស់ពួកគេ។ កិច្ចខិតខំប្រឹងប្រែងជាក់លាក់នានាគួរត្រូវបានធ្វើ ដើម្បីដោះស្រាយបញ្ហារនាំងខាងភាសា ជាពិសេសចំពោះក្រុមហ៊ុនបរទេសនានា និងនៅពេលដែលពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច។ ជាវិធានទូទៅ កងកម្លាំងប្រដាប់អាវុធ ពុំគួរមានវត្តមាននៅអំឡុងពេលនៃការចរចានៅថ្នាក់មូលដ្ឋាននោះទេ។ កងកម្លាំងប្រដាប់អាវុធ និង អាជ្ញាធរ រដ្ឋាភិបាលនានា (រាប់បញ្ចូលទាំងមន្ត្រីថ្នាក់ខេត្ត និងថ្នាក់ឃុំ) ក៏ដូចជាសហគមន៍នានា គួរជៀសវាងការប្រើប្រាស់អំពើហឹង្សា។

២៣៤. កិច្ចខិតខំប្រឹងប្រែងទាំងអស់ គួរត្រូវបានធ្វើ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលនៃយន្តការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដី និងតុលាការ ដើម្បីបង្កើនលទ្ធភាពដល់សហគមន៍នានា ក្នុងការទទួលបានដំណោះស្រាយទាក់ទងនឹងវិវាទដីធ្លី។ សមត្ថភាព និងឯករាជភាពរបស់ស្ថាប័នតុលាការ គួរត្រូវបានពង្រឹង ដើម្បីឲ្យស្ថាប័ននេះអាចទទួលបាននូវការគោរព និងទំនុកចិត្តពីពលរដ្ឋមូលដ្ឋានរបស់ខ្លួន។ ប្រព័ន្ធតុលាការ មិនគួរត្រូវបានប្រើប្រាស់សម្រាប់ជាយន្តការមួយដើម្បីធ្វើការចោទប្រកាន់សកម្មជនដីធ្លី បុគ្គលទាំងឡាយដែលបានធ្វើការទាមទារដីធ្លីរបស់ពួកគេ អ្នកការពារសិទ្ធិមនុស្ស និង អាជ្ញាធរមូលដ្ឋាន នោះទេ។

២៣៥. កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរត្រូវបានប្រើប្រាស់ដើម្បីឃ្លាំមើលករណីទំនាស់ដីធ្លី នៅក្នុងយន្តការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដី និងស្ថាប័នតុលាការ ជាក់ស្តែងដូចជា បញ្ហាទំនាស់ផលប្រយោជន៍ អន្តរាគមន៍ ខាងនយោបាយ ឬ អំពើពុករលួយ ដែលមានពាក់ព័ន្ធនឹងក្រុមហ៊ុនសម្បទាននានា។ មន្ត្រីរដ្ឋបាល ឬ មន្ត្រីតុលាការដែលធ្វើការសម្រេចចិត្ត ដោយផ្អែកលើបុព្វហេតុផ្ទាល់ខ្លួន គួរត្រូវបានហាមឃាត់មិនឲ្យបំពេញតួនាទី នៅក្នុងការវិនិច្ឆ័យសេចក្តី។

## ឆ. ការពិនិត្យឡើងវិញដោយស្ថាប័នសិទ្ធិមនុស្សនានា និងយន្តការបណ្តឹងអន្តរជាតិផ្សេងៗ

២៣៦. ការប្រើប្រាស់នីតិវិធី និងយន្តការបណ្តឹងតវ៉ាអន្តរជាតិ ក៏ដូចជាស្ថាប័នសិទ្ធិមនុស្សជាតិនានា នៅក្រៅប្រទេស គួរត្រូវបានពិនិត្យគិតគូបន្ថែមទៀត ដោយតួអង្គសង្គមស៊ីវិលនានា ដើម្បីនាំយកបណ្តឹងតវ៉ានៃការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយសហគ្រាសពាណិជ្ជកម្មបរទេស ឬ ធ្វើប្រតិបត្តិការដោយបរទេស ដែលជាប់ពាក់ព័ន្ធនឹងការរំលោភ

សិទ្ធិមនុស្សនៅកម្ពុជា (ទោះជាម្ចាស់ភាគហ៊ុនធំ ឬ តូចក៏ដោយ)។ តួនាទីដែលអាចមាន នៃគណៈកម្មការអន្តររដ្ឋាភិបាល អាស៊ាន ស្តីពីសិទ្ធិមនុស្ស អាចត្រូវបានពិនិត្យមើលជាបន្ថែមទៀត។

២៣៧. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការឃ្លាំមើល ស៊ើបអង្កេត និងធ្វើរបាយការណ៍ស្តីពីការរំលោភសិទ្ធិមនុស្ស នៅក្នុងបរិបទនៃសម្បទានដីនានា។ របាយការណ៍ទាំងនោះគួររួមបញ្ចូលអនុសាសន៍ជូនដល់ស្ថាប័នរដ្ឋពាក់ព័ន្ធនានា ព្រមទាំងសហគ្រាសពាណិជ្ជកម្មនានា និងគួរតែធ្វើការផ្សព្វផ្សាយជាសាធារណៈ។

២៣៨. ដើម្បីផ្តល់លទ្ធភាពត្រួតពិនិត្យបន្ថែមទៀតលើផលប៉ះពាល់សិទ្ធិមនុស្សនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗទៀត រដ្ឋាភិបាលគួរតែបន្ថែមសេចក្តីអញ្ជើញរបស់ខ្លួនទៅកាន់យន្តការនិតិវិធីពិសេសនៃអង្គការសហប្រជាជាតិ ឬ យ៉ាងហោចណាស់ ចេញសេចក្តីអញ្ជើញទៅអ្នកមានអាណត្តិពាក់ព័ន្ធនានា ដែលមានលទ្ធភាពផ្តល់ការវិភាគបានល្អិតល្អន់ជូនរដ្ឋាភិបាល។ អ្នកមានអាណត្តិពាក់ព័ន្ធជាពិសេសនោះ គឺរួមមាន អ្នករាយការណ៍ពិសេសស្តីពីជនជាតិដើមភាគតិច ក្រុមការងារស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានម្ហូបអាហារ សិទ្ធិមានលំនៅដ្ឋានសមរម្យ និងសិទ្ធិទទួលបានការអប់រំ អ្នករាយការណ៍ពិសេសស្តីពីភាពក្រីក្របំផុត និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានទឹកពិសារមានសុវត្ថិភាព និងអនាម័យ និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិខាងវប្បធម៌។

២៣៩. ដោយពិចារណាលើកំណើននៃការរំលោភបំពាននានា ទាក់ទិននឹងសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំ នៅក្នុងបរិបទនៃទំនាស់ដីធ្លី ការគិតគូពិចារណាបន្ថែមគួរត្រូវបានផ្តល់ឲ្យដោយ ស្ថាប័នសិទ្ធិមនុស្សនានា រួមមានអ្នករាយការណ៍ពិសេស និងស្ថាប័នសន្ធិសញ្ញានានា ដើម្បីរិះរកបន្ថែមទៀត និងចងក្រងជាឯកសារនូវករណីនៃការផ្តន្ទាទោសពីបទព្រហ្មទណ្ឌលើសកម្មជនដីធ្លី បុគ្គលទាំងឡាយដែលទាមទារសិទ្ធិលើដីធ្លីរបស់ពួកគេ និងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀត ដែលធ្វើការនៅក្នុងវិស័យដីធ្លី ក្នុងគោលដៅផ្តល់ការគាំទ្រ និងការការពារជាបន្ថែមដល់ពួកគេ។

## ជ. ការតស៊ូមតិលើសិទ្ធិដីធ្លី និងការអប់រំ

២៤០. អាស្រ័យដោយកំណើននៃការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំ រដ្ឋាភិបាលគួរចាត់វិធានការនានា ដើម្បីអនុវត្តជាបន្តនូវច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី រួមមានការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលស្តីពីវិធានណែនាំការអនុវត្តន៍ច្បាប់នេះ។ ក្រសួងមហាផ្ទៃ គួរបន្តផ្តល់ការណែនាំ និងលើកកំពស់ការយល់ ដឹងក្នុងចំណោមអាជ្ញាធរថ្នាក់ខេត្ត និងរាជធានី រួមទាំងមន្ត្រីអនុវត្តច្បាប់នានាអំពី របៀបអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី នៅក្នុងលក្ខណៈមួយដែលអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។

២៤១. រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត គួរធានាថាអង្គការសង្គមស៊ីវិល សហគមន៍ និងបណ្តាញសហគមន៍ទាំង ឡាយ មានសេរីភាពក្នុងការចូលរួមក្នុងសកម្មភាពនានា ដែលទាក់ទងនឹងការអប់រំសិទ្ធិដីធ្លី ដោយពុំគិតពីកម្មវិធីដំណាលគ្នា ឧទាហរណ៍ កម្មវិធីទាក់ទងនឹងការរៀបចំសម្រាប់ការបោះឆ្នោត និងតាមដានការបោះឆ្នោត នីតិវិធីផ្តល់កម្មសិទ្ធិដីធ្លី និងសកម្មភាពនៃគណៈបក្សនយោបាយនានា។

២៤២. រដ្ឋាភិបាលគួរចូលរួមក្នុងការគាំទ្រសហគមន៍នានា ដើម្បីឲ្យពួកគេកាន់តែយល់ដឹងច្បាស់លាស់អំពី សិទ្ធិនានារបស់ពួកគេ ក្រោមក្របខណ្ឌច្បាប់ជាតិ ដែលគ្រប់គ្រងដីធ្លី និងប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិ។ កិច្ចការនេះ រួមបញ្ចូលទាំងរបៀបដាក់បណ្តឹងតវ៉ាតាមផ្លូវច្បាប់ និងការធ្វើបណ្តឹងទាមទារ។

## ឧបសម្ព័ន្ធ ៖

# សម្បទានដីដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពារធម្មជាតិ ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យ (ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣) *- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ -*

| ១. ឧទ្យានជាតិ/ឧទ្យានធម្មជាតិ | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះតំបន់ការពារធម្មជាតិ | ឈ្មោះក្រុមហ៊ុន ឬ គម្រោង, ទំហំដី និងស្ថានភាពគតិយុត្តិនៃដី, និងគោលបំណងនៃដីសម្បទាន | | | | កាលបរិច្ឆេទនៃការអនុញ្ញាត/ ផ្តល់ដីសម្បទាន | ឯកសារដែលមានពាក់ព័ន្ធដីសម្បទានការកំណត់ ឬ ការធ្វើអនុប្បយោគដី ស្ថិតក្នុងតំបន់ការពារធម្មជាតិ ឬ កិច្ចសន្យាសម្បទានដី ឬ កិច្ចសន្យាជួលដី |
| | ឈ្មោះ | ទំហំដី (ហិកតា) | ការកំណត់ផ្ទៃដី | គោលបំណង | | |
| ១. ឧទ្យានជាតិ ព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" បង្កើតឡើងដោយៈ | ១.គីរីរម្យ អេកូទួរីសឹម អ៊ិនវេសមេន (Kirirom Eco-Tourism Investment) | ៦០៩ | តំបន់ប្រើប្រាស់ដោយចីរភាព | ទេសចរណ៍ធម្មជាតិ | ១ តុលា ២០០៩ | អនុក្រឹត្យលេខ ១៧៣ ចុះថ្ងៃទី ១ តុលា ២០០៩ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ៣៥.០០០ ហិកតា<br><br>**ទីតាំង:** ស្ថិតក្នុងខេត្ត កំពង់ស្ពឺ និង កោះកុង<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ២. យន់ ឃាងមីនើរ៉ល (ខេមបូឌា) (Yun Khean Minerals (Cambodia) Co., Ltd) | ២៩០ +១០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ២១ មិនា ២០១១ | អនុក្រឹត្យលេខ៥១ ចុះថ្ងៃទី២១ មិនា ២០១១ ដោយយោងអនុក្រឹត្យ១៥៦ ចុះថ្ងៃទី ៧ធ្នូ ២០១០ ផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៣. ជាន ខីង (ខេមបូឌា) អ៊ិនធើណាស្យូណាល់ អ៊ិនវេសមេន (Jian King (Cambodia) International Investment Co., Ltd) | ៨.៥៦៨ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំស្រល់ ចៀរជ័រស្រល់ និង បង្កើតរោងចក្រកែច្នៃផលិតផលជ័រស្រល់ | ៤ មករា ២០១២ | - អនុក្រឹត្យលេខ ០៣ ចុះថ្ងៃទី ៤ មករា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ៤៣ ចុះថ្ងៃទី១៦ មិនា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ផង ចាត់បញ្ចូល ផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៤. ខីង ឆេង (ខេមបូឌា) អ៊ិនធើណាស្យូណាល់ អ៊ិនវេសមេន (King Cheng (Cambodia) International Investment Co., Ltd) | ៧.៦៦៨ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំស្រល់ ចៀរជ័រស្រល់ និង បង្កើតរោងចក្រកែច្នៃផលិតផលជ័រស្រល់ | ៤ មករា ២០១២ | - អនុក្រឹត្យលេខ ០៤ ចុះថ្ងៃទី ៤ មករា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ៤៤ ចុះថ្ងៃទី១៦ មិនា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៥. A2A ថោន (ខេមបូឌា)<br><br>(A2A TOWN (Cambodia) Co., Ltd) | ២.០០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ទេសចរណ៍ធម្មជាតិ | ៤ មករា ២០១២ | - អនុក្រឹត្យលេខ ០៥ ចុះថ្ងៃទី ៤ មករា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ៤៥ ចុះថ្ងៃទី១៦ មិនា ២០១២ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៦. A2A ថោន (ខេមបូឌា)* (A2A Town (Cambodia) Co., Ltd) | ៧.៦៦៨ | តំបន់ប្រើប្រាស់ដោយចីរភាព | ទីក្រុងទេសចរណ៍ធម្មជាតិ ទីវាលវាយកូនហ្គោល ដំណាំស្រល់ ប្រមូលជ័រស្រល់ និង បង្កើតរោងចក្រចំរាញ់ជ័រស្រល់ | ៧ មិថុនា ២០១២ | អនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ៧ មិថុនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | | | | | | |
| **២. ឧទ្យានជាតិព្រះមុនីវង្ស** | ១. ខេមលេន (Camland Co., Ltd) | ១៦.០០០ (៥.៤៣៩ ហត ស្ថិតក្នុងឧទ្យានជាតិបូកគោ) | តំបន់ការពារ | ដំណាំដូងប្រេង | ២៦ តុលា ២០០០ | កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ថ្ងៃទី២៦ តុលា ២០០០។ យោងគេហទំព័រ៖ http://www.elc.maff.gov.kh/en/profile/15-kpt/42-kp-camland.html |

| | | | | | | |
|---|---|---|---|---|---|---|
| "ភ្នំបូកគោ"<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ១៤០.០០០ ហិកតា<br><br>**ទីតាំង:** ស្ថិតក្នុងខេត្តកំពត និង ព្រះសីហនុ<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ២. អ៊ី សេង ខូ អិលធីឌី (Y Seng Co., Ltd) | ២.៤៣២ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម | ១៣ សីហា ២០០៩ | អនុក្រឹត្យលេខ ១២៨ ចុះថ្ងៃទី ១៣ សីហា ២០០៩ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៣. ម៉ុង ឫទ្ធីគ្រុប (Mong Reththy Group Co., Ltd) | ៤.០៥៧,៧៥ | តំបន់ប្រើប្រាស់ដោយចីរភាព | ទេសចរណ៍ធម្មជាតិ និង កសិទេសចរណ៍ | ២០ សីហា ២០០៩ | អនុក្រឹត្យលេខ ១៣៣ (ចំណុច "ក") ចុះថ្ងៃទី ២០ សីហា ២០០៩ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៤. វីទីស ហ្គ្រីន ផ្លេនថេសិន (ខេមបូឌា) (Virtus Green Plantation (Cambodia) PTE., Ltd) | ៦.៧១៨ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំដូងប្រេង កៅស៊ូ ស្រូវ កាហ្វេ | ២២ កុម្ភៈ ២០១១ | - អនុក្រឹត្យលេខ ៣១ ចុះថ្ងៃទី ២២ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ៨៨ ចុះថ្ងៃទី២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៥. សុខា អូតែល (Sokha Hotel)<br><br>(Kampot and Preah Sihanouk) | ១៨.៩៨៧ | តំបន់ប្រើប្រាស់ដោយចីរភាព | អភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិ | ៣០ មិនា ២០១១ | - អនុក្រឹត្យលេខ ៥៩ ចុះថ្ងៃទី ៣០ មិនា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ១៨៤ ចុះថ្ងៃទី១២ សីហា ២០១១ ចាត់បញ្ចូលផ្ទៃដីដែលបាន |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | កំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | | | | | | |
| **៣. ឧទ្យានជាតិកែប**<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ៥.០០០ ហាត<br><br>**ទីតាំង:** ស្ថិតក្នុងខេត្តកែប<br><br>**ទំហំផ្ទៃដីបច្ចុប្បន្ន:** ១.១៥២ ហាត (ទំហំផ្ទៃដីឧទ្យានជាតិត្រូវបាន កាត់បន្ថយតាមរយៈ អនុក្រឹត្យរដ្ឋាភិបាលលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០)<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | (មិនមានពត៌មាន) | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **៤. ឧទ្យានជាតិរាម**<br><br>**បង្កើតឡើងដោយៈ** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដីៈ** ១៥០.000 ហិកតា<br><br>**ទីតាំងៈ** ស្ថិតក្នុងខេត្ត ព្រះសីហនុ<br><br>**សមត្ថកិច្ចគ្រប់គ្រងៈ** ក្រសួងបរិស្ថាន | ១. អេវើរហ្គ្រីន សាក់សេស អែនអាស៊ី រីសត ឌីវេលុប្បមែន ខូអិលធីឌី (Evergreen Success and Asia Resort Co., Ltd) | ២.៣៧៧ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | អភិវឌ្ឍន៍វិស័យទេសចរណ៍ | ២៣ មិថុនា ២០០៨ | - អនុក្រឹត្យលេខ ៧១ ចុះថ្ងៃទី២៣ មិថុនា ២០០៨ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង ធ្វើអនុបយោគ ផ្ទៃដីនេះទៅជាទ្រព្យសម្បត្តឯកជនរបស់រដ្ឋ សម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ២. រូយ៉ាល់ហ្រ្គួប (Royal Group) | ១.៤០៨ | តំបន់ប្រើប្រាស់ដោយចីរភាព | ទេសចរណ៍ធម្មជាតិ | ១៣ សីហា ២០០៩ | - អនុក្រឹត្យលេខ១២៨ ចុះថ្ងៃទី ១៣ សីហា ២០០៩ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ១៨៦ ចុះថ្ងៃទី៣០ តុលា ២០០៩ ស្តីពីការចាត់បញ្ចូលផ្ទៃដីដែលបានកំណត់ នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៣. វិមាន សីលា អិលធីឌី (Vimean Seila Ltd) (Preah Sihanouk) | ៩៤៧ | តំបន់ប្រើប្រាស់ដោយចីរភាព | ទេសចរណ៍ធម្មជាតិ | ១៨ មិនា ២០១០ | អនុក្រឹត្យលេខ ៣៤ ចុះថ្ងៃទី ១៨ មិនា ២០១០ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **៥. ឧទ្យានជាតិបុទុមសាគរ**<br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br>**ទំហំផ្ទៃដី:** ១៧១.២៥០ ហិកតា<br>**ទីតាំង:** ស្ថិតក្នុងខេត្ត កោះកុង<br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន<br>**ទំហំផ្ទៃដីបច្ចុប្បន្ន:** ១៣៥.២៥០ ហិកតា<br>(ទំហំផ្ទៃដីឧទ្យានជាតិត្រូវបានកាត់បន្ថយតាមរយៈព្រះរាជក្រឹត្យចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ២០០៨ ដែលព្រះរាជក្រឹត្យ | ១. ឌឹ ហ្គ្រីន រិច ខូ អិលធីឌី (The Green Rich Co., Ltd) | ៦០.២០០ | តំបន់ការពារ | ដំណាំដូងប្រេង ឈើហូបផ្លែ និងអាកាស្យា | ២៥ វិច្ឆិកា ១៩៩៨ | ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី ២៥ វិច្ឆិកា ១៩៩៨។ យោងគេហទំព័រ http://www.elc.maff.gov.kh/en/profile/17-kkg/58-kk-greenrich.html |
| | ២. យូនៀន ដេវីលប្បមេន គ្រុប (Union Development Group Co., Ltd) | ៣៦.០០០ | ដីឯកជនរបស់រដ្ឋ | តំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម និងរមណីយដ្ឋានទេសចរណ៍ | ៩ ឧសភា ២០០៨ | ព្រះរាជក្រឹត្យថ្ងៃទី ៩ មេសា ២០០៨ ធ្វើវិសោធនកម្មព្រះរាជក្រឹត្យថ្ងៃទី១ វិច្ឆិកា ១៩៩៣ ដោយកាត់ផ្ទៃដីទំហំ ៣៦.០០០ ហិកតាចេញពីផ្ទៃដី ១៧១.២៥០ ហិកតារបស់ឧទ្យានជាតិបុទមសាគរ និងចាត់បញ្ចូលផ្ទៃដីទំហំ ៣៦.០០០ហិកតានេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។<br>- កិច្ចសន្យាជួលទីតាំងចុះថ្ងៃទី ៩ ឧសភា ២០០៨ រវាងរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន។ |

| | | | | | | |
|---|---|---|---|---|---|---|
| នេះធ្វើវិសោធនកម្ម ព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ដោយ កាត់ផ្ទៃដីទំហំ ៣.៦០០០ ហិកតា ចេញពីឧទ្យានជាតិ)<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ៣. JW ខេមបូឌា អេកូ ហូលីដេ (JW Cambodia Eco Holidays) | ៥.០០០ | តំបន់ប្រើប្រាស់ដោយចីរភាព | ទេសចរធម្មជាតិ | ២០ សីហា ២០០៩ | អនុក្រឹត្យលេខ ១៣៣ (ចំណុច "ខ") ចុះថ្ងៃទី ២០ សីហា ២០០៩ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៤. កោះកុង អេស អ៊ី ហ្សិត ខូ អិលធីឌី (Koh Kong SEZ Co., Ltd) | ៩.៩៧៧ | តំបន់ប្រើប្រាស់ដោយចីរភាព | កសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម | ២០ សីហា ២០០៩ | អនុក្រឹត្យលេខ ១៣៣ (ចំណុច "គ") ចុះថ្ងៃទី ២០ សីហា ២០០៩ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៥. អិល.វ៉ាយ.ភី. គ្រុប (L.Y.P Group Co., Ltd) | ៤.១០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | កសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម | ១២ មិនា ២០១០ | - អនុក្រឹត្យលេខ ៣១ ចុះថ្ងៃទី ១២ មិនា ២០១០ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ៣៨ ចុះថ្ងៃទី ១៣ មេសា ២០១០ ស្តីពីការចាត់បញ្ចូលផ្ទៃដីដែលបានកំណត់ ៤.១០០ ហិកតានេះ ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីផ្តល់ជូនក្រុមហ៊ុនក្រោមលក្ខខណ្ឌជួល ឬសម្បទាន។ |
| | ៦. ឋានសួគ៌ ចំកាត់ (Paradise Investment Co., Ltd) | ៩.១៣៧ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម | ១ មេសា ២០១១ | អនុក្រឹត្យលេខ ៦០ ចុះថ្ងៃទី ១មេសា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | ៧. សីណូមិចស៊ីម អិនវេសមិន ខូ អិលធីឌី (Sinomexim Investment Co., Ltd) | ៩.២៨០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | កសិកម្ម-ទេសចរណ៍ | ២២ កក្កដា ២០១១ | -អនុក្រឹត្យលេខ១៧១ ចុះថ្ងៃទី ២២ កក្កដា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ២៣៩ ចុះថ្ងៃទី ២៨ តុលា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៨. យូនៀន ដេវីលប្បមេន គ្រុប (Union Development Group Co., Ltd) | ៩.១០០ | តំបន់ប្រើប្រាស់ដោយចីរភាព | អាងស្តុកទឹក និងវារីអគ្គិសនី | ៣ សីហា ២០១១ | អនុក្រឹត្យលេខ ១៧៨ ចុះថ្ងៃទី ៣ សីហា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | | | | | | |
| **៦. ឧទ្យានជាតិភ្នំគូលេន**<br><br>**បង្កើតឡើងដោយ:**<br>ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ | (មិនមានព័ត៌មាន) | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **ទំហំផ្ទៃដី:** ៣៧.៥០០ ហិកតា<br>**ទីតាំង:** ស្ថិតក្នុងខេត្ត សៀមរាប<br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | | | | | | |
| | | | | | | |
| **៧. ឧទ្យានជាតិវីរៈជ័យ**<br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br>**ទំហំផ្ទៃដី:** ៣៣២.៥០០ហិកតា<br>**ទីតាំង:** ស្ថិតក្នុងខេត្តស្ទឹងត្រែង និងរតនគីរី<br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ១. ទ្រី ភាព អ៊ីមផត អិចផត (Try Pheap Import Export Co., Ltd)<br>(ស្រុកតាវែង ខេត្តរតនគិរី) | ៩.៧០៩ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ៩ កុម្ភៈ ២០១១ | - អនុក្រឹត្យលេខ ២៥ ចុះថ្ងៃទី ៩ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៩២ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ២. ស្រ៊ុន សុវណ្ណភូមិ អ៊ិនវេសមេន (Srun Sovannaphoum Investment Co., Ltd)<br>(ស្រុកតាវែង ខេត្តរតនគិរី) | ៨.៩៩៨ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | កៅស៊ូ និងទេសចរណ៍ធម្មជាតិនិងតំបន់សេដ្ឋកិច្ចពិសេស | ១៥ កុម្ភៈ ២០១១ | - អនុក្រឹត្យលេខ ២៨ ចុះថ្ងៃទី ១៥ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ ៩០ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៣. នុភាព សុភី អ៊ិនវេសមេន (Noupheap Sophy Investment Co., Ltd) | ៩.០០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | កៅស៊ូ | ១៥ កុម្ភៈ ២០១១ | - អនុក្រឹត្យលេខ ២៩ ចុះថ្ងៃទី ១៥ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ ៨៩ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៤. ហ៊ង អាញ់ អណ្តូងមាស ខូ អិលធីឌី (Hong Anh Andong Meas Co., Ltd) | ៩.៧៨៥ | តំបន់ប្រើប្រាស់ដោយចីរភាព | កៅស៊ូ | ១៤ មិនា ២០១១ | អនុក្រឹត្យលេខ ៤១ ចុះថ្ងៃទី ១៤ មិនា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៥. អឹម ឌី អេស ថ្មដាអេស អ៊ីហ្សិត (MDS Thmorda SEZ Co., Ltd) | ៩.១៨៦ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ៩ កុម្ភៈ ២០១១ | - អនុក្រឹត្យលេខ ២៦ ចុះថ្ងៃទី ៩ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ ៩១ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៦. ហ្វូ ឆេង ហៃ (ខេមបូឌា) ខូ អិលធីឌី | ៧.០៧៩ | តំបន់ប្រើប្រាស់ដោយចីរភាព– | ដំណាំកសិ-ឧស្សាហកម្ម | ១៩ ឧសភា ២០១១ | - អនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ១៩ ឧសភា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ |

| | | | | | | |
|---|---|---|---|---|---|---|
| | (Fu Sheng Hai (Cambodia) Co., Ltd.) | | ដីឯកជនរបស់រដ្ឋ | តំបន់ទេសចរណ៍ធម្មជាតិ តំបន់សេដ្ឋកិច្ចពិសេស និងមជ្ឈមណ្ឌលកំសាន្ត | | ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ២៤៥ ចុះថ្ងៃទី ២៨ តុលា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |
| | ៧. ជីង ចុង តៀន ខូ អិល ធីឌី (Jing Zhong Tian Co., Ltd) | ៩.៩៣៦ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម តំបន់ទេសចរណ៍ធម្មជាតិ តំបន់សេដ្ឋកិច្ចពិសេស និងមជ្ឈមណ្ឌលកំសាន្ត។ | ១៩ ឧសភា ២០១១ | - អនុក្រឹត្យលេខ ៨៤ ចុះថ្ងៃទី ១៩ ឧសភា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ២៤៤ ចុះថ្ងៃទី ២៨ តុលា ២០១១ ដោយយោងអនុក្រឹត្យខាងលើផង ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ |

## ២. ដែនជំរកសត្វព្រៃ

| ឈ្មោះតំបន់ការពារធម្មជាតិ | ឈ្មោះក្រុមហ៊ុន ឬ គម្រោង, ទំហំដី និងស្ថានភាពគតិយុត្តិនៃដី, និងគោលបំណងនៃដីសម្បទាន | | | | កាលបរិច្ឆេទនៃការអនុញ្ញាត/ផ្តល់ដីសម្បទាន | ឯកសារដែលមានពាក់ព័ន្ធដីសម្បទាន, ការកំណត់ ឬ ការធ្វើអនុប្បយោគដី ស្ថិតក្នុងតំបន់ការពារធម្មជាតិ ឬ កិច្ចសន្យាសម្បទានដី ឬ កិច្ចសន្យាជួលដី |
|---|---|---|---|---|---|---|
| | ឈ្មោះ | ទំហំដី (ហិកតា) | ការកំណត់ផ្ទៃដី | គោលបំណង | | |

| | | | | | | |
|---|---|---|---|---|---|---|
| **១. ភ្នំឱរាល់**<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ២៥៣.៧៥០ហិកតា<br><br>**ទីតាំង:** ស្ថិតក្នុងខេត្ត ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ស្ពឺ<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ១. ញូវ កូសម៉ូ ឌីវេឡុបមេន ខូ អិលធីឌី (New Cosmos Development Co., Ltd) | ១.៩០០ | តំបន់ការពារ | ទេសចរណ៍ធម្មជាតិ (ហេត្ថារចនាសម្ព័ន្ធទេសចរណ៍ និងលំហែកាយ មានទាំង ភូមិសម្រាប់ងូតទឹកក្តៅធម្មជាតិ) | ឧសភា ២០០៤ | លិខិតទំនាក់ទំនងរវាងក្រុមហ៊ុន និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងអំឡុងឆ្នាំ២០០៣ និងកំណត់ហេតុស្តីពីការចុះកំណត់ព្រំប្រទល់ដី (តេទឹកពុះ) ដែលស្នើសុំដោយក្រុមហ៊ុន ចុះថ្ងៃទី១២ ឧសភា ២០០៤ (សូមមើលផងដែររបាយការណ៍ឆ្នាំ ២០០៧ របស់តំណាងពិសេស ទំព័រ១៤) |
| | ២. HLH អេហ្គ្រីខាលឈើរ ខេមបូឌា (HLH Agriculture Cambodia Co., Ltd.) | ៩.៩៨៥ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ៣០ មិនា ២០០៩ | អនុក្រឹត្យលេខ ៤៨ ចុះថ្ងៃទី ៣០ មិនា ២០០៩ ស្តីពីការចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៩.៩៨៥ ហិកតា ដែលបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៣. ហ្រ្គេត ហ្វៀល (ខេមបូឌា) អ៊ិនធីណាស្យូណាល់ លីមីធីត<br><br>(Great Field (Cambodia) | ៩.០៥៩ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ៨ មករា ២០១០ | - អនុក្រឹត្យលេខ ០៩ ចុះថ្ងៃទី៨ មករា ២០១០ ស្តីពីការកំណត់ផ្ទៃដី ចំនួន ២ កន្លែង ស្ថិតក្នុងដែនជំរកសត្វព្រៃភ្នំឱរាល់ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ផ្តល់ជូនក្រុមហ៊ុន (ហ្រ្គេត ហ្វៀល និង យេឡូ ហ្វៀល)។<br>- អនុក្រឹត្យលេខ ១៩ ចុះថ្ងៃទី ២៩ មករា ២០១០ ធ្វើអនុបយោគផ្ទៃដី ៩.០៥៩ |

| | | | | | | |
|---|---|---|---|---|---|---|
| | International Ltd) | | | | | ហិកតា និងចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សម្រាប់ផ្តល់ជូន ក្រុមហ៊ុនក្រោមលក្ខខ័ណ្ឌជួល ឬសម្បទាន។ |
| | ៤. ហ្វេលហ្វៀល (ខេមបូឌា) អ៊ិនធឺណាស្យូណាល់ លីមីធីត<br><br>(Yellow Field (Cambodia) International Limited) | ៨.៩៩១ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ៨ មករា ២០១០ | - អនុក្រឹត្យលេខ ០៩ ចុះថ្ងៃទី ៨ មករា ២០១០ ស្តីពីការកំណត់ផ្ទៃដី ២កន្លែង ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ សម្រាប់ផ្តល់ជូនក្រុមហ៊ុន (ហ្វេលហ្វៀល និង យេឡូហ្វៀល)។<br>- អនុក្រឹត្យលេខ ២១ ចុះថ្ងៃទី ២៩ មករា ២០១០ ធ្វើអនុបយោគផ្ទៃដី ៨.៩៩១ ហិកតា និងចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សម្រាប់ផ្តល់ជូន ក្រុមហ៊ុនក្រោមលក្ខខ័ណ្ឌជួល ឬសម្បទាន ដើម្បីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម។ |
| | ៥. កំពង់ស្ពឺ ស៊ូហ្គើរ (Kampong Speu Sugar Co., Ltd.) | ៤.៧០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំអំពៅ | ២១ មិនា ២០១១ | - អនុក្រឹត្យលេខ ១៧ ចុះថ្ងៃទី ២១ មិនា ២០១១ (ចំណុចទី៤) ស្តីពីការកំណត់ផ្ទៃដី ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ ៤៧ ចុះថ្ងៃទី ២១ មិនា ២០១១ ចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤.៧០០ ហត |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | សម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៦.ឫទ្ធី គីរី សាគរ (Reththy Kiri Sakor Co., Ltd) | ១.៤០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ៦ មេសា ២០១១ | - អនុក្រឹត្យលេខ ៦៤ ចុះថ្ងៃទី ៦ មេសា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។[២៧៩]<br>- អនុក្រឹត្យលេខ ៩៥ ចុះថ្ងៃទី ២៤ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន។[២៨០] |
| | ៧.យីះចៀ ធួរីហ្សឹម ឌីវេឡុបមេន (ខេមបូឌា) ខមភេនី281 (YEEJIA Tourism Development (Cambodia) Company) | ១.០០០ | តំបន់ប្រើប្រាស់ដោយចីរភាព | កសិ-ទេសចរណ៍ និងតំបន់ទេសចរណ៍ធម្មជាតិតេទឹកពុះ | ៣ ឧសភា ២០១១ | អនុក្រឹត្យលេខ ៧៧ ចុះថ្ងៃទី ៣ ឧសភា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៨. ៩៩ អភិវឌ្ឍន៍ កសិកម្ម ខូអិលធីឌី (99 Aphivath Kasekam | ១.៤០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ២៦ មករា ២០១២ | អនុក្រឹត្យលេខ ១៦ ចុះថ្ងៃទី ២៦ មករា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូន |

[២៧៩] ក្នុងអនុក្រឹត្យលេខ ១៦ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១២ មានចែងថា អនុក្រឹត្យនេះត្រូវនិរាករណ៍។

[២៨០] ក្នុងអនុក្រឹត្យលេខ ២២ ចុះថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ២០១២ មានចែងថា អនុក្រឹត្យនេះត្រូវនិរាករណ៍។

[២៨១] សម្បទានដីដែលបានផ្តល់ឲ្យក្រុមហ៊ុននេះមើលទៅមានភាពត្រួតលើផ្នែកខ្លះនៃសម្បទានដីទំហំ ១.៩០០ ហត ដែលផ្តល់ឲ្យក្រុមហ៊ុន New Cosmos Development Co.Ltd ក្នុងខែឧសភា ឆ្នាំ២០០៤ ។

| | | | | | | |
|---|---|---|---|---|---|---|
| | Co., Ltd) | | | | | ក្រុមហ៊ុន។ អនុក្រឹត្យនេះក៏បានចែងថា "និរាករណ៍អនុក្រឹត្យលេខ ៦៤ ចុះថ្ងៃទី៦ ឧមករា ២០១១"។[២៨២]<br>- អនុក្រឹត្យលេខ ២២ ចុះថ្ងៃទី ០៦ កុម្ភៈ ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | | | | | | |
| **២. ពាមក្រសោប**<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ២៣.៧៥០ ហិកតា<br><br>**ទីតាំង:** ស្ថិតក្នុងខេត្តកោះកុង<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | (មិនមានពត៌មាន) | | | | | |

[២៨២] អនុក្រឹត្យលេខ ៦៤ ចុះថ្ងៃទី ៦ មេសា ឆ្នាំ២០១១ ស្តីពីការកំណត់ផ្ទៃដីទំហំ ១.៤០០ហត ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន ឫទ្ធី គីរីសាគរ។

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| **៣. ភ្នំសំកុស**<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ៣៣៣.៧៥០ ហិកតា<br><br>**ទីតាំង:** ស្ថិតក្នុងខេត្តកោះកុង ពោធិសាត់ និងបាត់ដំបង<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ១. គីន សា អភិវឌ្ឍន៍ ខូ អិលធីឌី (Kin Sa Apivath Co., Ltd)<br><br>(ខេត្តពោធិសាត់) | ១.៩៥០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកៅស៊ូ | ៩ កក្កដា ២០១០ | អនុក្រឹត្យលេខ ៦៥ ចុះថ្ងៃទី ៩ កក្កដា ២០១០ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ២.អិម ឌីអេស អាហារ័ណ នីហារ័ណ (MDS Import Export Co., Ltd)<br><br>(ខេត្តពោធិសាត់) | ៤.៤០២ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកៅស៊ូ | ៥ សីហា ២០១០ | - អនុក្រឹត្យលេខ ៩២ ចុះថ្ងៃទី ៥ សីហា ២០១០ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៣. អិម ឌីអេស អាហារ័ណ នីហារ័ណ (MDS Import Export Co., Ltd)<br><br>(ខេត្តពោធិសាត់) | ១.៩៥០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកៅស៊ូ | ៣០ ធ្នូ ២០១០ | - អនុក្រឹត្យលេខ ១៧៦ ចុះថ្ងៃទី ៣០ ធ្នូ ២០១០ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ ១០ ចុះថ្ងៃទី ១២ មករា ២០១១ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **៤. រនាមដូនសំ**<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ១៧៨.៧៥០ ហ.ត<br><br>**ទំហំផ្ទៃដីបច្ចុប្បន្ន:** ៤០.០២១ ហ.ត (ទំហំផ្ទៃដីត្រូវបានកាត់បន្ថយតាមរយៈព្រះរាជក្រឹត្យចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៣)<br><br>**ទីតាំង:** ស្ថិតក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យ<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ១. លាង ហួរហុង (Leang Hour Hong Import and Export, Agro Industry Development and Processing) | ៨.០០០ | តំបន់ការពារ | ដំណាំអំពៅ និងដំឡូងមី | ៧ មិថុនា ២០០០ | - ក្រសួងបរិស្ថាន លិខិតលេខ ៣៣៤បស ចុះថ្ងៃទី ១០ សីហា ១៩៩៩ ស្តីពីការយល់ ព្រម និងអនុញ្ញាតិចំពោះការវិនិយោគ ដំណាំកសិ-ឧស្សាហកម្ម លើផ្ទៃដី ៥.០០០ហត ក្នុងដែនជំរកសត្វព្រៃ រនាមដូនសំ ក្នុងខេត្តបាត់ដំបង។<br><br>-ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅថ្ងៃទី ៧ មិថុនា ២០០០។ យោងគេហទំព័រ៖ *http://www.elc.maff.gov.kh/en/profile/9-btb/21-btb-leang.html* |
| | ២. សួន មានសម្បត្តិ ខូអិលធីឌី (Soun Mean Sambath Co.; Ltd) | ៤.០៩៥ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម | ៦ មេសា ២០១១ | អនុក្រឹត្យលេខ ៦៣ ចុះថ្ងៃទី ៦ មេសា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>- អនុក្រឹត្យលេខ ៩៤ ចុះថ្ងៃទី ២៤ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ៣. BSC អ៊ីមផត អិចផត ខូអិលធីឌី* (BSC Import Export Co., | ៤.៥៥៧ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម | ១២ មិថុនា ២០១២ | អនុក្រឹត្យលេខ ៩០ ចុះថ្ងៃទី ១២ មិថុនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូន |

| | | | | | | |
|---|---|---|---|---|---|---|
| | Ltd) | | | | | ក្រុមហ៊ុន។ |
| | | | | | | |
| ៥. គូលេនព្រហ្មទេព<br><br>**បង្កើតឡើងដោយ:** ព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣<br><br>**ទំហំផ្ទៃដី:** ៤០២.៥០០ ហ.ត<br><br>**ទីតាំង:** ស្ថិតក្នុងខេត្តសៀមរាប ព្រះវិហារ និងឧត្តមានជ័យ<br><br>**សមត្ថកិច្ចគ្រប់គ្រង:** ក្រសួងបរិស្ថាន | ១.ទីមរីង រ៉ាប់ប៊ើរ ខូអិលធីឌី (Toming Rubber Co., Ltd.) | ៧.៧៥០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម | ១៤ មិថុនា ២០១១ | អនុក្រឹត្យលេខ ១១២ ចុះថ្ងៃទី ១៤ មិថុនា ២០១១ ស្ដីពីការកំណត់ផ្ទៃដី ២ កន្លែង ក្នុងតំបន់ការពារ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្ដល់ជូនក្រុមហ៊ុន (ទីមរីង រ៉ាប់ប៊ើរ ខូអិលធីឌី និង ដាតារ៉ាប់ប៊ើរ (ខេមបូឌា) ខូអិលធី )។ |
| | ២. ដាតារ៉ាប់ប៊ើរ (ខេមបូឌា) ខូអិលធី (Data Rubber (Cambodia) Co., Ltd.) | ៧.៧០០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម | ១៤ មិថុនា ២០១១ | អនុក្រឹត្យលេខ ១១២ ចុះថ្ងៃទី ១៤ មិថុនា ២០១១ ស្ដីពីការកំណត់ផ្ទៃដី ២ កន្លែង ក្នុងតំបន់ការពារ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្ដល់ជូនក្រុមហ៊ុន (ទីមរីង រ៉ាប់ប៊ើរ ខូអិលធីឌី និង ដាតារ៉ាប់ប៊ើរ (ខេមបូឌា) ខូអិលធី )។ |
| | ៣. លី ឈួង សំណង់ & អាហរ័ណ នីហរ័ណ (Ly Chhoung Construction Import Export) | ៦.០០០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ៣ មិថុនា ២០១១ | -អនុក្រឹត្យលេខ ១០៦ ចុះថ្ងៃទី ៣ មិថុនា ២០១១ ស្ដីពីការកំណត់ផ្ទៃដីទំហំ ៦.០០០ ហត ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្ដល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៦៣ ចុះថ្ងៃទី ២៣ មេសា ២០១២ ស្ដីពីការកំណត់ផ្ទៃដីទំហំ ៦.០០០ ហត ទៅជាតំបន់ប្រើប្រាស់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ អនុក្រឹត្យនេះចែងផងដែរថា "និរាករណ៍លិខិតរបស់ទីស្តីការគណរដ្ឋមន្ត្រីចុះថ្ងៃទី ៣១ ឧសភា ២០១១ និងនិរាករណ៍អនុក្រឹត្យលេខ ១០៦ ចុះថ្ងៃទី ៣ មិថុនា ២០១១។ |
| | ៤. សិរី មុនី ត្រេនស្ព័រថេសិន & ខនស្ត្រាក់សិន (Serey Mony Transportation & Construction Co., Ltd) | ៦.៨៧០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ១៥ មិថុនា ២០១១ | អនុក្រឹត្យលេខ ១១៤ ចុះថ្ងៃទី ១៥ មិថុនា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៥. ហួត ម៉េង រីតា ខូអិលធីឌី (Hout Meng Rita Co., Ltd) | ៣.០០០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ១១ សីហា ២០១១ | អនុក្រឹត្យលេខ ១៨២ ចុះថ្ងៃទី ១១ សីហា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៦. ខេមបូឌា ដោន ផ្លេនថាសិន អិលធីឌី (Cambodia Dawn Plantation Co., Ltd) | ៩.២៣៧ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ៧ កញ្ញា ២០១១ | -អនុក្រឹត្យលេខ ២០៦ ចុះថ្ងៃទី ៧ កញ្ញា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ២៨១ ចុះថ្ងៃទី ១៣ ធ្នូ ២០១១ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ៧. អ៊ីកសែល ខាសធើរ ផ្លេនថេសិន ខូអិលធីឌី (Excel Caster Plantation Co., Ltd) | ៧.៤៧២ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ៨ វិច្ឆិកា ២០១១ | អនុក្រឹត្យលេខ ២៥៨ ចុះថ្ងៃទី ៨ វិច្ឆិកា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ៨. បេស រ៉ូយ៉ាល់ (ខេ) ខូអិលធីឌី (Best Royal (K) Co., Ltd) | ៦.៥០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ២៣ វិច្ឆិកា ២០១១ | -អនុក្រឹត្យលេខ២៦៣ ចុះថ្ងៃទី ២៣ វិច្ឆិកា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ០៧ ចុះថ្ងៃទី ១៨ មករា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៩. តៃនីញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ (Tay Ninh Siem Reap Aphivath Caoutchouch Co., Ltd) | ៧.៦០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ២៣ វិច្ឆិកា ២០១១ | អនុក្រឹត្យលេខ ២៦៤ ចុះថ្ងៃទី ២៣ វិច្ឆិកា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ០៦ ចុះថ្ងៃទី ១៨ មករា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ១០. នេតឈើរ ផ្លេនថេសិន (ខេ អេឆ) ខូ អិលធីឌី (Nature Plantation (K.H) Co., Ltd) | ៩.០២០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ១ ធ្នូ ២០១១ | អនុក្រឹត្យលេខ ២៧១ ចុះថ្ងៃទី ១ ធ្នូ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ០៨ ចុះថ្ងៃទី ១៨ មករា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ១១. ប៊ី.វី.ប៊ី (ខេមបូឌា) អេហ្គ្រីខលឈើរ ឌីវេឡុបមេន (B.V.B (Cambodia) Agriculture Development Co.,Ltd) | ៣.១៣៤ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | Agro-industrial crop and rubber | ២០ មករា ២០១២ | -អនុក្រឹត្យលេខ ១៤ ចុះថ្ងៃទី ២០ មករា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៤៨ ចុះថ្ងៃទី ១៦ មិនា ២០១២ ដោយយោងអនុក្រឹត្យខាងលើចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ១២. សុខ សំណាង ឌីវេឡុបមេន (Sok Samnang Development) | ១.៨៦៥ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ១៣ មិនា ២០១២ | -អនុក្រឹត្យលេខ ៣៩ ចុះថ្ងៃទី ១៣ មិនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ៧ មិថុនា ២០១២ ដោយយោងអនុក្រឹត្យខាងលើចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | ១៣. ខេមបូឌា ប្លូ ហេវិន លីមីតធីត (Cambodian Blue Haven Limited) | ៩.១២៩ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ១៣ មិនា ២០១២ | -អនុក្រឹត្យលេខ ៤០ ចុះថ្ងៃទី ១៣ មិនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ៧ មិថុនា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ១៤. ហួត ម៉េងរីតា ខូអិលធីឌី (Hout Mengrita Co.,Ltd) | ១.១៩៥ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ១៣ មិនា ២០១២ | -អនុក្រឹត្យលេខ ៤១ ចុះថ្ងៃទី ១៣ មិនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៨៤ ចុះថ្ងៃទី ៧ មិថុនា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ១៥. លន់ អេហ្គ្រីថេក អ៊ិនវេសមេន ខមភេនី (Lon Agritec Investment Company) | ៤.០៩៥ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ២៨ មិនា ២០១២ | -អនុក្រឹត្យលេខ ៥២ ចុះថ្ងៃទី ២៨ មិនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៨៦ ចុះថ្ងៃទី ៧ មិថុនា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ១៦. សេ ហុង ផ្លេនថេសិន ខមភេនី លីមីធីត (Se Hong Plantation Co., Ltd) | ៩.៧០០ | តំបន់ប្រើប្រាស់ដោយចីរភាព–ដីឯកជនរបស់រដ្ឋ | ដំណាំកសិ-ឧស្សាហកម្ម | ១១ មេសា ២០១២ | -អនុក្រឹត្យលេខ ៥៥ ចុះថ្ងៃទី ១១ មេសា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៨៧ ចុះថ្ងៃទី ៧ មិថុនា ២០១២ ដោយយោងអនុក្រឹត្យខាងលើ ចាត់បញ្ចូលជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់នេះ។ |
| | ១៧. យុន សៀ អ៊ឹមផត អិចផត* (Khun Sea Import Export) | ៨.២០០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ៧ មិថុនា ២០១២ | អនុក្រឹត្យលេខ ៧៨ ចុះថ្ងៃទី ៧ មិថុនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | ១៨. មេត្រីភាព កសិ-ឧស្សាហកម្ម* (Metrey Pheap Agro-Industry) | ៨.៥២០ | តំបន់ប្រើប្រាស់ដោយចីរភាព | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ និងចិញ្ចឹមសត្វ | ១២ មិថុនា ២០១២ | អនុក្រឹត្យលេខ ៩២ ចុះថ្ងៃទី ១២ មិថុនា ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨ | ស្រុករវៀង (ឃុំរមទម ឃុំរំដោះ ឃុំរបៀប និងឃុំរស្មី) | គីម ជា ទូន គ្រុប (Kim Chea Toun Group) | ៨.៨៤៦ | ដំណាំកសិ-ឧស្សាហកម្ម (កៅស៊ូ និងអាកាស្យា) និងដំណាំដទៃទៀត | ៦ កក្កដា ២០១១ | អនុក្រឹត្យលេខ ១៤៦ ចុះថ្ងៃទី ៦ កក្កដា ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើវិនិយោគដាំដំណាំ និងកំណត់ឲ្យក្រសួងកសិកម្ម និងក្រសួង បរិស្ថាន ក៏ដូចជាអជ្ញាធរពាក់ព័ន្ធដទៃទៀតមាននិតិវិធីជាបន្តសម្រាប់ការវិនិយោគនេះ។ | គួយ |
| ១៩ | ស្រុករវៀង | ឆាយណា គ្រេ្រត ខោស (China Great Cause) | ៥.៩៨០ | កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម | ៦ មិថុនា ២០១២ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ | គួយ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ដទៃទៀត | | ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទាន ដែលបានចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf) | |
| ២០ | ស្រុកសង្គមថ្មី | អេហ្វ ភី ម៉ាឡេស៊ី (ខេមបូឌា) ផ្លេនថេសិន ខូអិលធីឌី (FP Malaysia (Cambodia) Plantation Co., Ltd) | ៨.២០០ | កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មដទៃទៀត | ៣០ មេសា ២០១២ | ចុះកិច្ចសន្យាសម្បទានដីជាមួយ ក្រសួងកសិកម្ម (សូមមើលផងដែរៈ ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទាន ដែលបានចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf) | គួយ |
| ២១ | ស្រុកសង្គមថ្មី | អែមផល ហ្វកខឹស (ខេមបូឌា) (Ample Focus (Cambodia)) | ៨.០០០ | កៅស៊ូ | ២៤ កុម្ភៈ ២០១២ | អនុក្រឹត្យលេខ ៣២ ចុះថ្ងៃទី ២៤ កុម្ភៈ ២០១២ ស្តីពីការកំណត់ផ្ទៃដីទៅជាដីឯកជនរបស់រដ្ឋ សម្រាប់វិនិយោគដាំដំណាំ និងកំណត់ឲ្យ ក្រសួងកសិកម្ម និងក្រសួង បរិស្ថាន ក៏ដូចជាអជ្ញាធរពាក់ព័ន្ធដទៃទៀត មាននិតិវិធីជាបន្តសម្រាប់ | គួយ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | ការវិនិយោគនេះ។ | |
| ២២ | ស្រុកត្បែងមានជ័យ និងស្រុកជ័យសែន | ឡាន់ ហ្វេង (ខេមបូឌា) អ៊ិនធើណាស្យូណាល ខូ អិលធីឌី (Lan Feng (Cambodia) International Co., Ltd) | ៩.០១៥ | អាកាស្យា និងអំពៅ | ៨ វិច្ឆិកា ២០១១ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទានដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf) | គួយ |
| **ខេត្តរតនគិរី** | | | | | | | |
| ១ | ស្រុកអណ្ដូងមាស | អរយ៉ុង ខនស្ត្រាក់សិន (អេស៊ីអឹម) ខូ អិលធីឌី (Oryong Construction (ACM) Co., Ltd) | ៦.៨៦៦ | កៅស៊ូ | ៤ មេសា ២០០៦ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/74-rkiri-oryung.html) | កាចក់ |
| ២ | ស្រុកអណ្ដូងមាស | ហេង អភិវឌ្ឍន៍ (Heng Development) | ៨.៦៥៤ | ដំណាំកសិ-ឧស្សាហកម្ម និងដំណាំដទៃទៀត | ២៥ ឧសភា ២០០៦ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/73-rkiti-heng.html) | ចារ៉ាយ |
| ៣ | ស្រុកអណ្ដូងមាស | ហេង អភិវឌ្ឍន៍ (Heng Brother) | ២.៣៦១ | ចំការកៅស៊ូ និងអាកាស្យា | ៣១ កក្កដា ២០០៩ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ | ចារ៉ាយ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | http://www.elc.maff.gov.kh/en/profile/21-rtk/76-rkiri-hengbrother.html) | |
| ៤ | ស្រុកអណ្តូងមាស ឃុំតាឡាវ និងឃុំម៉ាលីក | វាសណា អ៊ិនវេសមេន (Veasna Investment) | ៥.០៨០ | ចំការកៅស៊ូ | ២៥ មិនា ២០១១ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/114-rkiri-vi.html) | កាចក់ និងទំពួន |
| ៥ | ស្រុកអណ្តូងមាស ឃុំតាឡាវ និងឃុំម៉ាលីក និងឃុំញ៉ាង | ឈាងលី អ៊ិនវេសមេន ខូ អិលធីឌី (Chaing Ly Investment Co., Ltd) | ១.៩០០ | ចំការកៅស៊ូ | ២៩ មិនា ២០១១ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/115-rkiri-chaingly.html) | ទំពួន |
| ៦ | ស្រុកអណ្តូងមាស ឃុំតាឡាវ និងឃុំម៉ាលីក និងឃុំញ៉ាង | ហ៊ង អាន អូយ៉ាដាវ ខូ អិលធីឌី (Horng An Oyadav Co., Ltd) | ៩.០០០ | កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មដទៃទៀត | ២២ កញ្ញា ២០១១ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/117-rtkiri-horng-an.html) | កាចក់ |
| ៧ | ស្រុកអណ្តូងមាស ឃុំញ៉ាង | ឌី អឹម គ្រុប (DM Group) | ៧៤៩ | កៅស៊ូ | ២៦ មករា ២០១២ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទានដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅ | ទំពួន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf) | |
| ៨ | ស្រុកបកែវ និងស្រុកអូយ៉ាដាវ | ជា ច័ន្ទរិទ្ធ អភិវឌ្ឍន៍ (Chea Chan Rith Development) | ៥.១២៤ | កៅស៊ូ | ១២ វិច្ឆិកា ២០០៧ | ចុះកិច្ចសន្យាសម្បទានដីបណ្ដោះអាសន្នជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទានដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅគេហទំព័រៈ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf) | ចារ៉ាយ |
| ៩ | ស្រុកលំផាត់ ឃុំសេដា | ជីង ហ្សុងរី ខូអិលធីឌី (Jing Zhong Ri Co., Ltd) | ៩.២២៤ | កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មដទៃទៀត | ៣០ ឧសភា ២០១១ | -អនុក្រឹត្យលេខ ៩៨ ចុះថ្ងៃទី ៣០ ឧសភា ២០១១ (ចំណុច ១) ស្ដីពីការកំណត់ផ្ទៃដី ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្ដល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ១៦២ ចុះថ្ងៃទី ២២ កក្កដា ២០១១ ចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីដែលបានកំណត់។ | ទំពួន |
| ១០ | ស្រុកលំផាត់ ឃុំសេដា | កៅស៊ូ អេលែវ ប៊ីអឹម យ៉យ | ៨.៤០០ | កៅស៊ូ | ៥ តុលា ២០១១ | ចុះកិច្ចសន្យាសម្បទានដីជាមួយ | ចារ៉ាយ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ស្តុក (Kao Su Ea Lev Bm Yoy Stock) | | | | ក្រសួងកសិកម្ម (សូមមើលផងដែរៈ ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទាន ដែលបានចុះកិច្ចសន្យាជាមួយ ក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf) | |
| ១១ | ស្រុកអូយ៉ាដាវ | គ្លូបល តិច អេសឌីអិន ប៊ីអេចឌី រ៉ាម៉ា ខ្មែរ អ៊ិនធើណាស្យូណាល & មិត្តភាព ម៉ែន សារុន<br><br>(ផ្ទៃដី ៧.០០០ ហត ត្រូវបានកាត់ចេញដើម្បីផ្តល់ឲ្យ ក្រុមហ៊ុន ហេងហ៊ាប) | ២០.០០០ | ដូងប្រេង | ២១ ធ្នូ ១៩៩៩ | ចុះកិច្ចសន្យាសម្បទានដីជាមួយ ក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/21-rtk/72-rkiri-globaltech.html | ចារ៉ាយ |
| ១២ | ស្រុកអូយ៉ាដាវ | ៣០/៤ យ៉ាឡៃ ខមភេនី លីមីធីត (30/4 Gialai Company Limited) | ៩.៣៨០ | ដំណាំកសិ-ឧស្សាហកម្ម បង្កាត់ពូជសត្វ និងរោងចក្រកែច្នៃ | ២៦ មេសា ២០០៥ | ចុះកិច្ចសន្យាសម្បទានដីជាមួយ ក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/21-rtk/71-rkiri-gialani.html) | ចារ៉ាយ |
| ១៣ | ស្រុកអូយ៉ាដាវ | ដាយ ដុង យឿង ខមីសល យ៉ាញ ស្តុក ខូ អិលធីឌី | ៤.៨៨៩ | ដំណាំកសិ-ឧស្សាហកម្ម បង្កាត់ពូជ | ២៩ មករា ២០១០ | ចុះកិច្ចសន្យាសម្បទានដីជាមួយ ក្រសួងកសិកម្ម (សូមមើលផងដែរៈ | ចារ៉ាយ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | (Dai Dong Yoeurng Commercial Yornh Stock Co., Ltd ) (ប្តូរមកពីក្រុមហ៊ុន ៣០/៤ យ៉ាឡៃ ខមភេនី លីមីធីត) | | សត្វ និងរោងចក្រកែច្នៃ | | http://www.elc.maff.gov.kh/en/profile/21-rtk/99-rkiri-daidong.html) | |
| ១៤ | ស្រុកអូរយ៉ាដាវ | ហេង ហ៊ាប អ៊ិនវេសមេន (Heng Heap Investment) (ដីសម្បទាន កាត់ចេញពីក្រុមហ៊ុន គួបល តិច អេសឌីអិន ប៊ីអេចឌី វ៉ាម៉ា ខ្មែរ អ៊ិនធើណាស្យូណាល & មិត្តភាព ម៉ែន សារុន) | ៧.០០០ | កៅស៊ូ ចំការJatropha | ៣១ កក្កដា ២០០៩ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/75-rkiri-heangheab.html) | ចារ៉ាយ |
| ១៥ | ស្រុកអូជុំ ស្រុកបកែវ និងស្រុកអណ្តូងមាស | ស៊ី អ ឌី (CRD) | ៧.៥៩១ | កៅស៊ូ | ២៥ មិនា ២០១១ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរ៖ http://www.elc.maff.gov.kh/en/profile/21-rtk/113-rkiri-crd.html) | គ្រឹង |
| ១៦ | ស្រុកតាវែង | ទ្រីភាព អ៊ីមផត អិចផត (Try Pheap Import Export Co., Ltd) | ៩.៧០៩ | ដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ | ៩ កុម្ភៈ ២០១១ | -អនុក្រឹត្យលេខ ២៥ ចុះថ្ងៃទី ៩ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។ -អនុក្រឹត្យលេខ ៩២ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោង | ទំពួន និង គ្រឹង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | អនុក្រឹត្យខាងលើ ចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ | |
| ១៧ | ស្រុកតាវែង | ស្រ៊ុន សុវណ្ណភូមិ អ៊ិនវេសមេន (Srun Sovannaphoum Investment Co., Ltd) | ៨.៩៩៨ | ដំណាំកៅស៊ូ ទេសចរណ៍ធម្មជាតិ និង តំបន់សេដ្ឋកិច្ចពិសេស | ១៥ កុម្ភៈ ២០១១ | -អនុក្រឹត្យលេខ ២៨ ចុះថ្ងៃទី ១៥ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៩០ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ | ទំពួន និង គ្រឹង |
| ១៨ | ស្រុកតាវែង ឃុំតាវែងលើ | អឹម ឌី អេស ថ្មដាអេស អ៊ីហ្សិត (MDS Thmorda SEZ Co., Ltd) | ៩.១៤៦ | ដំណាំកសិ-ឧស្សាហកម្មកៅស៊ូ | ៩ កុម្ភៈ ២០១១ | -អនុក្រឹត្យលេខ ២៦ ចុះថ្ងៃទី ៩ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដីទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុន។<br>-អនុក្រឹត្យលេខ ៩១ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ | ទំពួន និង គ្រឹង |
| ១៩ | ស្រុកតាវែង ឃុំតាវែងលើ និងស្រុកអណ្តូងមាស | នុភាព សុភី អ៊ិនវេសមេន (Noupheap Sophy Investment Co., Ltd) | ៩.០០០ | កៅស៊ូ | ១៥ កុម្ភៈ ២០១១ | -អនុក្រឹត្យលេខ ២៩ ចុះថ្ងៃទី ១៥ កុម្ភៈ ២០១១ ស្តីពីការកំណត់ផ្ទៃដី | គ្រឹង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ឃុំញាំង | | | | | ទៅជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់ផ្តល់ជូនក្រុមហ៊ុ។<br>-អនុក្រឹត្យលេខ ៨៩ ចុះថ្ងៃទី ២០ ឧសភា ២០១១ ដោយយោងអនុក្រឹត្យខាងលើចាត់បញ្ចូលផ្ទៃដីដែលបានកំណត់នេះជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ | |
| ២០ | ស្រុកតាវែង និងស្រុកអណ្តូងមាស | ក្រុង ប៉ុក រតនគិរី អភិវឌ្ឍន៍កៅស៊ូ (Krong Pok Ratanakiri Rubber Development Co., Ltd) | ៦.៦៩៥ | កៅស៊ូ | ៩ មេសា ២០១០ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/21-rtk/102-rkiri-krong.html) | គ្រឹង |
| ២១ | ស្រុកវើនសៃ | ហ៊ង អាញ់ មាំង យ៉ាំង ខេ អភិវឌ្ឍន៍ កៅស៊ូ (Hong An Mang Yang K Rubber Development) | ៦.៨៩១ | កៅស៊ូ | ២៥ កញ្ញា ២០០៩ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/21-rtk/78-rkiri-hongan.html) | គ្រឹង |
| ២២ | ស្រុកវើនសៃ | គិរី អភិវឌ្ឍន៍ (Kiri Development) | ៨០៧ | កៅស៊ូ | ៣១ កក្កដា ២០០៩ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/21-rtk/77-rkiri-kiri.html | គ្រឹង |
| **ខេត្តស្ទឹងត្រែង** | | | | | | | |
| ១ | ស្រុកសេសាន | សុភក្តិ នីកា វិនិយោគ | ១០.០០០ | អាកាស្យា ម៉ៃសាក់ | ៨ សីហា ២០០៥ | ចុះកិច្ចសន្យាសម្បទានដីជាមួយ | ព្នង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ដំណាំកសិ-ឧស្សាហកម្ម (Sopheak Nika Investment Agro-Industrial Plants Co., Ltd) | | និង ប្រភេទឈើផ្សេងទៀត | | ក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/24-stg/91-st-sopheaknika.html) | |
| ២ | ស្រុកសេសាន | សល សុភាពាណិជ្ជ (Sal Sophea Peanich Co., Ltd) | ៩.៩១៧ | អាកាស្យា ម៉ែសាក់ និង ប្រភេទឈើផ្សេងទៀត | ៨ សីហា ២០០៥ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/24-stg/89-st-salsophea.html) | ពួង |
| ៣ | ស្រុកសេសាន | ហ្គ្រេនលែន អេហ្គ្រីខលឆឺឌីវេឡុបមេន (ខេមបូឌា) ខូអិលធីឌី (Grand Land Agriculture Development (Cambodia) Co., Ltd) | ៩.៨៥៤ | ដំណាំកសិ-ឧស្សាហកម្ម | ២៣ មករា ២០០៦ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/24-stg/86-st-grandland.html) | ពួង |
| ៤ | ស្រុកសេសាន | ស៊ីវ ហ្គេក អ៊ិនវេសមេន (Siv Guek Investment) | ១.០០០០ | អាកាស្យា ម៉ែសាក់ និង ប្រភេទឈើផ្សេងទៀត | ២៤ មករា ២០០៦ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/24-stg/90-st-sivguek.html) | ពួង |
| ៥ | ស្រុកសេសាន | ភូ ម៉ាឌី អ៊ិនវេសមេន គ្រុប (Phou Mady Investment Group) | ៩.៨៥៤ | អាកាស្យា ម៉ែសាក់ និង ប្រភេទឈើផ្សេងទៀត | ២៤ មករា ២០០៦ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ ស្ថិតិក្រុមហ៊ុនវិនិយោគដីសម្បទានដែលបានចុះកិច្ចសន្យាជាមួយ | ពួង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | ក្រសួងកសិកម្ម គិតត្រឹមថ្ងៃទី ៨ មិថុនា ២០១២ នៅ http://www.elc.maff.gov.kh/en/attachments/article/122/Company%20Name.pdf; and http://www.elc.maff.gov.kh/en/profile/24-stg/88-st-phoumady.html) | |
| ៦ | ស្រុកសៀមប៉ាង | សេកុង អភិវឌ្ឍន៍ ខូអិលធីឌី (Sekong Aphivath Co. Ltd) | ៩.៨៥០ | ដំណាំ កសិ-ឧស្សាហកម្ម និងចិញ្ចឹមសត្វ | ១២ មេសា ២០០៦ | ចុះកិច្ចសន្យាសម្បទានដីជាមួយក្រសួងកសិកម្ម (សូមមើលផងដែរៈ http://www.elc.maff.gov.kh/en/profile/24-stg/92-st-sekong.html) | ព្នង |

# ឧបសម្ព័ន្ធ III

## ក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប (Union Development Group Co., Ltd) ឧទ្យានជាតិបុទុមសាគរ ខេត្ត កោះកុង

## I. សម្បទានដីផ្តល់នៅក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ

ឧទ្យានជាតិបុទុមសាគរ មានផ្ទៃដីទំហំ ១៧១.២៥០ ហិកតា ស្ថិតក្នុងខេត្តកោះកុង ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យឆ្នាំ ១៩៩៣[២៨៥] និងត្រូវបានចាត់ថ្នាក់ជាឧទ្យានធម្មជាតិ (ដែនធម្មជាតិ និងទស្សនីយភាពទេសភាព ដែលត្រូវការពារ សម្រាប់បម្រើឲ្យគោលបំណងវិទ្យាសាស្ត្រ ការអប់រំ និងការកំសាន្ត)។ ឧទ្យានធម្មជាតិនេះ ក្រោយមកទៀតត្រូវបាន កំណត់ជាតំបន់ការពារធម្មជាតិ ក្រោមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ (សូមមើលផ្នែក ៣ និងផ្នែក ៤) ។ ទោះជាដូច្នេះក៏ដោយ ចាប់ពីពេលនោះមក រាជរដ្ឋាភិបាលបានផ្តល់សម្បទានដី នៅក្នុងតំបន់ឧទ្យានជាតិនេះ ឲ្យដល់ក្រុមហ៊ុនចំនួន ៩ យ៉ាងតិច សម្រាប់ការដាំដំណាំកសិ-ឧស្សាហកម្ម (មានដូចជា អាកាស្យា ដូងប្រេង និងកៅស៊ូ) និងសម្រាប់ទេសចរណ៍ធម្មជាតិ និងការអភិវឌ្ឍន៍លក្ខណៈពាណិជ្ជកម្ម អាងស្តុកទឹក និងទំនប់វារីអគ្គីសនីជាដើម[២៨៦]។ ការផ្តល់សម្បទានដីទាំងនេះ គឺធ្វើឡើងតាមរយៈការចេញអនុក្រឹត្យស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដែលធ្វើឲ្យលេចឡើងនូវបញ្ហានៃការគោរពតាមក្របខ័ណ្ឌច្បាប់ អំពីការអភិរក្ស និងថែរក្សា តំបន់ការពារធម្មជាតិ (សូមមើលការវិភាគក្នុង ផ្នែក IV ដល់ផ្នែក VI)។

នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលដែលតំណាងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន បានចុះហត្ថលេខាលើកិច្ចសន្យាជួលសម្រាប់រយៈពេល ៩៩ ឆ្នាំ ជាមួយក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប សម្រាប់ការសាងសង់តំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម និងរមណីយដ្ឋានទេសចរណ៍ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ និងការវិនិយោគបន្ថែមទៀតលើផ្ទៃដី ទំហំ **៣៦.០០០ ហិកតា** ក្នុងស្រុកគិរីសាគរ និងស្រុកបុទុមសាគរ ។ កិច្ចសន្យាជួលនេះ ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រី ក្រសួងបរិស្ថាន និងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើជាសាក្សីដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម[២៨៧] ។ ផ្ទៃដីនេះលាតសន្ធឹងលើតំបន់ឆ្នេរក្នុងស្រុកគិរីសាគរ និងបុទុមសាគរ និងរួមមានទាំងតំបន់ដែលសំខាន់ ចាំបាច់សម្រាប់ការអភិរក្សនិងការពារបរិស្ថាន ក៏ដូចជាគ្របដណ្តប់លើភូមិដ្ឋានចំនួន ១២ ភូមិ ក្នុងឃុំចំនួន ៥ ។

---

[២៨៥] ព្រះរាជក្រឹត្យ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣

[២៨៦] រួមមានក្រុមហ៊ុន៖ ១- សីណូមិចស៊ីម អិនវេសមិន ខូ អិលធីឌី (Sinomexim Investment Co., Ltd) ខេត្តកោះកុង(៤.២៨០ហិកតា), ២- យូនៀន ដេវីលប្បមេន គ្រុប (Union Development Group Co., Ltd) (៩.១០០ ហិកតា), ៣- យូនៀន ដេវីលប្បមេន គ្រុប (Union Development Group Co., Ltd) (៣៦.០០០ហិកតា), ៤- ប៉ានសួគ៌ ចំកាត់ (Paradise Investment Co., Ltd) (៩.១៣៧ហិកតា) ៥- អិល.វ៉ាយ.ភី. គ្រុប (L.Y.P Group Co., Ltd) (៤.១០០ហិកតា) ៦- ឌឹ ហ្គ្រីន រិច ខូ អិលធីឌី (The Green Rich Co., Ltd) (៦០.២០០ហិកតា) ៧- គីរីសាគរ កោះកុង អេស អ៊ី ហ្សិត២ (Kiri Sakor Koh Kong SEZ 2) (២.២៦០ហិកតា) ៨- កោះកុង អេស អ៊ី ហ្សិត ខូ អិលធីឌី (Koh Kong SEZ Co., Ltd) (៩.៩៧៧ ហិកតា) ៩- JW ខេមបូឌា អេកូ ហូលីដេ (JW Cambodia Eco Holidays) (៥.០០០ហិកតា)

[២៨៧] កិច្ចសន្យាស្តីពីការជួលទីតាំង ក្នុងភូមិសាស្ត្រស្រុកគិរីសាគរ និងស្រុកបុទុមសាគរ ខេត្តកោះកុង រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន Union Development Group Co.,LTD ឆ្នាំ២០០៨។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៨ មួយខែមុនការចុះកិច្ចសន្យាជួល ព្រះមហាក្សត្របានឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ[២៨៨] ធ្វើវិសោធនកម្មព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ដើម្បីកាត់ផ្ទៃដីទំហំ ៣៦.០០០ ហិកតា ចេញពីផ្ទៃដីទំហំ ១៧១.២៥០ ហិកតា របស់ឧទ្យានជាតិបុទុមសាគរ និងធ្វើអនុបយោគផ្ទៃដីទំហំ ៣៦.០០០ហិកតា ទៅជាដីឯកជនរបស់រដ្ឋ ដូច្នេះធ្វើឲ្យមានភាពស្របច្បាប់ក្នុងការជួលដីរយៈពេលវែងឲ្យក្រុមហ៊ុន ។ នៅក្នុងខែដដែលនោះដែរ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ[២៨៩]មួយផ្សេងទៀត ដើម្បីធ្វើអនុបយោគផ្ទៃដីសម្បត្តិរបស់រដ្ឋទំហំ ៣៦.០០០ហិកតា ចេញពីឧទ្យានជាតិបុទុមសាគរ មកជាសម្បត្តិឯកជនរបស់រដ្ឋ ។ ជាបន្ថែមទៀត ក្នុងខែសីហា ឆ្នាំ២០១១ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការកំណត់ផ្ទៃដីទំហំ ៩.១០០ ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងបានផ្តល់សម្បទានដី លើកទី ២ ឲ្យក្រុមហ៊ុន យូនៀន ដេវើលប្បមេន គ្រុប ដើម្បីធ្វើអាងស្តុកទឹក និងវារីអគ្គិសនី[២៩០] ។

## II. ក្រុមហ៊ុន និង កិច្ចសន្យាជួលទីតាំង

ក្នុងកិច្ចសន្យាជួល ក្រុមហ៊ុន យូនៀន ដេវើលប្បមេន គ្រុប ត្រូវបានអនុញ្ញាតិឲ្យធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ផ្នែកទេសចរណ៍ មានដូចជា កាស៊ីណូ ខុនដូ អាផាតមេន និងរមណីយដ្ឋាន ។ កិច្ចសន្យាបានអនុញ្ញាតិឲ្យក្រុមហ៊ុន កាប់ឆ្ការព្រៃឈើ ដើម្បីអភិវឌ្ឍទីតាំងវិនិយោគនោះតាមប្លង់មេ ប៉ុន្តែតម្រូវឲ្យក្រុមហ៊ុនបង់សួយសារ និងបុព្វលាភ ចំពោះឈើដែលមានតម្លៃសេដ្ឋកិច្ច ដែលខ្លួនកាប់ប្រើប្រាស់ ឬ លក់ ។

កិច្ចសន្យាជួលនេះ យោងអនុក្រឹត្យ[២៩១] និងច្បាប់មួយចំនួនទាក់ទងនឹងការផ្តល់សម្បទានដី[២៩២] និងសេចក្តីសម្រេចមួយចំនួនចេញមកពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក៏ដូចជាចេតនាអនុវត្ត "គោលនយោបាយស្បែកខ្លា" ដើម្បីជៀសវាងការអភិវឌ្ឍនៅលើដីដែលសហគមន៍កាន់កាប់ ។ លក្ខខ័ណ្ឌនៃកិច្ចសន្យាជួលរយៈពេល ៩៩ឆ្នាំ អនុញ្ញាតិឲ្យមានការបន្តកិច្ចសន្យាក្នុងរយៈពេលកំណត់មួយបន្តទៀត[២៩៣]។ កិច្ចសន្យាជួលនេះអនុញ្ញាតិឲ្យក្រុមហ៊ុនអាចផ្ទេរសិទ្ធិបន្ត ឬផ្ទេរសិទ្ធិកាន់កាប់លើសិទ្ធិនិងផលប្រយោជន៍ (ណាមួយ ឬទាំងស្រុង) លើផ្នែកណាមួយនៃគម្រោង

---

២៨៨ ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៨/៣៩២ /ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៨ ស្តីពីការធ្វើវិសោធនកម្ម មាត្រា២, ចំណុច១,លេខរៀងទី៥ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី១ វិច្ឆិកា ឆ្នាំ១៩៩៣។

២៨៩ អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការធ្វើអនុបយោគដីឧទ្យានជាតិបុទុមសាគរ ទំហំ ៣៦.០០០ ហិកតា ទៅជាដីឯកជនរបស់រដ្ឋ ។

២៩០ អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ១៧៨ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១

២៩១ អនុក្រឹត្យមានដូចតទៅ៖ អនុក្រឹត្យ លេខ១២៩ អនក/បក ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធាណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ , អនុក្រឹត្យ លេខ១១៤ អនក/បក ស្តីពីការដាក់បញ្ចាំ និងការផ្ទេរសិទ្ធលើការជួលរយៈពេលវែង ឬ សិទ្ធិលើដីសម្បទានសេដ្ឋកិច្ច ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧, អនុក្រឹត្យ លេខ៣៨ អនក/បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការធ្វើ អនុប្បយោគដីទំហំ ៣៦.០០០ហិកតា របស់ឧទ្យានជាតិបុទុមសាគរ ទៅជាដីឯកជនរបស់រដ្ឋ។

២៩២ រួមមាន ច្បាប់របស់ប្រទេសកម្ពុជា ស្តីពីការវិនិយោគ ឆ្នាំ១៩៩៤ (ដោយត្រូវបានធ្វើវិសោធនកម្ម ឆ្នាំ២០០៣), ច្បាប់ភូមិបាលឆ្នាំ២០០១, ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨, ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៨/៣៩២ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ ស្តី ពីការធ្វើវិសោធនកម្ម មាត្រា ២, ចំណុច១ លេខរៀងទី៥ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

២៩៣ យោងតាមមាត្រា១.៤ នៃកិច្ចសន្យាជួល រាជរដ្ឋាភិបាលនឹងប្រគល់ទីតាំងជួលជូន ក្រុមហ៊ុនតាមរយៈលិខិតជាផ្លូវការក្នុងរយៈពេលមិនលើសពី ១០ ថ្ងៃ បន្ទាប់ពីគម្រោងប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ត្រូវបានទទួលការឯកភាព។ កាលបរិច្ឆេទនៃលិខិតប្រគល់ទីតាំងនេះ នឹងត្រូវចាត់ទុកថា ជាថ្ងៃប្រគល់ និង ការចាប់ផ្តើមកាលបរិច្ឆេទជួលទីតាំងជូនក្រុមហ៊ុន។ កិច្ចសន្យាជួលអាចត្រូវពន្យាពេលក្នុងរយៈពេលមួយបន្តទៀតបានតាមការឯកភាពគ្នារវាងភាគីទាំងពីរ និងតាមលក្ខខណ្ឌថ្មី។ ចេតនានៃការបន្តកិច្ចសន្យា ត្រូវលើកសំណើរសុំឲ្យបានយ៉ាងតិចមួយឆ្នាំ មុនពេលចប់អាណត្តិកិច្ចសន្យា។

វិនិយោគ ឬ ក៏លក់ហ្វាស៊ីលីធីទៅឲ្យតតីយបុគ្គលបាន។ កិច្ចសន្យាជួលនេះក៏អនុញ្ញាតិឲ្យរដ្ឋាភិបាលអាចលក់ទីតាំងជួលនេះទាំងមូល ឬ មួយផ្នែកបាន ដោយផ្តល់អាទិភាពជូន ក្រុមហ៊ុន ឬ អ្នកទទួលសិទ្ធិបន្តពីក្រុមហ៊ុន ។

ដូចជាគម្រោងវិនិយោគធំៗទាំងឡាយ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានតម្រូវឲ្យធ្វើឡើង និង ដោយត្រូវបញ្ចូលនូវការចូលរួមរបស់សហគមន៍ដែលរងការប៉ះពាល់ផង (សូមមើលផ្នែកទី III ចំណុច "ឃ" ១.១ និង ១.៣ អំពីច្បាប់ស្តីពីតំបន់ ការពារធម្មជាតិ និងច្បាប់ស្តីពីការការពារបរិស្ថាន ហើយនិងអនុក្រឹត្យពាក់ព័ន្ធ) ហើយក្នុងគ្រាដែលមាន សេចក្តីរាយការណ៍ថា មានការវាយតម្លៃផលប៉ះពាល់ត្រូវបានធ្វើឡើង ការពិគ្រោះយោបល់ជាមួយសហគមន៍ហាក់ដូចជា មិនត្រូវបានគេធ្វើឡើងទេ ហើយការវាយតម្លៃនោះទៀតសោតក៏មិនមានការពិនិត្យមើលបានពីសាធារណជននោះដែរ ។

ថ្វីបើមានការកំណត់ថា សម្បទាននេះនឹងអនុវត្ត (គោលនយោបាយរូបមន្តស្បែកខ្លា) ក៏ដោយ ក៏ការរំខានដល់ភូមិដ្ឋាននានាត្រូវបានគេគិតឃើញថានឹងកើតមាន ហើយបើមើលលើកិច្ចសន្យាជួលវិញ គឺរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកលើការងាររដ្ឋបាលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅថ្មី និងការផ្តល់សំណង ដោយសហការជាមួយក្រុមហ៊ុន យូនៀន ដេវឺលប្បមេន គ្រុប ដែលជាអ្នកទទួលបន្ទុកផ្តល់សំណង និងការសាងសង់តំបន់តាំងទីលំនៅថ្មី ។ ក្នុងករណីដែលពុំអាចរកដំណោះស្រាយឲ្យអ្នកភូមិ ឬ អ្នកកាន់កាប់ស្របច្បាប់នៅតាមទីតាំងមួយចំនួនចេញបាន នោះសកម្មភាពនៅលើទីតាំងទាំងនោះ ត្រូវបានព្យួរទុក។

## III. សហគមន៍កំពុងរស់នៅក្នុងតំបន់សម្បទានដី

ភូមិដែលរងការប៉ះពាល់ដោយគម្រោងនេះ បានចាប់បដិសន្ធិឡើង និងមានវត្តមាន ជាច្រើនជំនាន់មកហើយ។ សមាជិកនៃសហគមន៍ គឺជាក្រុមគ្រួសារដែលបានចូលមករស់នៅក្នុងភូមិទាំងនោះ តាមកាលៈទេសៈពេលវេលាខុសៗគ្នា គ្រួសារខ្លះបានមករស់នៅតំបន់នេះមុនសម័យសង្គមរាស្ត្រនិយមរបស់សម្តេចព្រះសីហនុ ក្នុងទសវត្សឆ្នាំ១៩៦០ ហើយគ្រួសារខ្លះទៀតបានជន្លៀសមករស់នៅក្នុងរបបខ្មែរក្រហម ឬ ក្រោយរបបខ្មែរក្រហម ក្នុងអំឡុងទសវត្សឆ្នាំ១៩៨០ (ក្រោយពីរបបខ្មែរក្រហមដួលរលំ)។ គ្រួសារជាច្រើនបានមករស់នៅក្នុងតំបន់នេះក្រោយមកទៀត តាមរយៈការទិញដីឯកជន។រដ្ឋាភិបាលបានទទួលស្គាល់ភូមិទាំងនេះជាផ្លូវការក្នុងឆ្នាំទសវត្សឆ្នាំ១៩៩០ បន្ទាប់ពីសង្គ្រាមស៊ីវិលបានបញ្ចប់។ យោងតាមមន្ត្រីស្រុកដែលបានចូលរួមធ្វើអង្កេតលើការកាន់កាប់ដីនៅទីនោះ បានឲ្យដឹងថា គម្រោងនេះអាចប៉ះពាល់ប្រជាពលរដ្ឋចំនួន ១.១៦៣ គ្រួសារ ដែលកំពុងរស់នៅក្នុងតំបន់នេះ ទាំងដីលំនៅដ្ឋាន និងដីចំការ ក្នុងឃុំចំនួន ៣ របស់ស្រុកគិរីសាគរ (គឺឃុំកោះស្តេច, ភ្ញីមាស និងព្រែកខ្សាច់) និងពីរឃុំទៀត របស់ស្រុកបុទុមសាគរ (ឃុំថ្មស និងតានូ)។

មានសេចក្តីរាយការណ៍ថា សហគមន៍ដែលរងផលប៉ះពាល់ មិនត្រូវបានគេពិគ្រោះយោបល់ជាមួយ អំពីគម្រោងនេះ និងអំពីផលប៉ះពាល់ជាសក្តានុពលរបស់គម្រោងនេះឡើយ ប៉ុន្តែគេបានសំគាល់ឃើញ មានតំណាងក្រុមហ៊ុន និងមន្ត្រីរដ្ឋាភិបាល បានធ្វើដំណើរមកកាន់ឃុំនានារបស់ពួកគេ និងវាស់វែងដីធ្លី នៅមុនការចុះហត្ថលេខាលើកិច្ចសន្យាជួលក្នុងឆ្នាំ ២០០៨។ មានសេចក្តីរាយការណ៍ថា សហគមន៍ត្រូវបានគេជូនដំណឹងជាផ្លូវការអំពីគម្រោងនេះ រួមទាំងការសន្យាអំពីសំណងជាលើកទីមួយ ក្នុងអំឡុងនៃទស្សនកិច្ចមកកាន់ស្រុកគិរីសាគរ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ ដោយមន្ត្រីមកពីក្រសួងបរិស្ថាន កងយោធពលខេមរភូមិន្ទ សាលាខេត្តកោះកុង និងតំណាងរបស់ក្រុមហ៊ុន យូនៀន ដេវឺលប្បមេន គ្រុប។

## IV. ការអនុវត្តគម្រោង - សំណង និងការផ្លាស់ប្តូរទីលំនៅថ្មី

ជាសរុប មានប្រជាពលរដ្ឋចំនួន ១.១៦៣ គ្រួសារ និងយ៉ាងហោចណាស់មាន សាលាបឋមសិក្សាមួយ និង វត្តអារ៉ាមចំនួនបី នឹងត្រូវផ្លាស់ប្តូរទីតាំងចេញពីតំបន់នោះ។ ថ្វីបើមានសេចក្តីសម្រេចឲ្យអនុវត្ត"គោលនយោបាយរូបមន្តស្បែកខ្លា" ដែលអាចធ្វើឲ្យមានតម្រូវការតិចតួចបំផុតការនៃការផ្លាស់ប្តូរទីលំនៅថ្មី និងការរំខានដល់ជីវភាពរស់នៅរបស់អ្នកភូមិក៏ដោយ ក៏មានសេចក្តីរាយការណ៍ថា ផែនការតាមរូបមន្តស្បែកខ្លានេះ ត្រូវបានបោះបង់ចោល ហើយការសម្រេចផ្ទុយពីនេះ ត្រូវបានយកមកអនុវត្ត ដើម្បីផ្លាស់ប្តូរទីតាំងសហគមន៍ចេញឆ្ងាយពីតំបន់ឆ្នេរសមុទ្រ ដែលសហគមន៍ទាំងនេះ ភាគច្រើនពឹងអាស្រ័យលើការនេសាទ និងប្រើប្រាស់ឈូងសមុទ្រថៃ សម្រាប់ម្ហូបអាហារ និងប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេ។ មន្ត្រីរដ្ឋាភិបាល និងតំណាងក្រុមហ៊ុន យូនៀន ដេវើលប្បមេន គ្រុប បានបញ្ជាក់ថា ការអនុវត្ត "គោលនយោបាយរូបមន្តស្បែកខ្លា" មិនអាចអនុវត្តបានឡើយ ដោយមូលហេតុដែលវាពាក់ព័ន្ធនឹងបញ្ហាទឹក និង អនាម័យ ហេតុដូច្នេះ បញ្ហានេះគឺជាអ្វីដែលគោលនយោបាយនេះ មិនអាចអនុវត្តបានឡើយ ពីព្រោះតែសហគមន៍កំពុងរស់នៅតាមបណ្តោយឆ្នេរធ្វើឲ្យក្រខ្វក់ដល់ទឹកសាមុទ្រ ហើយបើអនុញ្ញាតឲ្យពួកគេបន្តរស់នៅក្នុងភូមិបច្ចុប្បន្នដដែល នោះនឹងធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការវិនិយោគរបស់ក្រុមហ៊ុន។

សេចក្តីសម្រេចចិត្តនានាដែលបានធ្វើនៅឯក្រសួងបរិស្ថាន អំពីការផ្លាស់ប្តូរទីតាំងថ្មី និងសំណង ត្រូវបានគេរាយការណ៍ថា បានផ្តើមឡើងចាប់ពីដើមឆ្នាំរហូតដល់ពាក់កណ្តាលឆ្នាំ ២០០៩ ហើយលោករដ្ឋមន្ត្រី បានដាក់ចេញនូវគោលការណ៍ដោះស្រាយសម្រាប់សហគមន៍ នៅក្នុងលិខិតចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ដាក់ជូននាយករដ្ឋមន្ត្រី ដែលគោលការណ៍ទាំងនោះ អាស្រ័យលើស្ថានភាពនៃការកាន់កាប់ដី ហើយនិងប្រភេទឯកសារដែលអ្នកកាន់កាប់ដីមាន។[២៩៤] សំណងដែលអាចផ្តល់ឲ្យបានរួមមាន ការសងជាថវិកា (គេបានដឹងថាចាប់ពី ២៥០ ដល់ ៨.០០០ ដុល្លារអាមេរិក ក្នុងដីកសិកម្មមួយហិកតា), ផ្ទះមួយខ្នងសម្រាប់គ្រួសារនិមួយៗដែលសង់រួចនៅលើទីតាំងថ្មីដែលមានចម្ងាយប្រមាណជា ២០ គីឡូម៉ែត្រ ពីឆ្នេរសមុទ្រ, និងបែងចែកឲ្យនូវដីលំនៅដ្ឋាន និង/ឬ ដីកសិកម្មផង ។ គោលការណ៍សំណងមានសម្រាប់ការកាន់កាប់ដី ៤ ប្រភេទ ត្រូវនឹង ៩ ករណី[២៩៥] ។ ប្រភេទទី១ (ត្រូវនឹង ២ ករណី)[២៩៦] គឺគ្រួសារដែលមាន

---

[២៩៤] លិខិតរបស់ក្រសួងបរិស្ថាន លេខ ១៥២៩ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩។

[២៩៥] លិខិតរបស់ក្រសួងបរិស្ថាន លេខ ៤៩៦ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ជម្រាបអភិបាលនៃគណៈអភិបាលខេត្តកោះកុង អំពីសេចក្តីសម្រេចស្តីពីគោលការណ៍តម្លៃដែលត្រូវទូទាត់សំណង និងគោលនយោបាយសំណង៖ **ស្តង់ដាសំណង ក ៖** អតិបរមានៃសំណងជាថវិកា ៨.០០០ ដុល្លារអាមេរិក ក្នុងមួយហិកតា សម្រាប់ដីស្រែ និងដីដាំដំណាំ **ស្តង់ដាសំណង ខ ៖** ផ្ទះ ១-ក្រុមហ៊ុនត្រូវរៀបចំទីតាំងថ្មីមួយនៅក្នុងទីតាំងជួល នៅពេលដែលក្រុមហ៊ុនត្រូវធ្វើការរុះរើ តាមតម្រូវការសាងសង់ ហើយមានការព្រមព្រៀងពីប្រជាពលរដ្ឋទាំងនោះ, ២-ក្រុមហ៊ុននឹងធ្វើការទូទាត់សំណងដែលសមស្រប ឬ សាងសង់ជាថ្មី តាមស្តង់ដាដែលមិនទាបជាងស្តង់ដាមុន និង ៣-ភូមិដែលសាងសង់នៅតំបន់តាំងទីលំនៅថ្មី ត្រូវមានហេដ្ឋារចនាសម្ព័ន្ធដែលសមរម្យ **ស្តង់ដាសំណង គ ៖** ៧៥% នៃស្តង់ដាសំណង ក ចំពោះប្រជាពលរដ្ឋមូលដ្ឋាន ហើយ ៥០% នៃស្តង់ដាសំណង ក ចំពោះប្រជាពលរដ្ឋក្រៅមូលដ្ឋាន (ជាអតិបរមា ៦.០០០ ដុល្លារ អាមេរិក ក្នុងមួយហិកតា, **ស្តង់ដាសំណង ឃ៖** ផ្ទះមួយខ្នង (ដូចស្តង់ដា សំណង ខ)។

[២៩៦] **<u>ករណីទី១</u>** អ្នកដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចេញឲ្យមុនថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ហើយបានកាន់កាប់ប្រើប្រាស់ដីនោះ (ធ្វើផ្ទះ ឬ ក៏ដាំដុះលើដីនោះ) ដោយមិនគិតថា អ្នកនោះជាអ្នកមូលដ្ឋាន ឬ ក៏ក្រៅមូលដ្ឋានឡើយ គឺសំណងសម្រាប់ដីស្រែ ឬ ដីចំការ ត្រូវអនុវត្តតាមស្តង់ដាសំណង ក ហើយសម្រាប់ផ្ទះ ត្រូវអនុវត្តតាមស្តង់ដាសំណង ខ។ គណៈកម្មាការអន្តរក្រសួង មិនទូទាត់សំណងលើទំហំដី អះអាងដោយប្រជាពលរដ្ឋដែលមានលើសពីទំហំកំណត់ក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ឡើយ។ **<u>ករណីទី២៖</u>** ទាំងប្រជាពលរដ្ឋមូលដ្ឋាន ឬ ក្រៅមូលដ្ឋានដែលមានប័ណ្ណសំគាល់សិទ្ធិកាន់ កាប់ដី ចេញឲ្យមុនថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ប៉ុន្តែពួកគាត់មិនបានប្រើប្រាស់ដីនោះទេ គឺទូទាត់សង ២៥% នៃស្តង់ដាសំណង ក (ដែលស្មើនឹង ២.០០០ ដុល្លារ អាមេរិក ក្នុងមួយហិកតា) ទំហំដីដែលបានអះអាងលើសពីទំហំដែលមានកំណត់ក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី គឺមិនពិចារណាផ្តល់សំណងឡើយ។

ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចេញឲ្យមុនថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ ប្រភេទទី២ (ត្រូវនឹង ២ ករណី)[២៩៧] គឺគ្រួសារទាំងឡាយណាដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចេញឲ្យក្រោយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ ប្រភេទទី ៣ (ត្រូវនឹង ៣ ករណី) គឺគ្រួសារទាំងឡាយណាដែលគេគិតថា ជាប្រជាជន"មូលដ្ឋាន" ដែលគ្មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ប៉ុន្តែបានកាន់កាប់ ឬ ប្រើប្រាស់ដី។ ប្រភេទទី ៤ (ត្រូវនឹង ២ ករណី) គឺគ្រួសារទាំងឡាយណាដែលគ្មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ប៉ុន្តែមានលិខិត ឬ ឯកសារដែលចេញដោយមេភូមិ និងមេឃុំ។

ក្រុមការងារនៃគណៈកម្មការអន្តរក្រសួង ត្រូវបានគេរាយការណ៍ថា បានបង្កើតស្នាក់ការ នៅក្នុងស្រុកគិរីសាគរ និងនៅឃុំថ្មស ក្នុងស្រុកបុទុមសាគរ ពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៩ ដើម្បីអញ្ជើញអ្នកភូមិដែលរងផលប៉ះពាល់ ឲ្យនាំយកនូវឯកសារជាភស្តុតាងពាក់ព័ន្ធ (អត្តសញ្ញាណប័ណ្ណ, សៀវភៅគ្រួសារ និង ឯកសារទាក់ទងនឹងការផ្ទេរ និងការទិញលក់ដី) មកធ្វើការផ្ទៀងផ្ទាត់ដោយគណៈកម្មាធិការដោះស្រាយសំណង។ ការចរចារអំពីសំណង ត្រូវបានគេរាយការណ៍ថា បានធ្វើឡើងនៅបន្ទាប់ពេលនៃការចុះបញ្ជីដីដែលមាន ដោយបានចាប់ផ្តើមជាមួយនឹងសហគមន៍រស់នៅភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ (៦៧៨ ហិកតា)។

បន្ទាប់មកទៀត គេបានប្រាប់ដល់សហគមន៍ថា ពួកគាត់កំពុងតែរស់នៅលើដីរដ្ឋ ដូច្នេះត្រូវតែរើចេញ។ ការចរចារអំពីការផ្តល់សំណង ត្រូវបានគេរាយការណ៍ថា បានប្រព្រឹត្តទៅក្នុងឆ្នាំ២០១០ ហើយមានប្រជាពលរដ្ឋប្រហែលជា ១.០០០ គ្រួសារ ត្រូវបានផ្លាស់ប្តូរទីលំនៅទៅកន្លែងតាំងទីលំនៅថ្មីក្នុងឆ្នាំ ២០១១ ។ ក្រុមគ្រួសារខ្លះ បានតវ៉ាយ៉ាងស្វិតស្វាញ ចំពោះការឲ្យផ្លាស់ប្តូរទៅតាំងទីលំនៅនៅកន្លែងថ្មីនោះ ហើយកំពុងតែបន្តការតវ៉ានេះ ហើយគ្រួសារខ្លះ បានឲ្យដឹងថា ពួកគេទទួលយកសំណងដោយសារតែការបង្ខិតបង្ខំ ឬ ដោយមានការបំភិតបំភ័យ ឬ ដោយខ្វះព័ត៌មាន ឬ ខ្វះជម្រើសផ្សេងៗ។ ក្រុមគ្រួសារខ្លះទៀត ស្ម័គ្រចិត្តទទួលយកការផ្តល់សំណង ដោយសារតែដីរបស់ពួកគេនៅក្នុងភូមិចាស់នេះមានទំហំតូច ។

## V. ស្ថានភាពនៅកន្លែងតាំងទីលំនៅថ្មី

កន្លែងតាំងទីលំនៅថ្មីនេះ លាតសន្ធឹងលើផ្ទៃដីទំហំ ៤.០០០ ហិកតា ស្ថិតនៅខាងក្រៅផ្ទៃដីនៃគម្រោងវិនិយោគរបស់ក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប គឺចូលយ៉ាងជ្រៅទៅក្នុងផ្ទៃដីនៃឧទ្យានជាតិបុទុមសាគរ និងស្ថិតនៅឆ្ងាយពីឆ្នេរសមុទ្រ។ តាមការបញ្ជាក់របស់មន្ត្រីស្រុកថា សម្រាប់គោលដៅនេះ រដ្ឋាភិបាលបានចេញអនុក្រឹត្យមួយ កាត់ផ្ទៃដីទំហំ ៤.០០០ ហិកតា ចេញពីតំបន់ឧទ្យានជាតិ។ ការណ៍នេះ អាចត្រូវបានប្រមើលឃើញថា នឹងមានផលប៉ះពាល់ផ្នែកបរិស្ថានកាន់តែខ្លាំងថែមទៀត ដោយសារតែព្រៃឈើ នឹងត្រូវគេការកាប់ឆ្ការ ដើម្បីរៀបចំធ្វើជាតំបន់តាំងទីលំនៅថ្មី ហើយគ្មានមន្ទិលទេថា លំហូរនៃប្រជាពលរដ្ឋ នឹងបង្កើនដល់បញ្ហានៃការកាប់ព្រៃឈើ ការបរបាញ់សត្វ និងការបំពុលបរិស្ថាននៅក្នុងតំបន់ដ៏សំខាន់នេះ។ ថ្វីបើមានប្រជាពលរដ្ឋប្រហែលជា ១.០០០ គ្រួសារ បានប្តូរទីតាំងមកនៅកន្លែងថ្មីនេះ ប៉ុន្តែដោយតំបន់នេះ ស្ថិតនៅឆ្ងាយពីឆ្នេរសមុទ្រ ដូច្នេះមានគ្រួសារជាច្រើន ដែលបានទទួលយកសំណងរួចហើយនោះ មិនបានស្នាក់នៅជាប់លាប់នៅនឹងកន្លែងថ្មីនោះទេ ដោយសារតែជម្រើសក្នុងការរកប្រាក់ចំណូលមានតិចតួចពេក។

---

[២៩៧] **ករណីទី៣៖** ទាំងប្រជាពលរដ្ឋមូលដ្ឋាន ឬ ក្រៅមូលដ្ឋានដែលមានប័ណ្ណសំគាល់សិទ្ធិចេញឲ្យក្រោយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ប៉ុន្តែពួកគាត់សង់ផ្ទះ ឬ បានដាំដំណាំនៅលើដីនោះ គឺទូទាត់សំណងតាមស្តង់ដាសំណង គ សម្រាប់ ដីស្រែ ឬ ដីចំការ ហើយចំពោះលំនៅដ្ឋាន គឺសងតាមស្តង់ដាសំណង ឃ។ **ករណីទី៤៖** ទាំងប្រជាពលរដ្ឋមូលដ្ឋាន ឬ ក្រៅមូលដ្ឋាន ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី ចេញឲ្យក្រោយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ប៉ុន្តែពួកគាត់មិនបានប្រើប្រាស់ដីនោះទេ គឺទូទាត់សំណង ២៥% នៃស្តង់ដាសំណង ក (ដែលស្មើនឹង ២.០០០ ដុល្លារអាមេរិក ក្នុងមួយហិកតា សម្រាប់ដីកសិកម្ម) ទំហំដីដែលបានអះអាងលើសពីទំហំកំណត់ក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដី គឺមិនពិចារណាផ្តល់សំណងឡើយ។

គ្រួសារភាគច្រើន ដែលជីវភាពរស់នៅរបស់ខ្លួន ពឹងផ្អែកលើការនេសាទត្រី បានវិលត្រឡប់ទៅរស់នៅក្នុងភូមិចាស់របស់ខ្លួនវិញ ដោយការស្នាក់នៅជាមួយអ្នកភូមិដែលជាមិត្តភក្តិ ដែលជាសមាជិកសហគមន៍មិនព្រមរើទៅនៅកន្លែងតាំងទីលំនៅថ្មី ឬ ក៏ធ្វើជម្រកស្នាក់នៅជាបណ្ដោះអាសន្ន ដើម្បីអាចទៅប្រកបរបរនេសាទត្រីបាន។

ខណៈដែរកញ្ចប់សំណងផ្សេងៗគ្នា ជាទូទៅ ក្រុមគ្រួសារដែលបានផ្លាស់ប្ដូរទៅកន្លែងតាំងទីលំនៅថ្មី ត្រូវបានគេផ្ដល់ឲ្យដីលំនៅដ្ឋានទំហំ ទទឹង ៥០ ម៉ែត្រ បណ្ដោយ ១០០ ម៉ែត្រ និងផ្ទះឈើសង់រួចមួយដែលមានទទឹង ៦,៥០ ម៉ែត្រ បណ្ដោយ ៧,៥០ ម៉ែត្រ និងដីកសិកម្មមួយកន្លែងទំហំ ២ ហិកតា។ ដីកសិកម្មដែលគេផ្ដល់ឲ្យនោះ គឺជាដីព្រៃ ដែលភាគច្រើន ស្ថិតនៅជាប់នឹងដីលំនៅដ្ឋាន ប៉ុន្តែនៅចុងខែធ្នូ ឆ្នាំ២០១១ គ្រួសារប្រជាពលរដ្ឋភាគច្រើនដែលបានផ្លាស់ប្ដូរទៅកន្លែងតាំងទីលំនៅថ្មី ត្រូវបានគេរាយការណ៍ថា ពុំទាន់បានទទួលដីកសិកម្មទំហំ ២ ហិកតា ដូចដែលមានការសន្យានោះឡើយ។

ចំពោះហេដ្ឋារចនាសម្ព័ន្ធវិញ គិតមកត្រឹមខែកុម្ភៈ ឆ្នាំ២០១២ ក្រុមហ៊ុន យូនៀន ដេវើលប្បមេន គ្រុប បានឈូសឆាយដីធ្វើផ្លូវ ក្នុងតំបន់តាំងទីលំនៅថ្មី បានសាងសង់សាលារៀនមួយខ្នង និងផ្ដល់អណ្ដូងចំនួន ៦។ ក្រុមហ៊ុន ត្រូវបានគេរាយការណ៍ថា បានជួលបុគ្គលិកសន្តិសុខប្រដាប់អាវុធ (ឯកជន និងកងរាជអាវុធហត្ថ) ហើយបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យជាប្រចាំ ដើម្បីរិតបន្តឹងការធ្វើដំណើរចូលទៅកាន់ភូមិមួយចំនួន (ជាអាទិ៍ ភូមិពាមកាយ និងភូមិព្រែកស្មាច់) គឺជាភូមិដែលប្រជាពលរដ្ឋ មិនព្រមរុះរើទៅរស់នៅកន្លែងតាំងទីលំនៅថ្មី។ មានសេចក្ដីរាយការណ៍ថា តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេបដិសេធមិនឲ្យប្រើប្រាស់ផ្លូវនោះ ដើម្បីចូលទៅកាន់ភូមិ ក្នុងតំបន់មួយចំនួននៃឧទ្យាននោះឡើយ ។ ក្រុមហ៊ុន បានលើកឡើងអំពីបញ្ហាគ្រោះថ្នាក់ចរាចរ និងការព្រួយបារម្ភអំពីសុវត្ថិភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនថា ជាមូលហេតុនៃការរិតបន្តឹងបែបនេះ ប៉ុន្តែបន្ទាប់ពីមានការចុះផ្សាយអវិជ្ជមានពីករណីនេះ តាមប្រព័ន្ធព័ត៌មាន ក្នុងដើមឆ្នាំ ២០១២ មក ការរិតបន្តឹងនេះ ត្រូវបានគេរាយការណ៍ថាបានធូរស្រាលឡើងវិញ។

## VI. ការធ្វើបាតុកម្ម និង ភាពមិនចុះសម្រុងគ្នា

សហគមន៍ដែលរងផលប៉ះពាល់ជាច្រើន បានធ្វើបាតុកម្មចាប់តាំងពីឆ្នាំ ២០១០ មក ដើម្បីបង្ហាញពីការជំទាស់នឹងការផ្លាស់ប្ដូរទៅរស់នៅឯកន្លែងតាំងទីលំនៅថ្មី។ ក្នុងខែឧសភា ឆ្នាំ២០១០ មានប្រជាពលរដ្ឋប្រមាណជា ២០០ គ្រួសារ បានធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ដើម្បីដាក់ពាក្យបណ្ដឹង និងអំពាវនាវសុំឲ្យលោកនាយករដ្ឋមន្ត្រី ជួយធ្វើអន្តរាគមន៍លើបញ្ហាទំនាស់ដីធ្លីនេះ និង ជួយរកដំណោះស្រាយចំពោះបញ្ហាកញ្ចប់សំណងដែលផ្ដល់ឲ្យមិនសមរម្យ។ ការធ្វើបាតុកម្មតវ៉ា នាពេលចុងក្រោយបំផុតនេះ គឺនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ ដោយគ្រួសារដែលបានប្ដូរទីតាំងទៅរស់នៅកន្លែងតាំងទីលំនៅថ្មី ដោយបានបិទផ្លូវជាតិលេខ ៤៨ អស់រយៈពេល ៨ ម៉ោង ដែលគ្រួសារទាំងនោះ អំពាវនាវដល់អាជ្ញាធរ និងក្រុមហ៊ុន រក្សាការសន្យាផ្ដល់ដីកសិកម្ម ២ ហិកតា ដល់គ្រួសារដែលបានយល់ព្រមផ្លាស់ប្ដូរទៅរស់នៅកន្លែងតាំងទីលំនៅថ្មីនោះ។

មកដល់ខែកុម្ភៈ ឆ្នាំ២០១២ មានប្រជាពលរដ្ឋចំនួនជាង ១០០ គ្រួសារ បានបន្តជំទាស់នឹងការផ្លាស់ប្ដូរលំនៅដ្ឋានទៅកន្លែងតាំងទីលំនៅថ្មី និងការផ្ដល់សំណង ហើយពួកគេបន្តរស់នៅក្នុងភូមិរបស់ខ្លួន នៅក្នុងឃុំកោះស្ដេច រួមមាន (ភូមិពាមកាយ និងព្រែកស្មាច់) ឃុំភ្នីមាស មាន (ភូមិតានី គៀនក្រឡាញ់ និងភូមិភ្នីមាស) នៅឃុំថ្មស មាន (ភូមិ ចម្លងគោ) និងឃុំព្រែកខ្សាច់ មាន (ភូមិសម្រោងកែវ និង ភូមិយាយសែន)។

អ្នកភូមិដែលបន្តជំទាស់នឹងការផ្លាស់ប្ដូរទៅរស់នៅកន្លែងតាំងទីលំនៅថ្មី បានបន្តការខំប្រឹងប្រែងរបស់ខ្លួនដោយក្ដីសង្ឃឹមថា រដ្ឋាភិបាល នឹងមិនផ្លាស់ប្ដូរទីតាំងពួកគាត់ឡើយ ប៉ុន្តែការខំប្រឹងប្រែងរបស់ពួកគាត់ មិនទាន់បានលទ្ធផល

ជាផ្លែផ្កានៅឡើយទេ និងបានទទួលរងការរារាំងជាប្រចាំផងដែរ។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ដោយមានកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលប្រចាំនៅទីក្រុងភ្នំពេញ សហគមន៍មួយចំនួន បានធ្វើសន្និសីទសារព័ត៌មាន ដើម្បីឲ្យបញ្ហាទុក្ខព្រួយ និងការឈឺចាប់របស់ពួកគាត់បានដឹងលឺសុះសាយច្រើនឡើង។ ក្នុងខែមិនា ឆ្នាំ២០១២ សមាជិកសហគមន៍មួយចំនួន បានធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមក្នុងកិច្ចប្រជុំវេទិកាពលរដ្ឋអាស៊ាន និង ដើម្បីដាក់ពាក្យបណ្តឹងនៅស្ថានទូតសាធារណៈរដ្ឋប្រជាមានិតចិន ហើយពួកគាត់ត្រូវបានគេឃុំខ្លួនអស់មួយរយៈ នៅស្នងការនគរបាលរាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ ២០១២ និងក្រោយមក ពួកគាត់ត្រូវបានអមដំណើរបញ្ជូនត្រឡប់ទៅភូមិវិញ។

ជាមួយនឹងបទបញ្ជាថ្មីស្តីពីដីសម្បទានដីសេដ្ឋកិច្ច ដែលបានចេញនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ក្រុមគ្រួសារមួយចំនួនបានគិតថា អ្នកដែលមិនព្រមទទួលយកការផ្លាស់ប្តូរទៅរស់នៅកន្លែងតាំងទីលំនៅថ្មី នឹងមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិ ដែលជាចំណែកមួយនៃការអនុវត្ត "គោលនយោបាយរូបមន្តស្បែកខ្លា" (សូមមើលផ្នែក III (ជ))។ ទោះជាយ៉ាងណាក៏ដោយ មានសេចក្តីរាយការណ៍ថា ក្រុមយុវជនដែលចុះទៅតំបន់នោះ បានទទួលបទបញ្ជាមិនឲ្យវាស់វែងផ្ទៃដីអ្នកភូមិ ដែលបានកំណត់ផ្តល់ឲ្យក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប ឡើយ។

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋជាង ១០០ គ្រួសារ ជាមួយក្រុមហ៊ុន យូនៀន ដេវីលប្បមេន គ្រុប នៅតែមិនទាន់បានដោះស្រាយនៅឡើយ ខណៈដែលក្រុមហ៊ុន នៅតែបន្តការសាងសង់តាមផែនការគ្រោងទុក។

# ឧបសម្ព័ន្ធ IV

## ក្រុមហ៊ុន ជីង ហ្សុងរី ខេមបូឌា ខូអិលលធីឌី (Jing Zhong Ri Cambodia Company, Ltd) សម្បទានដីសេដ្ឋកិច្ចនៅលើដីជនជាតិដើមភាគតិចទំពួន ក្នុងស្រុកលំផាត់ ខេត្តរតនៈគិរី

## I. ជនជាតិដើមភាគតិចទំពួន

សហគមន៍ជនជាតិដើមភាគតិចទំពួន ក្នុងឃុំសេដា (ជាង៥០០ គ្រួសារ រស់នៅក្នុងភូមិសមុទ្រលើ ភូមិសមុទ្រក្រោម ភូមិថ្មី និងភូមិតាតួត) ក្នុងស្រុកលំផាត់ ខេត្តរតនៈគិរី បានរងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ឲ្យក្រុមហ៊ុន ជីង ហ្សុងរី ខេមបូឌា ខូអិលធីឌី និងក្រុមហ៊ុនផ្សេងទៀត។ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃលំផាត់[២៩៨] សមាជិកសហគមន៍នៅក្នុងភូមិទាំងនេះ ពឹងផ្អែកលើការធ្វើស្រែចំការ យកជ័រឈើ និង អនុផលព្រៃឈើ ព្រមទាំងការចិញ្ចឹមគោក្របី សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ជាផ្នែកមួយនៃវប្បធម៌ និងប្រពៃណីរបស់ពួកគាត់ ពួកគាត់ធ្វើកសិកម្មពនេចរ និងថែរក្សាដីព្រៃអារក្ស និងដីព្រៃកប់ខ្មោច។

ដូចគ្នានឹងជនជាតិដើមភាគតិចដទៃៗទៀតដែរនៅកម្ពុជា ដើម្បីការពារដីសហគមន៍របស់ខ្លួន សហគមន៍ជនជាតិដើមភាគតិចទំពួន កំពុងតែដំណើរការដាក់ពាក្យសុំចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ដោយមានការជួយឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល (សូមមើលផ្នែក III (ច))។ បន្ទាប់ពីការធ្វើស្វ័យអត្តសញ្ញាណកម្មរួចមក សហគមន៍ជនជាតិដើមភាគតិចទំពួន នៅភូមិសមុទ្រលើ ភូមិសមុទ្រក្រោម ភូមិថ្មី និងភូមិតាតួត ត្រូវបានក្រសួងអភិវឌ្ឍន៍ជនបទទទួលស្គាល់ពួកគាត់ថាជា ជនជាតិដើមភាគតិចទំពួន ក្នុងខែឧសភា ឆ្នាំ២០១០។ នៅអំឡុងពេលសរសេររបាយ-ការណ៍នេះ ក្រសួងមហាផ្ទៃ បានទទួលពាក្យសុំរបស់ពួកគាត់ និងបានទទួលស្គាល់សហគមន៍ពួកគាត់ ជានីតិបុគ្គលដែលអាចអនុញ្ញាតិឲ្យពួកគាត់អាចបន្តដំណើរការជាមួយនឹងជំហាននានាដែលចាំបាច់ ដើម្បីបង្កើតបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ និងការវាស់វែងព្រំប្រទល់ដីរបស់ពួកគាត់។ ដំណើរការទាំងនេះ មានសារៈសំខាន់ណាស់ ព្រោះវានឹងផ្តល់ឲ្យមាននូវការទទួលស្គាល់ជាផ្លូវការចំពោះប្រពៃណី វប្បធម៌ និងការប្រតិបត្តិខាងជំនឿរបស់ជនជាតិដើមភាគតិចទំពួន ក៏ដូចជាសិទ្ធិលើការអភិវឌ្ឍន៍ដីរបស់ពួកគាត់។

## II. សម្បទានដីសេដ្ឋកិច្ចផ្តល់នៅក្នុងដែនជម្រកសត្វព្រៃលំផាត់

ដែនជម្រកសត្វព្រៃលំផាត់ ត្រូវបានបង្កើតឡើង និងកំណត់ជាដែនជម្រកសត្វព្រៃ ដោយព្រះរាជក្រឹត្យ[២៩៩]។ ដែនជម្រកសត្វព្រៃនេះ លាតសន្ធឹងលើផ្ទៃដី ២៥០.០០០ ហិកតា ស្ថិតនៅក្នុងខេត្តរតនៈគិរី និងមណ្ឌលគិរី។ ក្នុងរយៈពេលចាប់ពីខែមីនា ឆ្នាំ២០១១ ដល់ ខែមិថុនា ឆ្នាំ២០១២ រដ្ឋាភិបាល បានចុះហត្ថលេខាលើអនុក្រឹត្យយ៉ាងតិចចំនួន ៦ កំណត់តំបន់គ្រប់គ្រងមួយចំនួននៅលើផ្ទៃដីដែនជម្រកសត្វព្រៃលំផាត់នេះ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដើម្បី

[២៩៨] ដែនជម្រកសត្វព្រៃលំផាត់ ត្រូវបានទទួលស្គាល់ថាជា តំបន់ការពារធម្មជាតិមួយក្នុងចំណោមតំបន់ការពារឯទៀតៗ ដែលត្រូវបានទទួលស្គាល់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ។ តំបន់ការពារនេះ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

[២៩៩] ព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ បានចែងថា ដែនជម្រកសត្វព្រៃ គឺជាដែនធម្មជាតិដែលធានានូវលក្ខខណ្ឌធម្មជាតិចាំបាច់ ក្នុងការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិសំខាន់ៗ ធ្វើឲ្យមានស្ថិរភាពដល់ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។ ច្បាប់ស្តីពីតំបន់ការពារទេសភាព ឆ្នាំ២០០៨ បានឲ្យនិយមន័យ ដែនជម្រកសត្វព្រៃ ថាជា “តំបន់ក្នុងដែនដី និង/ឬដែនទឹក ដែលតម្រូវឲ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្ម សម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឲ្យមានការថែទាំទីជម្រក និង/ឬ ដើម្បីបំពេញលក្ខខ័ណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ ឬ រុក្ខជាតិ។

អាចផ្តល់ដីនោះឲ្យដល់ក្រុមហ៊ុនឯកជន សម្រាប់អភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម។ ក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ រួមមាន៖ ១- ដូនពេញ អាហ្គ្រីកូ (Daun Penh Agrico Co.,Ltd) (៨.៨២៥ ហិកតា), ២- ម្កុដ ពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម (Mkod Pich Development Agro-Industry) (១.៩៥០ហិកតា), ៣- ហ៊ង អាញ លំផាត់ ខូអិលធីឌី (Hoang Anh Lumphat Co., Ltd) (៩.១៧៣ ហិកតា), ៤- ហ៊ង អាញ អណ្តូងមាស ខូអិលធីឌី (Hoang Ang Andong Meas Co., Ltd) (៩.៤៧០ ហិកតា), ៥- រ័ត្ន សុខុន អ៊ិនខមភើរេសិន* (Roath Sokhon Incorporation) (៩.០០០ ហិកតា), និង ៦- ក្រុមហ៊ុន ជីង ហ្ស៊ុងរី ខេមបូឌា ខូអិលធីឌី (Jing Zhong Ri Cambodia Company, Ltd) (៩.២២៤ ហិកតា)។ ក្រោយពីបានចេញអនុក្រឹត្យទាំងនេះមក រដ្ឋាភិបាល បានចេញអនុក្រឹត្យបន្ថែមទៀត ដើម្បីធ្វើអនុបយោគផ្ទៃដីដែលបានកំណត់ថាជា "តំបន់ប្រើប្រាស់ដោយចីរភាព" ទៅជាដីឯកជនរបស់រដ្ឋ ។ ការផ្តល់សម្បទានដីទាំងនេះ នាំឲ្យមានការលើកឡើងអំពីបញ្ហានៃការអនុវត្តតាមក្របខ័ណ្ឌច្បាប់ សម្រាប់ការការពារ និងអភិរក្សតំបន់ការពារធម្មជាតិ (សូមមើលការវិភាគក្នុងផ្នែក V (គ) និង VI) ។

ក្រុមហ៊ុន ជីង ហ្ស៊ុងរី ខេមបូឌា ខូអិលធីឌី បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី នៅក្នុងខែឧសភា ឆ្នាំ ២០១១ អនុញ្ញាតិឲ្យធ្វើការវិនិយោគ និងអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម និងកៅស៊ូ នៅក្នុងតំបន់ដែនជម្រកសត្វព្រៃនេះ សម្រាប់រយៈពេល ៧០ ឆ្នាំ[៣០០]។ ការអនុញ្ញាតិនេះ តម្រូវឲ្យមានការរៀបចំប្លង់មេ ក្រោមការសហការ ជ្រោមជ្រែងពីក្រសួងបរិស្ថាន និងចែងថា ត្រូវគិតគូរប្រុងប្រយ័ត្ន ដោយត្រូវចៀសវាងមិនឲ្យប៉ះពាល់ដល់ដីលំនៅដ្ឋាន និងដីស្រែចំការស្របច្បាប់ ផ្ទៃដីព្រៃឈើ និងផ្លូវទឹកផងដែរ។ ក្នុងរយៈពេលតែ ១៨ ថ្ងៃ ប៉ុណ្ណោះ បន្ទាប់ពីលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវបានចុះហត្ថលេខា រដ្ឋាភិបាល បានចេញអនុក្រឹត្យកំណត់ដីតំបន់នោះទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដើម្បីផ្តល់ឲ្យក្រុមហ៊ុន ជីង ហ្ស៊ុងរី ខេមបូឌា ខូអិលធីឌី[៣០១]។ រយៈពេល ៧ សប្តាហ៍ ក្រោយពីការចេញអនុក្រឹត្យនេះ រដ្ឋាភិបាល បានចេញអនុក្រឹត្យមួយផ្សេងទៀត ដើម្បីធ្វើអនុបយោគផ្ទៃដីដែលកំណត់ថាជាតំបន់ប្រើប្រាស់ដោយចីរភាព ទៅជាដីឯកជនរបស់រដ្ឋ សម្រាប់ឲ្យក្រុមហ៊ុន ជីង ហ្ស៊ុងរី ខេមបូឌា ខូអិលធីឌី ធ្វើការអភិវឌ្ឍ[៣០២]។

នៅអំឡុងពេលធ្វើទស្សនៈកិច្ចរបស់ខ្ញុំនៅក្នុងខេត្តរតនៈគិរី អាជ្ញាធរខេត្ត បានប្រាប់ខ្ញុំថា ការវាយតម្លៃផលប៉ះពាល់ ត្រូវបានគេធ្វើរួចហើយ មុននឹងក្រុមហ៊ុន ជីង ហ្ស៊ុងរី ចាប់ផ្តើមសកម្មភាពរបស់ខ្លួន ប៉ុន្តែវាមិនត្រូវបានចែកផ្សាយជាសាធារណៈទេ។ ការពិគ្រោះយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានរាយការណ៍ថា មានលក្ខណៈខ្វះខាត ឬ មិនបានទូលំទូលាយ (ដែលផ្ទុយទៅនឹងក្របខ័ណ្ឌច្បាប់តម្រូវ សូមមើលផ្នែក VI (ឃ))។ មានសេចក្តីរាយការណ៍ថា ជនជាតិទំពួនមួយចំនួន បានដឹងអំពីការផ្តល់សម្បទានដីនេះ តែនៅពេលដែល ក្រុមហ៊ុន ជីង ហ្ស៊ុងរី បានចុះមកដល់មូលដ្ឋានរបស់ពួកគាត់ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ប៉ុណ្ណោះ ជាមួយនឹងផែនការចាប់ផ្តើមអភិវឌ្ឍចំការកៅស៊ូ នៅលើដីដែលពួកគាត់កំពុងរស់នៅ និងធ្វើកសិកម្មជាប្រពៃណី (ដីស្រែចំការ និងដីព្រៃអារក្ស)។ ការផ្តល់សម្បទានដីនេះ

---

[៣០០] លិខិត ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជូន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ លិខិតនេះ ដោយយោងលិខិតចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងបរិស្ថាន និងយោងចំណាររបស់នាយករដ្ឋមន្ត្រី ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ២០១១ បានសរសេរថា រដ្ឋាភិបាលបានយល់ព្រមតាមសំណើរបស់ក្រសួងបរិស្ថាន ដោយអនុញ្ញាតឲ្យក្រុមហ៊ុន ជីង ហ្ស៊ុងរី ខូអិល ធីឌី ធ្វើការវិនិយោគអភិវឌ្ឍន៍របស់ខ្លួន។

[៣០១] អនុក្រឹត្យ លេខ ៩៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ (ចំណុច១) កំណត់តំបន់គ្រប់គ្រង ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងតំបន់ការពារដែនជម្រកសត្វព្រៃលំផាត់ សម្រាប់ផ្តល់ជូនក្រុមហ៊ុន ជីង ហ្ស៊ុងរី ខេមបូឌា ខូអិលធីឌី។

[៣០២] អនុក្រឹត្យ លេខ ១៦២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ដោយយោងអនុក្រឹត្យ លេខ ៩៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ដើម្បីធ្វើអនុបយោគផ្ទៃដី ដែលកំណត់ថាជាតំបន់ប្រើប្រាស់ដោយចីរភាព ទៅជាដីឯកជនរបស់រដ្ឋ។

ដល់ក្រុមហ៊ុន ជីង ហ្សុងរី វាហាក់ដូចជាមានដំណើរផ្ទុយគ្នាទាំងស្រុងទៅនឹងសិទ្ធិសម្រាប់ជនជាតិដើមភាគតិច ដែលមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ និងធ្វើឲ្យចុះខ្សោយដល់ដំណើរការកំណត់ក្នុងអនុក្រឹត្យ ឆ្នាំ២០០៩ ស្តីពីការចុះបញ្ជីដីជនជាតិភាគតិច (សូមមើលផ្នែក VI (ង) និង VII (ឆ) និង (ជ))។ កិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំ ក្នុងការទំនាក់ទំនងជាមួយក្រុមហ៊ុន គឺមិនបានសម្រេចឡើយ។

## III. ការធ្វើសកម្មភាពរបស់សហគមន៍ជនជាតិដើមភាគតិចទំពួន

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតិពីក្រសួងបរិស្ថានទាក់ទងនឹងសម្បទានដីនេះ ក្រុមហ៊ុន ជីង ហ្សុងរី បានដាក់លិខិតមួយជូនអភិបាលនៃគណៈអភិបាលខេត្ត នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១១ ដើម្បីសុំការអនុញ្ញាតិចាប់ផ្តើមអនុវត្តគម្រោងរបស់ខ្លួន ដោយធ្វើការអភិវឌ្ឍដីសម្បទាន និងការប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ផងដែរ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១១ ប្រធានមន្ទីរបរិស្ថានខេត្ត នៅក្នុងលិខិតមួយបានសរសេរថា ក្រុមហ៊ុន អាចដាក់គ្រឿងចក្រប្រើប្រាស់បាន ប៉ុន្តែដើម្បីបញ្ចៀសការប៉ះពាល់ជាយថាហេតុលើដីសហគមន៍ជនជាតិដើមភាគតិចទំពួន មិនគួរធ្វើការឈូសឆាយនៅតាមព្រំប្រទល់ដីសម្បទាន លុះត្រាតែព្រំប្រទល់ដីសម្បទាន បានវាស់វែង និងកំណត់ព្រំរួចរាល់ជាមុនសិន។ ទោះជាយ៉ាងណាក៏ដោយ ក៏សកម្មភាពការងាររបស់ក្រុមហ៊ុន បានចាប់ផ្តើម ដោយបណ្តាលឲ្យមានភាពតានតឹងរវាងសហគមន៍ដែលរងផលប៉ះពាល់មួយចំនួន ជាមួយនិងអាជ្ញាធរមូលដ្ឋាន និងតំណាងក្រុមហ៊ុន។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១១ សហគមន៍ជនជាតិដើមភាគតិចទំពួនមួយក្រុម បានទៅកាន់ការដ្ឋានក្រុមហ៊ុន ជីង ហ្សុងរី ដើម្បីប៉ុនប៉ងបញ្ឈប់ក្រុមហ៊ុនពីការឈូសឆាយដីព្រៃ និងការជីកប្រឡាយធ្វើព្រំប្រទល់ដីសម្បទាន ។ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ អ្នកភូមិ បានព្យាយាមបញ្ឈប់ក្រុមហ៊ុនពីការឈូសឆាយដី ព្រៃអារក្សរបស់ពួកគាត់ (ដែលគេដឹងថា នៅក្នុងពេលនោះ ក្រុមហ៊ុនបានឈូសឆាយអស់ចំនួន ២ ហិកតាទៅហើយ) ហើយក្រុមអ្នកភូមិប្រហែលជាជាង ១០០ នាក់ ដែលតវ៉ានេះ ត្រូវបានរាំងដោយសន្តិសុខរបស់ក្រុមហ៊ុន (ដោយមានការបាញ់ពីសន្តិសុខក្រុមហ៊ុនមួយគ្រាប់ផងដែរ)។ សមាជិកសហគមន៍ មានការខឹងសម្បាយ៉ាងខ្លាំង ហើយក៏បានវាយប្រហារលើត្រាក់ទ័ររបស់ក្រុមហ៊ុន និងបានចាប់បុគ្គលិកក្រុមហ៊ុនចំនួន ៤ នាក់ យកមកឃុំទុកនៅសាលាឃុំ ។ មានសេចក្តីរាយការណ៍ថា ទាល់តែដល់ពេលនោះ ទើបអភិបាលខេត្ត និងអាជ្ញាធរពាក់ព័ន្ធនានា ចុះមកជួបសហគមន៍ដែលរងផលប៉ះពាល់នៅសាលាឃុំ ដើម្បីធ្វើការចរចាសុំឲ្យដោះលែងបុគ្គលិកក្រុមហ៊ុនដែលបានចាប់ខ្លួននោះ និងសន្យាថា រកដំណោះស្រាយជូនសហគមន៍។ បន្ទាប់ពីឧប្បត្តិហេតុនេះមក និងជាការឆ្លើយតបទៅនឹងសកម្មភាពដ៏ខ្លាំងក្លានេះរបស់សហគមន៍ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះ មន្ត្រីអាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ជាច្រើននាក់ ត្រូវបានកោះហៅទៅសាកសួរ ដើម្បីរកអ្នកទទួលខុសត្រូវចំពោះបាតុកម្មនោះ។

ជាបន្តបន្ទាប់មកទៀត សមាជិកសហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានគេប្រាប់ថា ក្រុមហ៊ុន ជីង ហ្សុងរី និងក្រុមហ៊ុនផ្សេងទៀត ដែលប្រតិបត្តិការការងារលើដីសម្បទាននៅក្នុងតំបន់នេះ នឹងមិនធ្វើឲ្យប៉ះពាល់ដល់ដីស្រែចំការរបស់សហគមន៍ឡើយ ដោយក្រុមហ៊ុនអភិវឌ្ឍដីនៅជុំវិញដីរបស់សហគមន៍ ជាការអនុវត្តតាម "គោលនយោបាយរូបមន្តស្បែកខ្លា"។ ចាប់តាំងពីឧប្បត្តិហេតុក្នុងខែកុម្ភៈ ឆ្នាំ២០១២ មក និងមកត្រឹមពេលសរសេររបាយការណ៍នេះ ក្រុមហ៊ុនបានផ្អាកសកម្មភាពរបស់ខ្លួន។ ខ្ញុំត្រូវបានប្រាប់ឲ្យដឹងថា តំណាងក្រុមហ៊ុន បានប្រាប់អ្នកភូមិថា ក្រុមហ៊ុននឹងចាប់ដំណើរការសកម្មភាពរបស់ខ្លួនឡើងវិញ បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់នៅខែមិថុនា ឆ្នាំ២០១២ រួច។ ថ្វីបើមានការផ្អាកសកម្មភាពរបស់ក្រុមហ៊ុនក៏ដោយ ក៏ជនជាតិដើមភាគតិចទំពួន មិនត្រូវបានអាជ្ញាធរចេញនូវវិធានការការពារជាបណ្តោះអាសន្នជូនដល់ពួកគាត់ឡើយ ហើយដែលខណៈពេលនោះដែរ ពួកគាត់កំពុងតែដំណើរការដាក់ពាក្យសុំប័ណ្ណ

កាន់កាប់ដីសម្បូហភាព (សូមមើល ផ្នែក VI (ង)) ហើយគេមិនបានដឹងប្រាកដទេថា តើនៅពេលណាក្រុមហ៊ុន នឹងដំណើរការការអភិវឌ្ឍឡើងវិញនោះឡើយ។

## ឧបសម្ព័ន្ធ V ផែនទីនៃដីសម្បទានដែលមានទីតាំងជាប់ៗគ្នា ឬ ក្បែរៗគ្នា

**ដីសម្បទានដែលមានទីតាំងជាប់ៗគ្នា ឬ ក្បែរៗគ្នា សម្រាប់ដំណាំកៅស៊ូ ដែលបានផ្តល់ឲ្យក្រុមហ៊ុនសម្ព័ន្ធភាពចំនួន ៤ នៅខេត្តមណ្ឌលគីរី**



ដីសម្បទានដែលមានទីតាំងជាប់ៗគ្នា ឬ ក្បែរៗគ្នា សម្រាប់ដំណាំអំពៅ ដែលបានផ្តល់ឲ្យក្រុមហ៊ុនសម្ព័ន្ធភាពចំនួន ៣ នៅខេត្តឧត្តរមានជ័យ



ដីសម្បទានដែលមានទីតាំងជាប់ៗគ្នា ឬ ក្បែរៗគ្នា សម្រាប់ដំណាំអាកាស្យា និង ដំណាំអំពៅ ដែលបានផ្តល់ឲ្យក្រុមហ៊ុន សម្ព័ន្ធភាពចំនួន ៥ នៅខេត្តព្រះវិហារ



# ដីសម្បទានដែលមានទីតាំងជាប់ៗគ្នា ឬ ក្បែរៗគ្នា សម្រាប់ដំណាំអំពៅ ដែលបានផ្តល់ឲ្យក្រុមហ៊ុន សម្ព័ន្ធភាពចំនួន ២ នៅខេត្តកំពង់ស្ពឺ

